# សុជីវធម៌
# ប្រចាំសង្គមគ្រួសារ



# សុជីវធម៌
# ប្រចាំសង្គមគ្រួសារ

និពន្ធទី ៣៤

ដោយ

**សុខ-ស៊ីវ**

បោះពុម្ពលើកទី២

ព.ស. ២០៥៨ គ.ស. ១៩៦៥

រក្សាសិទ្ធិ

KHEMARARATANARAM KHEMARARATANARAM
វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស សាធី**

# អារម្ភបទ

សៀវភៅ "សុជីវធម៌ប្រចាំគ្រួសារ" នេះកើតឡើង ដោយខ្ញុំបានជួបប្រទះ នូវការរស់នៅមិនសមរម្យរបស់មនុស្សខ្លះ ដែលគ្មានរបៀបបែបបទ, គ្មានការគួរសម, ច្រលើសបើស, ជួជាតិ, . ឆ្មើងកន្ទ្រើង, . ឈ្លើយ, . ឥតសណ្តាប់ធ្នាប់.។

ក្នុងពេលដែលខ្ញុំបានជួបប្រទះជីវិតមនុស្សរបៀបនេះ តែងនឹកថាមិនមែនគ្នាចង់ធ្វើដូច្នោះទេ ប្រហែលជាមិនបានស្គាល់សុជីវធម៌ ទើបចេះតែបណ្តោយឱ្យជីវិតប្រព្រឹត្តទៅរម៉ាំងរម៉ោក ខ្ជោកខ្ជាកដូច្នេះ, គួរសរសេរជាសៀវភៅមួយអំពីសុជីវធម៌តាមសមត្ថភាពរបស់ខ្លួន បោះពុម្ពផ្សាយជាប្រយោជន៍ទូទៅ ។

សរសេរហើយជូនលោក ជីង - ប៉ោ ឱ្យបោះពុម្ពផ្សាយតាមសេចក្តីត្រូវការ ។

ទីបំផុតសូមគោរពចំពោះវិញ្ញាណក្ខន្ធអតីតអ្នកសុជីវធម៌ នឹងអ្នកសុជីវធម៌បច្ចុប្បន្ន ដែលបានបង្ហាញដំណើរសមរម្យរបស់ខ្លួនទុកឱ្យយើងខ្ញុំធ្វើដំណើរតាមទៅរកសុភមង្គល គ្រប់ប្រការ ។

សុង ស៊ីវ

WAT KHEMARARATANARAM

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

# ភាសិត

សុជីវធម៌ជាពណ៌រស្មីមនុស្ស
ជនស្រីប្រុសដែលខ្ពស់ថ្លៃថ្នូរបាន
ដោយមានឫកល្អប្រចាំប្រាណ
ទើបថ្កើងថ្កានផើតទាន់សម័យ ។
សុជីវធម៌ជាជាតិឈាមជ័រខ្មែរ
ដែលពូកែរាក់ទាក់មិនផ្ទើងផ្ទៃ
ជាតិចំណានបេះស៊ីវិល័យ
តាំងពីសម័យអង្គរមក ។

**សុខ ស៊ីវ**

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

# លំនាំសុជីវធម៌

ពាក្យថា « សុជីវធម៌ » ជាភាសាសំស្ក្រឹត និងបាលីគឺ ចំណេះ, សណ្តាប់ធ្នាប់, ការដឹងប្រមាណ គួរសម, ច្បាប់ជីវិតល្អ ឬរបៀបរស់នៅសមរម្យ បានដល់លំនាំរស់នៅសមភាពជាមនុស្ស ដែលប្លែកពីការរស់នៅរបស់សត្វតិរច្ឆាន ។

អ្នកអក្សរសិល្ប៍បច្ចុប្បន្ន ប្រដូចពាក្យទៅនឹងពាក្យបារាំងថា *Savoir Vivre* ។

ពាក្យនេះ មានន័យជ្រៅទូលាយ ព្រោះជាពាក្យប្រមូលក្រសោបយកដំណើរជីវិតមនុស្សទាំងអស់ទៅហើយ, ករណីយកិច្ច វិវត្តនកិច្ចគ្រប់យ៉ាងក្នុងជីវិតមនុស្ស ស្ថិតក្នុងអាណាខេត្តរបស់ពាក្យនេះទាំងអស់ ។ ព្រោះជាពាក្យជាប់ទាក់ទងក្នុងចង្កោមជាមួយ វឌ្ឍនធម៌, អារ្យធម៌, សីលធម៌, វប្បធម៌, និងចរិយាធម៌ ដែលជាគ្រឿងអលង្ការរបស់សង្គមមនុស្ស ។

សង្គមមនុស្សដូចរុក្ខជាតិមួយដើម វឌ្ឍនធម៌, អារ្យធម៌, សីលធម៌, វប្បធម៌, និងចរិយាធម៌ ដូចឫសគល់មែកធាងស្លឹក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាលី**

និងជីជាតិ ។ ឯសុជីវធម៌ ដូចរាងរៅទ្រង់ទ្រាយសមរម្យរបស់រុក្ខជាតិ ។

ធម្មតារុក្ខជាតិ ដែលដុះនាដីមានជីជាតិល្អ តែងមានការលូតលាស់ល្អណាស់ ។ ប៉ុន្តែ ឫស គល់ មែក ធាង់រុក្ខជាតិនោះមានការលូតលាស់មិនស្របស្រួលស្មើគ្នាទេ គឺមានរុក្ខាវយវៈខ្លះវែង ខ្លះខ្លី ខ្លះពុកស្អុយ ខ្លះវៀច ខ្លះត្រង់ប្រវេងប្រវាងក្រង៉ិចក្រង៉ក់ ដែលចេះតែលូតលាស់ទៅតាមសន្ទុះរបស់វាដោយឡែកៗខ្លះតុល្យភាពនោះ ទស្សនិកជនគេថាឈើនេះលូតលាស់ល្អពេកប៉ុន្តែប្រវេងប្រវាងគ្មានរាងរៅសមរម្យសោះ គេមិនចង់ទៅជិតមិនចង់ទស្សនា ព្រោះនាំឱ្យរំខានដល់ភ្នែកគេ ។

ឯសង្គមមនុស្សខ្លះ ដែលសម្បូរទៅដោយវឌ្ឍនធម៌ជាដើមហើយបែរជាខ្វះសុជីវធម៌ ក៏ដូច្នោះដែរ ។

ឧទាហរណ៍: ដូចសង្គមមនុស្សខ្លះ ដែលល្បីថាមានវឌ្ឍនធម៌ចំរើនលូតលាស់ គឺចំរើនលូតលាស់ខាងវិជ្ជាវឌ្ឍនធម៌ចេះដឹងយ៉ាងសំបើម រហូតដល់ចេះធ្វើយានយន្តអវកាស និងចំរើនលូត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេ សាទី**

លាស់ដោយលិង្គវឌ្ឍនធម៌ ចេះតុបតែងភេទប្រុសស្រីឱ្យមានរាង ពេសមរម្យមិនទាស់ភ្នែក គឺចេះប្រើសំលៀកបំពាក់សមតាមវិធី បុណ្យទាននឹងកាលសម័យ ប៉ុន្តែខ្វះអាចារវឌ្ឍនធម៌ ដែលជាតួ សីលធម៌ គឺគ្មានគំនិតមារយាទល្អ ចូលចិត្តប្រព្រឹត្តបំពារបំពាន ផ្តេសផ្តាសជិះជាន់សិទ្ធិគេឯង មានការគួរសមរដិបរដុបមិនស្មើ គួរ សមតែមាត់និងកាយវិការ ឯចិត្តគំនិតដោកជាំក្រខ្វក់ដោយលទ្ធិ ចក្រពត្តិ, លទ្ធិអាណានិគម និងលទ្ធិមូលធន ចេះតែចាក់ចុចអុជ អាល រកគួនបៀតបៀនរំខានដល់គេដល់អ្នកដទៃ ។

សង្គមមនុស្សណាមានលក្ខណៈដូច្នេះ, សង្គមមនុស្សនោះ ឈ្មោះថាគ្មានសុជីវធម៌ទេ ចាត់ទុកជាសង្គមមនុស្សថោកទាបទៅ វិញ ។

ម៉្យាងទៀតសង្គមមនុស្សខ្លះមានសុជីវធម៌ដែរ ប៉ុន្តែសុជីវ ធម៌របស់គេនោះ គ្មានគុណភាពវិសេសវិសាលទេ ព្រោះសង្គម មនុស្សនោះគ្មានការអប់រំអំពីលទ្ធិសាសនាវិសេសឆើតឆាយ គឺ គ្រាន់តែនាំគ្នាប្រឌិតតែងបង្កើតឡើង តាមគំនិតមនុស្សសាមញ្ញ

ប៉ុណ្ណោះ ។

បើសង្គមមនុស្សណា បានទទួលការអប់រំជិតដល់អំពីលទ្ធិសាសនាវិសេសឆើតឆាយ, សុជីវធម៌របស់សង្គមមនុស្សនោះក៏មានគុណភាពវិសេសឆើតឆាយដែរ ។

ដូច្នេះការដែលកំណត់ព្រំដែន លក្ខណៈគុណភាពនៃសុជីវធម៌ថា មានប៉ុណ្ណេះប៉ុណ្ណោះ ត្រឹមនេះត្រឹមនោះតាមគំរូសុជីវធម៌ជាតិសាសន៍នានានោះមិនគួរទេ ។

ការកំណត់ព្រំដែនសុជីវធម៌របស់សង្គមមនុស្សខ្លះ ត្រឹមតែការចេះគួរសមនឹងអ្នកដទៃប៉ុណ្ណោះ មិនទាន់អស់ដើងសមនឹងពាក្យថា Savoir-Vivre " សុជីវធម៌ " នេះទេ ព្រោះនៅមានលាយឡំដោយទុជ្ជីវធម៌ (Sans-savoir-vivre) អាចយកការគួរសមទៅបោកប្រាស ទៅធ្វើជានុយ ដើម្បីទាក់ទាញអ្នកដទៃឱ្យចូលក្នុងឧបាយកលក្នុងនឹម អាណានិគមនិយម, ចក្រពត្តិនិយម និងមូលធននិយមរបស់ខ្លួនបាន ។

បើការគួរសមរដិបរដុប សារ៉ាំ គ្មានទ្រឹស្តីប្រាកដ ប្រើក្នុងផ្លូវ

អាក្រក់ផងល្អផងដូច្នោះឱ្យឈ្មោះថា Savoir – Vivre " សុជីវធម៌ " មិនទាន់បានពេញលក្ខណៈទេ ។

ជាតិសាសន៍ខ្មែរយើង ជាជាតិពុទ្ធសាសនិក មានការអប់រំជិតដល់អំពីលទ្ធិព្រះពុទ្ធសាសនា ជាសាសនាសន្តិភាពដែលមានទ្រឹស្តីវិសេសវិសាលឆើតឆាយប្រកបដោយគតិបណ្ឌិតឥតខ្ចោះ ជាងសាសនាទាំងអស់ ក្នុងជុំពិភពដ៏ធំធេងនេះ ។

ដូច្នេះសុជីវធម៌ខ្មែរយើង មានទ្រឹស្តីវិសេសបន្ថែមលើការគួរសមទៀត ដើម្បីរក្សាការគួរសមនោះ ឱ្យស្ថិតនៅក្នុងផ្លូវល្អតែម្យ៉ាង គឺជាសុជីវធម៌ថ្នាក់ខ្ពស់បំផុត ដែលប្រកបដោយគុណសម្បត្តិច្រើនផ្នែក មានផ្នែកសុភាវធម៌, វឌ្ឍនធម៌, អារ្យធម៌, សីលធម៌, ចរិយាធម៌, មនុស្សធម៌, សង្គហធម៌, សប្បុរិសធម៌, អបចាយនធម៌, និងសេវនធម៌ជាដើម ។

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **ស៊ សាទី**

# អ្វីជាសុជីវធម៌

អង្គខ្លះនៃវឌ្ឍនធម៌ នឹងអារ្យធម៌ មានអាចារវឌ្ឍនធម៌ ការចំរើនដោយមារយាទល្អ នឹងអាចារារ្យធម៌ សណ្ដាប់ធ្នាប់ថ្លៃថ្នូរជាដើម នឹងជាភាគខ្លះនៃសីលធម៌ នឹងចរិយាធម៌ ឈ្មោះថាសុជីវធម៌ ប្រែថាច្បាប់ជីវិតល្អប្រពៃ ឬលំនាំរស់នៅសមរម្យ, មានទ្រឹស្ដីខ្ពស់ជាង សុជីវធម៌ គឺភាពសមរម្យ ដែលអ្នកស្រុកធ្លាប់ហៅថាសុភាពរាបសា ។

រួមឱ្យខ្លីគឺ ការគោរពប្រតិបត្តិតាមបទបញ្ញត្តិ នឹងទម្លាប់ទំនៀម ឬត្រណមទាំងឡាយ ដែលប្រកបដោយគតិបណ្ឌិត ឈ្មោះថាសុជីវធម៌ ។

សុជីវធម៌ខ្មែរយើង មានគុណភាពខ្ពស់ស្មើនឹងពាក្យថាសប្បុរិសធម៌ ដែលមានក្នុងទ្រឹស្ដីពុទ្ធសាសនា គឺធម៌សប្បុរសសំរាប់អប់រំមនុស្សឱ្យមានសណ្ដាប់ធ្នាប់ល្អស្អូតបូត, សមរម្យខ្ពង់ខ្ពស់, ថ្លៃថ្នូរពិតប្រាកដ ។ អ្នកមានសប្បុរិសធម៌ហៅថាជនសប្បុរស, - ជនមានសុជីវធម៌ ឬថាសុជីវធម្មិក ។

ពាក្យថាសប្បុរសនេះ ជាភាសាបាលីមានក្នុងទ្រឹស្ដីពុទ្ធ-

សាសនាពិតមែន ប៉ុន្តែជាគ្រាមភាសារបស់ខ្មែរយើងទៅហើយ នរណាក៏ចេះនិយាយដែរថា " មនុស្សសប្បុរស, ជនសប្បុរស, បុគ្គលសប្បុរស, សំដីសប្បុរស, ចិត្តសប្បុរស, ឬថាអ្នកនេះមានធម៌សប្បុរស " ដូច្នេះជាដើម ។

ការដែលខ្ញុំប្រៀបផ្ទឹម សុជីវធម៌ និងសប្បុរិសធម៌ដូច្នេះគង់មានមិត្តអ្នកអានខ្លះរិះគន់ថា មិនដឹងជាស្អីទេ! អ្វីក៏ធម៌ ៗ យកតែធម៌មកនិយាយផ្តេសផ្តាស ជាតិសាសន៍គេមិនដែលឃើញយកធម៌មកនិយាយដូចឯង ។

បើមានការរិះគន់ដូច្នេះមែន ពិតជាកើតមកពីការយល់ថា "ធម៌ព្រះពុទ្ធ, ព្រះសង្ឃនឹងវត្តអារាម ជាវត្ថុវិសេសដាច់ដោយឡែកពីមនុស្សលោក គឺធម៌សំរាប់តែសូត្រកំដរខ្មោច, - សូត្របង្សុកូល, - សូត្រកាត់គ្រោះលើករាសី; វត្តអារាមដូចខ្ទមអ្នកតា, ព្រះសង្ឃជាអ្នកតា សំរាប់តែពេលមនុស្សលោកមានអាសន្នគេទៅបន់ស្រន់ ឬក៏ទុកវត្ថុវិសេសទាំងនេះដូចទឹកត្រី ទឹកស៊ីអ៊ីវសំរាប់ពេលសាប ទើបគេត្រូវការជ្រលក់ឱ្យប្រៃ ។

ឯការពិតនោះមិនដូច្នោះទេ ព្រះធម៌នឹងមនុស្សលោកមាន សម្ពន្ធភាពជាប់ទាក់ទងគ្នា ជាចាំបាច់វែកញែកដកឱ្យឃ្លាតចេញពីគ្នាមិនបាន ។ សូម្បីជាតិសាសន៍ដែលមិនធ្លាប់ស្គាល់ព្រះធម៌សោះ ក៏ប្រព្រឹត្តកាន់តាមព្រះធម៌ដែរ ប៉ុន្តែមិនស្គាល់ថាជាធម៌ ស្គាល់ត្រឹមតែអ្នកប្រៀនប្រដៅផ្ទាល់ ថាជាច្បាប់ជាលទ្ធិរបស់អ្នកនោះទៅវិញ ។ ដូចជាស្គាល់ថា " លទ្ធិឡេនីន, - ស្តាលីន, ទ្រូម៉ាន់ " ជាដើម ។ ក្នុងលទ្ធិនោះៗសុទ្ធតែព្រះធម៌ គ្រាន់តែសាមីលទ្ធិនោះយកទៅក្រឡៃតាមអំណាច លោភៈ ទោសៈ មោហៈ របស់ខ្លួន ។ សូម្បីតែសាមីលទ្ធិនោះក៏មិនស្គាល់ថាជាព្រះធម៌ផងដែរ ។

ព្រះធម៌នេះហើយ ដែលទ្រទ្រង់ក្បាលមនុស្សឱ្យត្រង់ទៅលើ ឱ្យមានដំណើរត្រង់ មិនឱ្យផ្តេកមិនឱ្យទ្រេតមិនឱ្យទៅទទឹងខ្លួនដូចសត្វតិរច្ឆាន ។ បើគ្មានព្រះធម៌ជាប់ទាក់ទងនឹងមនុស្សទេ ក្នុងពិភពលោកនេះសុទ្ធតែសត្វតិរច្ឆានទាំងអស់ទៅហើយ, ព្រោះគ្មានមនុស្សធម៌គឺគ្មានការចេះដឹង វៃឆ្លាត ស្គាល់ខុសត្រូវ ល្អអាក្រក់ ។

# កំណើតសុជីវធម៌

សុជីវធម៌កើតពីមនុស្ស ប៉ុន្តែមិនមែនកើតមានចំពោះតែពីមនុស្សចេះដឹងជ្រៅជ្រះ ជាអ្នកប្រាជ្ញបញ្ញវន្ត, ជាអ្នកមានបុណ្យស័ក្តិ, ជាអ្នកមានទ្រព្យសម្បត្តិនោះទេ; អ្នកទ័លក្រ ឥតបុណ្យស័ក្តិ មិនមែនជាបញ្ញវន្ត ក៏មានសុជីវធម៌ដែរ ឱ្យតែមានការអប់រំអំពីអ្នកសុជីវធម៌ ។ ព្រោះជនខ្លះ មានប្រាជ្ញាជាបញ្ញវន្ត មានបុណ្យស័ក្តិ មានទ្រព្យស្តុកស្តម្ភ តែគ្មានសុជីវធម៌ទាល់តែសោះ សូម្បីតែជាមួយប្រពន្ធកូនខ្លួន ក៏គ្មានដែរ កើតជាមនុស្សឈ្លើយបណ្តោយខ្លួនផុះបន្ទា ឱ្យក្លាយជាសត្វខ្លា នាំឱ្យរំខានដល់អ្នកដទៃ ដែលបានជួបប្រទះ នឹងអ្នកនៅជិតខាង ។

ហេតុដែលមនុស្សលោកបង្កើតឱ្យមានសុជីវធម៌នោះ ព្រោះមនុស្សលោក ត្រេកអរចំពោះតែចរិយាមារយាទពាក្យសំដីល្អ ។ សូម្បីអ្នកដែលគ្មានចរិយាមារយាទ ពាក្យសំដីល្អសោះនោះ ក៏លោកខំបំបាត់ចោលនូវទុជ្ជីវធម៌ ហើយបង្កើតឱ្យមានសុជីវធម៌ឡើង ដើម្បីឱ្យស្របតាមបំណងរបស់ខ្លួន ។

---

## អំពីការចំរើនលូតលាស់

សុជីវធម៌មានការចំរើនលូតលាស់ទៅតាមសង្គមមនុស្ស ។ ដូចសម័យបច្ចុប្បន្ននេះ សង្គមខ្មែរយើងកំពុងចំរើនលូតលាស់គ្រប់វិស័យទាំងអស់ ក្រោមរស្មីប្រតិភាណនៃសម្ដេចព្រះនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋខ្មែរ ។

តាំងពីសម័យអង្គរមកដល់បច្ចុប្បន្ននេះ សុជីវធម៌ខ្មែរមានអត្ថន័យច្រើនសន្ធឹក ទាំងការកែប្រែតាមកាលៈទេសៈក៏មានចំនួនមិនតិចដែរ ។ សមត្ថភាពខ្ញុំមិនអាចស្រាវជ្រាវយកមកចងក្រងសរសេរក្នុងទីនេះឱ្យបានសព្វគ្រប់ទេ គ្រាន់តែដកស្រង់យកត្រង់នេះខ្លះ ត្រង់នោះខ្លះ ដែលជាសាធារណៈចំពោះជនភាគច្រើន តម្រូវតាមកាលៈទេសៈ ដែលជីវិតមនុស្សបច្ចុប្បន្នតែងជួបប្រទះញឹកញាប់ ហើយត្រូវតែចេះដឹងជាចាំបាច់ផង ។

ចំពោះសុជីវធម៌ខ្លះ ដែលមិនមែនជាសាធារណៈទូទៅដល់ជនភាគច្រើន ដូចជារបៀបបែបបទចូលក្រាបបង្គំគាល់ព្រះមហាក្សត្រ, - ចូលរួមក្នុងព្រះរាជពិធីធំៗ នោះ សូមមើលសៀវភៅទំលាប់ទំនៀមរបស់ឯកឧត្តមមហាមន្ត្រី ញ៉ុក - ធូវ នោះទៀតចុះ ។

---

# សុជីវធម៌ប្រចាំសង្គមគ្រួសារ

ក្នុងជុំពិភពដ៏ធំធេងនេះ គ្មាននរណារស់នៅទោលតែម្នាក់ឯងកើតទេ ហើយគ្មានសិទ្ធិដាច់មុខមករស់នៅតែម្នាក់ឯងផង ព្រោះមានហេតុជីវិតរាប់មិនអស់ មកដណ្តើមប្រណាំងប្រជែងគ្នារស់នៅក្នុងជុំពិភពនេះ ។

ការដណ្តើមគ្នារស់នៅអែអុកដូច្នេះ មិនមែនជាការងាយស្រួលទេ តែងតែប៉ះទង្គិចគ្នាជានិច្ចនិរន្តរ៍។

ពួកជីវិតមានសម្ថភាព ជិះជាន់បៀតបៀនធ្វើឱ្យរំខានដល់ពួកជីវិតទន់ខ្សោយក៏មាន, ពួកជីវិតទន់ខ្សោយបៀតបៀនធ្វើឱ្យរំខានដល់ពួកជីវិតមានសម្ថភាពក៏មាន ។ ការជិះជាន់ប៉ះទង្គិចគ្នាក្នុងដំណើរជីវិតនេះឯងបណ្តាលឱ្យមានការឈ្លោះប្រកែក មានគ្រឿងសស្ត្រាវុធ មានសង្គ្រាមត្រជាក់ក្តៅ កើតជាផ្សែងភ័យជាភ្លើងទុក្ខអាប់អួពេញជុំពិភព ។

ដើម្បីឱ្យដំណើរជីវិតប្រព្រឹត្តទៅស្របស្រួលគ្នា ក្នុងទីបក្នុងសង្គមធំ - តូចមួយ ៗ ត្រូវតែមានសុជីវធម៌ប្រចាំជីវិតគ្រប់ៗគ្នាខានពុំបាន ។

អាស្រ័យហេតុនេះ ទើបខ្ញុំស្រាវជ្រាវប្រមូលសុជីវធម៌ដែលមានក្នុងសង្គមខ្មែរយើងយកកមកចងក្រងរៀបចំឱ្យមានរបៀប ជាវត្តបទ ជាបាច់ចង្កោមសេចក្តីឡើង តម្រូវតាមឧត្តមគតិជាតិផង ឱ្យងាយស្រួលដល់ការអាន, - សិក្សារៀនសូត្រផង, ដូចតទៅនេះ៖

## សុជីវធម៌បែងចែកជាវត្តបទមាន ៦[1]

១- ការស្គាល់ហេតុផលគួរមិនគួរ,

២- ការស្គាល់ឋានៈខ្លួននិងអ្នកដទៃ,

៣- ការស្គាល់ប្រមាណជីវភាព,

៤- ការស្គាល់កាលសម័យ,

៥- ការស្គាល់ប្រជុំជននិងទីប្រជុំ,

៦- ការស្គាល់មិត្តសំឡាញ់,

វត្តបទទាំង៦នេះ ជាបទទៀងទាត់ គ្មានកែប្រែបន្ថែមបន្ថយទេ ។ ឯអត្ថន័យរបស់វត្តបទមួយៗនោះ ទើបអាចកែប្រែថែមថយទៅតាមកាលៈទេសៈបាន ។

១ - វត្តបទគឺចំណែកនៃសេចក្តីប្រតិបត្តិ ឬចំណែកនៃសណ្តាប់ធ្នាប់ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

## វគ្គបទទី១
## ការស្គាល់ហេតុផលគួរមិនគួរ

បទបញ្ញត្តិនឹងទំលាប់ទំនៀម ឬ ត្រណមទាំងឡាយដែលប្រកបដោយគតិបណ្ឌិតចាត់ទុកជាហេតុគួរមួយ ដែលជនពល់រូបគួរគោរពប្រព្រឹត្តតាម ។ បើជនណាមិនដឹងមិនយល់ថាជាហេតុគួរហើយចេះតែប្រព្រឹត្តធ្វើផ្តេសផ្តាសតាមអំពើចិត្តទៅ ជននោះប្រាកដជាបានទទួលផលអាក្រក់ទុក្ខព្រួយ ថោកទាបអាមាស់មុខក្នុងចំណោមមនុស្សទាំងឡាយ ត្រូវគេត្មះតិះដៀលថាជាមនុស្សឈ្លើយ, មនុស្សក្អើ, មនុស្សឆ្កួង មនុស្សឥតពូជអំបូរមនុស្សគ្មានសុជីវធម៌ ។

ឯអ្នកដែលស្គាល់ហេតុផលគួរមិនគួរ ច្បាស់លាស់ថា បទបញ្ញត្តិនឹងទំលាប់ទំនៀមឬត្រណមទាំងឡាយនោះៗប្រកបដោយហេតុផលល្អគួរតាមកាលៈទេសៈ, នោះៗមិនគួរ ហើយគោរពប្រតិបត្តិតាមតែហេតុផលដែលគួរ តែងបានផលល្អសុខចំរើនរស់នៅសមរម្យក្នុងចំណោមមនុស្ស អ្នកផងគេសរសើរថាជាមនុស្ស

មិនឈ្លើយ, - មានសណ្ដាប់ធ្នាប់ល្អ, - មានពូជអំបូរ, - មានសុជីវធម៌ ។

ការស្គាល់ហេតុផលគួរមិនគួរច្បាស់ប្រាកដពីចិត្តខ្លួនគំនិតខ្លួន ទើបអាចធ្វើខ្លួនឱ្យទៅជា មនុស្សមានសុជីវធម៌ ឬសុជីវធម្មិក បាន គឺស្គាល់ថាហេតុផលនេះល្អ ត្រូវតែប្រតិបត្តិតាម, ហេតុផលនេះអាក្រក់ត្រូវតែលះបង់ មិនត្រូវប្រព្រឹត្តធ្វើដូចតទៅនេះ៖

## ក-ស្គាល់ហេតុផលខុសត្រូវនៃចរាចរ

មនុស្សគ្រប់រូប គ្មាននរណាកើតមកហើយនៅតែមួយកន្លែង មិនទៅណាអស់មួយជីវិតនោះបានទេ តែងតែត្រាច់ចរទៅមកក្នុងទីផ្សេងៗគ្រប់ច្រកល្ហកទិសតំបន់ ខ្លះដើរទៅដោយជើង, ខ្លះទៅមកដោយរទេះគោក្របី, - ដោយជិះសេះដំរី, - ដោយទោចក្រ-យាន, ដោយទោចក្រយានយន្ត, ដោយរថយន្តធំតូច នឹងដោយទូកកប៉ាល់ជាដើម ។

ការធ្វើចរាចរទៅមកប្រទាក់ប្រទើស ខ្វាត់ខ្វែងដូច្នេះសុទ្ធតែ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី សស់ សាទី

មានច្បាប់ទំលាប់សម្រាប់ការពារគ្រោះថ្នាក់ កុំឱ្យបុកប៉ះទង្គិចផល់គ្នាឱ្យមានដំណើរប្រព្រឹត្តទៅស្របស្រួលសុខសប្បាយ ។

ឯច្បាប់ចរាចរនោះរដ្ឋាភិបាលបានចងជាបញ្ញត្តិ អនុញ្ញាតគ្រប់សព្វអស់ហើយ ។ អ្នកបើកបរទាំងឡាយក៏សុទ្ធតែរាជការមុខក្រសួងបានពិនិត្យសមត្ថភាពយ៉ាងហ្មត់ចត់ បើឃើញថាចេះច្បាប់ចរាចរគ្រប់សព្វគ្រប់ហើយ ទើបអនុញ្ញាតឱ្យបើកបររថយន្តធំតូចបាន ។ ដូច្នេះអ្នកបើកបរទាំងឡាយសុទ្ធតែចេះដឹងស្គាល់ហេតុផលខុសត្រូវក្នុងការធ្វើចរាចរនោះស្រេចទៅហើយ គ្រាន់តែមិនសូវចេះគោរពប្រតិបត្តិតាមច្បាប់នោះប៉ុណ្ណោះ ។ ការមិនចេះគោរពប្រតិបត្តិតាមដូច្នេះ ឈ្មោះថាគ្មានសុជីវធម៌ផ្នែកចរាចរ ។ លុះតែបុគ្គលណាចេះគោរពប្រតិបត្តិតាមច្បាប់ចរាចរដែលខ្លួនបានចេះដឹងស្គាល់ហេតុផលច្បាស់ហើយ បុគ្គលនោះទើបឈ្មោះថាជាអ្នកមានសុជីវធម៌ផ្នែកចរាចរបាន ។

ក្នុងទីនេះខ្ញុំគ្រាន់តែដកស្រង់ត្រង់ចំណុចខ្លះ នៃច្បាប់ចរាចរយកមកបញ្ជាក់ថែមទៀត៖

- ការបើកបររថយន្តធំក្នុងទីប្រជុំជនត្រូវមានល្បឿនត្រឹម ១៥ ឬ ២០ គីឡូម៉ែត្រក្នុង១ម៉ោង ។

- ការបើកបររថយន្តតូចក្នុងទីប្រជុំជនត្រូវមានល្បឿន ៣០ ឬ ៤០ គីឡូម៉ែត្រក្នុង១ម៉ោង ។

- ការបើករថយន្តដឹកមនុស្សក្រៅទីប្រជុំជន ត្រូវមានល្បឿន ៦០ គីឡូម៉ែត្រក្នុង ១ ម៉ោងយ៉ាងលឿន។

-ការបើករថយន្តដឹកទំនិញ ក្រៅទីប្រជុំជនត្រូវមានល្បឿន ៥០ គីឡូម៉ែត្រក្នុង ១ ម៉ោងយ៉ាងលឿន ។

- ក្នុងទីប្រជុំជនរថយន្តទាំងឡាយត្រូវប្រើភ្លើងតូច, ត្រង់ផ្លូវបំបែកប្រើភ្លើងកណ្ដាល ។ ក្រៅទីប្រជុំជនប្រើភ្លើងធំបាន បើមានរថយន្តឬ យានផ្សេងៗមកពីមុខត្រូវប្រើភ្លើងកណ្ដាលវិញ កុំឱ្យពិលភ្នែកគេបណ្ដាលឱ្យមានគ្រោះថ្នាក់ ។

- កំពុងបើកបរបើមានត្រីចក្រយាន, ទោចក្រយាន, ឬរទេះគោ, រទេះសេះនឹងអ្នកថ្មើរជើងជាដើម ត្រូវបង្អង់ចៀសចម្ងាយ ១ ម៉ែត្រឬ១ម៉ែត្រកន្លះបើចៀសបាន កុំបង្ខំបើកបរតាមអំពើចិត្តខ្លួន ។

- បើមានរថយន្តទឹក, រថយន្តប៉ូលិស, រថយន្តទាហាន នឹងរថយន្តពេទ្យ ទោះបីនៅខាងឆ្វេងក៏ដោយស្តាំក៏ដោយ ត្រូវបើកឱកាសឱ្យទៅមុនជានិច្ចកុំរារាំង ព្រោះរថយន្តទាំង៤ពួកនេះច្រើនមានការអាសន្ន ។

- អ្នកជិះទោចក្រយាន នឹងទោចក្រយានយន្តមិនត្រូវជិះទន្ទឹមគ្នារាយប៉ាយពេញផ្លូវ ត្រូវជិះឱ្យមានរបៀបមុនក្រោយតាមលំដាប់គ្នា ។ មុននឹងបត់ទៅខាងណាត្រូវបង្ហង់លើកដៃមើលគេឯងសិន ។ ជាពិសេសត្រូវឱ្យមានភ្លើងហ្វ្រាំងជាដើមខានមិនបាន ។

- អ្នកបរត្រីចក្រយាន ( ស៊ីក្លូ ) ត្រូវបរតាមលំដាប់លំដោយគ្នាមិនត្រូវប្រណាំងប្រជែង ឬជាក់ជើងម្ខាងកំសាន្តលេងតាមផ្លូវ ប្រយ័ត្នប្រយ៉ាងរំខានដល់អ្នកដទៃត្រូវតាមពាក្យសំដី នឹងកាយវិការគួរសមចំពោះអ្នកជួលជិះ ។ ឯអ្នកជួលជិះក៏ត្រូវមានការគួរសមវិញដែរ ថ្លៃឈ្នួលលើសខ្វះបន្តិចបន្តួចគួរយោគយល់គ្នាទៅវិញទៅមកកុំប្រកាន់រឹះគន់ពេក ។

- អ្នកបើកបររថយន្ត ទោចក្រយាន ទោចក្រយានយន្ត

នឹងអ្នកជាក់ស៊ីក្លូជាដើម បើមានទឹកកក់ដល់តាមភ្លៅ ហើយមានមនុស្សដើរជិតនោះ កុំបង្ខំបើកបរធ្វើព្រងើយ បន្សាចទឹកកក់នោះឱ្យខ្ទាតប្រឡាក់អ្នកដទៃ ។

- អ្នកធ្វើចរាចរដោយយានគ្រប់ប្រភេទខាងលើនេះ បើបានជួបប្រទះនឹងក្បួនហែឯកជនផ្សេងៗ មានហែសពជាដើមដែលគ្មានភ្នាក់ងារប៉ូលិសរក្សាក្បួនត្រូវឈប់រង់ចាំ ។ មិនត្រូវបង្ខំជ្រៀតជ្រែកបើកបរកាត់មុខកាត់ក្រោយប្រទាក់ប្រទើស នាំឱ្យរំខានដល់ក្បួនគេទេ បើមានការប្រញាប់បន្ទន់ចាំមិនបាន ត្រូវថយក្រោយរកផ្លូវផ្សេងទៀត ។

- អ្នកថ្មើរជើង កុំដើរចំកណ្ដាលផ្លូវ បើនៅទីក្រុងត្រូវដើរលើចិញ្ចើមថ្នល់ កុំដើរទន្ទឹមគ្នាទាំងហ្វូងៗ ជជែកសើចក្អាកក្អាយហ៊ោកញ្ជ្រៀវទះដៃពេញផ្លូវ ធ្វើឱ្យអ្នកដទៃដើរផងមិនបាន ។ បើចង់ឆ្លងទៅម្ខាងៗ ត្រូវដើរតាមគំនូសដែលរាជការក្រុងបានគូសកាត់ទទឹងផ្លូវ កុំដើរកាត់ផ្ដេសផ្ដាស នឹងមិនត្រូវរត់ឆ្លងជាដាច់ខាត ។

- បើមានបុណ្យទានមនុស្សកកកុញច្រើន ជួនជាដើរទៅ

មានប៉ះទង្គិចគ្នា គប្បីប្រើពាក្យសំដីទន់ភ្លន់សុំទោសគ្នា អត់ទោសឱ្យគ្នាដោយអាការៈគួរសម ។

- ការធ្វើចរាចរគ្រប់ប្រភេទ ត្រូវប្រព្រឹត្តទៅខាងស្តាំជានិច្ចតាមទំលាប់ជាតិខ្មែរយើង ។

- ត្រូវស្គាល់សញ្ញាភ្លើងដែលមាននៅផ្លូវបំបែក ក្នុងទីក្រុងបើឃើញភ្លើងលឿងត្រូវបង្អង់ ភ្លើងក្រហមត្រូវឈប់ ភ្លើងបៃតងត្រូវទៅ ។

- ត្រូវស្គាល់សញ្ញាដែលដាក់ណៅក្បែរផ្លូវ សញ្ញាអន្តរជាតិដែលមានប្រើនៅប្រទេសកម្ពុជាយើង សម័យនេះមានទាំងអស់ ៧៨ បែប សូមមើលចំណាំតាមច្បាប់ចរាចរឬសៀវភៅរៀនបើកបររថយន្តចុះ ។ ឯគោលសំខាន់នៃសញ្ញាទាំងអស់នោះមាន ៣ គឺ: ១- សញ្ញារាងមូលត្រូវស្គាល់ថាបំរាម មានហាមឃាត់ផ្សេងៗតាមគំនូស, ២ សញ្ញារាងបីជ្រុងប្រាប់ថាប្រយ័ត្នគ្រោះថ្នាក់, ៣. សញ្ញារាងបួនជ្រុងស្មើឬបួនជ្រុងទ្រវែងជាសញ្ញាឱ្យដំណឹង នឹងបង្ហាញផ្លូវ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

- អ្នកអូសរទេះទឹក ឬរទេះដឹកនាំសម្ភារៈផ្សេងៗ រទេះគោ រទេះសេះក្នុងក្រុងឬក្រៅក្រុង ក៏ត្រូវស្គាល់សញ្ញានេះខ្លះដែរ ព្រោះមានផ្លូវខ្លះហាមឃាត់មិនឱ្យទៅ មិនឱ្យឈប់ជាដើម ។

- បើផ្លូវចង្អៀត ហើយមានរថយន្ត ឬទោចក្រយានជាដើមមកពីក្រោយ អ្នកដើរគួរចៀសបើកឱកាសឱ្យរថយន្តជាដើមនោះទៅមុន កុំដើរធ្វើព្រងើយ មិនស្តាប់ស័ព្ទសញ្ញាគេសុំផ្លូវដោយអាងថាខ្លួនជាមនុស្ស គេមិនហ៊ានបើកបរកិន ដូចជុំគ្រួសនោះឡើយ ។

- ចំពោះអ្នកបើកបររថយន្ត និង ទោចក្រយានជាដើមវិញ បើផ្លូវចង្អៀតត្រូវតែបង្អង់ ឬឈប់សិនទុកឱកាសឱ្យអ្នកដើរចៀសឱ្យបានស្រួលបួលកុំប្រញាប់ប្រញាល់បរជិះពានពារ ឱ្យប៉ះទង្គិចដល់អ្នកថ្មើរជើង ដោយអាងថាខ្លួនជិះក្នុងឡានឬជិះលើទោចក្រ-យានជាដើម ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

## ១-អាការៈរបស់អ្នកដើរ

- ត្រូវដើរឱ្យសមភាពជាពលរដ្ឋឯករាជ្យថ្ងៃថ្នូរ កុំប្រើអាការៈមើងមាំង ចេះតែអើតមើលផ្ទះភូមិឋានគេមិនមើលក្រោមបណ្តោយឱ្យជំពប់ជើងដួលទាំងស្រស់នាំឱ្យខ្មាស់គេ ។

- កំពុងដើរបើឃើញរបស់ជ្រុះនៅផ្លូវ ដូចជាកញ្ចប់សំពត់អាវ កាបូប សំណុំលិខិតជាដើម គួរតែរើសឡើងកុំឱ្យរថយន្តជាដើមបរជាន់នាំឱ្យខូចខ្ទេចខ្ទីរបស់នោះ មួយស្របក់បើមិនឃើញម្ចាស់ទេ មិនត្រូវយកជាប្រយោជន៍ខ្លួន ឬយកទៅហែកចោលឡើយគួរយកទៅជូនភ្នាក់ងាររាជការ មានក្រុមព្រះនគរបាលជាដើម ឱ្យផ្សាយដំណឹងរកម្ចាស់ ឬក្រែងមានគេផ្សាយរកតាមវិទ្យុជាដើម ឱ្យបានឆាប់ឃើញរបស់នោះវិញ ។

- បើមានការទៅរកផ្ទះណាមួយដែលខ្លួនត្រូវរក ហើយស្គាល់ផ្ទះនោះមិនច្បាស់ ត្រូវការសួរគេ គប្បីដើរទៅឱ្យជិតដោយអាការៈគួរសម មានពាក្យថាសុំអត់ទោសចាប់ដៃឬសំពះជាដើម

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

តាមឋានៈមនុស្សក្មេងចាស់ដែលយើងត្រូវសួរ កុំស្រែកសួរគេពីចម្ងាយ ជាពិសេសកុំសួរគេឥតប្រើពាក្យសព្វនាមថា ពូ . មា . មីង អ៊ុំ . លោកជាដើម មានអ្នកខ្លះខ្វះការគួរសម ស្រាប់តែសួរគេថាៈ ស្គាល់ផ្ទះអ្នកនេះ អ្នកនោះឬទេ? គ្មានប្រើពាក្យគួរថា មា . មីង . ពូ អ៊ុំ . លោកជាការគួរសមផងសោះ ។ ត្រូវសួរគេថា មា . ពូ . អ៊ុំ . មីង . លោក ឬលោកតាលោកយាយជាដើម បានស្គាល់ផ្ទះឈ្មោះនេះឈ្មោះនោះឬទេ? ដូច្នេះទើបគួរ ។ កាលបើគេប្រាប់បង្ហាញដល់ខ្លួនហើយ គប្បីប្រើពាក្យថាអរគុណជាដរាប ។

- កំពុងដើរបើឃើញផ្ទះណាមួយគេធ្វើបុណ្យទាន កុំឈរមើលគេហាក់មិនដែលឃើញ ឬក៏ចូលទៅលាយឡំជាមួយគេធ្វើមុខស្មើមើលមាត់គេស៊ីផឹក មានអាការៈឥតរបបស្រេកឃ្លានចង់ស៊ីផឹកនឹងគេដែរ ។

- កំពុងដើរបើឃើញវត្ថុប្លែកៗក្នុងរបងឬក្នុងផ្ទះគេ កុំឈប់ឈរមើលក្រែងខ្លួនដរាបដល់ម្ចាស់គេដេញ ។

- កុំឈប់សំឡឹងមើលរបស់ទ្រព្យក្នុងរបង ឬក្នុងផ្ទះគេ ។

ដោយអាការៈភ្នែកមិនល្អ ដែលគេអាចសំគាល់ច្រឡំថាជាចោរចង់លួចទ្រព្យរបស់គេ ។

- នៅមុខផ្ទះជនបរទេស ដែលគេមកនៅក្នុងប្រទេសយើងដូចជាតិបារាំងជាដើម កុំដើរទៅឈរកាន់ទប់របងមើលគេ ឬមើលកូនចៅគេកំពុងលេង ដោយអាការៈហាក់ដូចជាមិនដែលធ្លាប់ស្គាល់មិនធ្លាប់ឃើញជនបរទេសសោះ ។

- កំពុងដើរមុខផ្ទះគេ បើម្ចាស់គេមានកើតហេតុឈ្លោះទាស់ប្រកែកគ្នាក្នុងគ្រួសារ កុំឈរឈ្ងោកមើលសម្ងំស្តាប់គេដែលនាំឱ្យគេអៀនខ្មាស់ ។ បើធ្លាប់ស្គាល់គ្នាគួរចូលទៅជួយសម្រុះសម្រួលផង ។

- កំពុងដើរបើជួនជាមានផ្ទះណាមួយ កើតអាសន្នដូចភ្លើងឆេះផ្ទះជាដើម កុំឈរមើលតែនឹងភ្នែក ត្រូវជួយខ្វល់ខ្វាយការពារអាសន្ននោះផង ។ ប៉ុន្តែកុំបន្លំឆក់លួចយករបស់ទ្រព្យគេ ត្រូវជួយការពារដូចទ្រព្យរបស់ខ្លួន ។

- កំពុងដើរបើមានក្អកកណ្តាស់ កុំខាកស្តោះផ្តេសផ្តាស

ឬញើសសំបោរទៅជូតរបងផ្ទះគេ ឬជូតបង្គោលភ្លើង បង្គោលខ្សែទូរលេខទូរស័ព្ទ ឬក៏ខាកស្ដោះដាក់ចំកណ្ដាលផ្លូវ ចំទ្វាររបងផ្ទះគេ ។ បើមានគេដើរជិតកុំខាកមុខក្អកកណ្ដាស់ទៅរកគេ គប្បីយកដៃបិទបាំង កុំឱ្យឮសូរខ្លាំងឱ្យគេភ្ញាក់ផ្អើល ។

- កំពុងដើរបើត្រូវការបន្ទោបង់មូត្រលាមក ដោយការអត់ទ្រាំពុំបាន ហើយគ្មានបង្គន់សាធារណៈនៅជិត គប្បីចូលទៅរកផ្ទះដែលនៅជិត សុំបង្គន់គេបន្ទោបង់ មិនគួរបន្ទោបង់ដាក់គល់ឈើ ឬគុម្ពផ្កា កៀនរបង គល់ជង់គោម ឬទីណាដែលធ្លាប់មានគេទៅមកនោះទេ ។ ឯម្ចាស់ផ្ទះវិញបើអ្នកមានអាសន្នដោយមូត្រលាមកចូលទៅសុំបង្គន់បន្ទោបង់ដូច្នេះ គប្បីទទួលដោយរាក់ទាក់នាំជូនបង្ហាញបង្គន់របស់ខ្លួន ដោយអាការៈគួរសម កុំថ្លែងអាការៈឱ្យគ្នាខ្មាស់អៀន កុំធ្មើងឆ្មៃប្រកាន់ឋានៈធំតូចមានក្រទើបឈ្មោះថាជាមនុស្សមានសុជីវធម៌ ព្រោះការបន្ទោបង់មូត្រលាមកនេះគ្មានឋានៈធំតូចមានក្រទេ ។

- កំពុងដើរមិនគួរជក់បារី ស៊ីស្លា ឬបរិភោគដូចជាអំពៅ

ពោតស្ងោជាដើម ហើយចោលសំបកវាយតាមផ្លូវ នឹងចោលកន្ទុយបារី ស្តោះកាកម្លូទឹកមាត់ក្រហម នាំឱ្យខូចលំអផ្លូវនឹងនាំឱ្យប្រឡាក់ជើងអ្នកដើរក្រោយដែលមិនបានជាមើល ។ បើមានកូនចៅដើរជាមួយក៏មិនគួរឱ្យស៊ីអ្វីៗដែរព្រោះជាអាការៈឥតរបប ។

- កំពុងដើរបើមានវត្ថុអ្វីៗត្រូវចោល គួរដើរឱ្យដល់ធុងសំរាមដែលមានក្បែរផ្លូវនោះសឹមចោល ឬដល់កន្លែងដែលគួរចោលសឹមចោល កុំចោលផ្តេសផ្តាសតាមទម្លាប់ដែឥតរបប ។

- កំពុងដើរមុខផ្ទះគេ បើម្ចាស់ផ្ទះត្រូវធ្វើដំណើរចេញ ឬចូល ត្រូវឈប់ឱ្យចេញចូលសិន កុំឱ្យគេឈប់ចាំខ្លួនដើរ ។

- ពេលព្រឹកឬល្ងាចត្រជាក់ ដែលម្ចាស់ផ្ទះគេនាំគ្រួសារ មកអង្គុយសម្រាកនៅក្រៅរបងមុខផ្ទះ ជួនជាយើងដើរលើចិញ្ចើមផ្លូវទៅ មិនត្រូវដើរកាត់ហ្វូងគេ ឬដើរជិតស្ទើរតែជាន់គេនោះទេ ត្រូវដើរវាងឱ្យឆ្ងាយបន្តិច កុំឱ្យគេរំខានដោយសារខ្លួន ។

- បើយើងជាកំឡោះឬក្រមុំ ដើរជាមួយមិត្រពីរបីនាក់ ឬដើរម្នាក់ឯងនៅមុខផ្ទះគេ ហើយឃើញប្រពន្ធកូនក្រមុំគេ ឬ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

ឃើញប្ដី ឬកូនកំឡោះគេ មិនត្រូវឈរសំឡឹងពិនិត្យដោយអាការៈភ្នែកមិនល្អ ឬធ្វើសញ្ញាកាយវិការណាមួយ ឬក៏ក្អកគ្រហែម និយាយសើចផ្ដេសផ្ដាស ដែលជាអាការៈឈ្លើយ នាំឱ្យគេមានសេចក្ដីរង្កៀស អៀនខ្មាស់មួម៉ៅដោយសារខ្លួនឡើយ ។

- បើដើរមានគ្នា កុំនិយាយជជែកដោយសំឡេងខ្លាំងៗឡូឡា ឬឈ្លោះគ្នាតាមផ្លូវ ដែលនាំឱ្យភ្ញាក់ផ្អើលដល់អ្នកនៅផ្ទះក្បែរផ្លូវនោះ ។

- កំពុងដើរបើមានគ្រោះថ្នាក់ផ្សេងៗកើតឡើង ដូចឡានបុកគ្នា ឬកង់ស៊ីក្លូជល់ទង្គិចគ្នាជាដើម មិនគួរឈរមើលធ្វើព្រងើយទេ គួរជួយឈឺឆ្អាល ។ បើគ្មានភ្នាក់ងារប៉ូលិសនៅជិតត្រូវទៅជំរាបអញ្ជើញឱ្យមកមើលខុសត្រូវ នឹងត្រូវជួយដឹកនាំអ្នករបួសទៅមន្ទីរពេទ្យ ។

- បើមានអ្នកជិះកង់ ឬម៉ូតូ ភ្ជាត់ស្នៀតដួលខ្លួនឯង ឬក៏ដើររអិលដួល មិនគួរឈរមើលសើចលេងជាល្បែងកំសាន្តទេ គួរប្រញាប់ទៅជួយលើកជួយមើលរបួសគ្នា ដោយអាការៈជាអ្នក

ជួយយកអាសាសង្គ្រោះពិតៗ ។

- កំពុងដើរ បើបានជួបប្រទះពេលដែលកំពុងគោរពទង់ជាតិ កំពុងបទ្ទីភ្លេងជាតិ (នគររាជ) កុំដើរធ្វើព្រងើយ ហាក់ដូចមនុស្សគ្មានជាតិកំណើត គួរឈប់ឈរគោរព តម្រឹមជើងសំយុងដៃ តម្រង់ខ្លួន ងើយសំឡឹងទៅទង់ជាតិ ទៅរកសូរសព្ទភ្លេងដែលកំពុងបទ្ទី កំពុងបង្ហូត ដរាបដល់ចប់សព្វគ្រប់ ទើបគួរធ្វើដំណើរទៅទៀត ។

- បើដើរទៅបានជួបក្បួនហែរផ្សេងៗមានហែរសពជាដើម មិនត្រូវជ្រៀតដើរកាត់ក្បួនគេទេ គួរឈប់ដោយអាការៈសមរម្យគោរពសព ។ បើមានការប្រញាប់មិនអាចបង្អង់ចាំបាន ត្រូវធ្វើដំណើរចៀសវាងឱ្យឆ្ងាយពីក្បួនបន្តិច ។

- ដើរឬអង្គុយលំហើយកាយមុខផ្ទះក្រៅរបងភូមិ ឬក្នុងរបងដែលគេអាចមើលពីក្រៅទៅឃើញច្បាស់ មិនគួរស្លៀកខោស្ទើបឬស្លៀកក្រមា, បើស្ត្រីមិនគួរពាក់ត្រឹមតែអាវបិទដោះ ឬលែងដោះអាក្រាតទទេ ដោយអាងថាចាស់ហើយនោះទេ គួរស្លៀក

ពាក់បិទកេន្តីខ្មាស់ ឱ្យសមរម្យតាមទម្លាប់ជាតិខ្មែរគឺៈ បុរសគួរស្លៀកសារុងអាវទ្រនាប់ខ្លីជាដើម, ស្ត្រីគួរពាក់អាវខ្លី ឬចោមពុងកន្សែងក្រមា តាមរបៀបបុរាណ ក៏សមរម្យដាងពាក់ប្រដាប់បិទតែត្រឹមដោះនោះដែរ ។

## គ-ការដើរមានត្រណម

អារ្យជនខ្មែរយើង មានចរិយាវិសេសម្យ៉ាងជាងជាតិសាសន៍នានា ដរាបដល់មានជាតិសាសន៍ចម្លងយកទៅប្រើតាម ដូចជាតិសៀម-លាវជាដើម ។

- ចរិយាវិសេសនោះគឺ ត្រណមក្នុងការដើរតត្រុករុកពីក្រោមនឹងដើរជាន់ពីលើ:

- មិនគួរដើររុកតត្រុកក្រោមស្នូហាលខោអាវ, ក្រោមជណ្តើរ,- ក្រោមគ្រែ,- ក្រោមអង្រឹង នឹងក្រោមទីផ្សេងៗ ដែលមានវត្ថុស្មោកគ្រោកមិនគួរគប្បីនៅពីលើ ។ បើមានការចាំបាច់- ត្រូវតែចូលទៅក្នុងទីនោះៗ ត្រូវពាក់មួកឬទទូកន្សែង

ទើបគួរចូលទៅ ។ ព្រោះសំពត់ខោសារុងជាដើម ដែលតែង ហាលលើស្នូនោះ ជារបស់បិទបាំងកេរ្តិ៍ខ្មាស់ តែងដាក់គូទអង្គុយ លើ បើដើររុកតត្រុកទៅ ហាក់ដូចជាដើរតត្រុកក្រោមគូទដែរ ។ ឯជណ្ដើរគ្រែជាដើមនោះ ជាទីស្ថានគេតែងជាន់ដោយជើង ឬ អង្គុយដោយគូទ បើដើររុកតត្រុកទៅ ហាក់ដូចជាយកក្បាល ទៅទ្រជើងទ្រគូទដែរ ។

- មិនត្រូវដើរជាន់ដើរកន្ទង ឬអង្គុយលើគម្ពីរសាស្ត្រាក្បួន ច្បាប់គ្រប់យ៉ាង ដែលគេសរសេរ ចារ បោះពុម្ព ឬឆ្លាក់លើថ្ម លើឈើ - ស្លឹករឹត ឬក្រដាស ។

- មិនត្រូវដើរជាន់ដើរកន្ទងទីដំណេកមាតាបិតាគ្រូអាចារ្យ អ្នកមានឧបការគុណទាំងឡាយ នឹងអ្នកមានវ័យចាស់ជាងខ្លួន ឬសំណឹងអាសនៈសមណៈព្រាហ្មណ៍ ។

- មិនគួរដើរជាន់ដើរកន្ទង ឬអង្គុយលើខ្នើយកើយរបស់ ខ្លួន ឬបុត្រភរិយារបស់ខ្លួន ឬសិស្សគណខ្លួន ។

- មិនត្រូវដើរជាន់ឬកន្ទងអាសនៈ ដែលមានក្រាលកន្ទេល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ព្រំចៀមជាដើម សំរាប់ធ្វើពិធីមង្គលផ្សេងៗដូចអាសនៈសំរាប់ព្រះសង្ឃ នឹងសំរាប់ផ្សំផ្គុំបុត្រធីតាក្នុងពិធីអាពាហ៍ពិពាហ៍ជាដើម ។

- ចូលទៅក្នុងព្រះវិហារកុដិសាលា នឹងបូជនីយស្ថានផ្សេងៗបើពាក់ស្បែកជើងត្រូវដោះចេញ វៀរតែបានអនុញ្ញាតពីអ្នកថែរក្សាថាគួរពាក់ចូលបានក្នុងទីនោះៗ ទើបគួរពាក់ ។

- មិនត្រូវដើរជាន់ ឬកន្លងព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ, ព្រះពុទ្ធរូប ព្រះបដ, រូបព្រះសង្ឃ, រូបឥស្សរជនអ្នកមានគុណចំពោះប្រទេសជាតិ, រូបមាតាបិតាគ្រូអាចារ្យ នឹងរូបជនរៀមច្បងក្នុងគ្រួសារជាដើម ។

- មិនត្រូវដើរកន្លងមនុស្ស សូម្បីគ្រាន់តែកន្លងដៃឬជើងទោះបីមនុស្សនោះជាកូនចៅ ឬជាទាសកម្មករ ឬក៏ជាស្មូមយាចកឆ្កួតលីលា ព្រោះអ្នកទាំងអស់នោះសុទ្ធតែមានសិទ្ធិជាមនុស្សដូចខ្លួនដែរ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

# ឃ - ការស្គាល់ហេតុផលវិនាសបំផ្លាញនៃសម្បត្តិជាតិ

- ព្រៃព្រឹក្សាទាំងឡាយ មិនត្រូវពីសដៃជើងយកភ្លើងទៅដុតលេង ឬដុតចាប់សត្វ ឬក៏ដុតឱ្យវាលស្រឡះដើម្បីបោចរពាក់បោចវល្លិ៍ជាដើម ។

- ចូលទៅក្នុងព្រៃដើម្បីបេះផលាផលសាធារណៈ ដូចផ្លែគុយ សិរីមាន់ជាដើម ដែលដុះឯងគ្មានទរណាដាំ មិនត្រូវរំលំដើមនឹងកាប់រំលំឈើនៅជិតៗ ឱ្យឈើមានផ្លែនោះរលំដល់ដី ដើម្បីបេះយកផ្លែត្រឹមតែមួយអម្រែកឬមួយសំពាយនោះឡើយ ។

- ឈើដុះឯង ឬរាជការដាំក្បែរផ្លូវសាធារណៈ ដើម្បីធ្វើម្លប់មិនត្រូវកាច់កាត់កាប់មែកបេះផ្លែ ឬស្មោះកាប់ចិញ្ច្រាំសំបកជីកគាស់ឫសគល់លេងជាល្បែង ឬយកទៅប្រើការជាប្រយោជន៍ផ្ទាល់ខ្លួន ឬក៏ឆ្លូតគូររូបផ្ដេសផ្ដាស មានរូបកេរ្តិ៍ខ្មាស់ជាដើមនៅនឹងដើមឈើ ដែលនាំឱ្យអ្នកផងទាំងពួងគេឃើញកើតសេចក្ដីអៀនខ្មាស់ ។

សុជីវធម៌ផ្នែកព្រៃព្រឹក្សានេះ កាលជំនាន់មុនខ្មែរគោរពតែដើមពោធិទេ គឺបើដើរទៅដល់ដើមពោធិ ត្រូវគោរពដោះឆ្នួត ដោះមួក ដាក់ទ្រនូល ហើយលើកដៃសំពះផង, កាប់កាត់កាច់មែកស្លឹកដើម ស្ទោះសំបក ជីកឫសមិនបាន ត្រូវមានទោសពិន័យពីរាជការ ព្រោះសំគាល់ថាជារុក្ខជាតិវិសេសដែលព្រះពុទ្ធបរមគ្រូបានត្រាស់ដឹងក្រោមម្លប់ ។

ដល់មកសម័យបច្ចុប្បន្ននេះ ការគោរពនោះបានប្រែប្រួលទៅតាមសម័យ គឺត្រូវគោរពគ្រប់រុក្ខជាតិទាំងអស់ ដែលជាសម្បត្តិជាតិ មិនចំពោះតែដើមពោធិមួយទេ ។ ឯការគោរពនោះគឺ មិនត្រូវដុតបំផ្លាញ មិនត្រូវកាប់កាត់កាច់ផ្តេសផ្តាសឥតច្បាប់អនុញ្ញាត ។

- ផ្លូវគមនាគមន៍គ្រប់ប្រភេទ មិនត្រូវជីកកកាយឱ្យខូច ទាំងមិនត្រូវយកវត្ថុអ្វីៗទៅចោលក្នុងផ្លូវថ្នល់នោះ ឬយកសត្វពាហនៈគោក្របីជ្រូកមាន់ទាជាដើម ទៅចងជិតចិញ្ចើមផ្លូវ ទៅលែងចោលឱ្យដើរផ្តេសផ្តាសក្នុងផ្លូវ ។

- ការចិញ្ចឹមជ្រូកមាន់ទាជាដើម ត្រូវធ្វើទ្រុងដាក់កុំឱ្យដើរផ្ដេសផ្ដាស ទៅជុះនោមដាក់ផ្លូវថ្នល់ ទៅឈ្លូសកកាយស៊ីដំណាំផ្ទះជិតខាង ដែលនាំឱ្យរំខានដល់អ្នកដទៃ កើតទៅជារឿងទាស់ឈ្លោះក្តីក្តាំគ្នា ។

- ស្ពាន បង្គោលគីឡូម៉ែត្រ ខ្សែទូរលេខទូរសព្ទ មិនត្រូវយកកាំបិត ពូថៅ ដំបង ដុំថ្ម ទៅកាប់គប់ចោលវាយសំពងលេងឱ្យបែក បាក់ ដាច់ ខូច ប្រេះ ឆែប ធា ទេ ។

- សត្វព្រៃទាំងឡាយ ដែលរាជការហាមឃាត់ទុកមិនត្រូវលួចបន្ទំសម្លាប់ ឬបំផ្លាញដោយហេតុណាមួយ ។

- ព្រៃក ឈូង ទន្លេ បឹងបួ ដែលរាជការទុកឱ្យមច្ឆ-ជាតិពងកូន មិនត្រូវទៅលួចចាប់បំផ្លាញទេ ។

- សាលាសំណាក់ដែលឬរាជការធ្វើក្តី អ្នកមានសទ្ធាធ្វើក្តីបើចូលទៅក្នុងសាលានោះមិនត្រូវបោចពោចកាច់រនាប ជញ្ជាំងដុតចំអិនអាហារ ឬកាប់ចាំងលេងដោយរពឹសដៃ ឬក៏យកធ្យូងនឹងអ្វីៗទៅគូសផ្ដេសផ្ដាស នៅជញ្ជាំងជាដើម ។ បើឃើញ

រនាបជាដើម បាក់បែក ធ្លាក់ជ្រុះគួររើសយកទៅជួសជុលវិញ ។ ជាពិសេស ប្រាសាទអង្គរ អ្នកទៅទស្សនាទាំងឡាយ មិនត្រូវយកអ្វីៗទៅគូរ ឬគប់លេងឱ្យបែកបាក់មានស្នាកស្នាម ឬក៏យកកាំបិតជាដើមទៅសំលៀងទេ ។

- សម្ភារៈគ្រប់យ៉ាងរបស់ជាតិ, ដែលមានសម្រាប់ក្រសួងរាជការទាំងអស់ ដូច តុ ទូ កៅអី ក្រដាសសរសេរ ប្រេងសាំង ខ្សាច់គ្រួស នឹងរថយន្តជាដើម បុគ្គលិករាជការទាំងឡាយត្រូវប្រើដោយថ្នាក់ថ្នមឱ្យដឹងបាត់ដឹងគង់ដូចជារបស់ផ្ទាល់ខ្លួន កុំប្រើខ្ជះខ្ជាយ អាងតែរបស់រាជការសាធារណៈ, ប្រើអស់មួយពីរចុះក្នុងបញ្ជីថាអស់បួនប្រាំ បន្ទំយកទៅផ្ទះខ្លះ ចែកទៅញាតិសន្តានខ្លះ ។ ជាពិសេសចំពោះការទិញចូល ថ្លៃប៉ុណ្ណេះកុំចុះបញ្ជីថាប៉ុណ្ណោះ ស៊ុមគ្រលំជាមួយអ្នកលក់ កេងយកប្រយោជន៍ផ្ទាល់ខ្លួន ដែលមានលក្ខណៈចូលទៅក្នុងបទលួចបន្លំសម្បត្តិជាតិ ជាអំពើអាក្រក់ទុច្ចរិត ដែលពាក្យបច្ចុប្បន្នថាអំពើពុករលួយ ។ អ្នកដែលរពឹសដៃ ប្រព្រឹត្តអំពើទុច្ចរិតដូចខាងលើនេះជាដើម ឈ្មោះថា

ជាមនុស្សគ្មានសុជីវធម៌ចំពោះជាតិ ចំពោះមុខក្រសួងខ្លួន ។

## ង - ការមើល មិនគួរពាល់ស្ទាប

- វត្ថុដែលគេដាក់តាំងឱ្យមើល ដូចជាវត្ថុបុរាណក្នុងសារមន្ទីរជាតិ នឹងវត្ថុទំនើបក្នុងមន្ទីរពិព័រណ៌ជាដើម មិនត្រូវយកដៃទៅពាល់ស្ទាបអង្អែល ឬក្តិច ចុច ហែក សង្កត់ ដាក់លើ ឬក៏ទាញរុញឱ្យប្រឡាក់រហែក ឬឱ្យឃ្លាតចាកទីខូចរបៀបរៀបចំរបស់គេ គ្រាន់តែមើលដោយភ្នែកបានហើយ ។ បើសៀវភៅដែលគេដាក់ឱ្យមើលក្នុងបណ្ណាល័យ ឬក្នុងទីនានាមានក្នុងបន្ទប់ទទួលភ្ញៀវជាដើមនោះ ទើបគួរចាប់ពាល់បើកមើលបាន ។ ប៉ុន្តែមិនត្រូវលួចបន្ទំយក ឬក៏ហែកយកត្រង់ទំព័រណាមួយដែលត្រូវការ ។ ជាពិសេស មើលហើយត្រូវដាក់ឱ្យមានរបៀបដូចដើមវិញកុំឱ្យអ្នកថែរក្សាពិបាករៀបដោយសារខ្លួន ។

- ជញ្ជាំងផ្ទះ សសរផ្ទះ ទ្វាបង្អួច តុទូរកៅអី មិនត្រូវយកដៃទៅស្ទាបអង្អែល ឬយកវត្ថុស្មោកគ្រោកដូចសំបោរជាដើម

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **ស៊ សាទី**

ទៅជូត ឬក៏យកអ្វីៗទៅកូតគូរលេងនាំឱ្យខូចលំអ នឹងនាំឱ្យធ្លាប់ដៃឥតរបប ទៅផ្ទះនរណា នាំឱ្យនរនោះរំខានអាក់អន់ចិត្តដោយសារខ្លួន បើឃើញវត្ថុប្លែកគ្រាន់តែមើលបានហើយ ។

- អក្សរសិលាចារិក រូបចម្លាក់ភ្ជាប់នឹងជញ្ជាំង ឬរូបចម្លាក់ជាដុំៗ ដូចរូបតោ - នាគជាដើម ឬក៏រូបគំនូរដោយទឹកថ្នាំ ដូចគំនូរក្នុងថែវព្រះវិហារព្រះកែវមរកតជាដើម មិនត្រូវពាល់ស្ទាបយកឈើដៃកកូត ឬយកកាំបិតពូថៅដុំថ្មជាដើម ទៅសំលៀងទៅកាប់ គោះ កោស គប់លេង ឱ្យបាក់បែក ធ្លែប ធ្លា រលុបសឹក ខូច ប្រក្រតិភាពឡើយ ។

- រថយន្ត នឹងទោចក្រយាន ទោចក្រយានយន្តជាដើមដែលម្ចាស់គេចតទុកក្នុងទីណាមួយ មិនត្រូវយកដៃទៅស្ទាបអង្អែលយកក្រចកទៅចុច កូតកោសលេង ឬឡើងជិះ អង្គុយលមើល ជាដាច់ខាត ព្រោះជាអំពើឥតរបបបំផុត ។

- ដើមផ្កា ឬដើមឈើមានផ្លែ ដែលមានក្នុងភូមិរបស់គេ ឬក្នុងសួនសាធារណៈមិនត្រូវយកដៃទៅពាល់ស្ទាប ក្តិចស្លឹក ចុច

ផ្លែទាញដើមលេង ឬអោនទៅថើបហិតផ្លែផ្កា អាការៈពើសដៃជើងដូចពានរនោះឡើយ ។

- ទៅលេងផ្ទះអ្នកដទៃ បើឃើញនំចំណីផ្លែឈើ ដែលគេរៀបដាក់លើតុតាំងជាដើម មិនត្រូវយកដៃទៅស្ទាបពាល់ ឬចាប់ច្របាច់ថើបមើល ហើយកុំប្រើអាការក្អែកសំឡឹងចំពោះចំណីទាំងនោះញយៗ ដែលនាំឱ្យគេទើសទាល់ខានឱ្យខ្លួនបរិភោគមិនបាន ឬនាំឱ្យគេខ្ពើមដៃខ្លួនដែលទៅប៉ះពាល់នំចំណីគេនោះផង ។

- ក្នុងការិយាល័យនានាដែលខ្លួនមានការចូលទៅ កុំឈរឬអង្គុយយកដៃច្រត់តុ ដែលជាអាការៈឥតការគួរសម នឹងកុំចាប់កាន់វត្ថុអ្វីៗ ដែលមាននៅលើតុ ។ ជាពិសេសមិនត្រូវបើកមើលសៀវភៅ បញ្ជី សារព័តមាន ឬសំបុត្រស្នាមដែលគេដាក់លើតុឡើយ ក្រែងគេដាក់អ្វីៗក្នុងស្រទាប់សៀវភៅជាដើមនោះដែលជាការសម្ងាត់របស់គេ ។

- ព្រះពុទ្ធរូប ឬរូបអនុស្សាវរីយ៍នៃរដ្ឋបុរសដែលជម្កល់ក្នុងទីណាមួយ មិនត្រូវយកដៃទៅស្ទាបពាល់អង្អែលលេងទេ ព្រោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **រស់ សាទី**

នាំឱ្យក្រខ្វក់ផង ជាអាការៈខ្វះសេចក្ដីគោរព ចំពោះវត្ថុវិសេសនោះៗផង ។

ជញ្ជាំង សសរផ្ទះ ទ្វារបង្អួច នឹងតុទូតាំងជាដើម មិនត្រូវយកខ្នងឬដៃជើងទៅជូតទៅជុសរូសឱ្យបាត់រមាស់ឬផ្អែកលេងតម្រង់ខ្នងឱ្យប៉ះពាល់ប្រឡាក់ញើសក្អែលទេ ព្រោះវត្ថុទាំងនេះមិនមែនជាបង្អែកសំរាប់ផ្អែក សំរាប់ជុសរូសឱ្យបាត់រមាស់ ឬសំរាប់ជូតដៃដែលប្រឡាក់នោះឡើយ ។

ប័ណ្ណប្រកាសផ្សាយដំណឹង ឬបទបញ្ញត្តិទាំងឡាយដែលគេសរសេរលើក្ដារខៀន ឬដែលគេបោះពុម្ពលើក្រដាស់យកទៅបិទនៅទីណាមួយ មិនត្រូវយកអ្វីៗគូសកោសលុបហែកលេង ឬហែកយកទៅមើលឯផ្ទះខ្លួនឡើយ ។

## ប . ការនិពន្ធ នឹងសរសេរសំបុត្រ

- ការនិពន្ធគ្រប់បែបយ៉ាងទាំងអស់ មានការនិពន្ធសៀវភៅ-សារព័តមានជាដើម ត្រូវជៀសវាងកុំឱ្យប៉ះពាល់សិទ្ធិ

បុគ្គលណាមួយ ។

-ចំពោះការនិពន្ធប្រលោមលោក នឹងរឿងល្ខោនជាដើម កុំនិពន្ធតាមលំនាំបរទេស ដែលមានលក្ខណៈខុះសីលធ៌មខុសពីលក្ខណៈជាតិយើង ដូចជារឿងផ្នែកស្នេហា គោរពមាតាបិតា គោរពសាសនា នឹងគោរពព្រះមហាក្សត្រជាដើម ។ គប្បីនិពន្ធឱ្យស្របតាមទម្លាប់ទំនៀមជាតិរបស់ខ្លួនពិត ៗ ។

-ការនិពន្ធគ្រប់យ៉ាងទាំងអស់ បើមានដកស្រង់យកអត្ថបទពីក្បួនច្បាប់ណាមួយ គួរធ្វើន័យលក្ខណៈប្រាប់ឈ្មោះក្បួនប្រាប់ឈ្មោះសៀវភៅនោះៗ នឹងឈ្មោះអ្នកនិពន្ធផង។ បើមិនចង់ប្រាប់ឈ្មោះអ្នកនិពន្ធទេ ក៏គប្បីប្រាប់ឈ្មោះក្បួនច្បាប់ឈ្មោះសៀវភៅជាចាំបាច់ កុំធ្វើអាការៈដូចជាលួចនិពន្ធ ។ ជាពិសេស បើដំណើរអត្ថបទយើង មានការទាក់ទងដល់អត្ថបទក្នុងសៀវភៅណាមួយ ដែលគេបាននិពន្ធបោះផ្សាយហើយៗ អត្ថបទក្នុងសៀវភៅនោះ ត្រឹមត្រូវស្របតាមគំនិតយើងដែរនោះ មិនបាច់ដកស្រង់យកមកសរសេរទៀតទេ គ្រាន់តែប្រាប់ថាសូមអាន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស សាទី**

សៀវភៅឈ្មោះនេះ របស់អ្នកនិពន្ធ ឈ្មោះនេះចុះ ។ ការធ្វើដូច្នេះជាលក្ខណៈប្រសើរមួយរបស់អ្នកនិពន្ធ អាចដឹកនាំអ្នកអានឱ្យបានអានក្បួនច្បាប់ច្រើន ។ បានក្រេបរសជាតិចុងប៉ាកការច្រើនបែបទៅទៀត ។

-ប៉ុន្តែមានអ្នកនិពន្ធខ្លះយល់ថា ការប្រាប់ឈ្មោះសៀវភៅប្រាប់ឈ្មោះអ្នកនិពន្ធដូច្នេះ នាំឱ្យថោកដល់ខ្លួនថាគ្មានសមត្ថភាពក្នុងការនិពន្ធ ។ ការយល់ដូច្នេះផ្ទុយពីគតិបណ្ឌិត មិនពេញលក្ខណៈជាអ្នកនិពន្ធទេ សូម្បីតែព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ដែលត្រាស់ដឹងឯង ចេះឯងនោះ ក៏ព្រះអង្គប្រកាសថា " ធម៌វិន័យទាំងអស់នោះ តថាគតត្រាសដឹងតាមព្រះពុទ្ធពីបុរាណ " ដែរ ។

- ការនិពន្ធសារពត៌មាន ពិតមែនតែពាក្យថា " នយោបាយ " ប្រកបដោយកលល្បិចច្រើន ប៉ុន្តែមិនត្រូវយកកុហកភូតភរ ឆបោក កាច់មួល និយាយតាមតែគំនិតខ្លួនយល់ តាមតែគេប្រាប់ មិនសំឡឹងមើលហេតុផលឱ្យច្បាស់ ហើយចេះតែសរសេរពិរោះតែម្នាក់ឯង ត្រូវតែម្នាក់ឯងនោះទេគប្បីពិនិត្យរាវ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

រកការពិតឱ្យហ្មត់ចត់ តម្រង់ចុងប៉ាកកាសំដៅទៅរកសុភមង្គល សុខសន្តិភាពយកមកជូនជាតិមាតុប្រទេស នឹងសកលលោក ។

-វៀរជាដាច់ខាតនូវទោសភាព ក្នុងការនិពន្ធទាំងឡាយ មាននិពន្ធសារព័តមានជាដើម ព្រោះបើយើងអ្នកនិពន្ធជាខ្ញុំកញ្ជះគេទៅហើយ សិទ្ធិនិពន្ធគ្រប់យ៉ាង នឹងគតិបណ្ឌិតដែលយើងមានជារបស់ឥតអំពើ មិនអាចនាំចុងប៉ាកកាខ្លួនទៅតាមគំនិតខ្លួនបាន ត្រូវតែនិពន្ធទៅតាមចៅហ្វាយនាយបង្គាប់ ក្លាយខ្លួនទៅជាអ្នកនិពន្ធតក្កតា ឬអ្នកនិពន្ធអាយ៉ង ។

ការសរសេរសំបុត្រស្នាមគ្រប់យ៉ាង សូមមើលរបៀបបែបផែនក្នុងសៀវភៅប្រជុំលិខិតរបស់ឯកឧត្តមមហាមន្ត្រី ញ៉ុក - ថូវ ចុះ, គ្រាន់តែសូមបញ្ជាក់ថា ការសរសេរសំបុត្រគ្រប់យ៉ាង ត្រូវសរសេរតាមសភាវៈពិតទាំងអស់ ដូចជាសរសេរទៅសួរសុខទុក្ខមាតាបិតាជាដើម, កុំក្លែងសរសេរឱ្យលើសឱ្យខ្វះ ទើបមាតាបិតាជាដើមលោកដឹងដំណឹងពិតពីយើងបាន ។ មានជនភាគខ្លះកាលបើត្រូវសរសេរសំបុត្រផ្ញើរទៅបុគ្គលណាមួយ ក៏តាំងនាំចុង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

ប៉ាកកាខ្លួនឱ្យកុហកនៅចំពោះក្មេកខ្លួន ។ ការធ្វើដូច្នេះឈ្មោះថាគ្មានសុជីវធម៌ក្នុងការសរសេរ, ឧទាហរណ៍: ខ្លួនមិនសូវជានឹកមាតាបិតាបងប្អូនប៉ុន្មានទេ តាំងក្មេងសរសេរថា " សព្វថ្ងៃខ្ញុំនឹករលឹកមក ប៉ា - ម៉ាក់ - បង -ប្អូន គ្រប់ដង្ហើមចេញចូល គ្រប់ទិនទិវារាត្រីមិនដែលខាន", ដូចនេះជាការមិនពិតមួយ, គួរសរសេរត្រឹមតែថា" ...នឹកមកប៉ា - ម៉ាក់ - បង - ប្អូន រាល់ពេលវេលា " បានហើយ គឺរាល់ពេលវេលាដែលនឹកនោះឯង ។

- បើមានគេផ្ញើរសំបុត្រមកត្រូវតបវិញខានពុំបាន ។

-ការសរសេរសំបុត្រទៅចៅហ្វាយនាយ ឬគ្រូអាចារ្យដើម្បីសុំច្បាប់ឈប់សំរាកធ្វើការ ឬឈប់សំរាករៀនជាដើម ត្រូវប្រើតែការពិតជាចាំបាច់ កុំក្មេងកុហកឱ្យសោះ ។ មានអ្នកខ្លះខ្ជិលរៀនខ្ជិលធ្វើការ ឬចង់ទៅលេងក្នុងទីផ្សេងៗ ក្នុងថ្ងៃដែលកំពុងធ្វើការ កំពុងរៀន ក៏តាំងក្មេងសរសេរសំបុត្រសុំច្បាប់ថា " សុំឈប់១ថ្ងៃ ឬកន្លះថ្ងៃ ដោយមិនស្រួលខ្លួន ឈឺពោះ ខ្យល់ចាប់ ឈឺក្បាល ឬថាឪពុកម្ដាយបង

ប្អូនមានធុរៈឈឺជាដើម ប៉ុន្តែខ្លួនឥតឈឺគ្មានធុរៈអ្វីទេ ។ ខ្វះហ៊ាន ដល់ទៅកុហកថាឪពុកម្ដាយស្លាប់ក៏សឹងមាន ។ នេះជាលក្ខណៈរបស់បុគ្គលថោកទាប គ្មានសុជីវធ៌មនៅក្នុងខ្លួន ។

## ធ-អំពីគេហស្ថាន

គេហស្ថានជាស្រោមនៃជីវិតមនុស្សគ្រប់រូប ព្រោះតាំងពីកើតដល់ស្លាប់ មនុស្សទាំងឡាយតែងតែអាស្រ័យនៅក្នុងគេហស្ថានជាចាំបាច់ ។

ម្យ៉ាងទៀត គេហស្ថានទាំងឡាយទោះធំដុំក្ដី តូចតាចជាខ្ទមកំសត់ក្ដី ដែលប្រកបដោយរបៀបរៀបចំនឹងគ្មានរបៀប គឺជាយីហោរបស់ជនម្ចាស់ផ្ទះ អ្នកទាំងពួងគេអាចស្គាល់ថាជាមនុស្សមានឋានៈថ្លៃថ្នូរឬថោកទាបយ៉ាងណាៗ បាន ក៏ព្រោះគេហស្ថានជាយីហោបង្ហាញឱ្យគេស្គាល់ ។

ម្យ៉ាងវិញទៀត គេហស្ថានជាអនុស្សាវរីយ៍នៃដួងព្រលឹងជនក្នុងគ្រួសារ នឹងជាសាលាគំរូសំរាប់គ្រួសារ បើមេគ្រួសារចេះ

រៀបចំសមរម្យល្អ សមាជិកគ្រួសារទាំងឡាយ ដល់មានគេហ-ស្ថានរៀងខ្លួនទៅ អាចចម្លងយករបៀបដែលជាទីពេញចិត្ត ជាអនុស្សាវរីយ៍នោះ ទៅរៀបចំគេហស្ថានរបស់ខ្លួនតៗទៅទៀត ។ ដូច្នេះគេហស្ថានទាំងឡាយ ទោះធំក្តី តូចតាចជាខ្ទមកំសត់ក្តី គប្បីរៀបចំឱ្យមានរបៀបជាចាំបាច់៖

-ត្រូវបោសសំអាត ជុសជូតគេហស្ថានជានិច្ចរាល់ថ្ងៃកុំឱ្យមានសមកាមធូលី សំបុកពីងពាងជាដើម ។

-គប្បីបែងចែកក្នុងផ្ទៃគេហស្ថានឱ្យមានកន្លែងដេក, កន្លែងទទួលភ្ញៀវ, កន្លែងបរិភោគអាហារ, កន្លែងចំអិនអាហារ បន្ទប់ទឹក, បង្គន់នឹងកន្លែងទុកដាក់សម្ភារៈប្រើប្រាស ដូចសំពត់អាវជាដើម ឱ្យមានសណ្តាប់ធ្នាប់ មានទីកន្លែងផ្សេងៗគ្នាកុំទុកដាក់ច្របូកច្របល់ ។

- ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវមានព្រះពុទ្ធរូបឬគំនូរព្រះពុទ្ធរូប ដម្កល់នៅកន្លែងវិសេសថ្កុំថ្កើងក្នុងគេហស្ថានរបស់ខ្លួន សំរាប់ធ្វើសក្ការបូជារាល់ថ្ងៃ ឬរាល់ថ្ងៃសីល ។ ជាពិសេស

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **ស៊ សាធី**

គប្បីមានព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬឆាយាលក្ខណ៍របស់ខ្លួន ដាក់តាំងនៅទីដ៏សមគួរក្នុងគេហស្ថាន ។

បើជាខ្ទមកំសត់តូចតាច ដែលមានតែកន្លែងសំរាប់ដេកនោះ ក៏គួរឱ្យមានព្រះពុទ្ធរូប នឹងព្រះឆាយាលក្ខណ៍ដូចខាងលើនេះដាក់នៅទីគួរសម មានទីក្បាលដំណេកជាដើមដែរ ។ ជាការចាំបាច់ ដើម្បីឱ្យខ្ទមកំសត់តូចនោះមានរបៀបល្អ កាលបើក្រោកពីដេកហើយ ត្រូវបត់មូរប្រមូលមុងកន្ទេលខ្នើយ រៀបដាក់ទុកទៅទីកំបាំង កុំពាក់ព្យួរ សារុងខោអាវ កន្ទប រណែងរណោងតាមជញ្ជាំង ហើយត្រូវបោសប្រាសឱ្យស្អាតយកកន្លែងដេកនោះធ្វើជាកន្លែងទទួលភ្ញៀវផង កន្លែងបរិភោគអាហារផង ។ ឯកន្លែងចំអិនអាហារ បន្ទប់ទឹក បង្គន់ គួររកស្លឹក ឬបន្ទះក្តារជាដើម ដែលអាចរកបានបិទបាំងនៅទីដាច់ដោយឡែកពីខ្ទមនោះ កុំដាក់ចង្ក្រានឆ្នាំងពាងក្រឡប្រហុកផ្អក ក្នុងទីជិតក្បាលដំណេក នឹងចុងជើង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាធី**

- ចំពោះគេហស្ថានដែលក្រាលក្តារ ឬឥដ្ឋស៊ីម៉ង់ត៍ ឬក៏ផ្ទាល់នឹងដី មិនត្រូវខាកស្តោះចោលកន្ទុយបារី នឹងកំទេចក្រដាសជាដើម លើកម្រាលនោះៗតាមទម្លាប់ដៃឥតរបប ត្រូវខាកស្តោះចោលទៅក្នុងកន្ថោរឬកន្ត្រកជាដើម ចំពោះកន្ថោរឬកន្ត្រក ដែលបានខាកស្តោះចោលអ្វីៗទៅក្នុងហើយ កុំទុកឱ្យដល់ខ្ជួប ត្រូវប្រញាប់ចាក់ចោលដុសលាងឱ្យស្អាត ។

- រនាំង ឡប់ឡែ រាំងនន កម្រាលតុ កម្រាលពូក នឹងមុខទ្វារបង្អួចផ្ទះ មិនត្រូវយកដៃទៅជូត ឬទាញមកជូតញើសក្អែលមុខមាត់ទេ ។ ជាពិសេសមិនត្រូវយកដៃទទឹក ឬប្រឡាក់អ្វីៗ ទៅជូតសំលៀកបំពាក់ដែលកំពុងស្លៀក ឬទាញជាយសំពត់អាវ ដែលកំពុងស្លៀកពាក់នោះ មកជូតមុខមាត់ មានជូតមាត់កំពុងស៊ីស្លាជាដើម គប្បីឱ្យមានកូនកន្សែង ឬកំណាត់សម្រាប់ជូត ។

- នៅកៀនជញ្ជាំងមិនត្រូវស្តោះទឹកមាត់ ញើសសំបោរ ចោលកន្ទុយបារីកាកស្លា កៀសក្រញមបារី ឬបោះញាត់អ្វីៗ

ទៅក្នុងកៀនជញ្ជាំងនោះ ឱ្យកើតជាសំបុកកណ្តុរកន្ទាតឡើយ គប្បីខ្វេះកកាយ បោសច្រាសឱ្យស្អាតជានិច្ច ។

ផ្ទះដែលសង់ខ្ពស់ពីដី មិនត្រូវស្តោះកាកម្លូទឹកមាត់ កំហាក សំបោរ ចោលកន្ទុយបារី នឹងសំរាមផ្សេងៗ ទៅក្រោមផ្ទះក្រោមខ្ទមទេ ទ្រូវចាក់ជះចោលឱ្យឆ្ងាយ ។ ជាពិសេស កំចាក់ទឹកបាយសម្ល ទឹកលាងចានឆ្នាំង ទៅក្រោមផ្ទះក្រោមខ្ទម ដែលនាំឱ្យកើតភក់ជ្រាំស្អុយអាសោចិ៍ ។

ក្រោមផ្ទះក្រោមខ្ទម ត្រូវបោសឱ្យស្អាត ។ បើមាន គោក្របីកំដាក់ពីក្រោម គួរធ្វើរោងដាក់ដោយឡែក ។ បើមិនអាច ធ្វើដូច្នេះបានទេ ព្រឹកឡើងដឹកគោក្របីចេញ ត្រូវកើបកោយ ប្រមូលឱ្យស្អាតកុំឱ្យមានក្លិនអាក្រក់ ។

- បើមានចិញ្ចឹមជ្រូកមាន់ទា ត្រូវធ្វើទ្រុងដាក់ដោយឡែក ពីផ្ទះពីខ្ទម កុំយកទៅចិញ្ចឹមពីក្រោម ហើយមិនថែទាំបោសជុះ លាង បណ្តោយឱ្យមានក្លិនស្អុយកើតភក់ជ្រាំគ្រខ្វក់ពេញក្រោម ក្រោមផ្ទះក្រោមខ្ទមគ្មានអនាម័យ ។

- អ្នកដែលមានគេហស្ថានសង់ក្នុងដីឡូត៍មួយៗ មានសល់ដីនៅជុំវិញល្មមដាំដំណាំបាន មិនត្រូវដាំដំណាំជិតកិបនឹងរបងពេកទេ យ៉ាងជិតណាស់ក៏ឱ្យឃ្លាត១ម៉ែត្រពីរបងដែរ ដើម្បីកុំឱ្យមែកធាងដំណាំលយចូលទៅក្នុងដីគេ ។ បើមានមែកធាងដំណាំលយចូលទៅដីគេហើយត្រូវកាត់កាប់ត្រឹមរបងខ្លួន ។ម្យ៉ាងទៀតបើម្ចាស់ដំណាំនោះមិនបានកាត់កាប់ ហើយយើងចង់កាត់កាប់ ត្រូវមានការគួរសមប្រាប់ដល់ម្ចាស់ដំណាំសិន ឱ្យគេយល់ហេតុផលដែលយើងចង់កាប់ ។ ការធ្វើដូច្នេះ ដើម្បីរក្សាវិស្សាសភាពរវាងអ្នកនៅជិតខាងគ្នា ។

- មិនត្រូវយកសំរាម ឬវត្ថុស្មោកគ្រោកដែលមានក្លិនស្អុយជាដើម ទៅដាក់ជិតរបងឡើយ ដើម្បីការពារកុំឱ្យក្លិនអសោចិ៍បក់ផ្សាយទៅនាំឱ្យរំខានខូចសុខភាពដល់អ្នកនៅផ្ទះជិតខាង ។

- នៅទីធ្លាក្រៅរបងមុខផ្ទះ ឬជុំវិញផ្ទះមិនត្រូវបោសសំអាមពីមុខផ្ទះខ្លួនទៅចោលមុខផ្ទះគេ ឬយកវត្ថុអ្វីៗមានសំរាមជាដើមនោះទៅចោលក្នុងដីភូមិគេទេ ។

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **ស៊ សាទី**

- អ្នកនៅផ្ទះល្វែងក្នុងទីក្រុង បើមានរថយន្ត ឬទោចក្រយាន ទោចក្រយានយន្តជាដើម មិនត្រូវចត ឬដាក់នៅចំពីមុខផ្ទះគេ ។ ត្រូវតែទៅឈប់មួយកន្លែងៗ ដោយត្រូវការចូលទៅប្រាស្រ័យទាក់ទងជាមួយអ្នកផ្ទះនោះ ។

-ការហាលគ្រឿងស្លៀកពាក់ប្រើប្រាសទាំងឡាយ មានខោអាវ សារុង មុង ភួយជាដើមមិនគួរធ្វើស្នូហាលចំពីមុខផ្ទះ ឬពាក់ហាលលើបង្កាន់ដៃផ្ទះ នឹងលើមេទ្វាបង្អួចជាដើម ត្រូវហាលនៅទីកំបាំងភ្នែកមហាជន ។

- បង្គន់នឹងបន្ទប់ទឹក រោងបាយ មិនគួរធ្វើនៅទីមុខផ្ទះ ឬធ្វើឱ្យកៀកជិតជាប់នៅនឹងរបងទេ កុំឱ្យផ្ទះអ្នកជិតខាងគេរំខាន ដោយសាខ្ទួននឹងឱ្យមានបរិយាកាសមុខផ្ទះស្រឡះស្អាតស្អំល្អ ។

- មនុស្សគ្រប់រូបបើមានផ្ទះដេកនៅ ត្រូវតែមានបង្គន់ បន្ទប់ទឹក រោងដាំបាយ ជាចាំបាច់ ទោះតូចក្ដីធំក្ដី បើគ្មានដំបូលក៏ត្រូវឱ្យមានជញ្ជាំងបិទបាំងដែរ កុំឱ្យបន្ទោបង់មូត្រលាមកដោយគុម្ពឈើ គុម្ពស្មៅ ដែលមានអាការដូចសត្វតិរច្ឆាន នឹងមិន

ត្រូវផ្ងូតទឹកកណ្តាលទីវាល ឱ្យអ្នកផងគេឃើញអាការមិនគួរគប្បី ទាំងមិនត្រូវដាំស្ងួកណ្តាលវាលឱ្យគេឃើញចង្ក្រានផ្ទាំង ។ ការដាំស្ងនោះ វៀរតែក្នុងពិធីបុណ្យទាន ។

- ការបរិភោគអាហារ មិនគួរបរិភោគកណ្តាលវាល ឬចំទ្វារផ្ទះ ឬក៏លើគ្រែមុខផ្ទះ ឱ្យអ្នកផងដែលធ្វើដំណើរទៅមកឃើញឡើយ ។ វៀរតែក្នុងពិធីបុណ្យទាន ។

- ទីជុំវិញគេហស្ថាន ត្រូវជម្រះស្មៅបោសប្រាសរៀបចំឱ្យស្អាត កុំដាក់វត្ថុអ្វីៗគររាត់រាយគ្មានសណ្តាប់ធ្នាប់ ។ ជាពិសេសគួរដាំសួនផ្កានៅមុខគេហស្ថានជាគ្រឿងលំអផង ។

- គេហស្ថានសាងសង់នៅទីណា ត្រូវធ្វើរបងព័ទ្ធជុំវិញទីនោះ យ៉ាងហោចណាស់ក៏ធ្វើពីឫស្សី ឬកូនឈើដែរ កុំឱ្យមានតែផ្ទះអាក្រាតទទេនៅកណ្តាលវាល ដូចខ្ទមអ្នកតា ។ បើមានដាំកូនឈើធ្វើរបងដូចកូនអំពិលទឹកជាដើម ត្រូវឧស្សាហ៍កាត់ឱ្យបានសមរម្យល្អ កុំឱ្យដុះទ្រុបទ្រុលដូចព្រៃស្មសាន ឬឱ្យដុះគ្របសង្កត់ដំណាំអ្នកនៅជាប់នឹងដីភូមិខ្លួន នាំឱ្យគេរំខានចិត្ត ។

# ជ-គោរពអ្នកមានជម្ងឺ និងផ្ទះពេទ្យ

ក្នុងគ្រួសារមួយ ៗ តែងមានមាតាបិតាជីដូនជីតាជាដើម, បើជនណាមួយមានជម្ងឺហើយ អ្នកឯទៀតត្រូវយកចិត្តទុកដាក់ជួយមើលថែទាំរក្សាដោយថ្នាក់ថ្នមប្រុងប្រយ័ត្នៈ

- ឧស្សាហ៍សាកសួរ គក់ប្រាប់បំរើបាយទឹកនំចំណី នឹងថ្នាំកែពេគផ្សេងៗ កុំឱ្យអ្នកជម្ងឺពិបាកហៅរក ។
- ត្រូវមានពាក្យសំដីល្អសុភាពទន់ភ្លន់គួរជាចាប់ចិត្តរបស់អ្នកមានជម្ងឺ ។
- មិនត្រូវឈ្លោះប្រកែកជជែកគ្នា ឱ្យអ្នកជម្ងឺដឹងឮ នាំឱ្យខ្វល់ពិបាកចិត្ត រឹតតែមានជម្ងឺខ្លាំងថែមទៀត ។
- មិនត្រូវនិយាយខ្លាំងៗឡូឡា ជេរស្តីបន្ទោសកូនចៅក្នុងទីចំពោះមុខអ្នកជម្ងឺ ។
- ត្រូវដើរថ្នមៗជើង កុំដើរខ្លាំងអស់ទំហឹង នាំឱ្យកក្រើករញ្ជួយដល់អ្នកមានជម្ងឺ ។

- ចំណីអាហារណាដែលអ្នកជម្ងឺត្រូវតម កុំយកទៅជិតឱ្យអ្នកជម្ងឺឃើញ នាំឱ្យមានចំណង់ក្រែងតមមិនបាន ។

- កុំបោសច្រាសជជុះរលាស់របស់អ្វីខ្លាំង ។ ឱ្យហុយធូលីទៅលើអ្នកជម្ងឺ ។

- ត្រូវប្រើមធ្យោបាយដោយពាក្យសំដី គឺឧស្សាហ៍និយាយពីរឿងរ៉ាវផ្សេង ៗ ដែលជាទីត្រេកអររីករាយនៃអ្នកមានជម្ងឺ ។

- កុំនាំរឿងរ៉ាវណាដែលជាទំនាស់ចិត្តអ្នកជម្ងឺ ឬនិយាយឱ្យអ្នកជម្ងឺភ័យតក់ស្លុត ។

- កុំបញ្ចេញអាការៈភិតភ័យរបស់ខ្លួន ឱ្យអ្នកជម្ងឺពិបាកចិត្ត ឬភិតភ័យតាមខ្លួន ។

- បើមានភ្ញៀវមកសួរ ត្រូវឆាប់ចេញទៅទទួលប្រាប់ឱ្យភ្ញៀវបានដឹងជាមុនអំពីត្រណមផ្សេងៗ ដែលនាំរំខានដល់អ្នកមានជម្ងឺ ។

- បើភ្ញៀវមករកកិច្ចការអ្វីផ្សេងៗ ត្រូវនាំឱ្យឆ្ងាយពីអ្នកជម្ងឺ កុំឱ្យអ្នកជម្ងឺរំខានដោយសារភ្ញៀវនោះ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

- ពេលយប់កុំចោលអ្នកជម្ងឺឱ្យនៅតែម្នាក់ឯង ហើយខ្លួននាំគ្នាដេកលក់អស់ គួរឲ្យមានគ្នាយាមថែរក្សាអ្នកជានិច្ចជាកាល ។

- អ្នកនៅផ្ទះជិតខាង បើដឹងថាផ្ទះក្បែរខ្លួនមានមនុស្សឈឺហើយ មិនត្រូវស្រែកឡូឡា ឬធ្វើអ្វី ៗ ដែលមានសូរស័ព្ទនាំឱ្យរំខានដល់អ្នកជម្ងឺឡើយ ។ ជាពិសេសមិនគួរស៊ីផឹកជប់លៀងមានភ្លេងភ្ញាត់ហ៊ោកញ្ជ្រៀវ ដូចជាធ្វើមង្គលការជាដើមទេ គួរបង្អង់ខានសិន ដើម្បីគោរពដល់អ្នកជម្ងឺ ។

- នៅក្នុងផ្ទះពេទ្យ បើយើងចូលទៅសួរញាតិមិត្រណាមួយដែលមានជម្ងឺ មិនត្រូវនិយាយឡូឡាខ្លាំងៗឬយកអ្វីៗដែលជាទំនាស់ដល់ច្បាប់ពេទ្យទៅជាមួយផងទេ ។

- កុំនៅនិយាយប៉ប៉ាច់ប៉ប៉ោចយូរពេក ឆាប់លាត្រឡប់វិញកុំឱ្យអ្នកជម្ងឺដែលយើងទៅសួរ ឬអ្នកជម្ងឺឯទៀត ធុញទ្រាន់ដោយសារខ្លួន ។

- កុំនាំរឿងផ្តេសផ្តាសទៅនិយាយក្នុងផ្ទះពេទ្យ ដែលនាំឱ្យអ្នកជម្ងឺកើតក្តៅក្រហាយ ឬភ័យតក់ស្លុត ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

- ឯគិលានុប្បដ្ឋាក គិលានុប្បដ្ឋាយិកា នឹងកម្មករពេទ្យជាដើម ត្រូវមានចរិយានឹងកាយវិការ សុភាពរាបសា គួរសមថ្នាក់ថ្នមជាចាំបាច់តាមច្បាប់ពេទ្យ ចំពោះអ្នកជម្ងឺ ។

- មិនត្រូវធ្មៀតធ្វើស្រែលើខ្នងអ្នកជម្ងឺ គឺកុំប្រើអាការៈផ្ទេសផ្តាសឱ្យគេស្លុកប៉ាន់ ទើបខ្នួនយកចិត្តទុកដាក់ថ្នាក់ថ្នមនោះឡើយ។

- ចំពោះអ្នកធ្វើដំណើរ ដោយរថយន្ត ឬដើរជាដើម បើទៅជិតផ្ទះពេទ្យហើយ ត្រូវថ្នាក់ថ្នមកុំឱ្យឮសូរខ្លាំង កុំជជែកគ្នាឡូឡាឱ្យភ្ញាក់ផ្អើលរំខានដល់អ្នកជម្ងឺ។

## ឈ-ចេះស្គាល់បាបស្គាល់បុណ្យ

ការស្គាល់បាបបុណ្យនេះជាលក្ខណៈខ្ពង់ខ្ពស់សុជីវធម៌ ។ អ្នកមានសុជីវធម៌ខ្ពង់ខ្ពស់នេះ អាចសាងអាត្មនឱ្យខ្ពង់ខ្ពស់បានច្រើនដំណាវជីវិត ហើយជាទីស្រឡាញ់រាប់អាននៃមហាជនគ្រប់ប្រភេទ។

ពាក្យថាស្គាល់បាបបុណ្យនេះ ជាគ្រាមភាសា ខ្មែរយើងតែង ប្រើក្នុងការសរសើរ នឹងការត្មះតិះដៀលចំពើមនុស្សដែលមាន កិរិយាមារយាទល្អនឹងអាក្រក់ថា « អ្នកនេះនាងនេះ ជាមនុស្សល្អ ស្គាល់បាបបុណ្យ, អានេះមេនេះ ជាមនុស្សអាក្រក់មិនស្គាល់ បាបបុណ្យ » ។

ដូច្នេះអ្នកសុជីវធម៌ទាំងឡាយ ត្រូវតែស្គាល់បាបបុណ្យឱ្យ ច្បាស់លាស់ក្នុងគំនិត ហើយគប្បីលះបង់នឹងប្រព្រឹត្តធ្វើទៅតាម ការស្គាល់នោះ ។

អំពើណាដែលប្រព្រឹត្តធ្វើទៅហើយ នាំឱ្យកើតទុក្ខពោគភ័យ ដល់ខ្លួននឹងដល់អ្នកដទៃ អំពើនោះហៅថាបាប - អកុសល - ទុច្ចរិត - អយុត្តិធម៌ - អំពើពុករលួយ ។ អំពើទាំងអស់នេះត្រូវលះ បង់មិនគប្បីប្រព្រឹត្តធ្វើះ

- មិនត្រូវធ្វើបំពារបំពានច្បាប់ទំលាប់ នឹងកាច់មួលអ្នកធ្វើ ត្រូវឱ្យខុស អ្នកធ្វើខុសឱ្យត្រូវ ព្រោះលំអៀងដោយសេចក្ដី ស្រឡាញ់គាប់ចិត្ត ត្បិតបានសំណូកជាដើម, ព្រោះលំអៀង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី ស៊ សាទី

ដោយសេចក្ដីល្ងង់មិនស្គាល់ខុសត្រូវ នឹងព្រោះលំអៀងដោយសេចក្ដីខ្លាច មានខ្លាចបុណ្យស័ក្តិទ្រព្យសម្បត្តិគេជាដើម ។

- មិនត្រូវប្រព្រឹត្តអបាយមុខ មានលេងល្បែងភ្នាល់បៀប៉ោជាដើម ឌេលច្បាប់រួបានហាមឃាត់ ។

- មិនត្រូវសម្លាប់ផ្ដាច់បង់ជីវិតអ្នកដទៃ ព្រោះតែចង់រស់ចង់រស់ដូចខ្លួនដែរ, គប្បីយល់ថា បើខ្លួនយើងខ្លាចស្លាប់ អ្នកដ៏ទៃក៏ខ្លាចស្លាប់ដូចខ្លួនដែរ ។

- មិនត្រូវលួចឆក់បំបាត់កេងកិបទ្រព្យរបស់អ្នកដទៃ ព្រោះគេចង់មានដូចខ្លួនដែរ, គប្បីយល់ថាបើគេលួចឆក់បំបាត់កេងកិបទ្រព្យរបស់ខ្លួនវិញ តើខ្លួនកើតទុក្ខសោកស្ដាយយ៉ាងណា ។

- មិនត្រូវលួចប្រព្រឹត្តមេថុននឹងកូនប្រពន្ធអ្នកដទៃ ព្រោះគេស្រឡាញ់ប្រពន្ធកូនគេដូចខ្លួនដែរ, គប្បីយល់ថាបើមានអ្នកដទៃមកលួចប្រពន្ធកូនយើងវិញ តើយើងក្ដៅក្រហាយឈឺចិត្តអាម៉ាស់មុខយ៉ាងណា។

- មិនត្រូវនិយាយកុហកក្រឡិចក្រឡុចបោកប្រាស ឱ្យគេ

ខូចប្រយោជន៍ ខូចកិត្តិយសវិនាសអន្តរាយ ដោយពាក្យសំដីមិនពិតរបស់ខ្លួន, គប្បីយល់ថា បើគេនិយាយកុហកបោកប្រាស ឱ្យយើងខូចប្រយោជន៍ វិនាសអន្តរាយវិញ តើយើងក្តៅក្រហាយកើតទុក្ខឈឺចិត្តដែរឬទេ ។

- មិនត្រូវនិយាយញុះញង់ បំបែកបំបាក់ចាក់រុកដោយអាការណាមួយដែលនាំឱ្យវិនាសអន្តរាយ បែកបាក់សាមគ្គី ទាស់ទែងខ្វែងគំនិតគ្នាដោយសារខ្លួន, គប្បីយល់ថា បើគេញុះញង់យើងដូច្នោះវិញ តើយើងក្តៅក្រហាយកើតទុក្ខខ្លោចផ្សាយ៉ាងណា ។

- មិនត្រូវប្រើពាក្យទ្រគោះអាក្រក់ មានជេរបញ្ចោរប្រទេចផ្តាសសា គំហកកំហែង ចំពោះអ្នកដទៃឱ្យគេភ័យតក់ស្លុត អាម៉ាសមុខអៀនខ្មាស់ខូចកិត្តិយសដោយសារខ្លួន, គប្បីយល់ថា បើអ្នកដទៃ គេប្រើពាក្យអាក្រក់ដូច្នោះចំពោះខ្លួនវិញ តើខ្លួនក្តៅក្រហាយតក់ស្លុតអាមាស់មុខយ៉ាងណា ។

- មិនត្រូវប្រើពាក្យសំដីពេយរាយ របិញរបុញរឡឹករឡក់ឥត

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី សេង សាទី

ប្រយោជន៍ ដែលនាំឱ្យខាតពេលវេលា នឹងថោកទាបខូចកិត្តិយសឱ្យគេមើលងាយដល់ខ្លួន។

- មិនត្រូវប្រើគំនិតរំលោភ សំឡឹងរំពៃចំពោះទ្រព្យសម្បត្តិអ្នកដទៃ ដែលជាប្រភពនៃអំពើទុច្ចរិតអាចនាំកាយវាចាឱ្យហ៊ានកុហកឆបោកកាប់សម្លាប់លួចប្លន់ប្រព្រឹត្តអំពើពុករលួយ មានស៊ីសំណូកជាដើម ឥតមានសេចក្ដីអៀនខ្មាស់ ។

- មិនត្រូវមានចិត្តព្យាបាទ ចងគំនុំគុំគួនអ្នកដទៃដែលជាហេតុឱ្យហ៊ានប្រព្រឹត្តអំពើអាក្រក់ ឧក្រិដ្ឋគ្រប់ជំពូកយ៉ាងក្លាហានឥតតក់ស្លុត ។

- មិនត្រូវប្រកាន់គំនិតឆ្វេង យល់ខុសពីសការពិត ឃ្លាងពីច្បាប់ធម្មជាតិ ដែលបណ្ដាលឱ្យធ្វើអ្វីចេះតែឈ្វេយខុសអ្នកដទៃ ឃ្លាតឆ្ងាយពីគតិបណ្ឌិត ខូចខាតផលប្រយោជន៍ខ្លួន នឹងប្រយោជន៍អ្នកដទៃគ្រប់យ៉ាង ។

ក្នុងពាក្យថាចេះស្គាល់បាបស្គាល់បុណ្យដូចបរិយាយមកនេះ បើតាមទ្រឹស្ដីពុទ្ធសាសនាថា ចេះកាន់រក្សាតាមនូវបញ្ចសីលា

គឺសីល៥ កម្មបទ១០ មិនលំអៀងដោយអគតិទាំង ៤ នឹងមិនប្រព្រឹត្តអបាយមុខ ។

អត្ថបទដូចនាំមកបរិយាយជាគោលៗនេះ ជាវត្ថុបទទី ១ នៃសុជីវធម៌ គឺការស្គាល់ហេតុផលគួរមិនគួរ ឬជាការស្គាល់ហេតុផលនៃសេចក្ដីសុខ នឹងទុក្ខក៏បាន ។

ក្នុងវត្ថុបទទី១នេះ បើបំព្រួញឱ្យខ្លីថា « ហេតុដែលនាំឱ្យកើតទុក្ខថោកទាបត្រូវលះបង់កុំធ្វើ, ហេតុដែលនាំឱ្យកើតសុខចំរើនថ្លៃថ្នូរត្រូវប្រព្រឹត្តធ្វើ » ។

បានជារៀបរៀងដាក់ការស្គាល់ហេតុផលនេះ ជាវត្ថុបទទី ១ នៃសុជីវធម៌ដូច្នេះ ព្រោះមនុស្សគ្រប់រូបត្រូវតែស្គាល់ហេតុផលខុសត្រូវល្អអាក្រក់ជាចាំបាច់ខានមិនបាន ទើបស្ថិតក្នុងឋានៈជាមនុស្សកើត បើមិនស្គាល់ទេមិនប្លែកអ្វីពីសត្វតិរច្ឆានឡើយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

# វគ្គបទទី២

# ការស្គាល់ឋានៈខ្លួន និងអ្នកដទៃ

ដើម្បីរស់នៅឱ្យបានសុខស្រួលក្នុងពិភពលោក ដែលកម្ម នឹងធម្មជាតិ បានបង្កើតមនុស្សមក ឱ្យមានឋានៈមិនស្មើគ្នានោះ មនុស្សម្នាក់ៗត្រូវតែស្គាល់ឋានៈខ្លួន នឹងឋានៈអ្នកដទៃឱ្យច្បាស់ ហើយញ៉ាំងដំណើរជីវិត ឱ្យប្រព្រឹត្តទៅតាមទំហំឋានៈរៀងៗខ្លួន ទើបមានសមត្ថភាពអាចទាក់ទងរួបរួមគ្នាបាន មិនប៉ះទង្គិចថ្នាំងថ្នាក់បែកបាក់គ្នា ។

ពាក្យថាស្គាល់ឋានៈ គឺស្គាល់ជាតិ-ត្រកូល-វ័យ-យស-ស័ក្តិ-សម្បត្តិ នឹងសមត្ថភាពសេចក្តីចេះដឹងរបស់ខ្លួន នឹងអ្នកដទៃដូចតទៅនេះ។

## ក-មាតាបិតា និង បុត្រធីតា

បុគ្គលពីរជំពូកនេះ ត្រូវស្គាល់ឋានៈរៀងខ្លួនថា អញជាមាតាបិតា, អញជាបុត្រធីតា ហើយចេះគោរពគួរសមសង្គ្រោះទំនុកបំរុង មានសុជីវធម៌ចំពោះគ្នាទៅវិញទៅមកតាមឋានៈ៖

- មាតាបិតា ត្រូវចេះសង្គ្រោះប្រៀនប្រដៅកូនឱ្យសមតាមឋានៈខ្លួន ត្រូវហាមប្រាមកុំឱ្យធ្វើអាក្រក់ មានលួចប្លន់ ឆបោក កាប់សម្លាប់ កុហកកូតករអ្នកដទៃជាដើម ។

កូនដែលមានបែបបទល្អ ដោយតាមពាក្យប្រៀនប្រដៅទាំងនេះបាន លុះតែមាតាបិតាបានទម្លាប់វាតាំងពីតូច ៗ មកគឺ បើមានចំណីអាហារ ឬវត្ថុអ្វីដែលវាចង់បាន ត្រូវតែលៃលកឱ្យវាខ្លះ ៗ បើមិនគួរឱ្យវាទេ កុំលាក់ទុកឱ្យវាស្គាល់ទីកន្លែងលួចវាលួចបាន, កាលបើមាតាបិតាបង្អត់ឱ្យវាឃ្លានជ្រុល ឱ្យវាចង់បានខ្លាំង ហើយវាស្គាល់ទីកន្លែងដែលលាក់ទុកនោះ វាមុខតែប្រថុយលួចជាមិនខាន បើលួចបានម្តងហើយ ក្រោយលួចទៀត, ដល់ធំថ្មីកក្នុងការលួច ហ៊ានលួចប្លន់អ្នកដទៃ រហូតដល់លួចប្លន់ទ្រព្យសម្បត្តិជាតិ ។ ជាពិសេសចំពោះមាតាខ្លះ ច្រើនតែស៊ុមគ្រលុំនឹងកូន លួចលាក់លុយកាក់ឱ្យទៅកូនចាយមិនឱ្យស្វាមីដឹង ដោយស្រឡាញ់កូនជ្រុល ក្រែងកូនចាយមិនគ្រប់គ្រាន់ ។ នេះជាលក្ខណៈអាក្រក់មួយ ដែលនាំឱ្យកូនចេះចាយធំផង មានចិត្ត

មិនស្មោះត្រង់ចេះលាក់ការណ៍កំបាំង ចំពោះជនក្នុងគ្រួសារផង ។ កាលបើធ្វើយ៉ាងនេះយូរៗទៅ ពេលខ្វះចាយវាហ៊ានខ្ចីលុយកាក់គេ ដោយអាងទារពីម្ដាយបាន, ដល់ពេលក្រោយមកទៀតម្ដាយលួចលាក់ឱ្យចាយមិនទាន់ចិត្ត វាក៏ហ៊ានលួចម៉ែឪឯងនឹងអ្នកដទៃយ៉ាងស្និទ្ធ ។

អំពីការសម្លាប់ទៀតក៏ដូចគ្នា មាតាបិតាមិនគួរកាប់សម្លាប់សត្វជាដើម ក្នុងទីចំពោះកូនតូចៗទេ ដូចជាវាយសម្លាប់ស្រមោចមូសរុយសង្កើចចៃជាដើម ។ បើកូនចេះសម្លាប់តាមត្រូវហាមឃាត់វា ឱ្យវាមានចិត្តភ័យខ្លាចតក់ស្លុត ក្នុងការសម្លាប់, ទោះបីមាតាបិតា មិនមែនជាឧបាសកឧបាសិកាក៏ដោយ គួរតែប្រដៅបែបនេះទើបល្អ ព្រោះបើបណ្ដោយឱ្យសម្លាប់ ឬក៏ខំប្រដៅវាឱ្យសម្លាប់ ហើយត្រេកអរសរសើរវា ក្នុងការសម្លាប់នោះទៀត, ដល់ធំឡើង វាឥតញញើតដៃក្នុងការកាប់សម្លាប់នោះទេ ឱ្យតែនរណាធ្វើឱ្យខឹង វាទាស់ចិត្ត មានដណ្ដើមស្រីគ្នាជាដើម វាដាច់ខាតជាហ៊ានចាក់កាប់សម្លាប់ រហូតដល់ខ្លួនជាមាតាបិតាវា

នោះទៀត បើខឹងដល់ចិត្តវាហើយ ក៏វាហ៊ានសម្លាប់ដែរ។

អំពីការកុហកកូតករទៀតក៏ដូចគ្នា, មាតាបិតាត្រូវអប់រំកូនពីនៅតូចៗ មិនគប្បីកុហកកូតករកូនលេង ឬកុហកឱ្យបាត់យំថាឆ្មាអោងខាំ ខ្លាចមៀមទីទុយជាដើម ឬកុហកថាកុំយំចាំស្អែកទិញនំឱ្យញ៉ាំ ទិញរបស់នេះនោះឱ្យលេង ឬក៏យករបស់អ្វីមួយដែលវាពេញចិត្តទៅលាក់ ហើយកុហកវាថាបាត់ដើម្បីសើចលេង ដល់បន្តិចបង្ហាញវាវិញ ។ កាលបើមាតាបិតាកុហកកូតករយ៉ាងនេះញយៗទៅ វាក៏ចេះធ្វើត្រាប់តាម បណ្តាលឱ្យខូចមនោគតិដ៏ល្អពីកំណើតវា ក្លាយទៅជាមនុស្សខ្លាចញ៉ាក មិនអង់អាច ការមិនពិតក៏ហ៊ានថាពិត ព្រោះខ្លាចញ៉ាក ចេះតែនិយាយផ្តេសផ្តាសគ្មានការពិតនៅក្នុងខ្លួន ហ៊ានកុហកកូតករតាំងម៉ែឪឯង រហូតដល់អ្នកដទៃឥតញញើតមាត់ ។

- ត្រូវសង្គ្រោះប្រៀនប្រដៅកូន ឱ្យមានកល្យាណធម៌នៅក្នុងខ្លួន មានចិត្តមេត្តាករុណាចំពោះសមណព្រាហ្មណ៍នឹងមនុស្សកំសត់ទុគ៌ត ចេះគួរសមចែករំលែកធ្វើទាន កុំឱ្យមានអត្តទត្ត-

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ភាពដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ចង់រស់តែម្នាក់ឯង នឹងអប់រំកូនឱ្យមានកតញ្ញូកតវេទិតាធម៌ ចំពោះអ្នកមានគុណ ។

ដើម្បីអប់រំកូនឱ្យមានសណ្ដាប់ធ្នាប់ល្អ ប្រសើរដូច្នេះបាន មាតាបិតាត្រូវធ្វើខ្លួនឱ្យជាគំរូដល់កូន តាំងពីនៅតូចៗឱ្យវាឃើញជាក់ច្បាស់នឹងភ្នែក កុំប្រៀនប្រដៅវាតែមាត់ គ្មានគំរូជាកសត្តុតាង ព្រោះថា បើមាតាបិតាជាមនុស្សកំណាញ់ មិនដែលធ្វើបុណ្យទាន ចែករំលែកឱ្យសុខដល់អ្នកដទៃ គ្មានកតញ្ញូកតវេទិតាធម៌ គោរពក្រាបសំពះថ្វាយបង្គំ ទំនុកបំរុងបំរើផ្គត់ផ្គង់ មាតាបិតា គ្រូអាចារ្យខ្លួន នឹងគ្មានពាក្យសំដីល្អ ប្រើតែពាក្យគំរោះគំរើយអញ ឯង មេ ហ្វង ឡូឡា ជេរបញ្ចោរនោះ បុត្រធីតាដែលវារស់នៅជាមួយ វាបានឃើញជាក់នឹងភ្នែក ឮច្បាស់នឹងត្រចៀក រាល់ៗថ្ងៃ ដល់ធំឡើង វាក៏ធ្វើតាមតែគំរូដែលវាបានផ្ដិតទុកក្នុងខួរក្បាល ជាយូរឆ្នាំហើយនោះឯង គឺវាកើតប្រាកដជាមនុស្សឆ្មើង

ផ្ទៃ មានពាក្យសំដីអាក្រក់ព្រហើនគ្មានគួរសម កំណាញ់ស្វិតស្វាញគិតតែប្រយោជន៍ផ្ទាល់ខ្លួន គ្មានដឹងគុណម៉ែឪ ដូចជាម៉ែឪវា ដែលមិនដឹងគុណជីដូនជីតាវាដូច្នោះដែរ ។ ដល់មកត្រង់ចំណុចនេះម៉ែឪខកចិត្ត តែងតែលើកកំហុសនោះឱ្យកូនទាំស្រុងស្ដីបន្ទោសប្រាប់គេឯងថា ជាកូនអកតញ្ញូ មិនដឹងគុណម៉ែឪដែលបានបង្កើតមក ។

តាមពិតកំហុសនេះគឺ ខ្លួនមាតាបិតានោះឯង ដែលជាមនុស្សគ្មានសុជីវធម៌ មិនចេះអប់រំកូន បានសាងកូនឱ្យកើតជាមនុស្សដូច្នោះ ។ វៀរលែងតែកូនជាអវជាតបុត្រ ដែលខូចបំផុតអាក្រក់ពីកំណើតចេញ ព្រោះកូនបែបនេះ ទោះបីមាតាបិតាជាមនុស្សមានសុជីវធម៌ ខំអប់រំប្រដៅយ៉ាងណា ក៏វាមិនបានបែបបទល្អដូចបំណងដែរ ។

- ត្រូវអប់រំកូន ឱ្យសិក្សារៀនចំណេះវិជ្ជាគ្រប់យ៉ាង ឱ្យបានជាមនុស្សចេះដឹង មានសតិប្រាជ្ញា ស្គាល់ខុសត្រូវល្អ

អាក្រក់ជាដើម ។

ការអប់រំកូន ឱ្យកើតជាមនុស្សចេះដឹងនេះ មិនមែនជាការងាយស្រួល ត្រឹមតែនាំកូនទៅចូលសាលាទុកជាការស្រេចនោះទេ ព្រោះក្នុងសាលា គ្រាន់តែទៅចម្លងមេរៀន ស្ដាប់គ្រូពន្យល់ នឹងសាកល្បងឱ្យដឹងថាសិស្សណាខំរៀនមិនខំប៉ុណ្ណោះ ។ ចំពោះការរៀនឱ្យបានចេះចាំ ឱ្យមានចំណង់ក្នុងការរៀននោះ ជាភារៈមាតាបិតាឯផ្ទះ ដែលយកចិត្តទុកដាក់ជួយសង្គ្រោះណែនាំកូន ។

ដូច្នេះ នៅផ្ទះគប្បីឱ្យមានតុកៅអី បើមិនអាចរកបានទេឱ្យមានតែកន្លែងពិសេសមួយ ដែលមានពន្លឺច្បាស់ល្អ ឱ្យឃ្លាតពីកន្លែងទទួលភ្ញៀវ ហើយរៀបចំឱ្យមានសិក្ខូបករណ៍សព្វគ្រប់ មានសៀវភៅសរសេរ សៀវភៅមើល ដងប៉ាកកា ទឹកខ្មៅ ក្ដារខៀន ដីសជាដើម នឹងត្រូវកំណត់ពេលរៀន ពេលដេក ពេលលេងរបស់កូនឱ្យទៀងទាត់ បើកូនមិនយល់ត្រូវពន្យល់ជួយណែនាំឱ្យបានយល់ច្បាស់គ្រប់មុខវិជ្ជាដែលកូនរៀន ។ ជាពិសេស បើយើងជាមាតាបិតាមិនចេះ ឬមានរវល់ច្រើនមិនអាច

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី សស់ សាទី

ផ្ទៀតពេលជួយបង្រៀនកូនបាន គប្បីពឹងពាក់អ្នកដទៃដែលចេះដឹង ឱ្យគេជួយបង្រៀន ។ បើជាអ្នកមានទ្រព្យអាចជួលគេបាន ត្រូវតែជួលបង្រៀននៅផ្ទះថែមទៀត នៅពេលយប់ ឬពេលណាដែលកូនមិនបានទៅសាលា ។

ដល់កូនធំ មាតាបិតាត្រូវរៀបចំឱ្យមានស្វាមីភរិយាដើម្បីរក្សាប្រពៃណីវង្សត្រកូលឱ្យបានល្អតទៅមុខទៀត ។

ការរើសរកគូស្រករឱ្យកូនប្រុសស្រីនេះ ជាបញ្ហាស្មុកស្មាញណាស់ ។ បើតាមបុរាណនិយម គេរើសមើលពូជអំបូរវង្សត្រកូលធនធាន នឹងចរិយាមារយាទ លៃឱ្យមានតុល្យភាពស្មើគ្នា ឬប្រហាក់ប្រហែលគ្នាទើបគួរឱ្យ ឬគួរទៅស្ដីដណ្ដឹងយកមកធ្វើកូនប្រសា, ត្រង់កូនប្រុសស្រីជាសាមីខ្លួន ម៉ែឪមិនបានសួរចិត្តទេ ព្រោះអាងទៅលើភាសិតបរមបុរាណមួយថា « នំមិនដែលធំជាងនាឡិ » ។ បែបនេះក៏សមរម្យម្យ៉ាងតាមបុរាណសម័យ ។

ម្យ៉ាងទៀត ក្នុងសម័យបរមាណូនេះ មាតាបិតាមិនសំរេច

ដាច់ខាតម្នាក់ឯងទេ ត្រូវសួរចិត្តកូនប្រុសស្រីសាមីខ្លួនសិន បើគេមានស្រឡាញ់ទាក់ទងគ្នាជាមួយគូប្រចាំជីវិតគេ ចំពោះរូបណាហើយ មាតាបិតាគ្រាន់តែជួយសម្របសម្រួល សួរបញ្ជាក់ស្ដីដណ្ដឹងឱ្យចាស់ទំបានដឹងឮ ហើយកំណត់ពេលរៀបអាពាហ៍ពិពាហ៍តែម្ដង ។ មុនពេលរៀបអាពាហ៍ពិពាហ៍នោះ ម៉ែឪទាំងពីរខាង បានអនុញ្ញាតឱ្យកូនប្រុសស្រីទាក់ទងបណ្ដើរគ្នាលេងឱ្យបានស្គាល់ចិត្តគំនិតអធ្យាស្រ័យគ្នាច្បាស់លាស់ ដើម្បីថ្ងៃក្រោយកុំឱ្យទាស់ទែងខ្វែងគំនិតគ្នា បន្ទោសដល់ម៉ែឪថា ចេះតែឱ្យចេះតែទៅស្ដីដណ្ដឹង យកមនុស្សផ្ដេសផ្ដាសមកឱ្យខ្លួន ។ បែបនេះក៏ល្អម្យ៉ាងដែរ បើថ្ងៃក្រោយទៅមានកំហុស មិនធ្លាក់ទាំងស្រុងមកលើម៉ែឪទេ ។

- ត្រូវសង្គ្រោះចែកទ្រព្យសម្បត្តិ ឱ្យកូនចាយធ្វើសោហ៊ុយរៀនសូត្រ នឹងធ្វើបុណ្យទានតាមកាលសម័យ, ដល់កូនមានគូស្វាមីភរិយាហើយ គប្បីចែកមត៌កមានស្រែចំការ ផ្ទះសំបែងមាសប្រាក់ជាដើមតាមសម្ថភាពខ្លួន ឱ្យកូនធ្វើដើមទុនទៀត ។

ប៉ុន្តែមាតាបិតា មិនគួរចែកឱ្យកូនទាល់តែអស់រលីង ហើយទៅផ្សងសំណាងនៅជាមួយកូន ឱ្យគេចិញ្ចឹមវិញនោះទេ ។ គប្បីរំលែកទុកខ្លះ ល្មមចិញ្ចឹមជីវិតបាន ដរាបដល់ស្លាប់ ។

- កូនប្រុសស្រីត្រូវស្គាល់ឋានៈខ្លួនជាកូនថា អញគឺមាតាបិតាបង្កើតមក ហើយថែរក្សាថ្នាក់ថ្នមនឿយព្រួយលំបាកទាំងយប់ទាំងថ្ងៃជាច្រើនឆ្នាំ អញត្រូវតែចិញ្ចឹមថែរក្សាលោកវិញដរាបដល់អស់ជីវិតសង្ខារ ។

ការថែរក្សាចិញ្ចឹមមាតាបិតាវិញនេះ មិនមែនជាការលំបាកដូចកាលមាតាបិតាចិញ្ចឹមថែរក្សាខ្លួននោះទេ ប៉ុន្តែកូនប្រុសស្រីមិនសូវចូលចិត្តសោះ ចូលចិត្តតែប្រើលោកថែមទៅទៀត មានប្រើឱ្យជួយមើលកូនចៅ ឱ្យជួយធ្វើការផ្សេងៗមានចាំផ្ទះជាដើម ។ បើលោកចាស់ជ្រុលពិបាកប្រើ ច្រើនលះបង់ចោលដូចគោចាស់ បញ្ជូនលោកឱ្យចេញផុតពីផ្ទះទៅជ្រកនៅក្នុងវត្តអារាម ហើយថែមពាក្យគ្រាន់បើថាឱ្យទៅរៀនធម៌អាថ៌ទៀត ។ ជាពិសេសមិនសូវមានចិត្តជ្រះថ្លាលើកដៃសំពះថ្វាយបង្គំគក់ប្រាប់ទេ ។ ឯអ្នក

ដទៃគ្រាន់តែស្គាល់គេនោះ អាចលើកដៃសំពះ គំនាប់គាប់គួរនឹងគេ ដោយទឹកមុខយ៉ាងស្រស់ញញឹម ។

ឯការផ្គត់ផ្គង់បាយទឹកនំចំណីវិញ មិនសូវយកចិត្តទុកដាក់ដែរ បានចំណីម្ហូបអាហារល្អៗ បែរជាជ្រះថ្លាជ្រុលយកទៅបូជាព្រះឯវត្ត ឬយកទៅជូនអស់លោកឯណានោះវិញ ចំណែកមាតាបិតាដែលជាព្រះរស់កន្ទ្វើកនៅជាមួយក្នុងផ្ទះ ហើយដែលបានជប់បង្កើតខ្លួន ឱ្យកើតជាមនុស្សនោះ មិនបូជាផងសោះឱ្យលោកអត់ ។

ដូច្នេះកូនប្រុសស្រី គប្បីចែកជូននំចំណីអាហារល្អៗចំពោះមាតាបិតាមុន១ចំណែក ទើបគួរយក១ចំណែកទៀតទៅបូជាព្រះឯវត្ត ឬយកទៅជូនអ្នកដទៃជាក្រោយ ។

គប្បីរៀបចំទីដេកអង្គុយ ជូនមាតាបិតាឱ្យសមរម្យ ហើយមើលថែរក្សាបោសសំអាតបោកគក់មុងកន្ទេល ពូកខ្នើយភួយសំលៀកបំពាក់ នឹងដេញស្រមោចស្រមើលសង្កើចមូសរុយជាដើម ឱ្យស្អាតជានិច្ចរាល់ថ្ងៃ កុំធ្វេសប្រហែសបណ្តោយឱ្យសំលៀក

បំពាក់មុងក្អួយខ្សែ មាតាបិតាប្រឡាក់ក្អែល នឹងទឹកមាត់ស្វាក្រខ្វក់ ឡើងពណ៌ដូចខ្នុកម្រ័ក្សណ៍ ព្រោះលោកចាស់ងងឹតមើលមិនឃើញ គ្មានកំឡាំងបោកគក់ ។

គប្បីមើលផ្គត់ផ្គង់ទឹកក្ដៅត្រជាក់ គ្រប់ពេលវេលា ក្រែងមាតាបិតាត្រូវការ ។

គប្បីគោរពក្រាបសំពះថ្វាយបង្គំ រាល់ពេលដែលខ្លួនលាចេញទៅទីណា នឹងពេលចូលមកផ្ទះវិញ ។ បើនៅផ្ទះដទៃពេលទៅលេងនឹងមាតាបិតា នឹងពេលលាទៅផ្ទះខ្លួនវិញ ត្រូវតែគោរពក្រាបសំពះថ្វាយបង្គំជានិច្ច ទោះបីខ្លួនមានយសស័ក្តិ មានសម្បត្តិ ឬមានអាយុចាស់សក់ស្កូវហើយក៏ដោយ ។

គប្បីឈរឬអង្គុយប្រកបដោយសេចក្ដីគោរព ចំពោះមាតាបិតា មិនត្រូវវាយឫកស្មើ ។

គប្បីប្រើពាក្យសំដីទន់ភ្លន់ ប្រកបដោយសេចក្ដីគោរពជានិច្ចចំពោះមាតាបិតា ។

គប្បីតក់ច្របាច់ថៃទាំរកថ្នាំសង្កូវពេទ្យហ្មជាដើម ក្នុងពេល

ដែលមាតាបិតាមិនស្រួលខ្លួន ។

គប្បីផ្ចិតទឹក ដុះលាងមន្ទិលក្អែលខ្លួនប្រាណមាតាបិតាឱ្យ ដូចកាលមាតាបិតាថែរក្សាខ្ញុំថែរក្សាខ្លួនកាលនៅពីតូច ។

- កូនប្រុសស្រីកាលបើម៉ែឪមានកិច្ចរវល់ គប្បីបញ្ឈប់ការងារខ្លួន ជួយធ្វើការមាតាបិតាដោយស្មោះស្ម័គ្រ កុំទាថ្លៃឈ្នួល ឬយករង្វាន់អ្វី ដូចជាអ្នកក្រៅដទៃ ។ ទោះជាកូនប្រុសាក្តី កូនបង្កើតក្តី កុំមើលតែនឹងភ្នែក បើឃើញម៉ែឪធ្វើការអ្វីត្រូវជួយធ្វើ កុំចាំឱ្យលោកប្រើ ។ បើមានការត្រូវទៅដើរលេង ឬទៅទីណាៗ ដែលមិនមែនជាការចាំបាច់ គប្បីខកខានជួយធ្វើលោកសិន ។

ចំពោះកូនប្រសាស្រី ទោះបីខ្លួនជាកូនអស់លោកមន្ត្រីធំតូច ឬកូនអ្នកមានទ្រព្យធ្លាប់ស្រណុក ក្រចកលាស់ប្រវែងណាក៏ដោយ បើទៅនៅខាងត្រកូលស្វាមីហើយ មិនត្រូវប្រកាន់ថ្នមខ្លួនឱ្យម្តាយឪពុកក្មេក ឬបងថ្លៃ មាមីង បំរើនោះទេ ត្រូវតែរ៉ាប់រងធ្វើជំនួសទាំងអស់ ទើបមានលក្ខណៈជាស្រីល្អអ្នកមានពូជអំបូរ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីឱ្យព្រះធម៌ផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

មានសុជីវធម៌ ។ ឯកូនប្រសារប្រុសក៏ដូចគ្នាដែរ កុំយកបុណ្យស័ក្តិទ្រព្យសម្បត្តិ ទៅប្រើជាមួយម្ដាយក្មេកឪពុកក្មេក កុំប្រកាន់ថាអញជាថា- ជាអស់លោក- ជានាម៉ឺន- ជាអ្នកមានទ្រព្យមិនត្រូវធ្វើការអ្វី ឃើញមាតាបិតាធ្វើការ ឈរច្រត់ចង្កេះមើល ដូចជាចៅហ្វាយនាយ ត្រួតទាសកម្មករនោះឡើយ ។

កូនប្រុសស្រី ត្រូវស្ដាបនាវង្សត្រកូលនៃមាតាបិតាឱ្យមានវឌ្ឍនភាពខ្ពង់ខ្ពស់ឡើង បើមិនអាចឱ្យខ្ពស់ឡើងទៀតបានទេ មិនត្រូវញ៉ាំងវង្សត្រកូលនោះ ឱ្យថោកទាបទៅឡើយ យ៉ាងហោចណាស់ក៏ឱ្យបានតាំងនៅដូចដើម គឺមិនត្រូវបំផ្លាញទ្រព្យសម្បត្តិកេរ្តិ៍មត៌កឱ្យវិនាសឥតប្រយោជន៍ នឹងមិនត្រូវបណ្ដោយខ្លួនឱ្យជាមនុស្សមានចរិយាថោកទាបជាងមាតាបិតាខ្លួន កិច្ចការអ្វីដែលលោកបានធ្វើមកត្រឹមត្រូវតាមគតិបណ្ឌិតហើយ ដូចជាគោរពសាសនា នឹងបរិច្ចាគទានជាដើម មិនត្រូវលះបង់កិច្ចការដ៏ល្អប្រពៃនោះចោលទេ ទោះលោកធ្វើមរណកាលបាត់បង់ទៅហើយក៏ដោយ ។

- កូនប្រុសស្រីត្រូវផ្ចិតផ្ចង់ចរិយាមារយាទ ឱ្យត្រឹមត្រូវល្អ កុំប្រព្រឹត្តអំពើអាក្រក់តាមចំណង់ មានប្រព្រឹត្តអបាយមុខលេង ល្បែងភ្នាល់ បៀ ប៉ោ ជាដើម ដែលនាំឱ្យមាតាបិតាទាស់អធ្យាស្រ័យកើតសេចក្តីទុក្ខព្រួយ អស់សង្ឃឹមទៅអនាគតថានឹងបានទៅជាមនុស្សល្អ ល្មមទទួលថែរក្សាមត៌ករបស់វង្សត្រកូលបាន ហើយត្រូវជៀសវាង អាការបោកបញ្ឆោតដោយចរិយាចំពោះម៉ែឪ ព្រោះមានកូនខ្លះចង់បានមត៌កទ្រព្យសម្បត្តិពីម៉ែឪ ចង់ឱ្យលោកប្រគល់ឱ្យឆាប់ៗក៏តាំងប្រើចរិយាខ្ជាប់ខ្ជួនសីល ធ្វើជាអ្នកត្រឹមត្រូវដឹងគុណណាស់ លោកសុំសីលធ្វើទាន ក៏ខំធ្វើដូចលោក នឹងខំបំរើផ្គត់ផ្គង់បាយទឹកនិចំណី គក់ច្របាច់ក្រាបសំពះថ្វាយបង្គំរាល់ពេលវេលា ធ្វើឱ្យម៉ែឪភ្លូកភ្លឹកចិត្ត ដរាបដល់លោកប្រមូលមត៌កប្រគល់ឱ្យអស់គ្មានសល់មួយសេន ក៏តាំងប្រែក្រឡាពក់មុខខ្ជាបន្តិចម្តង ៗ ដរាបលោកខ្ជាចទ្រាំនៅជាមួយផងមិនបាន ឬក៏ដេញលោកឱ្យចុះចេញពីផ្ទះ ដូចគោចាស់ដែលគេហួតកន្ទុះលែងចោល ។

- កូនប្រុសស្រី ត្រូវមានចិត្តចង់ចាំមាតាបិតាឱ្យច្បាស់ប្រាកដ គួសភ្ជាប់ឱ្យមាំក្នុងគំនិត ទុកជាអនុស្សាវរីយ៍ប្រចាំជីវិតកុំភ្លេចឱ្យសោះ ចាប់តាំងពីលោកធ្វើមរណកាលទៅ ត្រូវធ្វើបុណ្យទានឧទ្ទិសផលជូនលោកតាមកាលសម័យ យ៉ាងហោចណាស់ក៏មួយខួបម្តង ដែលធ្លាប់នាំគ្នាហៅថាបុណ្យខួប ។ ត្រូវទៅបោសសំអាតផ្នូរ ឬចេតិយ បូជាដោយគ្រឿងសក្ការៈផ្សេងៗមានផ្កាទៀន ធូប នឹងនិមន្តព្រះសង្ឃបង្សុកូលជាដើម តាមកាលដ៏ទៀងទាត់កុំធ្វេសប្រហែសបំភ្លេចចោល មិនរវល់អើពើទឹកនាធ្វើហាក់ដូចជាមនុស្សកើតឯង មិនមែនកើតពីម៉ែឪ គ្មានម៉ែឪបង្កើត ដែលធ្លាក់ទៅក្នុងតម្រាថា « មនុស្សឥតពូជឥតអំបូរ » ។ ឯឪពុកធំម្តាយធំ មាមីង នឹងក្មួយ ក៏គួរឱ្យមានសុជីវធម៌ទៅវិញទៅមកតាមទំនងដូចមាតាបិតានឹងកូនដែរ ។

## ខ- ស្វាមី និងភរិយា

ស្វាមីនឹងភរិយានេះ ពិតមែនតែមានពាសពេញផ្ទៃលោក

ប៉ុន្តែមិនសូវមានសុជីវធម៌ ចំពោះគ្នាទៅវិញទៅមកតាមឋានៈទេ ទើបចេះតែកើតឈ្លោះប្រកែក ប្រចែប្រច័ណ្ឌលែងលះគ្នា កើតជាមនុស្សពោះម៉ាយ មេម៉ាយច្រើនសន្ធឹកមិនសូវបានសុខស្ងប់ក្នុងគ្រួសារសោះ ។

ដើម្បីសុខក្សេមក្សាន្ត បានរីករាយសប្បាយ មូលចិត្តគំនិតមិនបែកខ្ញែកគ្នារហូតដល់យាវជីវំនោះ ត្រូវមានសុជីវធម៌ចេះគោរពសន្តោសគ្នាទៅវិញទៅមក តាមឋានៈរៀងៗខ្លួន៖

- បុរសជាស្វាមី ត្រូវមានពាក្យសំដីល្អទន់ផ្អែមទៅរកភរិយា មិនត្រូវនិយាយសំឡុត គំហកគំហែង ជេរបញ្ចោរ ឬវាយទាត់ធាក់ក្នុងពេលដែលខ្លួនថ្នាំងថ្នាក់ចិត្ត ទាស់អធ្យាស្រ័យ ។ ធម្មតាស្ត្រីតែងតែមាត់ច្រើន បើមានលើសលោះមកលើខ្លួន គប្បីអត់ឱន ឱ្យសមភាពជាបុរសអ្នកមានភេទខ្ពង់ខ្ពស់ជាង ដែលតែងតែអត់ឱនគោរព មិនប្រទូស្តចំពោះស្ត្រីភេទ ។ ប៉ុន្តែមិនត្រូវដាក់ខ្លួនគោរព ឱ្យទាល់តែថោកទាបដូចជាខ្ញុំកញ្ជះបាទជើងភរិយា ដែលនាំឱ្យភរិយាមើលងាយ បង្ខិតជីកច្រមុះឱ្យ

ដោយតាមដូចគោក្របី វិលខួរក្បាលលែងស្គាល់ម៉ែឪ បងប្អូន ខុសត្រូវល្អអាក្រក់នោះឡើយ គប្បីតាំងខ្លួនឱ្យសមឋានៈជាប្តី របស់គេ កុំរីងរូសច្រឡើសបើសហួស កុំទន់ជ្រាយហួស ។ បើភរិយាប្រព្រឹត្តរំលោភលើខ្លួន គប្បីប្រដៅរំលឹកទូន្មានដោយ ពាក្យសំដីល្អសមហេតុផល ជាពាក្យមានឥទ្ធិពល ដែលអាច ញុំាងភរិយាឱ្យលះបង់អំពើអាក្រក់នោះចោលផង ឱ្យខ្លាចផង ឱ្យស្រឡាញ់ផង ។

- បុរសជាស្វាមី មិនគប្បីបៀតបៀន មើលងាយភរិយា ដូចខ្ញុំកំដរ ។ កុំត្រាប់តាមបុរសអាក្រក់ ដែលស្រឡាញ់ពប់ អានភរិយាដូចជាស្រឡាញ់ស្រីសហាយស្មន់ ដល់ពេលស្អប់ ស្អប់អស់ស្នេហាហើយ ក៏ប្រែក្រឡាភ្នែក ឃើញភរិយាខ្លួនចេះ តែអាក្រក់ មិនគាប់ចិត្ត ធ្វើការងារគោរពបំរើមិនគាប់អធ្យាស្រ័យ ចេះតែស្អប់ បន្ថយឋានៈភរិយាខ្លួនទុកដូចជាខ្ញុំបំរើ បៀតបៀន មើលងាយ រិះគន់ភរិយាសព្វយ៉ាង មានរិះគន់ដល់ពូជអំបូរជា ដើម ហើយប្រើភរិយាខ្លួនឱ្យធ្វើការបំរើ, ដូចខ្ញុំកញ្ជះបាទជើង ។

បើជាអ្នកមានត្រកូលខ្ពស់ មានយសស័ក្តិ មានទ្រព្យសម្បត្តិជាងភរិយាទៀតនោះ ក៏រឹតតែមើលងាយ ធ្វើឱ្យភរិយាខ្វះសិទ្ធិសេរីភាពគ្រប់យ៉ាង មានទឹកភ្នែកជូតក្បាលជង្គង់គ្រប់វេលា បើភរិយានោះជាស្រីមិនល្អ បណ្តាលឱ្យទៅជាផិតក្បត់រត់ចោលកូនចៅ ព្រោះទ្រាំនៅជាមួយស្វាមីមិនបាន

ដូច្នេះបុរសជាស្វាមី ត្រូវមានសុជីវធម៌ គោរពសន្តោសប្រណីចំពោះភរិយាខ្លួនជានិច្ច ទោះបានជួបឧបស័គ្គយ៉ាងណា ក៏មិនត្រូវបៀតបៀនមើលងាយភរិយា ដូចជាខ្ញុំកញ្ជះខ្លួនឡើយ ។ ចាប់ពីពេលបានភពប្រសព្វគ្នាមក រហូតដល់អវសានជីវិត ត្រូវតម្កល់ភរិយាខ្លួន ឱ្យនៅក្នុងឋានៈជាភរិយាដដែល ។

- បុរសជាស្វាមី មិនត្រូវក្បត់ចិត្តភរិយាខ្លួន ដោយមានស្រីញីប្រពន្ធទៀត មិនឱ្យភរិយាដឹង គឺដែលភរិយាមិនបានអនុញ្ញាតឱ្យយក ។ បើភរិយាបានដឹងយល់ព្រមផង មិនឈ្មោះថាក្បត់ទេ ។

ការក្បត់ចិត្តគ្នាក្នុងរឿងនេះ ជាមហាចង្រៃធំបំផុតក្នុងគ្រួសារ

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

អាចញ៉ាំងគ្រួសារអន្តរធានព្រាត់ប្រាសបែកបាក់គ្នា រលាយទ្រព្យសម្បត្តិ កំព្រើកំព្រាកូនចៅ ខូចអនាគតគ្រប់យ៉ាង ។ ដែលបណ្តាលអន្តរធានធំដូច្នេះ មកពីបុរសជាស្វាមីគ្មានសុជីវ-ធម៌ចំពោះភរិយា ច្រើនតែបំភ្លេចភរិយាដើមចោល ខ្វះការគួរសម នឹងការទំនុកបំរុងគ្រប់យ៉ាង ឆ្កួតវង្វេងខំផ្គាប់ផ្គុន បំរើតែស្រីញីប្រពន្ធចុងនោះទៅវិញ ។

ដូច្នេះបុរសជាស្វាមី មិនត្រូវក្បត់ចិត្តភរិយា ត្រូវស្មោះត្រង់ជានិច្ច ។ បើបានជាជ្រុលភ្លាត់មានស្រីញីប្រពន្ធចុងហើយ គប្បីប្រាប់ភរិយាតាមត្រង់ ឱ្យគេយល់ហេតុផលផង ហើយត្រូវចេះចាញ់ចេះឈ្នះ គឺបើខ្លួនខុសដូច្នេះហើយ ត្រូវញមខ្លួនចាញ់ភរិយាគ្រប់យ៉ាង ព្រោះខ្លួនក្បត់គេ ឯគេមិនបានក្បត់ខ្លួនទេ ទោះបីគេស្តីបន្ទោសដាក់ទណ្ឌកម្មយ៉ាងណា ក៏ត្រូវតែទទួលដោយរីករាយ ស៊ូទ្រាំអត់ធន់កុំធ្វើអាការៈឱ្យគេរឹតតែក្តៅខឹងថែមទៀត គប្បីអង្វរគេឱ្យបាត់ខឹងអត់ទោសឱ្យ តាមភាពជាអ្នកមានកំហុសក្នុងគ្រួសារ ដោយគិតពិចារណាប្រៀបធៀបថា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

" ចុះបើប្រពន្ធគេផិតក្បត់មានប្រុសវិញ តើអញក្តៅយ៉ាងណា? "

ឯហេតុដែលនាំឱ្យស្វាមីទៅជាក្បត់ មានស្រីញីប្រពន្ធចុងទៀតនោះ ច្រើនតែបណ្តាលមកពីភរិយាខ្វះសុជីវធម៌ចំពោះស្វាមី មិនចេះអប់រំស្វាមី ឱ្យរីករាយសប្បាយជាប់ចិត្តក្នុងគ្រួសារ ព្រោះមានភរិយាខ្វះតែស្វាមីក្រមកដល់ផ្ទះ ក៏កាត់ទោសក្បត់ដាក់ឱ្យភ្លាម ដោយឥតពិចារណារកយុត្តិធម៌ឱ្យស្វាមី ហើយក៏តាំងពាក់មុខយក្សក្រញែក្រញូវ រអ៊ូរទាំបោកប្រាស និយាយបញ្ចិតបញ្ចៀង ចាក់ដោតឱ្យស្វាមីក្តៅក្រហាយរអាខ្វាចអំណាចយក្សនោះ មិនសូវចង់ចូលផ្ទះ ចេះតែគេចវេះទៅលេងនឹងមិត្រសំឡាញ់បងប្អូន ដើម្បីបន្ធូរបរិយាកាសក្នុងទ្រូង ។ បើភរិយានោះ មិនព្រមដោះមុខយក្សចេញឱ្យប្តីបាត់ខ្លាចគេ គេក៏មានស្រីញីប្រពន្ធចុងតែម្តងទៅ ព្រោះទ្រាំនៅរួមជាមួយ នឹងអ្នកពាក់មុខយក្សនោះមិនបាន ។

- បុរសជាស្វាមី ត្រូវប្រគល់ឋានៈមេផ្ទះឱ្យទៅភរិយាដាច់

មុខ មិនគប្បីជ្រៀតជ្រែករិះគន់ ក្នុងការចាត់ចែងបាយទឹកម្ហូបចំណីទេ ។ មានស្វាមីខ្លះត្បិតត្បៀតជ្រុលពេក រហូតដល់ខ្វាចភរិយាកេងកិបលុយកាក់ ស៊ូទៅផ្សារទិញត្រីសាច់ខ្លួនឯង ឬក៏មិនរវល់ឱ្យលុយកាក់ទៅភរិយា ចាត់ចែងបាយទឹកម្ហូបចំណីទេ ចាំតែទារស៊ីឆ្ងាញ់តែម្តង បណ្តាលឱ្យភរិយាទៅខ្ចីបុលគេ យកមកផ្គត់ផ្គង់បាយទឹកម្ហូបចំណីឱ្យខ្លួន នាំឱ្យថោកទាបសៅហ្មងអាប់កិត្តិយសគ្រួសារ ។

- បុរសជាស្វាមី ត្រូវផ្គត់ផ្គង់ទំនុកបំរុងគ្រឿងប្រដាប់តុបតែងខ្លួនប្រាណ មានមាសពេជ្រសំពត់អាវជាដើមដល់ភរិយា តាមឋានៈខ្លួន កុំឱ្យហ៊ឺហាពេក កុំឱ្យរហេមរហាមពេក ដើម្បីទៅទីណាៗ មានទៅធ្វើបុណ្យទានជាដើម ឱ្យបានសមរម្យចូលចំណោមជំនុំចុះនឹងគេ កុំឱ្យគេរិះគន់មើលងាយថាហ៊ឺហាហួស ឬស្មោកគ្រោកហួសមិនចុះជំនុំ ។

- ស្ត្រីជាភរិយា ត្រូវស្គាល់ឋានៈខ្លួនថា អញជាស្ត្រីមេផ្ទះ គប្បីចាត់ចែងគ្រឿងឧបភោគបរិភោគ មានបបរបាយជា

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាធី**

ដើមដោយផ្ចិតផ្ចង់សំរាប់ស្វាមី ឱ្យត្រូវតាមពេលវេលា មិនត្រូវប្រចាំស្វាមី ។ កាលបរិភោគរួចហើយ គប្បីលាងផ្ទុះរៀបចំទុកដាក់កែវចាន ផ្ទាំងឱ្យមានសណ្ដាប់ធ្នាប់ល្អតាមទីកន្លែង មិនត្រូវទុកចោលឱ្យប្រឡាក់ស្រកាក ដល់ខួបនោះឡើយ ។

គប្បីរៀបចាត់ចែងឱ្យមានទឹកផឹក ទឹកប្រើប្រាស អុស ភ្លើង អង្ករ អំបិលជាដើម បំរុងទុកឱ្យមានជានិច្ច កុំចាំដល់ពេលដាំស្ល ពេលប្រើប្រាស ទើបរត់រកសុំខ្ចីទិញគេ ពីផ្ទះមួយទៅផ្ទះមួយ មានស្បែកមុខក្រាស់មិនចេះអៀនខ្មាស់ ។ មានស្ត្រីមេផ្ទះខ្លះ គ្មានសុជីវធម៌ក្នុងរឿងនេះសោះ គិតតែពីដេកផ្កិះសម្រួចក្រចក មិនហ៊ានកាន់កាំបិតចានផ្ទាំងចូលចង្ក្រានទេ ខ្លាចមិនបានកើតជាស្រីល្អ បណ្ដោយឱ្យខ្ញុំកំដរដាំស្លផ្ដេសផ្ដាសស្មោកគ្រោក មិនមើលថែទាំផ្ចិតផ្ចង់ដោយខ្លួនឯង ដែលមានលក្ខណៈផ្ទុយស្រឡះពីស្រីល្អទៅវិញ ។ បើខ្លួនជាបុគ្គលិករាជការជាដើម គ្មានពេលនឹងដាំស្លចូលចង្ក្រានផ្ទាល់ខ្លួនទេ ក៏គប្បីត្រួតពិនិត្យចាត់ចែងបង្គាប់ឱ្យបានហ្មត់ចត់ដែរ មិនត្រូវ

បណ្តោតបណ្តោយ ឥតរវល់សោះក្នុងវិជ្ជាមេផ្ទះនេះឡើយ ។

- ស្ត្រីជាភរិយា ត្រូវរាប់អានសង្គ្រោះដល់ញាតិរបស់ខ្លួននឹងញាតិស្វាមី ដោយអាការលរាក់ទាក់ស្មោះស្មើ មិនគប្បីឱ្យលំអៀងម្ខាងៗ ទោះបីញាតិនោះខ្ពង់ខ្ពស់ក៏ដោយ ថោកទាបក៏ដោយ ៗ មិនគប្បីនិយាយអាក្រក់ ពីម្តាយឪពុកពីញាតិខាងនេះ ប្រាប់ម្តាយឪពុកប្រាប់ញាតិខាងនោះ ឬនិយាយពីខាងនោះប្រាប់ខាងនេះ ចាក់ចុចអុជអាលចុះឡើងឱ្យមានរឿងហេតុ ។

បើមានឱ្យវត្ថុអ្វី ៗ ដល់ម្តាយឪពុក ដល់ញាតិម្ខាងមិនគប្បីនិយាយរំលើកគុណ ប្រាប់ដល់ម្តាយឪពុកដល់ញាតិម្ខាងទៀតឡើយ ដើម្បីកុំឱ្យមានការថ្នាំងថ្នាក់ អាក់អន់អៀនខ្មាស់ម្ខាងៗ ដែលជាហេតុនាំឱ្យអ្នកទាំងនោះ មើលមុខគ្នាមិនត្រង់ផង នាំឱ្យស្វាមីរង្កៀសអាក់អន់ចិត្តផង ។

- ស្ត្រីជាភរិយាត្រូវចេះរៀបចំទុកដាក់ ថែរក្សាទ្រព្យដែលស្វាមីខំរកបានមកហើយ មិនគប្បីខ្ជះខ្ជាយដូចស្រីកញ្ជើធ្លុះ ។ សំលៀកបំពាក់ មុងកន្ទេលជាដើម ត្រូវចេះថែទាំបោកគក់

រៀបចំទុកដាក់តាមទីកន្លែងឱ្យមានរបៀប កុំចោលរាត់រាយ ឱ្យកណ្តុរកន្ធាតកណ្តៀរ ខាំស៊ីកាត់ខូចអន្តរាយប្រើការមិនកើត ។

មិនគប្បីឱ្យគេខ្ចីប្រើប្រាស ឬប្រាក់កាសតែម្នាក់ឯង មិនឱ្យស្វាមីដឹង ។ ចង់ទិញដូររបស់អ្វីៗ មិនត្រូវលួចលាក់ទិញតាមអំពើចិត្ត ទិញថ្លៃប៉ុណ្ណេះ កុហកស្វាមីថាថ្លៃប៉ុណ្ណោះ ឱ្យថោកដើម្បីកុំឱ្យស្វាមីបន្ទោស ឬក៏ឱ្យលើសថ្លៃ ដើម្បីបានចំណេញពីស្វាមី ។ គ្រឿងអលង្ការ នឹងគ្រឿងស្លៀកពាក់ក៏ត្រូវប្រើប្រាសឱ្យចេះប្រុងប្រយ័ត្ន ចេះថែទាំ កុំចេះតែផ្លាស់ប្តូរស្រួតតាមអំពើចិត្ត មិនគិតពីការបង់ខាត ព្រោះតែចង់បានបែបម៉ូតថ្មី លក់អាម៉ូតចាស់ចោលថោកៗចោលទាំងថ្មីបណ្តាលឱ្យមានការចំណាយហួសកំរិតក្នុងគ្រួសារ នាំឱ្យស្វាមីហ៊ានប្រព្រឹត្តអំពើពុករលួយ លួចប្លន់កេងកិបស៊ីសំណូកជាដើម ។

ស្ត្រីជាភរិយា មិនត្រូវប្រព្រឹត្តកន្លងចិត្តស្វាមី បែកចិត្តគំនិតទៅសហាយស្មន់នឹងបុរសដទៃទៀត ព្រោះតែស្វាមីចាស់ជរា ឬមានរូបអាក្រក់ ឬក៏ទីទាល់ក្រគ្មានទ្រព្យសម្បត្តិយសស័ក្តិ ។

ធម្មតារបស់ស្ត្រីល្អប្រកបដោយសុជីវធម៌ តែទទួលបុរសណាជាស្វាមីហើយ ទោះបុរសនោះ ធ្លាក់ខ្លួនជាមនុស្សទីទាល់ក្រលំបាកតោកយ៉ាក ខូចបុណ្យស័ក្តិយ៉ាងណាក៏ដោយ មិនដែលផ្លាស់ប្តូរចោល ដូចផ្លាស់ប្តូរសំលៀកបំពាក់ចាស់ចោលនោះទេ រឹតតែមានសេចក្តីស្រឡាញ់ស្មោះត្រង់ អាណិតអាសូរស៊ូប្តូរជីវិតលើសដើម ។

- ស្ត្រីជាភរិយាមិនត្រូវខ្ជិលទម្រន់ ឱ្យតាំងសតិប្រាជ្ញាគប្បីប្រឹងប្រែង ឱ្យឈ្លាសវៃ ប៉ិនប្រសប់ ក្នុងកិច្ចការទាំងពួងមានចេះផ្សេផ្សំ ដេរប៉ាក់ផុល របស់ដែលចាស់ ដែលខូចដែលតិច ឱ្យទៅជារបស់ប្រើការកើត ជារបស់ច្រើន ។ ត្រូវជាអ្នកស្ទាត់ជំនាញក្នុងវិជ្ជាមេផ្ទះ ចេះចាត់ចែងចំណីអាហារដែលមានឱជារសឆ្ងាញ់ពិសាប្រកបដោយអនាម័យ ហើយអស់សោហ៊ុយតិច ព្រោះជាស្ត្រីវៃឆ្លាតចេះសំចៃ ចេះផ្សេផ្សំមិនខ្ជះខ្ជាយ ។ ដូចអង្ករមិនត្រូវដាំបាយឱ្យសល់ ចាក់ចោលកន្ទះៗផ្ទាំង, អុសឰង មិនត្រូវដុតបង្ករឱ្យឆេះចោលទទេៗ, ទឹកត្រី

ទឹកស៊ីអ៊ីវ អំបិលមិនត្រូវចាក់ដាក់កន្ទះៗចាន ទាល់តែបរិភោគមិនអស់ចាក់ចោលជាដើម ។

## គ- គ្រូ និង សិស្ស

គ្រូអាចារ្យនឹងសិស្សនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ ៖

គ្រូអាចារ្យ ត្រូវប្រៀនប្រដៅសិស្ស អប់រំសិស្ស ឱ្យចេះស្គាល់ហេតុផលល្អអាក្រក់ អប់រំសិស្ស ឱ្យចេះគោរពប្រតិបត្តិតាមចំណេះវិជ្ជាទាំងឡាយ ដែលបានរៀនចេះដឹងហើយ ដើម្បីឱ្យសិស្សកើតជាពលរដ្ឋល្អ មានសម្ថភាពបរិបូណ៌ ។

បង្ហាត់បង្រៀនសិស្ស ឱ្យបានត្រឹមត្រូវតាមកម្មវិធីសិក្សា មិនត្រូវធ្វើឃោសនាជ្រៀតជ្រែកបន្ទំ ដើម្បីដឹកទាញគំនិតមារ-យាទសិស្ស ឱ្យទៅតាមគោលបំណងប្រយោជន៍ផ្ទាល់របស់ខ្លួនទាំងមិនត្រូវខ្ជិលច្រអូស ។ បើវិជ្ជាណាដែលខ្លួនមិនសូវប៉ិនប្រសប់ គប្បីរាវរកមើលក្បួនច្បាប់ឱ្យប្រាកដត្រឹមត្រូវ កុំបង្រៀន

ស្មានៗ នាំឱ្យខូចខួរក្បាលសិស្ស ត្រូវបង្រៀនដោយឧ-បាយវៃឆ្លាត ដែលអាចឱ្យសិស្ស ចេះចាំចូលចិត្តតាមត្រឹមត្រូវតាមមុខវិជ្ជា ដែលបានកំរិតក្នុងកម្មវិធីបង្រៀន ។

- ខំបង្ហាត់បង្រៀនសិស្សឱ្យអស់សមត្ថភាព ដែលខ្លួនបានចេះដឹងមិនលាក់ទុក គឺកុំបង្រៀនចោលៗ គ្មានយកចិត្តទុកដាក់ បង្រៀនឱ្យតែគ្រប់ពេលវេលា បង្រៀនយកតែលាភរង្វាន់ប្រាក់ខែ ។

- គ្រូអាចារ្យគប្បីជួយលើកដំកើង សរសើរឱ្យរង្វាន់សិស្សដែលចេះដឹងបរិបូណ៌ដោយចំណេះវិជ្ជា នឹងចរិយាល្អ ឱ្យល្បីខ្ចរខ្ចាយឡើង ដើម្បីលើកទឹកចិត្តសិស្សនោះផង លើកកំឡាំងចិត្តសិស្សឯទៀត ដែលកំពុងសិក្សាផង ។

- គ្រូអាចារ្យ គប្បីជួយការពារ កាន់ជើងសិស្ស បំរុងទុកមុនគ្រប់វិស័យ គឺជួយរំលឹកទូន្មានប្រាប់ពន្យល់សិស្ស ឱ្យចេះដឹងវៃឆ្លាត មិនឱ្យទើសទាល់ ក្នុងពេលដែលសិស្សទៅប្រស្រ័យទាក់ទងក្នុងទិសទីផ្សេងៗ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

- សិស្ស ត្រូវមានសេចក្ដីគោរពចំពោះគ្រូអាចារ្យ គឺបើកំពុងអង្គុយនៅទីណាមួយ ដែលមិនមានឥស្សរជនជាធំជាងគ្រូអាចារ្យ ហើយឃើញគ្រូអាចារ្យមកក្នុងទីនោះ ត្រូវក្រោកឈរគោរពសំពះគួរសម ។ បើលោកមានកាន់វត្ថុអ្វី ត្រូវទទួលជួយកាន់លោក ។ បើលោកត្រូវការអង្គុយ ត្រូវរៀបអាសនៈជូន, លុះលោកអង្គុយហើយ សឹមខ្លួនអង្គុយជាក្រោយ ។ ដល់លោកលាទៅវិញ ត្រូវក្រោកជូនលោក យ៉ាងជិតត្រឹមមាត់ទ្វាររបង ។

- សិស្សទាំងឡាយ ត្រូវលៃពេលចូលទៅគួរសម បំរើគ្រូអាចារ្យតាមកាលទេសៈ, ចំពោះគ្រូជាគ្រហស្ថ ពេលលោកមានរវល់ធ្វើពិធីណាមួយ បើបានដឹង ត្រូវតែទៅជួយខ្វល់ខ្វាយមានជួយរៀបចំតុបតែងផ្ទះសំបែងជាដើម ។ ជាពិសេស ពេលដាច់ឆ្នាំចាស់ ចូលឆ្នាំថ្មីម្ដងៗ គួរយកគ្រឿងឧបភោគបរិភោគទៅជូនលោកតាមសមត្ថភាពខ្លួន កុំធ្មើងឆ្មៃប្រកាន់ថា ខ្លួនគ្រាន់បើ មានទ្រព្យមានបុណ្យស័ក្ដិជាងគ្រូអាចារ្យ ។ បើទីលំនៅ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

លោកនៅឆ្ងាយ គ្មានមធ្យោបាយផ្ញើទៅជូនបាន គប្បីផ្ញើសំបុត្រជូនពរសេព្ទសាធុការទៅជូនលោក ។

- សិស្ស ត្រូវប្រុងសតិស្មារតីចងចាំនូវឱវាទ ពាក្យប្រៀនប្រដៅគ្រូអាចារ្យដោយគោរព គឺមិនត្រូវស្តាប់គ្រាន់តែឮ គប្បីចងចាំហើយ ប្រតិបត្តិតាមអស់មួយជីវិត ។

- បើនៅផ្ទាល់ក្នុងសំណាក់ជាមួយគ្រូអាចារ្យ គប្បីបំរើផ្គត់ផ្គង់ មានរៀបចំទីអាសនៈ ជូនទឹកក្តៅត្រជាក់ គក់ច្របាច់ជាដើម បើមានឱកាសអាចធ្វើបាន ។

- សិស្ស ត្រូវយកចិត្តទុកដាក់រៀនសូត្រគ្រប់មុខវិជ្ជាដែលគ្រូអាចារ្យតម្រូវឱ្យរៀន កុំគ្រាន់តែទៅកត់ចម្លងយកពីសាលាទទួលឱ្យផុតតែពីមុខគ្រូអាចារ្យ យកទៅចោលឱ្យចាំកន្ទែងហើយដើរលេងឥតទន្ទេញរៀនសូត្រសោះ ។

## ឃ- អ្នកបួស និង គ្រហស្ថ

អ្នកបួសគឺ ព្រះសង្ឃសមណព្រាហ្មណ៍ និងគ្រហស្ថនេះ

ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក ទើបអាចទាក់ទងគ្នាបានសុខចំរើន ក៏ត្រូវប្រតិបត្តិគោរព តាមឋានៈរៀងៗខ្លួន៖

- អ្នកបួស ត្រូវរំលឹកទូន្មានហាមឃាត់គ្រហស្ថ ដែលទាក់ទងជាមួយ មិនឱ្យប្រព្រឹត្តអំពើអាក្រក់ទុច្ចរិត មានកាប់សម្លាប់លួចប្លន់ជាដើម ។

- ត្រូវដឹកនាំពន្យល់គ្រហស្ថ ឱ្យយល់ជឿច្បាស់នូវកម្មនឹងផលនៃកម្ម គឺឱ្យចេះធ្វើទានសីល តាមប្រពៃណីសាសនា ឱ្យមានការបរិច្ចាគ តាមកំឡាំងសទ្ធានិងធនធាន, មិនគួរបង្ខំឱ្យទាល់តែខូចសទ្ធាអស់ ឃ្លាងពីពុទ្ធឱវាទកំរិតខាតវិន័យ ព្រោះតែចង់កសាងកុដិសាលា ចេះតែយកប្រូក្រាម ទៅបង្ខំញឹកៗញយៗ ដើរជ្រែកអំពកគ្រប់ផ្ទះ ដរាបដល់គ្រហស្ថខ្លាច រអាមិនចង់ជួបមុខ ។

- ត្រូវអនុគ្រោះដោយកល្យាណចិត្ត ផ្សាយមេត្តាដល់គ្រហស្ថទាំងឡាយ ឱ្យបានសុខចំរើន កុំឱ្យមានទុក្ខសោកពេភ័យបៀតបៀន ។

- គប្បីឧស្សាហ៍និយាយពន្យល់ ច្បាប់ទម្លាប់ធម៌អាថ៌ប្លែកៗ ដែលគ្រហស្ថមិនធ្លាប់បានស្តាប់ ឱ្យបានស្តាប់ចេះដឹងឡើង ។

- ច្បាប់ទម្លាប់ធម៌អាថ៌ណា ដែលគ្រហស្ថធ្លាប់បានស្តាប់ហើយ គប្បីវែកញែកពន្យល់ ច្បាប់ទម្លាប់ធម៌អាថ៌នោះ ឱ្យមានន័យច្បាស់លាស់ប្រាកដឡើង ដរាបដល់គ្រហស្ថអស់សង្ស័យ ។

- អ្នកបួស ត្រូវប្រាប់ឧបាយដែលប្រតិបត្តិឱ្យបានសុខចំរើន ក្នុងលោកនេះនឹងលោកខាងមុខ មានប្រាប់ឧបាយទៅសួគ៌និព្វានជាដើម តាមសភាវពិត ដែលមានក្នុងទ្រឹស្តីសាសនា ។

- គ្រហស្ថ ត្រូវបន្ទាបបន្ទន់កាយ ឱ្យសុភាពរាបសាគោរពអ្នកបួស មានថ្វាយបង្គំ នឹងជួយកិច្ចធុរៈកសាងកុដិសាលាវិហារ ហើយនឹងបំរើទឹកក្តៅត្រជាក់ គក់ច្របាច់ជាដើម ។

- ការគោរពអ្នកបួសដោយកាយនេះ ពីសម័យអង្គរ គេគោរពហ្មត់ចត់ណាស់ បើធ្វើដំណើរតាមផ្លូវ កំពុងវែកពុនទូលកញ្ជើ ឬពាក់មួកជួតឈ្នួតជាដើម ជួនជាមានព្រះសង្ឃនិមន្តមកដល់ គេឈប់ដើរ ដោះមួក ដោះឈ្នួត ដាក់អំរែកដាក់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ទទួលហើយលុតជង្គង់ដល់ដី លើកដៃប្រណម្យ ជរាបដល់ព្រះសង្ឃនិមន្តផុត ទើបក្រោកធ្វើដំណើរទៅទៀត ។ សព្វថ្ងៃនៅក្នុងខែត្រសៀមរាប យូៗបានឃើញអ្នកសុជីវធម៌សម័យអង្គរនេះម្តងៗដែរ ។

- ត្រូវបន្ទាបបន្ទន់វាចា ឱ្យសុភាពរាក់ទាក់ គួរសមមិនឱ្យឆ្គង មានឆ្លើយថា ព្រះករុណាម្ចាស់ ព្រះតេជព្រះគុណ ព្រះគុណម្ចាស់ ចាន់ សឹង ស្រង់ទឹកជាដើម នឹងចេះនិយាយដឹកនាំអ្នកឯទៀត ឱ្យចេះគោរពធ្វើបុណ្យទាន ចំពោះអ្នកបួស ។

- ត្រូវមានមេត្តាចិត្ត គិតឱ្យអ្នកបួសទាំងឡាយ ជាអ្នកដឹកនាំគ្រហស្ថ ឱ្យបានសុខសន្តិភាព លោកខំនិមន្តមកទូន្មានប្រដៅត្រកូលយើង ដោយឥតគិតនឿយហត់ សូមឱ្យលោកបានសុខចំរើន ធាប់បានសម្រេចដល់ព្រះនិព្វាន ។

- ត្រូវជាអ្នកមានទ្វារផ្ទះមិនបិទ គឺបើមានអ្នកបួសមកដល់ផ្ទះហើយ គប្បីធ្វើទាន មានប្រគេនចង្ហាន់ ភេសជ្ជៈជាដើម មិនត្រូវត្អូញត្អែចំពោះរបស់ដែលមាន ថាគ្មានវិញឡើយ ។

- ឧស្សាហ៍ធ្វើទាន ផ្តល់នូវបច្ច័យទាំងបួន មានបាយទឹក នំចំណីជាដើមញយៗដល់អ្នកបួស ព្រោះលោកគ្មានធ្វើជំនួញ ដូញប្រែដូចគ្រហស្ថឡើយ គឺលោករស់នៅ ដោយសារគេឱ្យ ដោយសទ្ធាជ្រះថ្លា ។

## ង-ចៅហ្វាយនាយ និងទាសកម្មករ

ចៅហ្វាយនាយនិងទាសកម្មករនេះ ច្រើនតែមិនសូវមាន សុជីវធម៌ចំពោះគ្នានិងគ្នា តាមឋានៈខ្លួនទេ ទើបចេះតែកើត វិវាទទាស់ទែងខ្វែងគំនិតគ្នា ។

ដើម្បីបានសុខស្រួលស្រួល មិនទាស់អធ្យាស្រ័យគ្នានោះ ត្រូវមានសុជីវធម៌ ចេះគោរពសន្តោសគ្នា តាមឋានៈរៀងៗខ្លួន៖

- ចៅហ្វាយនាយ ត្រូវចេះលៃលកចាត់ចែងការងារ តាម សមត្ថភាព និងកំឡាំងទាសកម្មករ គឺដាក់ការងារឱ្យធ្វើ តាម វ័យចាស់ក្មេង ធំតូច ស្រីប្រុស ចេះល្មម់ វៃឆ្លាត ទាំង ពាក្យសំដី ក៏និយាយឱ្យគួរសមតាមវ័យមនុស្ស មានពាក្យថា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

តា យាយ មីង ពូ អ៊ុំ បង ប្អូនជាដើម កុំហៅថា មី អា មីង ដាច់សាច់ នឹងមិនត្រូវជេរប្រទេចផ្ដាសា គំហក កំហែងគំរោះគំរើយជាដើម ។

- ចៅហ្វាយនាយ គប្បីចែករំលែកឱ្យថ្លៃឈ្នួល ឱ្យបាន ត្រឹមត្រូវតាមសមត្ថភាពទាសកម្មករ និងតាមកាលៈទេសៈ ។

- ត្រូវមើលថែទាំរក្សាទាសកម្មករ ដែលមានជម្ងឺផ្សេងៗ ឱ្យបានឆាប់ជាសះស្បើយ, បើដឹងថាគ្នាឈឺហើយ មិនគួរបង្ខំឱ្យ ធ្វើការអ្វីទេ គប្បីយោគយល់គ្នាថាជាមនុស្សដូចខ្លួនដែរ មិនត្រូវ ចេះតែប្រើ ដល់ឈឺបោះបង់ចោលឡើយ ។

- បើមានចំណីអាហារ ដែលមានរសឆ្ងាញ់ពិសា គប្បី លៃលកចែកឱ្យគ្នាបរិភោគផង ទោះតិចក្ដី ច្រើនក្ដី កុំឱ្យគ្នា ឈរមើលមាត់ ហើយខ្លួនបរិភោគឆ្ងាញ់ពិសា យករស់តែម្នាក់ ឯង ឱ្យគ្នាស៊ីឆ្អឹងបាតចាន សោះតែគ្មាននោះឡើយ ។

- ត្រូវបើកឱ្យទាសកម្មករ ឈប់តាមកាលគួរ នឹងពេលដែល គ្នាមានការចាំបាច់ ដូចម្ដាយឪពុក បងប្អូន មាមីង ជីដូនជីតា

ស្លាប់ជាដើម នឹងឱ្យឈប់តាមកាលបរិច្ឆេទ ដែលក្រសួងការងារបានកំរិតឱ្យឈប់ ។

- ទាសកម្មករ ត្រូវក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ នឹងទៅធ្វើការឱ្យបានទាន់ពេលម៉ោង កុំខ្ជិលច្រអូសចេះតែធ្វើពុតឈប់ញយៗ ។ ទៅធ្វើការដោយធុញទ្រាន់ច្បិចច្បើមក្នុងមួយខែៗ ទៅមិនទាន់ម៉ោងស្ទើរតែរាល់ថ្ងៃ នឹងឈប់ផ្ដេសផ្ដាសជាញយ ៗ ។

- ពេលឈប់ធ្វើការ ត្រូវឈប់តាមកំរិតម៉ោង កុំឈប់សំរាករ៉ៃ រ៉ែចាំតែម៉ោងចេញ នឹងលួចបន្លំចេញទៅផ្ទះ ទៅដើរលេងមុនពេលម៉ោង ។

- ត្រូវស្មោះត្រង់ចំពោះចៅហ្វាយនាយ មិនត្រូវលួចកេងកិប យករបស់ទ្រព្យអ្វីៗដោយមិនបានសុំ ឬដែលចៅហ្វាយនាយមិនបានអនុញ្ញាត្តឱ្យ ។

- ត្រូវធ្វើការដោយផ្ចិតផ្ចង់ ដឹងបាត់ដឹងគង់ កុំធ្វើខ្ជះខ្ជាយបាចសាចចោលរាត់រាយ ឱ្យខូចខាត ដោយអាងថាមិនមែនជា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

របស់ខ្លួន ។

- គប្បីជួយសរសើរ ផ្សាយកិត្តិគុណរបស់ចៅហ្វាយនាយ ដែលបានធ្វើសេចក្ដីល្អចំពោះខ្លួន មិនគប្បីយករឿងហេតុអាក្រក់បន្តិចបន្តួច ទៅផ្សាយប្រាប់អ្នកដទៃ ដើម្បីបំបាត់សេចក្ដីល្អដែលចៅហ្វាយនាយបានធ្វើច្រើនចំពោះខ្លួន ។

## ប-មនុស្សចាស់ និងក្មេង

មនុស្សចាស់និងក្មេង គឺមនុស្សដែលមានអាយុតិចច្រើនជាងគ្នានេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ ។

- មនុស្សចាស់គប្បីសង្គ្រោះយោគយល់ឱ្យវត្ថុផ្សេងៗ ដល់ក្មេង មានឱ្យចំណីអាហារបរិភោគជាដើម ទោះក្មេងនោះជាញាតិសន្ដានក្ដី អ្នកដទៃក្ដី ។ បើបានបរិភោគជាមួយក្នុងពិធីបុណ្យទានហើយក្មេងគ្នាគោរពខ្លាចយើង គប្បីហៅរក ប្រាប់ឱ្យបរិភោគបានឆ្អែតស្រួលបួលកុំឱ្យអៀនខ្មាស់ មិនត្រូវយកឆ្អែតតែម្នាក់ឯង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេ សាទី**

ដោយអាងថាខ្លួនចាស់ជាងនោះឡើយ ។ បើគ្នាជាមនុស្សខ្សត់ខ្សោយ គួរជួយទំនុកបំរុងឱ្យសិក្សារៀនសូត្រជាដើម តាមសមត្ថភាព កុំឱ្យគ្នារហេមរហាមខូចអនាគត ព្រោះក្មេងជាអនាគតរបស់ប្រទេសជាតិ ។

- គប្បីប្រើពាក្យសំដីល្អទៅរកក្មេង មានពាក្យថា នាងអ្នក ប្អូន ក្មួយជាដើម កុំហៅអាមីងដាច់សាច់ ដោយអាងថាខ្លួនចាស់កើតមុន ។

- គប្បីផ្តល់ប្រយោជន៍ឱ្យក្មេង មានជួយរំលឹកដាស់តឿនឱ្យធ្វើអំពើល្អជាដើម ។ បើឃើញគ្នាបានប្រព្រឹត្តខុស មិនគួរគប្បីហើយ ត្រូវណែនាំឱ្យបានល្អឡើង កុំត្មះតិះដៀលផ្តន្ទាគ្នាថែមទៅទៀត ។

- ត្រូវមានមេត្តាអាណិតអាសូរ រាប់អានដោយស្មោះស្មើកុំបៀតបៀន រំលោភលើសិទ្ធិក្មេង គប្បីយោគយល់ថា កូនគេដូចកូនខ្លួន ទោះដេកដើរឈរអង្គុយក្តី មិនត្រូវបៀតបៀនជ្រៀតជ្រែកជាន់កន្ទួងរំលងក្បាលដោយអាងថាខ្លួនចាស់ជាង ។

- ក្មេង ត្រូវយោគយល់ចែកជូនវត្ថុផ្សេង ៗ មានបាយ ទឹកនំចំណីជាដើម ដល់មនុស្សដែលមានវ័យចាស់ជាង ទោះមិនមែនជាញាតិសន្តានក៏ដោយ ចែកជូនតាមសមត្ថភាពខ្លួន ដែលអាចធ្វើទៅបាន ដូចជាពេលបរិភោគចំណីអាហារ រួមជាមួយមនុស្សចាស់ ក្នុងពិធីបុណ្យទានណាមួយ មិនត្រូវបរិភោគតាមឃ្លាន យកឆ្អែតតែម្នាក់ឯងទេ បើចំណីអាហារណា ដែលគួរដល់មនុស្សចាស់ ឬដែលមនុស្សចាស់ចូលចិត្ត យើងគួរទុកជូនគាត់បរិភោគ ឱ្យបានច្រើនជាងយើង ឬក៏យើងកុំបរិភោគចំណីអាហារនោះ ។ បើមានមនុស្សចាស់ ដែលក្រខ្សត់ គួរចែកជូនវត្ថុផ្សេងៗ ដែលអាចចែកជូនបាន ។

- ត្រូវប្រើពាក្យសំដីគួរសមជានិច្ច ចំពោះមនុស្សចាស់ មានពាក្យថា លោកតា លោកយាយ ពូ មីង អ៊ុំ បង ជាដើម លៃឱ្យគួរសមតាមឋានៈ កុំឱ្យខ្ពស់ហួស ទាបហួស, មិនត្រូវប្រើពាក្យព្រហើន ឯង អញ អ៊ី វ៉ៃយជាដើមឡើយ ។

- ត្រូវគោរពមនុស្សចាស់ដោយកាយ គឺបើមនុស្សចាស់

កំពុងដេកឬអង្គុយ ហើយយើងជាក្មេងត្រូវទៅទីនោះ គប្បីដើរតិចៗ ដោយអាការៈគួរសមឱនលំទោន ។ បើដើរទៅជួបមនុស្សចាស់ កំពុងដើរឬឈរកណ្ដាលផ្លូវ ត្រូវថ្លែងអាការៈគួរសម ចៀសឱ្យឆ្ងាយបន្តិច ឬដោះមួកគោរពតាមប្រពៃណីជាតិ កុំដើរប្រជែងប្រជាង មិនស្គាល់ចាស់ព្រឹទ្ធាចារ្យ ។

- គប្បីជួយផ្ដល់ផលប្រយោជន៍ឱ្យមនុស្សចាស់ ដែលខ្លួនអាចជួយបាន ដូចជាជួយលើកដាក់វត្ថុផ្សេងៗ ឬទៅទិញនេះទិញនោះ នឹងជួយធ្វើការអ្វីៗ ដែលមនុស្សចាស់ពឹងពាក់ឱ្យជួយ មិនត្រូវខ្ជិលប្រកាន់ខ្លួនឡើយ, បើមានពេលអាចជួយបាន ។

- ត្រូវរាប់អានដោយស្មោះស្មើ ដោយសំគាល់ថា ដូចជាជីតា ជីដូន មាតាបិតា មាមីងរបស់ខ្លួន មិនត្រូវបៀតបៀនប្រមាថមើលងាយ ទោះបីមនុស្សចាស់ នោះបានប្រព្រឹត្តខុសឆ្គងមកលើខ្លួនបន្តិចបន្តួចក៏ដោយ ឬក៏មនុស្សចាស់នោះ ជាអ្នកល្ងង់ទ័លក្រថោកទាបជាងខ្លួន គប្បីរាប់អានគោរពថា ជាមនុស្សចាស់ជាដរាប ។

# ធ-ម្ចាស់ផ្ទះ និងភ្ញៀវពន្លឺ

ជនជាម្ចាស់ផ្ទះ ម្ចាស់ប្រទេស និងភ្ញៀវពន្ទីនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ ៖

- ជនជាម្ចាស់ផ្ទះ បើមានភ្ញៀវមកដល់ហើយ គប្បីមានអាការៈគួរសមតាមឋានៈភ្ញៀវ មានចេញទៅទទួលចាប់ដៃ ឬសំពះសួរសុខទុក្ខ ជួយកាន់ជួយជញ្ជូនឥវ៉ាន់ នាំចូលទៅក្នុងផ្ទះរបស់ខ្លួន រៀបអាសនៈឱ្យអង្គុយ ជូនបារីម្លូស្លាតែ នឹងភេសជ្ជៈផ្សេងៗទៀត តាមការគួរ ។

- បើភ្ញៀវមកពីឆ្ងាយ ដឹងថាត្រូវសំណាក់នៅផ្ទះខ្លួនហើយ គប្បីសាកសួរឃាត់ឱ្យដេកនៅផ្ទះខ្លួន មុនភ្ញៀវសុំសំណាក់ដើម្បីកុំឱ្យភ្ញៀវមានសេចក្ដីអៀនខ្មាស់ទើសទាល់ ហើយត្រូវនាំទៅឱ្យងូតទឹក បង្ហាញបង្គន់ បន្ទប់ដេក នឹងរៀបចំបាយទឹកទទួលដោយរាក់ទាក់ កុំឱ្យមានអាការៈទឹកមុខ នឹងកាយវិការមិនល្អដែលនាំឱ្យភ្ញៀវរង្កៀសចិត្ត មិនស្និទស្នាល ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

- បើយើងជាម្ចាស់ផ្ទះកំពុងធ្វើការ ឬកំពុងដេក ដែលមានសំលៀកបំពាក់មិនគួរសម ឬខ្លួនទទេមានតែខោឬសារុង គ្មានពាក់អាវ ជួនជាភ្ញៀវមកដល់ គប្បីរៀបអាសនៈឱ្យភ្ញៀវអង្គុយរួច ទៅផ្លាស់សំលៀកបំពាក់ដែលមិនសមរម្យនោះចេញ បើខ្លួនទទេ ត្រូវទៅពាក់អាវរួចសឹមមកគួរសមសំណេះសំណាលជាមួយភ្ញៀវ កុំទទួលភ្ញៀវដោយសំលៀកបំពាក់មិនសមរម្យ ឬដោយខ្លួនទទេឬឥតពាក់អាវ ។

- គប្បីហៅប្រពន្ធកូន ឬស្វាមីមកសំពះសួរសុខទុក្ខគួរសមនឹងភ្ញៀវ បើភ្ញៀវនោះជាមនុស្សស្និទស្នាល ឬជាអ្នកមានឧបការគុណ ។

- កំពុងមានភ្ញៀវនៅក្នុងផ្ទះ មិនត្រូវឈ្លោះប្ដីប្រពន្ធ ឬជេរវាយកូនចៅ ស្ដីបន្ទោសទាសកម្មករ ឱ្យភ្ញៀវរំខានចិត្តដោយសារខ្លួនទេ ទោះមានហេតុយ៉ាងណា ក៏ត្រូវអត់ទ្រាំឱ្យភ្ញៀវទៅផុតសិន ។

- ភ្ញៀវកំពុងតែនិយាយជាមួយ មិនគួរបណ្ដោយឱ្យកូន

ចៅប្រឡែងគ្នា ឱ្យមកលំអុកទារនេះនោះ ឬចាប់ទាញខោអាវ ដៃជើង ដែលជាអាការៈឥតរបប ឬក៏បណ្តោយឱ្យឈរ អើត មើលមុខភ្ញៀវ ដែលកំពុងនិយាយ ឬកំពុងបរិភោគអ្វីនោះ ឡើយ, ឯអ្នកដែលមិនបានជាប់និយាយជាមួយភ្ញៀវ ត្រូវនាំ យកក្មេងនោះចេញ ដោយអាការៈប្រយ័ត្ន កុំឱ្យភ្ញៀវរំខានចិត្ត ដោយសារការនាំក្មេងនោះ ។

- បើភ្ញៀវមានកូនមកជាមួយផង គប្បីគួរសមនឹងក្មេង នោះដែរ មានអង្អែលក្បាលចាប់បីព នឹងឱ្យចំណីញ៉ាំជាដើម បើយើងមានកូនដែរ ត្រូវហៅកូនយើង ឱ្យមកស្គាល់គ្នា ហើយ ឱ្យនាំគ្នាទៅលេងផង ។

- មិនត្រូវនិយាយកាត់ពាក្យភ្ញៀវ ដែលកំពុងនិយាយ ទោះពាក្យសំដីនោះ ជាទំនាស់ដល់អធ្យាស្រ័យយើងយ៉ាងណា ក៏ដោយ ត្រូវអត់ទ្រាំ ថ្លែងអាការៈគួរសម បណ្តោយឱ្យភ្ញៀវ និយាយចប់សិន ចាំនិយាយកែសម្រួលជាក្រោយ បើមានការ ចាំបាច់និយាយកាត់ ត្រូវមានពាក្យគួរសមថា " សុំនិយាយ

កាត់បន្តិច ៉ ។ ជាពិសេស មិនត្រូវនិយាយផ្ទាញ់ផ្ទាល បន្ទុះបន្ទាប់ភ្ញៀវ ឱ្យមានសេចក្តីអៀនខ្មាស់ឡើយ ។

- កំពុងមានភ្ញៀវនៅក្នុងផ្ទះ បើមានជនណាមួយ ធ្វើឱ្យប៉ះជល់ទង្គិច ធ្លាក់បែកបាក់ ចានឆ្នាំងកែវជាដើម មិនត្រូវថ្លៃងអាការៈសោកស្តាយ ស្តីបន្ទោសគ្នីគ្នាទេ ទោះបីស្តាយយ៉ាងណា ក៏ត្រូវមានអាការៈស្រស់ស្រាយ ហាក់ដូចជាគ្មានចាប់អារម្មណ៍នឹងវត្ថុទាំងនោះ ។ ត្រូវនិយាយបន្ធូរបរិយាកាស កុំឱ្យភ្ញៀវរំខានចិត្ត មាននិយាយថា «របស់ទ្រព្យ វាតែងតែបែកបាក់ខូចដូច្នេះឯង បើគ្មានការបែកបាក់ខូចទេ អ្នកលក់ក៏គ្មានដែរ» ។

- បើមានការរវល់ចង់ធ្វើអ្វីមួយ មិនត្រូវថ្លៃងអាការៈឱ្យភ្ញៀវដឹងថា ចង់ដេញឱ្យគេឆាប់ទៅនោះទេ ។ វៀរតែមានការចាំបាច់ ដូចជាត្រូវទៅក្នុងពិធីបុណ្យណាមួយ ដែលមានកំរិតពេលវេលានោះ គប្បីនិយាយសំរួល សុំទោសភ្ញៀវថា ៉ខ្ញុំមានការទៅទីនេះទីនោះបន្តិច ព្រោះជិតដល់ម៉ោងហើយ សុំ

អង្គុយលេងជាមួយអ្នកនេះអ្នកនោះសិនចុះ ខ្ញុំសុំអនុញ្ញាតទៅមុន ហើយ សូមអត់ទោសកុំប្រកាន់" ។

- ពេលភ្ញៀវលាត្រឡប់វិញ ត្រូវមានការគួរសមដោយ វាចា សុំឃាត់ឱ្យនៅបន្តិចទៀត ឬថាអីក៏ប្រញាប់ម្ល៉េះ យូរៗ មកលេងម្តង និយាយលៃឱ្យសមទៅតាមឋានៈភ្ញៀវ ។

- ពេលភ្ញៀវទៅវិញ ត្រូវជូនដំណើរយ៉ាងជិត ត្រឹម មាត់ទ្វារផ្ទះ ឬទ្វាររបង បើមានឥវ៉ាន់ គួរជួយកាន់ទៅដាក់ដល់ រថយន្ត ដែលចតនៅមុខផ្ទះ ។ បើភ្ញៀវនោះ ជិះយានឈ្នួល មានស៊ីក្លូជាដើម ត្រូវជួយហៅ ហើយចេញថ្លៃឈ្នួលឱ្យផង ចំពោះអ្នកស្និទស្នាល ឬអ្នកមានឧបការគុណ ។

- ចំពោះការទទួលភ្ញៀវបរទេស ដែលគេមកជាផ្លូវរដ្ឋ ដើម្បីជាកិត្តិយសដល់ប្រទេសជាតិយើងនោះ យើងជាពលរដ្ឋ ទាំងឡាយ ត្រូវតែនាំគ្នាទាំងប្រុសស្រីចាស់ក្មេង ទៅគួរសមអបអរ សាទរ ទទួលគេតាមពេលវេលា ដែលក្រុម គណៈកម្មការបដិសណ្ឋារកិច្ច បានឱ្យដំណឹងតាមវិទ្យុ នឹងតាម

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

សារពត៌មានជាដើម កុំខ្ជិលច្រអូសមិនអើពើ ធ្វើជាមិនដឹងមិនឮ ទោះកំពុងមានការរវល់យ៉ាងណាក៏ដោយ ត្រូវតែឆៀតទៅទទួលគេគ្រប់ៗគ្នា ដោយអាការៈរីករាយ មានទះដៃ បក់ទង់ជាតិ បាចផ្កា នឹងស្រែកឱ្យពរជាដើម ទើបឈ្មោះថាជាអ្នកមានសុជីវធម៌ ។ ឯសំលៀកបំពាក់ ក៏ត្រូវស្លៀកពាក់ឱ្យបានស្អាតបាត សមរម្យមានអាវមានខោ កុំស្លៀកសារុង ខោទ្រនាប់ឥតពាក់អាវឱ្យសោះ បើយើងក្រណាស់គ្មានសំលៀកបំពាក់ថ្មីថ្មោងសមរម្យទេ ក៏ត្រូវតែទៅទទួលឱ្យបានគ្នាច្រើនកុះករដែរ ប៉ុន្តែកុំចេញទៅឈរមុខគេ ។ ពិសេស បើរថយន្តភ្ញៀវជាប្រធានគណៈប្រតិភូទៅផុតហើយ កុំអាលឈប់ទះដៃ ឈប់បក់ទង់ជាតិ ហើយដើរព្រោងព្រាតឡើយ ព្រោះនៅមានរថយន្តសមាជិកគណៈប្រតិភូដែលជាភ្ញៀវទៀត ត្រូវទះដៃ បក់ទង់ជាតិ ស្រែកឱ្យពរគេដែរ ដរាបដល់ផុតក្បួនអស់ សឹមបែកគ្នាទៅទីលំនៅវិញ ។ បើឮដំណឹងថា ឱ្យទៅទទួលទីណាទៀត ត្រូវទៅគ្រប់គ្នាកុំខាន ។

- ជនជាភ្ញៀវ មុននឹងចូលទៅផ្ទះគេ គប្បីឱ្យសញ្ញាដល់

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សានី**

គេសិន មានស្រែកហៅដោយវាចាទន់ភ្លន់គួរសម គោះទ្វារ ឬចុចកណ្ដឹង បើផ្ទះគេមានដាក់នៅមាត់ទ្វារ ឬក៏ក្អកក្រហែមតិចៗ កុំឱ្យគេភ្ញាក់ផ្អើល តែតាមការគួរហើយចាំស្ដាប់គេឱ្យដំណឹងសិន តើគេឱ្យចាំបន្តិច ឬក៏ឱ្យចូលភ្លាម កុំប្រញាប់ចូលឥតច្បាប់ទម្លាប់ ។

- បើបានជួបនឹងម្ចាស់ផ្ទះ ដែលយើងទៅរកនោះហើយ ត្រូវថ្លៃងអាការៈគួរសម សំពះចាប់ដៃ ប្រើពាក្យសំដី ទឹកមុខឱ្យគួរជាទីចាប់ចិត្តរបស់ម្ចាស់ផ្ទះ នឹងលៃឱ្យសមទៅតាមឋានៈផង ។

- បើឃើញមានឆ្កែដេកនៅក្នុងផ្ទះគេ គប្បីសួរថាឆ្កែនេះកាចឬស្លូត ក្រែងម្ចាស់គេភ្លេច នាំឱ្យឆ្កែភ្ញាក់ឡើង ដេញខាំភ័យលោះព្រលឹង កើតចលាចលក្នុងផ្ទះគេ មានខ្វះទៅដល់របូតខោអាវ ដួលត្រឡប់ត្រឡិន នាំឱ្យកើតសេចក្ដីអៀនខ្មាស់ក៏មាន ។

- មុននឹងអង្គុយក្នុងផ្ទះគេ ចាំម្ចាស់ផ្ទះគេបង្ហាញអាសនៈសិន បើផ្ទះគេមានអាសនៈច្រើនបែបដូចជាកៅអីផង គ្រែជើផងជាដើម កុំចេះតែអង្គុយផ្ដេសផ្ដាសតាមចិត្តខ្លួន នាំឱ្យខុស

របៀបផ្ទះគេ អាប់កិត្តយសដល់ខ្លួន ។

- កុំអង្គុយនិយាយ ប៉ប៉ាច់ប៉ប៉ោចយូរពេក នាំឱ្យម្ចាស់ផ្ទះគេធុញទ្រាន់ ត្រូវឱ្យស្គាល់អាការៈរបស់អ្នកម្ចាស់ផ្ទះថា តើគេមានការប្រញាប់ធ្វើអ្វីៗ ឬក៏ទំនេរទេ គេចង់ឱ្យយើងនៅអង្គុយយូរជាមួយគេ ឬក៏គេចង់ឱ្យយើងលាគេឆាប់ ។ ជាពិសេសត្រូវឱ្យស្គាល់ពេលបាយ នឹងពេលដេក កុំទៅផ្ទះគេឱ្យជួបពេលទាំងពីរនេះ ឬអង្គុយឱ្យដល់ពេលទាំងពីរនេះឡើយ ត្រូវប្រញាប់ប្រញាល់លាគេមុន បើមានការច្រើននិយាយមិនទាន់ចប់ចាំថ្ងៃក្រោយទៅទៀត ។

- បើឃើញរបៀបក្នុងផ្ទះគេមិនរៀបរយ នាំឱ្យទាស់ភ្នែក កុំនិយាយ កុំសំឡឹងញយៗ ទាំងកុំនាំឱ្យរឿងរ៉ាវថា ផ្ទះអ្នកនេះអ្នកនោះ គ្មានសណ្ដាប់ធ្នាប់ មិនចេះរៀបចំជាដើម ដែលនាំឱ្យម្ចាស់ផ្ទះ កើតសេចក្ដីអៀនខ្មាស់រង្គោសចិត្តដោយសារខ្លួន ។

- ទៅផ្ទះគេ បើមានយកកូនចៅទៅផង ក្រោយដែលខ្លួនសំពះចាប់ដៃគួរសមរួចហើយ ត្រូវនាំកូនចៅ ឱ្យសំពះសួរ

ជនទាំងនោះផង ។ បើកូនចៅមិនស្គាល់ជនទាំងនោះ ត្រូវប្រាប់ថា នេះអ៊ុំ នេះមា នេះមីងជាដើម ហើយត្រូវឱ្យកូនចៅអង្គុយស្ងៀមក្បែរខ្លួន កុំបណ្តោយឱ្យទៅរុះរើរបស់ទ្រព្យក្នុងផ្ទះគេ បើកូនចៅនោះធ្វើខុសឆ្គងបន្តិចបន្តួច កុំស្តីបន្ទោសទះតប់ចំពោះមុខម្ចាស់ផ្ទះ គប្បីនិយាយសំរួលឱ្យស្រួល ហើយលៃលកឆាប់នាំកូនចៅលាគេមកផ្ទះវិញ ។

- ទៅដល់ផ្ទះគេ បើត្រូវបន្ទោបង់មូត្រ (នោម) ដែលអត់ទ្រាំមិនបាន ទោះយប់ក្តីថ្ងៃក្តី ត្រូវសួរម្ចាស់ផ្ទះសុំកន្លែងបន្ទោបង់ មិនត្រូវបន្ទោបង់ដាក់ទីកៀនកោះ គុម្ពគល់ក្បែរផ្ទះគេទេ ។

- កំពុងនិយាយគ្នាជាមួយម្ចាស់ផ្ទះ បើមានភ្ញៀវថ្មីចូលទៅទៀត ទោះយើងស្គាល់ក្តី មិនស្គាល់ក្តី ត្រូវតែថ្លែងអាការៈគួរសម មានចាប់ដៃជាដើម ដូចម្ចាស់ផ្ទះដែរ ។ បើយើងអស់ការទាក់ទង ជាមួយម្ចាស់ផ្ទះហើយ គប្បីលាត្រឡប់វិញទុកឱកាសឱ្យភ្ញៀវក្រោយ ក្រែងគេមានការសម្ងាត់ ជាមួយម្ចាស់ផ្ទះ ។

បើយើងមកពីឆ្ងាយ ត្រូវនៅសំណាក់ក្នុងផ្ទះគេ មួយថ្ងៃឬពីរបីថ្ងៃ ត្រូវប្រុងកិរិយាមារយាទឱ្យមែនទែន លៃលកយ៉ាងណាឱ្យម្ចាស់ផ្ទះ គេសប្បាយចិត្តដោយសារខ្លួន ។ បើម្ចាស់ផ្ទះគេធ្វើអ្វីៗ ត្រូវជួយធ្វើ ជួយយកចិត្តទុកដាក់ ចំពោះកិច្ចការនោះៗ ទោះបីម្ចាស់ផ្ទះ គេថ្លែងអាការៈគួរសមហាមឃាត់មិនឱ្យធ្វើ ក៏ត្រូវតែជួយធ្វើបន្តិចបន្តួច កុំមើលតែនឹងភ្នែក ឬក៏ធ្វើជាមិនឃើញ ។ ចំពោះស្រីៗវិញ ដូចជាការរៀបបាយទឹក ដាំស្ល ចិតបន្លែ លាងចានឆ្នាំងជាដើម បើអ្នកម្ចាស់ផ្ទះដែលធ្វើនោះ មានឋានៈខ្ពស់ជាង ឬប្រហែលគ្នានឹងយើង ត្រូវតែខ្វល់ខ្វាយជួយធ្វើគេខានពុំបាន ។ នេះជាការគួរសមរបស់យើងចំពោះគេជាម្ចាស់ផ្ទះ ។ មុននឹងលាចេញពីផ្ទះគេទៅ ត្រូវរៀបបត់ភួយមុងខ្នើយ ម្ចូរកន្ទេលដែលគេរៀបឱ្យយើងដេក ដាក់ឱ្យស្រួល កុំទុកចោលរាត់រាយ ឱ្យគេពិបាកដោយសារយើង បើមានសំរាម ឬកំទេចក្រដាសអ្វីៗ ត្រូវប្រមូលចោល បោសឱ្យស្អាតពីកន្លែងបន្ទប់ ដែលគេឱ្យយើងសំណាក់ដេកនៅ ។

- យើងជាភ្ញៀវទៅផ្ទះគេ ប្រយ័ត្នពីរឿងស៊ីជក់បារីមួស្វាឱ្យមែនទែន ព្រោះមានផ្ទះខ្លះគេស្អាតណាស់ មិនឱ្យមានធូលីជិតជាប់នៅកំពលឥដ្ឋ ឬក្តាទេ ។ ដូច្នេះត្រូវប្រុងប្រយ័ត្ន កុំកៀសក្រញមបារីផ្តេសផ្តាស នៅជ្រុងតុឬក៏កៀសនឹងកៅអី ត្រូវកៀសចោលឱ្យចំប្រអប់កំទៀស ឬកន្ថោរ ។ ឯទឹកមាត់ស្វា ឬកំហាកដែលត្រូវខាកស្តោះនោះទៀត ក៏កុំខាកស្តោះផ្តេសផ្តាសខុសកន្ថោរ ឱ្យខ្ទាតប្រឡាក់ផ្ទះគេ ដែលនាំឱ្យម្ចាស់ផ្ទះពិបាកជុះលាងជូត ក្រោយពេលដែលយើងជាមេស្មោកគ្រោក ចេញផុតពីផ្ទះគេទៅ ។ មានម្ចាស់ផ្ទះខ្លះ ឬអ្នកបំរើរបស់គេ រអ៊ូរទាំតិះដៀលយើងថែមទៀត ថាជាមនុស្សគ្មានសុជីវធម៌ ។

- អំពីស្បែកជើង ក៏ត្រូវប្រយ័ត្នដែរ មានផ្ទះខ្លះ គួរដើរចូលទាំងស្បែកជើងបាន ផ្ទះខ្លះត្រូវតែដោះចេញទើបគួរចូលទៅបាន ។ ដើម្បីថាបានមិនបាននោះ ត្រូវមើលផ្ទះគេ គួរដើរចូលទាំងស្បែកជើង ឬមិនគួរ នឹងមើលជើងម្ចាស់ផ្ទះ តើគេពាក់ ឬដោះទុកនៅមាត់ទ្វារ បើឃើញគេពាក់ ទើបយើង

គួរពាក់ចូលទៅបាន ។ ប៉ុន្តែមុននឹងពាក់ចូលទៅ ត្រូវគោះជូតនឹងជំនូតជើង ដែលគេដាក់នៅមាត់ទ្វារឱ្យស្អាត សឹមចូលទៅ ។ បើផ្ទះគេស្អាត ម្ចាស់ផ្ទះគេដោះស្បែកជើងទុកនៅមាត់ទ្វារ គឺគេមិនបានពាក់ដើរក្នុងផ្ទះទេនោះ យើងត្រូវតែដោះទុកនៅមាត់ទ្វារតាមគេ រួចសឹមចូលទៅក្នុងផ្ទះ កុំឱ្យគេរំខានដោយសារយើង ។

- យើងជាភ្ញៀវត្រូវកាន់ចរិយាឱ្យល្អ សមរម្យជាភ្ញៀវពន្ទឺ កុំឱ្យក្លាយខ្លួនទៅជាភ្ញៀវពន្ទិច គឺកុំនាំរឿងហេតុមិនល្អ ទៅនិយាយឱ្យម្ចាស់ផ្ទះគេកើតរឿងហេតុ ទាស់គ្នាក្នុងគ្រួសារ ឬឱ្យអាក់អន់ចិត្តនឹងអ្នកនេះអ្នកនោះ នឹងមិនត្រូវនាំរឿងហេតុអាក្រក់ពីគ្រួសារខ្លួន ទៅលាតត្រដាងប្រាប់គេ មាននិយាយដើមពីម្តាយក្មេក ឪពុកក្មេក ពីភរិយា ពីស្វាមីថា ប្តីខ្លួនមានស្រីសហាយ នៅទីនេះទីនោះធ្វើបាបខ្លួនឱ្យរងទុក្ខវេទនា ហើយក៏យំស្រែករហេមរហាម ជេរប្រទេចស្រីសហាយ នឹងស្វាមីខ្លួន ដោយពាក្យសំដីអាសគ្រាមក្នុងផ្ទះគេ នាំឱ្យម្ចាស់ផ្ទះពិបាក

ចិត្ត អៀនខ្មាស់ដោយសារខ្លួន ។

មានភ្ញៀវខ្លះទៀត ទៅពន្ទិចគេតែម្តង គឺទៅនិយាយបោកប្រាសខ្ចីលុយកាក់ ខ្ចីរបស់ទ្រព្យ ឬយករបស់ចោរ របស់ក្លែងក្លាយ ទៅលក់បញ្ចាំឱ្យ ខ្លះទៀតទៅបន្លំលួចទ្រព្យសម្បត្តិគេតែម្តង ។ ភ្ញៀវដែលមានលក្ខណៈដូច្នេះ ឈ្មោះថាភ្ញៀវពន្ទិច បើបានស្គាល់មុខហើយ មិនត្រូវឱ្យឡើងផ្ទះឡើយ ។

- អំពីការលាម្ចាស់ផ្ទះត្រឡប់វិញ បើក្នុងផ្ទះនោះមានគ្នាបួនឬប្រាំនាក់ គឺមាតាបិតាស្វាមីបងប្អូនគេ នៅអង្គុយជាមួយគ្នា ត្រូវគោរពសំពះ ឬចាប់ដៃង៉ក់ក្បាលលាទាំងអស់គ្នា ដោយអាការៈគួរសម លៃទៅតាមឋានៈមនុស្សចាស់ក្មេង កុំលាតែម្នាក់ ដែលយើងមានការទៅជួប ហើយដើរចេញមកធ្វើព្រងើយ មិនអើពើនឹងអ្នកដទៃទៀតនោះ ជាការមិនសមរម្យទេ ។ បើទ្វារផ្ទះ ឬទ្វាររបងគេបិទ ហើយយើងបើកចេញមកត្រូវបិទឱ្យគេដូចដើមវិញ កុំចំហចោល ។

# ជ-បង និង ប្អូន

ជនទាំងពីរពួក គឺបងប្រុសស្រី និងប្អូនប្រុសស្រីនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក រៀងៗខ្លួនតាមឋានៈដែរ ៖

- បង ត្រូវស្រឡាញ់រាប់អានប្អូនដោយស្មោះត្រង់ មិនត្រូវច្រណែនឈ្នានីស កំណាញ់គិតតែប្រយោជន៍ផ្ទាល់ខ្លួន ព្រោះសុទ្ធតែជាអ្នកកើតមកពីទងសុកតែមួយ មានជាតិលោហិតដូចគ្នា បើមានគ្រឿងឧបភោគបរិភោគ ត្រូវចែករំលែកឱ្យប្អូនបានបរិភោគប្រើប្រាស់ផង នឹងជួយអាហារូបករណ៍ដល់ប្អូនឱ្យរៀនចំណេះវិជ្ជា បានកើតជាពលរដ្ឋចេះដឹង មានសមត្ថភាពគ្រប់គ្រាន់ ។ ដល់ប្អូនមានស្វាមីភរិយា គួរតែចែកដើមទុនថែមទៀត តាមសមត្ថភាពរបស់ខ្លួន ដែលគួរលៃលកចែកបាន ។

- ត្រូវមានពាក្យសំដីល្អ ទឹកមុខរីករាយ ប្រកបដោយមេត្តាករុណាចំពោះប្អូន កុំប្រើអំណាចរបស់ខ្លួនជាបង សំឡុតគំហក កំហែង ជេរបញ្ចោរ ហៅអាមីងដាច់សាច់ គួរហៅថា

ប្អូន. លោកប្អូន-ថីប្អូន-ឬថីអូន, នាងអូន ស្រីអូន ឬក៏ហៅចំណោះថា ប្អូនសៃ.ប្អូនហា-ប្អូនហុក-ប្អូនហាប់ជាដើម។ បើមានបងតិចតែពីរបីនាក់ គួរហៅថាប្អូនប្រុស-ប្អូនស្រីឬបងប្រុស-បងស្រីដូច្នេះក៏សមរម្យម្យ៉ាងដែរ ។

- ត្រូវជួយយកអាសាផ្តល់ប្រយោជន៍ឱ្យប្អូន គឺជួយធ្វើកិច្ចការផ្សេងៗ មានជួយបង្ហាត់បង្រៀន និយាយពន្យល់ប្រាប់ឱ្យប្អូនបានទទួលផលប្រយោជន៍សុខចំរើន ពីខ្លួនបាន ។

- ត្រូវរាប់អានប្អូនយ៉ាងស្មោះស្មើ ដោយសំគាល់ថាជាប្អូនរបស់ខ្លួនបង្កើត មិនត្រូវប្រកាន់ទោសពៃរ៍ មើលបំណាំ ផ្ដន្ទាផ្ដាញ់ផ្ដាល ឱ្យវិនាសអន្តរាយ ដោយហេតុណាមួយឡើយ ។ បើប្អូនប្រព្រឹត្តខុសឆ្គងមកលើខ្លួន ត្រូវតែលុបលាងទោសចោល កុំចងគំនុំ ចងកំហឹងចំពោះប្អូនឱ្យសោះ ។

- ប្អូនត្រូវស្រឡាញ់រាប់អានបង ដោយស្មោះត្រង់ មិនត្រូវច្រណែនឈ្នានីស កំណាញ់គិតតែប្រយោជន៍ផ្ទាល់ខ្លួន បើ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

មានគ្រឿងឧបភោគបរិភោគ ដូចបាយ ទឹកនំចំណី សំលៀកបំពាក់ជាដើម ត្រូវចែកជូនដល់បង តាមសមត្ថភាពរបស់ខ្លួន ។ បើបងជាអ្នកទ័លក្រ ហើយខ្លួនជាអ្នកមាន ត្រូវតែជួយទំនុកបំរុងបងខានមិនបាន ទោះតិចក្តីច្រើនក្តី ដើម្បីយឹតយោងបងកុំឱ្យរហេមរហាម ដុនដាបដាងខ្លួនពេក ។

- ត្រូវមានកាយវិការ នឹងពាក្យសំដីសុភាពទន់ភ្លន់ គោរពចំពោះបង កុំវាយឫកស្មើនឹងបង ហាក់ដូចជាពួកម៉ាក មានហៅថា អានេះ.អានោះ-មីនេះ-មីនោះ ឬក៏ហៅតាមរូបភាពរបស់បងថា អាសំគម-មីសំគម-អាម៉ាប់. មីកន្ទាត់ជាដើម ដែលជាពាក្យព្រហើនឥតគួរសម, ត្រូវហៅថា បង - អ្នកបងថីបង - លោកបង - ស្រីបង ឬក៏ហៅថាបងប្រុស - បងស្រីដូច្នេះក៏គួរម្យ៉ាងដែរ បើមានបងប្អូនតិចមិនច្រឡំគ្នា ។ ជាពិសេសបងប្អូនប្រុសស្រី មិនត្រូវនិយាយអ្វីៗ ដែលនាំឱ្យកើតសេចក្តីអៀនខ្មាស់ រវាងភេទនឹងភេទទេ ។

- ត្រូវជួយផ្តល់ប្រយោជន៍ឱ្យបង មានជួយហុចនេះ ហុច

នោះ ឬទៅទិញអ្វីៗ តាមដែលបងប្រើ នឹងជួយកិច្ចធុរៈរបស់បង មានជួយធ្វើការងារផ្សេងៗ ដែលខ្លួនអាចជួយបាន កុំខ្ជិលច្រអូស កុំគិតទារថ្លៃឈ្នួលរង្វាន់អ្វីអំពីបង គឺត្រូវជួយផ្តល់ប្រយោជន៍ឱ្យបងពិតៗ ។

- ត្រូវរាប់អានស្មោះស្មើអស់ពីចិត្តថ្លើម ដោយសំគាល់ថាជាបងបង្កើត រួមឧទរជាមួយខ្លួន មិនត្រូវបៀតបៀន ប្រកាន់ខឹង ចងគំនុំគុំគួនព្យាបាទ ប្រមាទមើលងាយ ទោះបីបងបានប្រព្រឹត្តខុសធ្ងាំធ្ងងមកលើខ្លួនក៏ដោយ ឬក៏បងនោះជាមនុស្សថោកទាប លូងទ័លក្រគ្មានបុណ្យស័ក្តិ ក៏គប្បីរាប់អានគោរពក្នុងឋានៈជាបងរបស់ខ្លួនជាដរាប ។

## ឈ-អ្នករាជការ និងប្រជារាស្ត្រ

បុគ្គលទាំងពីរពួកនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមកចំពោះគ្នានិងគ្នា តាមឋានៈរៀងៗខ្លួនៈ

- អ្នករាជការគ្រប់ប្រភេទ ត្រូវប្រព្រឹត្តឱ្យត្រឹមត្រូវតាម

ច្បាប់សំរាប់រដ្ឋ ដែលជាករណីយ៍របស់ខ្លួន ត្រូវបំពេញតាមមុខក្រសួង ដើម្បីប្រយោជន៍ដល់ប្រទេសជាតិ នឹងប្រជារាស្ត្រ ។ ឯអ្នករាជការ នឹងប្រជារាស្ត្រនេះ មានការប្រស្រ័យទាក់ទងគ្នាជាចាំបាច់ជានិច្ចកាល ព្រោះជាអ្នកបំរើរាស្ត្របំរើរដ្ឋ ។ ដូច្នេះ អ្នករាជការទាំងឡាយ កាលបើមានប្រជារាស្ត្រចូលទៅប្រស្រ័យជាមួយ មានបង់ពន្ធ នឹងសុំច្បាប់អនុញ្ញាតផ្សេងៗជាដើម គប្បីមានការគួរសម ទឹកមុខរីករាយ ហៅឱ្យអង្គុយ គោរពចាប់ដៃ និយាយដោយពាក្យសំដីពីរោះពិសា លៃតាមឋានៈចាស់ក្មេងឱ្យសមតាមភាពខ្លួន ជាអ្នកបានរៀនចេះដឹង រហូតដល់បានឋានៈជាអ្នករាជការ ។

- មិនត្រូវលំអៀង ឱ្យឃ្លាតពីករណីយ៍កិច្ចរបស់ខ្លួន ព្រោះតែស្រឡាញ់ ស្អប់ - លង់ នឹងខ្លាច គប្បីបំពេញការងារឱ្យត្រឹមត្រង់ តាមករណីយ៍របស់ខ្លួន ដែលបានទទួលពីចៅហ្វាយនាយមក ។

- មិនត្រូវប្រកាន់ឋានៈប្រជារាស្ត្រ ទោះបីប្រជារាស្ត្រនោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សារឹម**

ជាអ្នកលួង ត្រីត្រជោកទាប យ៉ាងណា ក៏ត្រូវមានពាក្យសំដីនឹងកាយវិការឱ្យសមរម្យ គោរពដល់សិទ្ធិមនុស្ស កុំឃើញគ្នាអន់ខ្សោយហើយ ហៅគ្នាអាមីងគំពោះគំរើយ ឬធ្វើជាមិនឃើញមិនរវល់ចំពោះកិច្ចការរបស់គ្នា ឱ្យគ្នាឈរចាំ ឬអង្គុយនឹងដីឬក៏ដេញគ្នាឱ្យទៅចាំឯក្រៅ ជាពបដល់ហួសម៉ោង ទើបដេញគ្នាថែមឱ្យទៅផ្ទះវិញ ថាចាំថ្ងៃនេះថ្ងៃនោះ សឹមមកនោះឡើយ ។ បើមិនសូវមានការរវល់ ជាចាំបាច់ពេកទេនោះ គួរតែប្រញាប់ប្រញាល់ ធ្វៀតធ្វើឱ្យគ្នាមុន ព្រោះអ្នកទ័លក្រខ្សត់ខ្សោយច្រើនតែសម្បូរណ៍ទៅដោយសេចក្ដីភ័យខ្លាចច្រើនផង គ្មានសោហ៊ុយនឹងធ្វើដំណើរទៅមកញយៗ ផង ។

- មិនត្រូវយកការងារផ្ទាល់ខ្លួន ទៅធ្វើក្នុងការិយាល័យដោយខ្លួនឯង ឬប្រើអ្នកក្រោមបង្គាប់ឱ្យធ្វើ ព្រោះជាហេតុឱ្យសៅហ្មងច្រើនយ៉ាង នាំឱ្យអ្នកក្រោមបង្គាប់មើលងាយផង, នាំឱ្យអ្នកក្រោមបង្គប់យកតម្រាប់តាមផង, នាំឱ្យយឺតយូរដល់ការងារ ដែលប្រជារាស្ត្រទៅប្រស្រ័យផង នឹងនាំឱ្យមានការភ្ញាំង

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ក្ងាត់ខុស ដល់ការងារពជការ ដែលជាករណីយ៍កិច្ចរបស់ខ្លួនផង ព្រោះរវល់តែជក់ចិត្តគំនិត ជាប់ដៃនឹងការងារនោះ ។ ជួនកាលកំពុងតែធ្វើមានប្រជារាស្ត្រចូលទៅជួប ច្រើនតែឃាត់ឱ្យគេចាំខ្លួន ដែលកំពុងតែធ្វើការជាប្រយោជន៍ផ្ទាល់ខ្លួននោះសិន ។

- បើមានមិត្រសំឡាញ់ ទៅជជែកលេងជាមួយ ក្នុងការិយាល័យ ក្នុងថ្ងៃដែលធ្វើការ ឬមានកំពុងមើលសារពត៌មាន ហើយមានប្រជារាស្ត្រចូលទៅប្រស្រ័យជាមួយ គប្បីបញ្ឈប់ការជជែកលេងក្រៅផ្លូវការនឹងការមើលសារពត៌មាន របស់ខ្លួននោះសិន បែរមកទទួលបំពេញកិច្ច ឱ្យប្រជារាស្ត្រភ្លាមៗ, មិនគួរឃាត់ឱ្យគេចាំ ហើយខ្លួនចេះតែមើល ចេះតែជជែកគ្នាលេងពីនេះពីនោះ មានរឿងស្រីញី និងរឿងតុងទីនជាដើម ឱ្យប្រជារាស្ត្រគ្នាចាំអស់មួយម៉ោងពីរម៉ោងនោះឡើយ ។ មានខ្លះ ដេញអ្នកទៅប្រស្រ័យការនោះឱ្យទៅផ្ទះវិញ ថាចាំស្អែក ព្រោះថ្ងៃនេះមានការរវល់ គឺរវល់នឹងជជែកគ្នាលេងពីរឿងស្នេហាជាដើមនោះផង ។

ក្នុងការិយាល័យធ្វើការ មិនគួរយកបាយទឹកនំចំណី មានគុយទាវជាដើម ទៅបរិភោគ ឱ្យប្រឡាក់តុទូ ឬដាក់ចាន ទើរលើមេទ្វាបង្អួច ឬដាក់កៀនជញ្ជាំង ឱ្យមានក្លិនមិនស្រួល នឹងគ្រខ្វក់ខូចលំអរការិយាល័យរបស់រដ្ឋ នាំឱ្យជនបរទេស នឹងប្រជារាស្ត្រ ដែលចូលប្រស្រ័យជាមួយ ឃើញលក្ខណៈឥតរបប មិនស៊ីវិល័យ អាចម៉ៃបានថាជាមនុស្សគ្មានសុជីវធម៌ ។

- បើមានប្រជារាស្ត្រ ចូលទៅប្រស្រ័យក្នុងការិយាល័យ មិនគួរនិយាយគ្នាពីរឿងអាសគ្រាម មានចំអកចំអន់គ្នា ជាមួយស្រីឈ្មោះនេះឈ្មោះនោះ នៅទីនេះទីនោះ យ៉ាងនេះយ៉ាងនោះ ហើយសើចជាដើម ដែលនាំឱ្យមានសេចក្ដីអៀនខ្មាស់រង្កៀសចិត្តអ្នកចូលទៅប្រស្រ័យជាមួយ ។

- គប្បីតាំងចិត្តថា ជាអ្នកធ្វើការឱ្យរាស្ត្រ ឱ្យរដ្ឋពិតៗ កុំយកឋានៈនឹងមុខក្រសួងធ្វើជាអាវុធធ្វើជាមុខយក្ស ពាក់សំឡុតបំភ័យរាស្ត្រ ដែលទៅប្រស្រ័យជាមួយឱ្យភិតភ័យតក់ស្លុតខ្លាចមានបំភ័យបទ្វាចថា ការនេះពិបាកណាស់-ខុសហើយ-គ្មាន

ទេ -ហួសពេលហើយ - អ្នកឯងត្រូវលក់ពិន័យហើយ - តម្លៃពិន័យប៉ុណ្ណេះៗយ៉ាងតិចជាដើម ដើម្បីឱ្យអ្នកទៅប្រស្រ័យនោះវេចិត្តគំនិតធ្លាក់ទៅក្នុងផ្លូវស្ទូកប៉ាន់ ពឹងពាក់ឱ្យខ្លួនជួយ ហើយក៏បន្ថែមបើកផ្លូវទៅទៀតថា ខ្ញុំមិនអីទេ ចេះតែជួយបាន ចាំខ្ញុំទៅជួយនិយាយអង្វរលោកនេះ លោកនោះឱ្យ ប៉ុន្តែទាល់តែប៉ុណ្ណេះៗទើបបាន ។ នេះជាលក្ខណៈមនុស្សគ្មានសុជីវធម៌ ។

- គប្បីរាប់អានប្រជារាស្ត្រ ដែលចូលទៅប្រស្រ័យជាមួយដោយស្មោះស្មើ ដូចជាមាតាបិតាបងប្អូន ញាតិសន្តានខ្លួនមិនគួរធ្មើងឆ្មៃបៀតបៀន ប្រើអំណាច សំឡុតបំភ័យជាដើម ។

- គួរទៅការិយាល័យធ្វើការ ឱ្យទាន់ពេលម៉ោងដែលបានកំរិត ដើម្បីឱ្យស្រួលដល់ប្រជារាស្ត្រ កុំឱ្យគ្នាពិបាកទៅចាំ ។ ឯការចេញពីការិយាល័យវិញក៏ដូចគ្នា ព្រោះបើពេលចេញ ទឹងចូលមិនទៀងតាមពេលម៉ោងទេ ប្រជារាស្ត្រដែលមានការ ត្រូវទៅប្រស្រ័យតែពីរបីនាទី ទៅជាខាតពេលអស់ពីរបីថ្ងៃ មកពីទៅមិនចេះជួប ។

- ប្រជារាស្ត្រ ត្រូវមានចិត្តស្មោះត្រង់ លះបង់នូវការកេងកិប បំបាត់រាជការ ត្រូវបង់ពន្ធអាករឱ្យគ្រប់គ្រាន់តាមកំរិតច្បាប់ និងតាមពេលវេលា កុំប្រើគំនិតអាក្រក់គ្មានសុជីវធម៌ ស៊ូយកលុយកាក់ទៅសូកអ្នករាជការ ឱ្យជួយលួចបន្ថយប្រាក់ពន្ធខ្លួនឱ្យថយនៅតិច ដើម្បីបានចំណេញច្រើន ហើយសំគាល់ខ្លួនឯងថា ជាមនុស្សឆ្លាតទាន់សម័យ ប៉ិនរកស៊ីធ្វើការ ។ ប៉ុន្តែបើផ្ទុយទៅវិញ គឺជាចោរពិតប្រាកដ លួចសម្បត្តិរដ្ឋសម្បត្តិជាតិ ។

- ត្រូវមានសេចក្តីគួរសមជានិច្ច ក្នុងពេលដែលមានការចូលទៅប្រស្រ័យជាមួយអ្នករាជការ ទោះបីខ្លួនជាអ្នកមានទ្រព្យសម្បត្តិ មានមិត្រសុទ្ធតែជាអ្នកមានយសស័ក្តិធំដុំយ៉ាងណាក៏ដោយ ត្រូវតែមានការគួរសម សំពះចាប់ដៃ និយាយសុភាពរាបសា គោរពឱនលំទោន កុំប្រើឫកពាក្រអឺតក្រទម ទៅអង្គុយច្រត់តុ ស្ទឹមចង្កេះ ក្រពាត់ដៃ ប្រើទឹកមុខមើលងាយឱ្យសោះ ។

- ច្បាប់បញ្ញត្តិ ឬបទបញ្ជាទាំងឡាយ ដែលរាជការបានប្រកាស ផ្សាយប្រាប់ឱ្យដឹងហើយ ត្រូវប្រតិបត្តិគោរពតាម

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

កុំឆ្លេសប្រហែស ដរាបដល់រាជការលក់ពិន័យ ដូចជាពន្ធទឹក ពន្ធភ្លើង ផ្ទាកកង់ជាដើម ទើបឈ្មោះថាជាអ្នកមានសុជីវធម៌ ។

- ការប្រស្រ័យទាក់ទង ជាមួយអ្នករាជការគ្រប់យ៉ាង ត្រូវគោរពច្បាប់ជានិច្ច មិនត្រូវរំលោភមើលងាយ សំគាល់អ្នករាជ-ការថា ដូចជាវត្ថុអ្វីមួយ ដែលខ្លួនអាចយកលុយកាក់ទៅទិញបាន ហើយប្រើឧបាយកល ក្នុងអំណាចនៃសេចក្ដីលោភ យកលុយកាក់ទៅលួងលោមប្រលោមទិញ ធ្វើឱ្យអ្នករាជការនោះភ្លុកភ្លឹកភាន់កាំង ប្រព្រឹត្តអំពើពុករលួយដោយសារខ្លួន ព្រោះតែខ្លួនចង់បានចំណេញច្រើន នឹងចង់បានឈ្នះជាដើម ។

- ត្រូវចេះចាញ់ចេះឈ្នះ គឺចេះទទួលខុសត្រូវអំពីអ្នករាជការ មិនគប្បីចចេសរឹងមុខ ខ្លួនចាញ់គេហើយ ខ្លួនខុសហើយ នៅតែមិនព្រមចាញ់ សុខចិត្តខុស ចេះតែទទូចតវ៉ាធ្វើឱ្យរំខានដល់អ្នករាជការ ឱ្យរវល់តែដោយសារខ្លួន ។ នេះជាលក្ខណៈរបស់មនុស្សកំសាក គ្មានសុជីវធម៌ មិនគោរពច្បាប់ទម្លាប់ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

- មិនត្រូវខ្លាចហួសហេតុហួស ចំពោះអ្នករាជការ គប្បីដឹងថា អ្នករាជការ គឺជាអ្នកធ្វើការដើម្បីសុខស្រួល ចំរើនរុងរឿងដល់ប្រជារាស្ត្រ ។ ដូច្នេះយើងជារាស្ត្រ មិនត្រូវញ័រញាក់ខ្លាចធ្វើមុខស្លាំង ដើរឱបដៃត្រុន ៗ ចូលទៅក្នុងការិយាល័យណាមួយ ដរាបដល់គេគួរសមហៅឱ្យអង្គុយចេះតែឈរ ឬក៏អង្គុយផ្ទាល់នឹងដី និយាយអ្វីៗញាក់ញ័ររកស្តាប់មិនបាននោះឡើយ ។ ហើយកុំហ៊ានហួស ដរាបដល់មានអាការៈព្រហើនច្រងេងច្រងាង និយាយខ្លាំងៗឡូឡា វាសដៃជើង ដែលជាលក្ខណៈ ខ្វះសេចក្តីគោរពគួរសម ។

- មុននឹងចូលទៅ ក្នុងបន្ទប់ការិយាល័យណាមួយបើមានទ្វារបិទ ឬបុគ្គលិកក្នុងបន្ទប់នោះ កំពុងធ្វើការអ្វីៗដែលមិនបានឃើញយើងទៅ មិនត្រូវដើរចូលទៅតែម្តងទេ គប្បីឱ្យសញ្ញាដោយគោះទ្វារ ឬក្អកកត្រហែមតិចៗ កុំឱ្យភ្ញាក់ផ្អើល បើគេអនុញ្ញាតហៅឱ្យចូលទៅ ទើបគួរទៅបាន ។

- ពេលប្រស្រ័យការរួចហើយ គប្បីគោរព សំពះឬចាប់

ដែលគេមកវិញ ដោយអាការៈសមរម្យ កុំក្រោកដើរចេញធ្វើព្រងើយ ឥតការគួរសម ។

- ត្រូវស្គាល់ពេលវេលា នឹងកិច្ចការដែលខ្លួនទៅប្រស្រ័យជាមួយអ្នករាជការ គឺបើកិច្ចការយើង បានបំពេញសព្វគ្រប់ហើយ គប្បីលាត្រឡប់វិញភ្លាម កុំអង្គុយសំកុក និយាយសូញសាញ ដដែល ៗ ក្រែងខ្លាចតែគេមិនធ្វើឱ្យ ដរាបដល់ធុញទ្រាន់ ដេញឱ្យក្រោកចេញ នាំឱ្យខូចកិត្តិយស ។ ប៉ុន្តែកុំប្រញាប់ប្រញាល់ពេក ដល់ភ្លេចភ្លាំងនិយាយមិនអស់កិច្ច ដែលត្រូវនិយាយ ។

- ប្រជារាស្ត្រ ត្រូវរាប់អានអ្នករាជការដោយស្មោះស្មើ ដោយតាំងចិត្តថា ដូចជាមាតាបិតា មាមីង បងប្អូនរបស់ខ្លួន កុំរិះគន់បៀតបៀនមើលងាយ មានលួចជេរប្រមាថ ដាក់បណ្ដាសា ព្រោះតែការពឹងពាក់ សុំអ្វីៗមិនបាននោះឡើយ ។

- ការចូលទៅប្រស្រ័យជាមួយអ្នករាជការ ត្រូវប្រើសំលៀកបំពាក់សមរម្យស្អាតបាត ។ ចំពោះការចូលទៅប្រស្រ័យជាមួយវរជន ដែលមានបណ្ដាស័ក្តិធំដូចរដ្ឋមន្ត្រីជាដើម បើឱ្យសមរម្យ

គួរប្រើសំលៀកបំពាក់ក្រុង ឬអាវសឺមីដៃវែងចងក្រវាត់ មិនគួរពាក់អាវដៃខ្លី ពាក់ស្បែកជើងផ្ទាត់ទេ ។ វៀរជាដាច់ខាត នូវការមូរដៃអាវ ព្រោះជាអាការៈខ្វះសេចក្តីគួរសម ។

- ការគោរពសំពះ ទីងចាប់ដៃចំពោះវរជន ក៏គួរប្រយ័ត្នដែរ ត្រូវឱ្យចេះរបៀប គឺរាស្ត្រសំពះវរជនដែលមានយសស័ក្តិទីឧកញ៉ា ត្រូវលើកដៃសំពះត្រឹមច្រមុះ, សំពះអ្នកមានគុណមានមាតាបិតាជាដើម ត្រូវលើកដៃសំពះត្រឹមចិញ្ចើម, អ្នករាជការសំពះចៅហ្វាយនាយ ដែលមានយសស័ក្តិតូចជាងទីឧកញ៉ា ត្រូវលើកដៃសំពះត្រឹមមាត់, មនុស្សស្មើស័ក្តិគ្នា ឬរាស្ត្រដូចគ្នា ត្រូវលើកដៃសំពះត្រឹមទ្រូង ។

- អំពីការចាប់ដៃ អ្នកមានអាយុតិចជាង និងរាស្ត្រ ឬអ្នករាជការតូចតាច មិនត្រូវហុចដៃ ទៅចាប់មនុស្សចាស់ជាង, ទៅចាប់ក្សត្រ, ទៅចាប់មន្ត្រីមុនទេ បើជួបប្រទះហើយ ត្រូវលើកដៃសំពះ ឬឈរទឹមជើង ឯក់ក្បាល បន្ទន់ខ្លួនបន្តិចគោរពសិន ចាំជនទាំងនោះហុចដៃមក សឹមទទួលចាប់ ។ ជាពិសេស

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី សស់ សាទី

ចំពោះស្ត្រីភេទ បុរសមិនត្រូវហុចដៃទៅចាប់មុនទេ ។ ដូច្នេះ យើងជាភស្ត្រ បើមានការចូលទៅប្រស្រ័យជាមួយអ្នករាជការ ដែលមានបណ្តាស័ក្តិ ត្រូវប្រយ័ត្នកុំប្រទ្បំហុចដៃទៅចាប់មុន ។

## ៣-អ្នកមាន និង អ្នកក្រ

- ជនទាំងពីរពួកនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ ៖

- អ្នកមានទ្រព្យសម្បត្តិ ត្រូវមានចិត្តមេត្តាករុណា ចំពោះខ្លួននិងអ្នកដទៃ កុំលុះទៅក្នុងអំណាចលោភៈ កំណាញ់ស្វិតស្វាញ គិតតែពីបានប្រមូលទុក ស៊ូស្លៀកពាក់ បរិភោគចំណីអាហារ រយីករយាក រលីបរលោប ដូចជាខ្ញុំកញ្ជះគេ នាំឱ្យខូចកិត្តិយសខ្លួន ។ ជនខ្លះលុះទៅក្នុងសេចក្តីលោភ ឱ្យអំណាចទ្រព្យជិះជាន់ធ្វើឱ្យធ្លួតវង្វេង ហ៊ានប្រព្រឹត្តអំពើទុច្ចរិត អាក្រក់ស្មូរជនគ្រប់យ៉ាង មានលួចលាក់គេងកិបប្រាក់ពន្ធរាជការ នឹងប្រព្រឹត្តអំពើពុករលួយ សូកប៉ាន់ជាដើម ។ មានខ្លះទៀត ហេតុតែចង់

បានស្មើរដាច់ខ្យល់ស្លាប់ ស្ងួកគេហើយនៅមិនអស់ចិត្ត ខំនាំកូនប្រពន្ធនឹងកម្មករទៅគួរសម ជួយធ្វើការរុះរើ ធ្វើផ្ទះសម្បែងអបទ្រដើងគេនោះទៀត ។ នេះជាការអែបអប ល្បួងផ្គុំត្រចៀកដាក់ស្នេហ៍ ដើម្បីញ៉ាំងអ្នកនោះឱ្យធ្លាក់ស៊ុបទៅក្នុងអំពើពុករលួយសំរាប់បំពេញបំណងក្រខ្វក់របស់ខ្លួន ។ ម្យ៉ាងទៀត នៅទីណាដែលសង្ឃឹមថា នឹងស្រវ៉ាកើបយកប្រយោជន៍បានច្រើន នាំគ្នាទៅឈររហង់នៅទីនោះ លេបទឹកមាត់ក្អឿកក្អែកសំឡឹងភ្លឹះៗដូចកុកសំគមជំហមត្រី មិនចេះអៀនខ្មាស់ មិនចេះស្អប់ស្អល់ចង់បានឥតរបប គ្មានសុជីវធម៌ ។

- ដូច្នេះអ្នកមានទ្រព្យសម្បត្តិទាំងឡាយ ត្រូវដម្កល់ខ្លួនឱ្យប្រកបដោយសុជីវធម៌ គឺរស់នៅក៏ឱ្យគាប់ ស្លាប់ទៅក៏ឱ្យគួរ បានដល់ការចេះរកទ្រព្យ នឹងចេះចាយវាយទ្រព្យ ឱ្យសមតាមឋានៈកិត្តិយសខ្លួនដែលជាអ្នកមានទ្រព្យ នឹងត្រូវធ្វើបុណ្យទាន ចែករំលែកសង្គ្រោះដល់អ្នកដទៃ កុំគិតតែពីសង្កត់កបឺតឈាមគេតាមអំណាចទឹកប្រាក់ គឺត្រូវជួយសង្គ្រោះដោយគ្រឿងឧបភោគ

បរិភោគ រំលែកសេចក្តីសុខ ចែកដល់អ្នកក្រខ្សត់ ឱ្យគ្នាបាន សុខខ្លះដូចខ្លួនផង ។

- ត្រូវមានកាយវិការ នឹងពាក្យសំដីគួរសម ចំពោះ អ្នកក្រខ្សត់ជាងខ្លួន មិនត្រូវវាយឫកខ្ពស់ឆ្មើងឆ្មៃ ដោយអាង កញ្ចប់ទ្រព្យសម្បត្តិ ហើយប្រើទឹកមុខមើលងាយ ដើរចង់ជាន់ អ្នកក្រខ្សត់ និយាយពាក្យសំដីអសុរោះ ហៅអាមីង ឯងអញ អ៊ីអើ វ៉ែយវ៉ី ព្រហើនកោងកាចនោះឡើយ គប្បីប្រើពាក្យសំដី ឱ្យសុភាព ចំពោះអ្នកក្រខ្សត់ មានពាក្យថាលោក លោកតា លោកយាយ មីងមា ពូអ៊ុំ បងប្អូនជាដើម ។

- ត្រូវប្រើជាប្រយោជន៍ដល់អ្នកក្រខ្សត់ ចេះជួយផ្តល់ សំរាលសេចក្តីខ្វះខាត ជួយធុរៈ ផ្តល់ការងារឱ្យធ្វើ នឹងរំលឹក ដាស់តឿន ជួយដោយមធ្យោបាយណាមួយ ឱ្យគ្នាបានសុខ ចំរើន គួរតាមសមត្ថភាពខ្លួន ។ ព្រោះដើមកំណើតទ្រព្យ សម្បត្តិរបស់ខ្លួន កើតមកពីអ្នកក្រខ្សត់ គឺរកបានពីអ្នកក្រមក ។

- ត្រូវរាប់អានដោយស្មោះស្មើចំពោះអ្នកក្រខ្សត់ ដោយ

សំគាល់ថា ដូចជាមាតាបិតា ជីដូនជីតា មាមីង បងប្អូនខ្លួនដែរ មិនត្រូវបៀតបៀនសង្កត់សង្កិន បឺតជញ្ជាក់ឈាមទេ ត្រូវរាប់អានក្នុងឋានៈ ជាមនុស្សជាតិដូចគ្នា ។

- ឯអ្នកក្រខ្សត់វិញ ត្រូវមានចិត្តមេត្តាករុណា ចំពោះអ្នកមានទ្រព្យសម្បត្តិ មិនត្រូវច្រណែនឈ្នានីស លោភលន់ហួសប្រមាណ ដរាបដល់ទៅលួចប្លន់ បោកបញ្ឆោតកេងកិបយកទ្រព្យសម្បត្តិរបស់គេ ។ បើមានបាយទឹកនំចំណីម្ហូបអាហារគួរចែកជូនអ្នកមានទ្រព្យតាមកាលគួរ ដោយសេចក្តីរាប់អានទោះវត្ថុនោះឧត្តុង្គឧត្តម ឬថោកថយតែន្តិចបន្តួចក៏ដោយ ។

- ត្រូវមានកាយវិការ នឹងពាក្យសំដីទន់ភ្លន់ សុភាពរាបសា ឱនលំទោន ចំពោះអ្នកមានទ្រព្យសម្បត្តិ កុំប្រើឫកពារព្រហើនកោងកាច អាងកម្លាំងបាយ ត្មះតិះដៀលជេរបញ្ចោរថា អាអ្នកមាន អាចក្រពត្តិ អាមូលធនជាដើម គប្បីប្រើតែពាក្យគួរសម មានហៅថា លោក អ្នក ពូមីង បងប្អូនជាដើមលៃតាមឋានៈចាស់ក្មេង ។

- ត្រូវជួយផ្ដល់ផលប្រយោជន៍យកអាសា លុះមិនឱ្យអ្នកមានទ្រព្យសម្បត្តិពឹងពាក់បាន ក្នុងពេលមានការក្រលំបាកយប់ថ្ងៃ កុំប្រកាន់ចិត្តឈ្នានីស ទាល់តែគេឱ្យឈ្នួលផ្ទាន់ ទើបជួយយកអាសានោះឡើយ បើបានដឹងហេតុផលអាក្រក់ ដែលនាំឱ្យវិនាសខូចទ្រព្យសម្បត្តិ ឬអន្តរាយដល់ជីវិតអ្នកមានទ្រព្យនោះ គប្បីប្រាប់ ហើយជួយការពារផង កុំឱ្យវិនាសអន្តរាយបាន ។

- ត្រូវរាប់អានដោយស្មោះស្មើ អស់ពីចិត្តថ្លើម ដោយសំគាល់ថា ដូចជាមាតាបិតា ញាតិសន្ដានរបស់ខ្លួនៗ មិនត្រូវប្រកាន់ថាគេមាន ឯងក្រ ទុកជាសត្រូវគ្នានោះឡើយ ។

## ជ-ម្ចាស់យានជំនិះ និងអ្នកជិះ

បុគ្គលទាំងពីរប្រភេទនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមកតាមឋានៈរៀងៗខ្លួនដែរ៖

- រថយន្តផ្ទាល់ខ្លួនតូច បើមានហៅគេឱ្យជិះជាមួយផង បើម្ចាស់រថយន្ត ត្រូវបើកទ្វារអញ្ជើញ ឱ្យគេឡើងជិះអង្គុយ

ស្រួលបួលហើយ បិទទ្វារស្រេច ទើបគួរឡើងជិះជាក្រោយ ។

- បើមានគ្នាត្រឹមតែពីរឬបីនាក់ និងម្ចាស់រថយន្ត ជាអ្នកបើកបរនោះ យើងជាភ្ញៀវដែលគេអញ្ជើញឱ្យជិះ ត្រូវជិះទន្ទឹមនិងអ្នកបរ គឺជិះបាំងមុខជាមួយគ្នាទើបគួរ ។ បើយើងជិះបាំងក្រោយ នាំឱ្យខូចកិត្តិយសដល់ម្ចាស់រថយន្តដែលជាអ្នកបើកបរ ។ អ្នកផងគេសំគាល់ថា អ្នកបរនោះ ជាអ្នកស៊ីឈ្នួលយើងទៅវិញ ។

- បើរថយន្តនោះជារបស់អ្នកធំ មានឈ្នួលបរ ហើយលោកហៅឱ្យជិះ យើងត្រូវជិះជាមួយអ្នកបរ វៀរតែអ្នកធំហៅឱ្យទៅអង្គុយជិត ទើបគួរជិះបាំងជាមួយលោកបាន ។

- បើយើងអ្នកតូចជាម្ចាស់រថយន្ត មានឈ្នួលបរ ហើយអញ្ជើញអ្នកធំណាមួយឱ្យជិះជាមួយ ត្រូវឱ្យអ្នកធំនោះជិះបាំងក្រោយ លុះបើកទ្វារឱ្យលោកជិះស្រួលបួល បិទទ្វារហើយ យើងត្រូវជិះខាងមុខ ។ វៀរតែលោកហៅឱ្យជិះជាមួយ ។

- មនុស្សស្មើគ្នា តែពីរនាក់នឹងយើង ត្រូវជិះជាមួយគ្នា

ខាងក្រោយ ។ បើម្ចាស់រថយន្តជាអ្នកបរ យើងត្រូវជិះជាមួយគ្នាខាងមុខ ។

- បើចៅហ្វាយនាយ ឬអ្នកធំណាមួយ ប្រើទៅណាមកណា ឱ្យឈ្នួលបររថយន្តលោកជូនទៅ យើងត្រូវអង្គុយជិតអ្នកបរ មិនត្រូវអង្គុយក្រោយចំកន្លែង ដែលចៅហ្វាយនាយ ឬអ្នកធំតែងជិះទេ ។ វៀរតែរថយន្តនោះ មានកន្លែងតែមួយចេញ ។

- បើរថយន្តធំ (កាមីញ៉ុង) ត្រូវឱ្យអ្នកធំ មនុស្សចាស់ ឬស្ត្រីអង្គុយមុខ បន្ទាប់ពីនាក់បរមក, ឯយើងជាអ្នកតូចតាច ឬក្មេងជាងគេ ត្រូវអង្គុយក្រោយ ។ វៀរតែរថយន្តឈ្នួលដែលមានលក់លេខកន្លែងចេញ ។ បើជាព្រះសង្ឃវិញក៏ដូច្នោះដែរ អង្គណាដែលខ្ចីវស្សា ឬគ្មានសមណស័ក្តិត្រូវគង់ខាងក្រោយ ទុកកន្លែងខាងមុខប្រគេនលោកគ្រូ មហាថេរ ឬព្រះអង្គណាដែលមានសមណស័ក្តិធំជាងខ្លួន ។

- អ្នកជិះក្នុងរថយន្ត អយស្ម័យយាន ឬកប៉ាល់យាន កាណូតជាដើម ទោះជិះមានឈ្នួលក្តី ឥតឈ្នួលក្តី មិនត្រូវខាកស្តោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេ សាធី**

ទឹកមាត់ ឬជក់បារី ឱ្យហុយ ឱ្យខ្ទាតប្រឡាក់អ្នកជិះជាមួយទេ ទាំងមិនត្រូវជជែកប្រកែកឡូឡាឈ្លោះទាស់គ្នា ឬនិយាយចំអកគេវង្វាសអាក់អន់ចិត្ត ។

- ចំពោះបុគ្គលិកអ្នកធ្វើការ ក្នុងរថយន្តឈ្នួល ឬអយ-ស្ម័យយានជាដើម ដូចជាអ្នកលក់សំបុត្រ នឹងអ្នករៀបចំកន្លែងត្រូវមានអាការៈគួរសម ប្រើពាក្យសំដីទន់ផ្អែម ទៅរកអ្នកជិះឱ្យដឹងតូចធំចាស់ក្មេង មិនត្រូវព្រហើនកោងកាច ។ ឯអ្នកជិះវិញ ក៏ត្រូវគួរសមវិញដែរ ខុសត្រូវបន្តិចបន្តួច កុំប្រកាន់ ឱ្យកើតឈ្លោះប្រកែកគ្នា ។

- អ្នកម្ចាស់យានទាំងឡាយ មិនត្រូវចង់បានខុសច្បាប់អនុញ្ញាតពីរាជការមុខក្រសួង ដែលខ្លួនបានសន្យាថានឹងគោរពតាមរួចហើយនោះទេ គឺមិនត្រូវបណ្តោយឱ្យអ្នករៀបចំកន្លែងចេះតែដាក់មនុស្សឱ្យជិះហួសចំណុះ ខុសលេខកន្លែង ធ្វើឱ្យចង្អៀតចង្អល់ ធុញទាន់ដល់អ្នកដួលជិះ ។ ឯអ្នកដួលជិះវិញ ក៏ត្រូវ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

គោរពសិទ្ធិអ្នកជិះដូចគ្នា បើឃើញថាកន្លែងគេជិះមុន ពេញគ្រប់គ្រាន់តាមលេខអស់ហើយ មិនត្រូវចចេសឡើងទៅជិះ ជ្រៀតបៀតនឹងគេទេ ទោះបីមានការចាំបាច់ប្រញាប់យ៉ាងណា ក៏ត្រូវតែគោរពសិទ្ធិអ្នកជិះមុន ។ វៀរតែអ្នកជិះមុន សុខចិត្តហៅឱ្យជិះជាមួយ ទើបគួរទៅជិះជ្រៀតបៀតនឹងគេបាន ។

- អ្នកធ្វើដំណើរ តាមយានជំនិះគ្រប់ប្រភេទ ត្រូវឱ្យមានសំលៀកបំពាក់ ស្អាតបាត ទោះបីមានតែរបស់ចាស់រហែក ប៉ះប៉ុនយ៉ាងណា ក៏ត្រូវបោកឱ្យស្អាត ឱ្យអស់ក្លិនខ្មោះខ្មួរ កុំស្លៀកពាក់ខោអាវស្មោកគ្រោក ដែលមានព័ណក្រខ្វក់ដូចកំណាត់ជូតជើង នឹងឡើងផ្កាអំបិលសក្បុស នាំឱ្យអ្នកអង្គុយជិតខាងថប់ដង្ហើម ទៅជាខ្យល់ចាប់ ។

អំពីការយកឥវ៉ាន់ទៅជាមួយ បើឥវ៉ាន់នោះមានក្លិនមិនស្រួល ដូចជាប្រហុកផ្អកម៉ាំជាដើម ត្រូវវេចខ្ចប់ឱ្យជិតជិតល្អ ហើយឱ្យគេយកទៅដាក់ឆ្ងាយអំពីកន្លែងជិះ កុំដាក់ជិតក្បែរខ្លួន នាំឱ្យវេទនាច្រមុះអ្នកជិះជាមួយ ។ ព្រោះថា ការស្មោកគ្រោក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ដោយសំលៀកបំពាក់ នឹងយកឥវ៉ាន់មានក្លិនមិនស្រួល ទៅ បញ្ចេញឃើហោក្នុងយានជំនិះដូច្នេះ បើមានជនបរទេសគេជិះជាមួយផងនោះ នាំឱ្យខូចកិត្តិយស ដល់ប្រទេសជាតិមាតុភូមិថែមទៀត ។

- អ្នកដែលមានកូនចៅតូចៗមិនទាន់ដឹងក្តី មិនត្រូវធ្វើដំណើរយកទៅជាមួយទេ ដូចជាកូនចៅទើបនឹងកើត បានមួយខែឬពីរបីខែ ដែលមិនទាន់ចេះឱ្យដំណឹង ប្រាប់ពីការបន្ទោរបង់មូត្រលាមកនៅឡើយ ។ បើយើងចេះតែបីព ឱ្យយកទៅជិះក្នុងយានជំនិះជាមួយគេ អាចនាំឱ្យខូចសុភាពក្មេងផង នាំឱ្យរំខានដល់អ្នកជិះជាមួយផង គឺជូនកាលវាយំស្រែកផ្តេសផ្តាស ជួនកាល វាបន្ទោបង់មូត្រលាមកដាក់ក្នុងយាន នាំឱ្យផ្សាយក្លិនអសោចិ៍ ទៅបៀតបៀនអ្នកជិះជាមួយ នឹងនាំឱ្យគេខ្ពើមរអើម រំខានចិត្តដោយសារខ្លួន ។

- អំពីការមានអាសន្នដោយមូត្រលាមក ក្នុងយានជំនិះ ដូចជារថយន្តឈ្នួលដែលគ្មានបង្គន់, កាលបើអាសន្ននេះកើត

ឡើងហើយ ត្រូវប្រាប់ដល់អ្នកបើកបរភ្លាមឱ្យគេឈប់ ហើយចុះទៅបន្ទោបង់នៅទីកំបាំងឱ្យឆ្ងាយបន្តិចពីរថយន្ត កុំខ្មាស់អៀនមិនហ៊ានប្រាប់ឱ្យគេឈប់បេះតែសម្ងំ ទាល់តែកើតចលាចលក្នុងរថយន្ត នាំឱ្យរឹតតែខ្មាស់គេថែមទៀត ។ ឯអ្នកបើកបររថយន្តវិញ ក៏ត្រូវមានសុជីវធម៌ យោគយល់ដល់ការអាសន្នបែបនេះ ។ កាលបើគេប្រាប់ហើយត្រូវឈប់ភ្លាម កុំបង្អែបង្អង់ឱ្យយឺតយូរហើយកុំរអ៊ូរទាំ ។ ចំណែកអ្នកជិះជាមួយ ក៏ត្រូវជួយយកអាសាគ្នា ឆាប់ជួយប្រាប់ដល់អ្នកបើកបរ ហើយកុំបញ្ចេញអាការៈណាមួយ ឱ្យអ្នកមានអាសន្ននោះកើតសេចក្ដីអៀនខ្មាស់ ។

## ឋ-អ្នកបេះ និងអ្នកល្ងង់

- ជនទាំងពីរពួកនេះ ក៏ត្រូវមានសុជីវធម៌ ចំពោះគ្នានិងគ្នាទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ ។

- អ្នកមានចំណេះវិជ្ជាទាំងឡាយ ត្រូវតម្កល់ខ្លួនឱ្យល្អតាមការចេះដឹង ល្មមឱ្យអ្នកល្ងង់យកជាគំរូ ប្រតិបត្តិតាម កើតផល

សុខចំរើន កុំប្រើចរិយាហោកទាប ផ្សុយពីឋាន:ខ្លួន ដែលនាំឱ្យអ្នកល្ងង់ ប្រមាថមើលងាយបាន ។

- ត្រូវមានការគួរសមសុភាពរាបសា ចំពោះអ្នកល្ងង់ខ្លៅ កុំដំឡើងអាស្មិមាន: ព្រោះតែខ្លួនមានចំណេះវិជ្ជា ហើយប្រមាថមើលងាយឆ្មើងឆ្មៃ មិនស្គាល់ចាស់ព្រឹទ្ធាចារ្យ មានហៅអាមឹង នឹងប្រើកាយវិកាច្រងេងច្រងាង ដោយសំអាងថា គ្មាននរណាស្មើនឹងខ្លួន ។

- ត្រូវគោរពស្តាប់បង្គាប់ចៅហ្វាយនាយ មាតាបិតា នឹងគ្រូកូលរៀមច្បង ទោះបីជនទាំងនោះ ជាអ្នកល្ងង់ខ្លៅ គ្មានសញ្ញាប័ត្រប្រកាសថា ជាអ្នកចេះដឹងដូចខ្លួនក៏ដោយ មិនត្រូវចចេសមុខរឹង គ្មានស្តាប់នរណា ដោយសំគាល់ថា គ្មាននរណាចេះស្មើនឹងខ្លួន ។ គប្បីដឹងថា ទោះបីខ្លួនចេះយ៉ាងណា ក៏នៅតែមានគេចេះជាងជាដរាប សូម្បីតែសត្វតិរច្ឆាន ក៏វាមានចំណេះខ្លះ ចេះជាងមនុស្សបញ្ញវន្តដែរ ដូចសត្វបក្សាបក្សី វាចេះហោះហើរជាងមនុស្ស. សត្វឃ្មុំ វាចេះធ្វើក្រមួន ចេះធ្វើទឹក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ឃ្មុំ ជាងអ្នកប្រាជ្ញវិទ្យាសាស្ត្រជាដើម ។ ដូច្នេះក្នុងមនុស្សម្នាក់ៗ សុទ្ធតែមានចំណេះអ្វីមួយ ចេះជាងគ្នាជាដរាប ដែលថាឱ្យចេះ ផ្ដាច់គេតែឯងនោះគ្មានទេ សូម្បីតែព្រះពុទ្ធ ក៏ព្រះអង្គត្រាស់ថា ចេះដឹងតាមព្រះពុទ្ធមុនៗដែរ ។

- ត្រូវចេះចាញ់ចេះឈ្នះអំពីអ្នកល្ងង់ គឺបើដឹងថាខ្លួនប្រព្រឹត្ត ខុសឆ្គង ត្រង់កន្លែងណាមួយហើយ ត្រូវតែទទួលសារភាពថា ខ្លួនខុស កុំប្រើមធ្យោបាយវិងវេស កែកំហុសខ្លួនជាត្រូវ ឱ្យអ្នកត្រូវបែរជាខុសជំនួសខ្លួនទៅវិញ ធ្វើឱ្យអ្នកល្ងង់ខ្លៅកើតទុក្ខក្ដៅក្រហាយដោយសារខ្លួន ។

- ត្រូវស្រោចស្រង់អ្នកល្ងង់ខ្លៅ ឱ្យបានចេះដឹង យល់ ហេតុផលវិនាសចំរើន ឧស្សាហ៍រំលឹកដាស់តឿន ដឹកនាំឱ្យលះបង់អំពើឥតប្រយោជន៍ អំពើខ្ញុំឆ្គង ហើយណែនាំ ឱ្យធ្វើតែអំពើល្អត្រឹមត្រូវ កើតផលសុខចំរើនរុងរឿង ។

- ត្រូវរាប់អានដោយស្មោះស្មើ ចំពោះអ្នកល្ងង់ខ្លៅ ដោយសំគាល់ថាដូចជាញាតិសន្ដានរបស់ខ្លួនពិតៗ មិនត្រូវប្រកាន់ថា

ខ្លួនគ្រាន់បើ ខ្ពង់ខ្ពស់ជាអ្នកមានប្រាជ្ញផ្ដាច់គេឯអ្នកដទៃល្ងង់ថោកទាប មិនត្រូវរាប់អានទាំឱ្យថោកដល់ខ្លួន ។

- ឯអ្នកល្ងង់ខ្លៅវិញ ត្រូវតម្កល់ខ្លួនឱ្យល្អ សុភាពរាបសា លួមអ្នកចេះដឹង គេស្រឡាញ់រាប់អាន អាណិតអាសូរ ជួយណែនាំប្រាប់ពន្យល់ការខុសត្រូវបាន ។

- ត្រូវមានការគួរសម គោរពកោតខ្លាចអ្នកចេះដឹង កុំប្រណាំងប្រជែងវាសនា នឹងអ្នកមានចំណេះ ដោយប្រើអាការៈប្រងើងប្រងាង ព្រហើនមើលងាយមិនខ្វីស្ដាប់គោរពតាម អាងតែកំឡាំងបាយ ។

- មិនត្រូវស្ងាប់ដូចពស់ រស់ដូចកង្កែប គឺកុំដាក់ការៈចិត្តទាំងស្រុងថា ខ្លួនល្ងង់គ្រប់ជប់ មិនបាច់គិតគូរពីការខុសត្រូវល្អអាក្រក់គួរមិនគួរ ឱ្យតែអ្នកចេះដឹងថាម៉េច អញធ្វើតាមយ៉ាងនោះ ខុសក៏ដោយត្រូវក៏ដោយ គឺកុំញ៉មខ្លួនឱ្យអ្នកចេះដឹង គេចាប់ក្ដុះប្រមុះដឹកដូចគោក្របីនោះឡើយ ។ ព្រោះមនុស្សម្នាក់ៗគ្មាននរណាចេះសព្វ គ្រប់ជប់នោះទេ ត្រូវតែត្រិះរិះពិចារណា

តាមសមត្ថភាពប្រាជ្ញាខ្លួនហើយ សឹមគោរពប្រតិបត្តិ ជឿតាមជាក្រោយ ។

- ត្រូវជួយយកអាសា ផ្តល់ប្រយោជន៍ឱ្យអ្នកចេះដឹង មានជួយអួតសរសើរ ឱ្យសមតាមកិត្តិយសនៃចំណេះវិជ្ជា នឹងចរិយា ។ បើអ្នកចេះដឹងនោះ មានសមត្ថភាពល្មមធ្វើជាតំណាងខ្លួន ឬជាអ្នកដឹកនាំកិច្ចការណាមួយបាន ត្រូវជួយឱ្យសំរេចសមតាមឋានៈ ដូចជាជួយបោះឆ្នោត ឱ្យបានជាប់ជាតំណាងរាស្ត្រជាដើម ។

- ត្រូវមានសេចក្តីរាប់អានដោយស្មោះស្មើ ចំពោះអ្នកចេះនឹង ឱ្យដូចជារាប់អានញាតិសន្តានខ្លួនពិតៗ មិនត្រូវប្រកាន់ថាគេចេះដឹង ឯងល្ងង់ខ្លៅ ទុកជាសត្រូវនឹងគ្នានោះឡើយ ។

## ៥-កំលោះ និង ក្រមុំ

- យុវជនទាំងពីរពួកនេះ ក៏ត្រូវមានសុជីវធម៌ ចំពោះគ្នានិងគ្នាទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ៖

- កំលោះគឺមនុស្សប្រុសដែលពេញការ មានចិត្តគំនិត

នឹងរូបកាយកំពុងពេញកំលាំង ត្រូវប្រុងប្រយ័ត្នបេះអត់ធន់ កុំកើតភ្លើនទៅតាមអំណាចចិត្តស្នេហា រំលោភមើលងាយស្ត្រីគេទមានស្រីក្រមុំជាដើម ឱ្យជ្រុលខុសច្បាប់ទំលាប់ប្រពៃណី ដែលនាំឱ្យសៅហ្មង ខូចកិត្តិយសខ្លួននឹងត្រកូល ។

- ត្រូវវៀរនូវមនុស្សណា ដែលខិលខូចល្មោភស្នេហា បំផ្លាញព្រហ្មចារិនីរបស់ស្រីក្រមុំ នឹងអ្នកលេងស្រីផ្កាមាសជាដើម ។ បើយើងសេពគប់នឹងមនុស្សដូច្នោះ សមចិត្តយើងកំពុងកើតភ្លើនស្រាប់ផង អាចនឹងក្លាយខ្លួនភ្លាមៗពីភាពកំលោះទៅជាមនុស្ស មានព្រហ្មចារីពុករលួយ ពោះម៉ាយមិនខាន ។

- ត្រូវរាប់អានស្ត្រីក្រមុំ ដូចជាប្អូនក្រមុំ ឬបងក្រមុំរបស់ខ្លួនគឺរាប់អានប្រកបដោយសេចក្តីថ្លៃថ្នូរ កុំឱ្យស្និទស្នាលហួសព្រំដែននឹងកុំឱ្យធ្មើងឆ្មៃពេក ដរាបដល់ឃើញមុខគ្នាគេចចេញ ហាក់ដូចជាគូសត្រូវយកជីវិតគ្នាបាន ដែលជាទំនាស់ដល់វិស្សាសភាព រវាងមនុស្សនិងមនុស្ស ។

- បើឃើញស្ត្រីក្រមុំ កំពុងឈរ ឬដើរ ឬអង្គុយ នៅទីណា

មួយជាមួយគ្រួសារគេក្តី តែម្នាក់ឯងក្តី មិនត្រូវដើរទៅធ្វើច្រិមច្រម ឱ្យប៉ះទង្គិច ឬនិយាយបញ្ចិតបញ្ចៀង ក្អកកណ្តាស់ គ្រហែមសើចហ៊ោកញ្ជៀវ ដែលជាអាការៈមើលងាយគេយ៉ាងកំសាកនោះឡើយ ។ បើយើងមានសេចក្តីស្រឡាញ់ពេញចិត្តចង់សួរចិត្តគ្នាទៅវិញទៅមក តាមរបៀបសម័យនិយមនោះ យើងត្រូវគោរពងក់ក្បាល ឬថ្លែងអាការៈគួរសមណាមួយ សុំឱ្យគេអត់ទោសឱ្យ ហើយនិយាយស្នើការយ៉ាងចេញមុខតែម្តង កុំប្រើឫកថោកទាប ឱ្យគេដេរប្រមាថ មើលងាយដូចទាសកម្មកររបស់គេនោះឡើយ ។

- ត្រូវមានកាយវិការ និងពាក្យសំដីសុភាពគួរសម ហើយសច្ចៈទៀងត្រង់ មានហៅថា នាង -អ្នក-បង ឬប្អូនជាដើម ទាំងក្នុងទីចំពោះមុខ នឹងកំបាំងមុខ កុំហៅគេមីនេះមីនោះ នឹងកុំនិយាយកាច់មួលគ្មានការពិត ប្រាប់មិត្រសំឡាញ់ជាការកំសាន្តថា គេស្រឡាញ់ខ្លួន គេឱ្យនេះឱ្យនោះដល់ខ្លួន ឬថាខ្លួនបានខ្លួនប្រាណគេជាដើម ដែលជាសាម៉ីខ្លួនគេឥតបានប្រព្រឹត្តធ្វើដូច្នោះ

នឹងខ្លួនសោះ ។

- មុននឹងផ្ដក់ស្នេហា ទៅលើរូបស្ត្រីក្រមុំណាមួយ ត្រូវពិចារណាឱ្យហ្មត់ចត់ថា នាងនោះមានវង្សត្រកូល គុណសម្បត្តិ សមត្ថភាព ល្មមមាតាបិតាខ្លួនញាតិសន្តានខ្លួន រាប់អានបានឬទេ ប្រហាក់ប្រហែលគ្នាឬទេ ចូលទៅនៅក្នុងគ្រួសារប្រទ្បំគ្នាឬទេ ។ បើមានតុល្យភាពល្មម ឬប្រហាក់ប្រហែលគ្នាហើយ ទើបគួរទាក់ទងគ្នាបាន ដើម្បីរក្សាកិត្តិយសដល់វង្សត្រកូលផង កុំឱ្យគេខកចិត្តដោយសារខ្លួនផង ។ ព្រោះមានកំលោះខ្លះទាក់ទងស្នេហានឹងក្រមុំណាមួយ បានប្ដេជ្ញាដាច់ស្រេចនឹងគ្នាទៅហើយ ដល់មាតាបិតាញាតិសន្តាន មិនយល់ព្រមផង ក៏លះបង់ចោល ទៅទទួលយកស្រីដទៃតាមបំណងមាតាបិតាទៅវិញ ធ្វើឱ្យស្ត្រីនោះខកចិត្ត កើតទុក្ខវេទនា ។ ដូច្នេះកំលោះទាំងឡាយ ត្រូវមានសុជីវធម៌ក្នុងសេចក្ដីស្នេហាគឺ កុំបោះទំពក់ស្នេហាទៅខ្ពស់ពេកទាបពេក ត្រូវឱ្យស្គាល់ប្រមាណសមត្ថភាពខ្លួន ។

-កុំប្រើស្នេហាបោកប្រាស បើបានទាក់ទង ធ្វើឱ្យស្ត្រី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ក្រមុំណាមួយ ភ្ញាក់ភ្ញឹកជាប់ចិត្តបានប្ដូរផ្ដាច់ ស៊ូស្លាប់រស់នឹងខ្លួន ហើយ ត្រូវតែប្ដូរផ្ដាច់ ស៊ូស្លាប់រស់នឹងគេវិញជាដាច់ខាត ទោះមានឧបសគ្គយ៉ាងណា ក៏ត្រូវតែរក្សាពាក្យសច្ចៈឱ្យបាន ទើបពេញជាបុរសថ្លៃថ្នូរ មិនមែនជាព្រានទ្រើគ ឬជាឃាតករ ។

-ស្ត្រីក្រមុំ ត្រូវរក្សាព្រហ្មចារិនីរបស់ខ្លួនឱ្យបរិសុទ្ធ ចេះអត់ធន់ កុំប្រព្រឹត្តកន្លងប្រពៃណី ដែលនាំឱ្យថោកវង្ស-ត្រកូលខ្លួនផង នាំឱ្យអាប់កិត្តិយសដល់កំលោះជាអនាគតស្វាមីរបស់ខ្លួនផង ។ ព្រោះបើយើងមិនបរិសុទ្ធ ជាមួយបុរសណាហើយ ដល់មានស្វាមីទៅ នាំឱ្យបុរសនោះមើលងាយស្វាមីខ្លួនថា ជាអ្នកយកស្រីមេម៉ាយដដែលគេ ។

-ត្រូវវៀរនូវក្ដីស្រលាញ់ដែលខិលខូច មានព្រហ្មចារិនីពុករលួយមិនបរិសុទ្ធ ដែលអាចដឹកនាំឱ្យខិលខូចដូចគ្នា ធ្វើឱ្យកំលោះភ្ញាក់ភ្ញឹកចិត្ត ខូចអនាគត អាប់កិត្តិយសដោយសារខ្លួន ។

-ត្រូវរាប់អានបុរសកំលោះ ដូចជាបងប្រុស ឬប្អូនប្រុសរបស់ខ្លួនគឺ រាប់អានដោយអាការថ្លៃថ្នូរ កុំស្និទស្នាលពេក កុំ

ខ្វាចពេក ដរាបដល់ឃើញកំលោះវត់ពួន ហើយលួចមើលមិនឱ្យគេឃើញ មានចរិយាដូចជាម្រឹគខ្លាចខ្លា ។

-បើឃើញកំលោះនៅទីណា មិនគួរទៅទីនោះ ឱ្យប៉ះទង្គិច ក្អកក្រហែម និយាយបញ្ចិតបញ្ចៀងសើច ធ្វើអាការៈញ៉ិកញ៉ក់កាច់រាង ឱ្យកំលោះហ៊ានមើលងាយ ដោយសំគាល់ថាជាស្រីមិនល្អបរិសុទ្ធនោះឡើយ ។

-ត្រូវមានកាយវិការ នឹងពាក្យសំដីសុភាពរាបសា ឱនលំទោនចំពោះកំលោះ កុំប្រើឫកប្រងើងប្រងាង និយាយហៅអាមីងជេរទ្រគោះបោះបោក ធ្វើទឹកមុខមើលងាយជាដើម ។

-មុននឹងដាក់ការចិត្តស្នេហា ចំពោះកំលោះណា ត្រូវត្រិះរិះសង្កេតពិនិត្យកំលោះនោះ ឱ្យសព្វគ្រប់តាំងពីវង្សត្រកូល គុណសម្បត្តិ សមត្ថភាពចំណេះវិជ្ជា ចរិយាមារយាទ លៃថ្លឹងប្រៀបផ្ទឹមគ្នាឱ្យមានតុល្យភាព ប្រហាក់ប្រហែលគ្នា កុំឱ្យខ្ពស់ពេក ទាបពេក ល្មមមាតាបិតាគ្រួសារពេញចិត្តផង ។ ព្រោះថា បើមានឋានៈវង្សត្រកូល នឹងសមត្ថភាពខុសគ្នាឆ្ងាយពេក នាំ

ឱ្យថោកទាបខូចកិត្តយស ម្នាងៗគឺ បើខាងយើងទាបពេក មាតាបិតាគ្រួសារយើងដូចជាខ្ញុំកញ្ជះរបស់គេ, បើខាងយើងខ្ពស់ពេកដូចជាយកទាសកម្មកររបស់ខ្លួនមកធ្វើជាស្វាមីករិយា នាំឱ្យអ្នកផងគេច្រឡំ ខូចកិត្តិយសគ្រួសារ ។

-បើខ្លួនមិនដាច់ខាត ប្តូរផ្តាច់ជាមួយកំលោះណាមួយទេ មកពីមានឧបស័គ្គដោយហេតុៈ មិនប្រហាក់ប្រហែលគ្នានោះ កុំប្រើពាក្យសំដីទីងចរិយា ឱ្យកំលោះស្ទាប់ចិត្តគំនិត ប្តូរផ្តាច់ចំពោះខ្លួន ដែលនាំឱ្យគ្មានរងទុក្ខវេទនា ក្នុងពេលខ្លួនទទួលយកស្វាមីទៀតតាមអំណាចមាតាបិតា ។

-ត្រូវមានចិត្តស្មោះត្រង់ កាន់ពាក្យសច្ចៈ ចំពោះកំលោះណាមួយ ដែលខ្លួនបានសន្យាដាច់ខាតហើយ កុំប្រែក្រឡាស់ទៅសន្យាដាច់ខាតនឹងកំលោះដទៃទៀត តាមអំពើចិត្តចើកសារ៉ាំចិត្តស្រីកាកី ដែលនាំឱ្យពួកកំលោះខកចិត្ត ឆ្កួតវង្វេងដោយសារពាក្យសំដីខ្លួន ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

# ឃ-អ្នកនៅវត្ត និងព្រះសង្ឃ

បុគ្គលទាំងពីរប្រភេទនេះ ក៏ត្រូវមានសុជីវធម៌ទៅវិញទៅមក តាមឋានៈរៀងៗខ្លួនដែរ៖

-ព្រះសង្ឃគឺ លោកគ្រូចៅអធិការ និងភិក្ខុសាមណេរ ដែលជាអ្នកគ្រប់គ្រងថែរក្សាវត្តអារាម ។ តាមប្រពៃណីពីព្រេងនាយមក ពួកគ្រហស្ថពុទ្ធបរិស័ទ តែងយកកូនចៅទៅផ្ញើ ឱ្យដេកនៅបាយទឹកក្នុងវត្ត ដើម្បីរៀនសូត្រចំណេះវិជ្ជាផ្សេងៗ ។ អ្នកដែលទៅស្នាក់នៅក្នុងវត្តនោះ គេហៅថា កូនសេក្ខ-សិស្សលោក ឬក្មេងវត្ត ទោះបីធំពេញកំលោះហើយក៏ដោយ ។ សម័យឥឡូវ ចំពោះវត្តក្នុងទីក្រុង ច្រើនតែមនុស្សធំៗ អាយុ ២០ឬ៣០ឆ្នាំទៅស្នាក់នៅរៀនសូត្រ ឬស្នាក់ចាំប្រឡងប្រជែងរកការធ្វើ ។ ដូច្នេះ ព្រះសង្ឃត្រូវតែជួយអប់រំប្រដៅអ្នកនៅក្នុងវត្តទាំងអស់នោះ ឱ្យស្គាល់បាបបុណ្យ ឱ្យមានចិត្តគំនិតជាពុទ្ធសាសនិក ចេះគោរពរាប់អាន ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

-ត្រូវប្រៀនប្រដៅ ឱ្យចេះគោរពតាមច្បាប់សំរាប់វត្ត និងករណីយកិច្ច ដែលខ្លួនជាអ្នកនៅវត្តត្រូវប្រព្រឹត្តធ្វើ ។

-គួរចែករំលែកអាហារភោជន នឹងទឹកភ្លើងជាដើមឱ្យគ្នា បរិភោគប្រើប្រាស់តាមការគួរផង កុំទារយកថ្លៃឈ្នួលរង្វាន់ដូចជាគ្រហស្ថ ដែលផ្ទុយពីវិន័យសិក្ខា របស់ព្រះពុទ្ធសាសនា ។

-គប្បីតាំងចិត្ត ប្រកបដោយមេត្តាករុណា ជាអ្នកជួយយកអាសាសង្គ្រោះពិតៗតាមច្បាប់ព្រះពុទ្ធសាសនា មានប្រៀនប្រដៅ ឱ្យខំរៀនសូត្រ កុំឱ្យដើរលេងផ្តេសផ្តាស ស៊ីផឹកស្រាស្រីល្បែងភ្នាល់ ដូចជាអ្នកនៅផ្ទះ គឺកុំគ្រាន់តែឱ្យស្នាក់នៅហើយ មិនរវល់ធ្វើដឹងឮ ដូចជាគោគេហូតកន្ទុះលែងចោល ដែលនាំឱ្យអាប់ឱនសៅហ្មង ខូចដល់កិត្តិយសវត្តអារាម ។

-គួរប្រើវាចាឱ្យសមរម្យតាមសមណភេទ ចំពោះគ្រហស្ថអ្នកនៅវត្តជាមួយ មានហៅចំឈ្មោះ ឬហៅថាអ្នក នាង បងប្អូនជាដើម មិនគួរហៅ អាមីងដាច់សាច់ នឹងឆ្លើយ អ៊ីអើអញឯងជាដើម ដែលមិនមែនជាសមណវាចា ។

-ពេលគ្នាមានជម្ងឺរោគាពាធគួរជួយឈឺឆ្អាលថែរក្សា ចែកថ្នាំសង្កូវ ទៅតាមច្បាប់វិន័យសិក្ខា ។

-មិនត្រូវប្រើគ្នាឱ្យធ្វើកិច្ចការផ្សេងៗ ខុសពេលវេលា ឱ្យខូចការសិក្សារៀនសូត្រឡើយ ។

-ឯអ្នកនៅវត្តវិញ ត្រូវផ្លាស់ចិត្តគំនិតទៅតាមទឹកន្លែង គឺពីពេលមិនទាន់ទៅនៅវត្ត បើយើងជាអ្នកធ្វើងធ្មៃ មិនសូវចេះគោរពព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ត្រូវតែខំហាត់ពត់ កាយវាចាចិត្ត ឱ្យបានជាអ្នកមានបែបបទល្អ ចេះគោរពប្រតិបត្តិឡើង ។ បើពីដើម ធ្លាប់ខិលខូចស្រីស្រាល្បែងពាលាជាដើម ត្រូវលះបង់ ត្រូវតម ឈប់ធ្វើដូច្នោះទៀត ព្រោះយើងជាអ្នកទៅនៅក្នុងវត្តអារាមហើយ; គួរយកតម្រាប់តាមសត្វជីងចក់ ដែលវាចេះផ្លាស់ពណ៌សម្បុរ ទៅតាមទីកន្លែង ។

-ត្រូវញ៉ាំមខ្លួន គោរពតាមច្បាប់សំរាប់វត្ត ដែលព្រះសង្ឃបានប្រៀនប្រដៅ ប្រាប់ហាមប្រាម មានមិនឱ្យជិះកង់ក្នុងវត្តជាដើម ។

-ត្រូវមានកាយវាចា គោរពឱនលំទោន ចំពោះភិក្ខុសាមណេរ កុំព្រហើនកោងកាច ប្រមាថមើលងាយ ទោះលោកមានចរិយាបែបណាក៏ដោយ គប្បីគោរពចំពោះស្បង់ចីពរ ដែលជាទង់ជ័យនៃព្រះអរហន្តសម្ពុទ្ធ ។ ជាពិសេស មិនគួរយកភិក្ខុសាមណេរ ធ្វើជាពួកម៉ាក ។

-មិនត្រូវឱ្យភិក្ខុសាមណេរបំរើខ្លួន, ត្រូវបោសសំអាតកុដិ សាលា វត្តអារាម ដែលខ្លួននៅឱ្យស្អាតបាត មិនត្រូវពង្រាយសំរាម ចាក់ជះទឹកកាកបាយសំឡជាដើម ឱ្យភិក្ខុសាមណេរពិបាកសំអាតដោយសារខ្លួនឡើយ ។

-មិនគួរអង្គុយលើអាសនៈ ស្មើនឹងភិក្ខុសាមណេរ ហើយជជែកគ្នាលេង ឬទៅដេកលេងលើគ្រែសំណឹង ភិក្ខុសាមណេរឡើយ ព្រោះជាអាការមិនគួរសម ខ្វះសេចក្តីគោរពចំពោះបព្វជិតអ្នកបួសក្នុងព្រះពុទ្ធសាសនា ។

-ទៅណាមកណា ត្រូវប្រគេនដំណឹង ដល់ភិក្ខុសាមណេរជាម្ចាស់កុដិ ម្ចាស់ទីកន្លែង ដែលខ្លួនទៅសុំស្នាក់នៅជា

WAT KHEMARARATANARAM

មួយ ។ បើមានការប្រញាប់ ហើយគ្មានឱកាសនឹងប្រគេនដំណឹងទេ ។ គួរផ្តាំផ្ញើឱ្យអ្នកនៅជាមួយ ឬអ្នកនៅជិតខាងប្រគេនដំណឹងជំនួសកុំខាន ។

-មិនត្រូវនិយាយពាក្យសំដីអាសគ្រាមមិនគួរគប្បី មាននិយាយពីស្រីញីជាដើម ចំពោះមុខភិក្ខុសាមណេរ ព្រោះជាអាការៈខ្វះសេចក្តីគោរពគួរសម, គួរនិយាយតែអំពីកិច្ចការណាដែលមានប្រយោជន៍ មាននិយាយពីការរៀនសូត្រ ពីធម៌អាថ៌ជាដើម ដែលជាវាចាសប្បុរស ។

-របស់ប្រើប្រាសផ្សេងៗ មានទឹកភ្លើងជាដើម ដែលព្រះសង្ឃអនុញ្ញាតឱ្យប្រើ ត្រូវចេះសំចៃ ឱ្យដឹងបាត់ដឹងគង់ កុំប្រើខ្ជះខ្ជាយបាចសាច តាមអំពើចិត្ត ព្រោះរបស់ទាំងអស់នោះសុទ្ធតែជារបស់សង្ឃ របស់ព្រះពុទ្ធសាសនា បានមកដោយសទ្ធាជ្រះថ្លានៃទាយកទាយិកា ដែលគេបានលើកប្រទូលផុតក្បាលហើយ ទើបឱ្យមក ។

-ក្នុងអនាគតកាល ដែលខ្លួនឈប់ស្នាក់នៅក្នុងវត្ត បែក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

ពីព្រះសង្ឃទៅប្រកបអាជីវកម្មណាមួយហើយ មិនត្រូវបំភ្លេច អតីតកាល ដែលខ្លួនបានរស់នៅក្នុងវត្តអារាមនោះឡើយ ត្រូវ តែគួរសការរស់នៅក្នុងវត្តនោះ ភ្ជាប់ទៅនឹងដួងវិញ្ញាណ ទុកជា អនុស្សាវរីយ៍ដរាបដល់អស់មួយជីវិតថា ‹‹វត្តអារាមនេះ ជាមាតុ ភូមិវិជ្ជារបស់អញ អញបានចេះដឹង បានស្គាល់ខុសត្រូវ បាន ឋាន:បុណ្ណោះ ដោយសារវត្តអារាមនេះផ្តល់ឱ្យអញ ប្រសូត បង្កើតអញមក›› ហើយត្រូវឧស្សាហ៍ចេញចូល ធ្វើបុណ្យទាន ទំនុកបំរុងឱ្យអស់ពីសមត្ថភាព ដោយសំគាល់ថា ជាវត្តអារាម របស់ខ្លួនពិតៗ ។ ឯការប្រព្រឹត្តទៀត ក៏ឱ្យមានកាយវាចា ចិត្តត្រឹមត្រូវ ប្រកបដោយគតិបណ្ឌិត ឱ្យសមរម្យជាអ្នកធ្លាប់ រស់នៅក្នុងវត្តអារាម ក្រោមពន្លឺព្រះពុទ្ធសាសនា កុំឱ្យចេញផុត តែពីរបងវត្តទៅ ប្រែក្រឡាក្លាយកើតជាអ្នកប្រមឹក លួចប្លន់កាប់ សម្លាប់ ស៊ីសំណូកសូកប៉ាន់ ប្រព្រឹត្តអំពើពុករលួយក្រខ្វក់ ដែលផ្ទុយស្រឡះពីទីកំណើត ដែលខ្លួនកើត ។ មានជនខ្លះ ប្រែក្រឡាពីរបីជាន់ ដរាបដល់លែងជ្រះថ្លា ក្នុងគុណព្រះរតន-

ត្រ័យ  បែរជាប្រមាថមើលងាយភិក្ខុសាមណេរ  ថាមិនស្មើនឹងខ្លួន ហើយមានវាចាបរិហារសំអុយទិតៀនប្រទូសរ៉ាយ  ចំពោះវត្តអា-រាមនិងភិក្ខុសាមណេរថែមទៀត  ។  នេះជាលក្ខណៈរបស់មនុស្សគ្មានសុជីវធម៌ ។

-បើយើងបានឋានៈ  ជាអ្នកមានទ្រព្យឬជាអ្នករាជការ  មានសមត្ថភាព  បានយសស័ក្តិធំ  ត្រូវយកចិត្តទុកដាក់ជួយឧបត្ថម្ភវត្តអារាមនោះឱ្យបានរុងរឿង  ។  បើវត្តមានធ្វើពិធីបុណ្យអ្វីៗត្រូវទៅជួយចាត់ចែងជាសមាជិកគណៈកម្មការបុណ្យនោះកុំលាក់មុខ ។

-អត្ថបទដូចនាំមកបរិយាយ  ជាគោរពនេះ  ជាវត្ថុបទទី២នៃសុជីវធម៌  គឺការស្គាល់ឋានៈខ្លួននិងអ្នកដទៃ  ដើម្បីនាំមនុស្ស  ឱ្យចេះយោគយល់  ស្គាល់សុខទុក្ខគ្នាទៅវិញទៅមកឱ្យលះបង់នូវការប្រមាថមើលងាយ  ប្រកាន់អស្មិមានៈ  ដែលជាហេតុឱ្យមានការថ្នាំងថ្នាក់  អាក់អន់ចិត្ត  បែកសាមគ្គីក្នុងសង្គមគ្រួសារ និងក្នុងសង្គមជាតិ ។



WAT KHEMARARATANARAM

# វគ្គបទទី៣

## ការស្គាល់ប្រមាណជីវភាព

មនុស្សគ្រប់រូបក្នុងលោកនេះ សុទ្ធតែមានការខ្វះខាតជានិច្ចគ្រប់គ្នា ដើម្បីបន្ធូរបន្ថយ ការខ្វះខាតនោះ កុំឱ្យឡើងដល់កំរិតខ្ពស់ពេក ត្រូវចេះលៃលកគ្នាន់គ្នេរ ទប់ទល់ប៉ាន់ស្មាន នូវការរកបានមក នឹងការប្រើប្រាស់ចាយវាយទៅវិញ កុំឱ្យមានអនុភាពក្នុងថវិកាជីវិត ត្រូវឱ្យឆ្លាតវៃក្នុងការរបររកស៊ី និងការចាយវាយចិញ្ចឹមជីវិត គឺឱ្យស្គាល់ប្រមាណជីវភាព ។

-ការស្គាល់ប្រមាណជីវភាពនេះ បានន័យថា «ចេះបានចេះបង់, ចេះចាយចេះរក» បើចេះតែចង់បាន ចេះតែខំរកមិនគិតពីការខុសត្រូវល្អអាក្រក់ គួរមិនគួរសោះនោះ នឹងធ្លាក់ទៅក្នុងផ្លូវអាក្រក់ទុច្ចរិត មានស៊ីសំណូក លួចប្លន់ជាដើម នាំឱ្យថោកទាបខូចកិត្តិយស ឬក៏ចេះតែខំរកមក មិនហ៊ានស៊ីចាយឱ្យសមឋានៈនោះ ក៏នាំឱ្យខូចកិត្តយសដែរ ឈ្មោះថាជាអ្នកមិនស្គាល់ប្រមាណជីវភាពទៅវិញ ។

-ម្យ៉ាងទៀត បើចេះតែស៊ីចាយ ចេះតែឱ្យបាត់បង់ មិន

ចេះរក មិនចេះថែរក្សាទុកដាក់ ក៏នឹងធ្លាក់ខ្លួនទៅជាមនុស្សទ័លក្រខ្វះខាតរហេមរហាមលំបាកវេទនា អាប់ឱនខូចកិត្តិយស ឈ្មោះថាជាអ្នកមិនស្គាល់ប្រមាណជីវភាពដែរ ។ ដូច្នេះមនុស្សម្នាក់ៗត្រូវតែឱ្យមានមុខរបរធ្វើ ដើម្បីឱ្យមានចំណូល ហើយចេះលៃលកកាញ់គ្នេរ នូវការចំណូលនឹងចំណាយនោះ ឱ្យមានតុល្យភាព និងសមតាមកំរិតជីវភាពរបស់ខ្លួន, ទើបឈ្មោះថាជាអ្នកមានសុជីវធម៌ ដូចតទៅនេះ ។

## ក-អំពីការរបរ

-មនុស្សគ្រប់រូប ត្រូវតែមានមុខរបរគ្រប់ៗគ្នាខានមិនបានទោះរបរនោះ តូចក្តីធំក្តី បានផលតិចឬច្រើន ត្រូវតែធ្វើកុំឱ្យនៅទំនេរ ទោះបីយើងមានចំណេះវិជ្ជា ខ្ពង់ខ្ពស់ក៏ដោយ បើយើងរកមុខរបរខ្ពង់ខ្ពស់ ដែលសមនឹងចំណេះវិជ្ជាយើងនោះមិនខានទេ យើងកុំដេកផ្សងសំណាង ចាំការងារនោះៗយូរពេកព្រោះក្រពះរបស់យើង វាស្រេកឃ្លាន វាទារចំណាយរាល់ថ្ងៃ ។ បើ

យើងចាំតែសុំគេ មានសុំពីមាតាបិតាបងប្អូនជាដើម មកបំពេញក្រពះយូរពេកនោះ នាំឱ្យអាប់ឱនកិត្តិយសខ្វះសុជីវធម៌មិនរុងរឿង, ដូចភាសិតពោលថា «រដ្ឋគ្មានអាករ មនុស្សគ្មានរបរ មិនរុងរឿង» ។

-បើសមត្ថភាពរបស់យើង ប្រឡងប្រជែងដណ្តើមការងារាជការមិនបានហើយ មិនគួរគ្រាញនៅសប្បាយក្នុងទីក្រុង លះបង់ការរៀនសូត្រ លះបង់ស្រុកទេស នឹងលះបង់របរកសិកម្ម ពាណិជ្ជកម្ម ទំរើសទំរន់ខ្លួនឱ្យស្មោកខ្វច ធ្វើអ្វីមិនកើតៗ ចំរើនតែខាងខ្ជិល គិតតែពីដេកក្រោក នឹងដើរលេង រស់នៅដោយវត្តអារាមនោះទេ, ត្រូវតែត្រឡប់ទៅជួយធ្វើការងារ មាតាបិតាវិញប្រសើរជាង មិនខូចកិត្តយស, កុំយល់ខុសថា ទៅស្រុកវិញខ្មាស់គេ ហើយស៊ូទ្រាំគ្រាញនៅបំរើអ្នកដទៃ យកតែបាយស៊ីខោអាវស្បៀកពាក់ហ៊ុំហានោះ នាំឱ្យខូចអនាគតធំណាស់ ។

-មនុស្សសត្វគ្រប់រូប ដែលកម្មនឹងធម្មជាតិបង្កើតមក សុទ្ធតែបានទទួលសម្ភារៈសំរាប់ធ្វើការរបរ ឱ្យកើតផលចំណូល

ដើម្បីចិញ្ចឹមជីវិតរាល់ៗរូបតាំងពីកើតមក គ្មានអ្នកណាម្នាក់ដែលខ្វះសម្ភារៈសំរាប់ធ្វើរបររកស៊ីទេ គឺមនុស្សមានដៃនឹងជើងជាសម្ភារៈសំរាប់ធ្វើរបរឱ្យកើតផលចំណូល មាត់នឹងក្រពះសំរាប់ចំណាយ ។ សត្វមានជើង-ដៃ-ប្រមោយ-ស្លាបនឹងព្រុយ ជាសម្ភារៈសំរាប់ធ្វើរបរឱ្យកើតផលចំណូល មាត់នឹងចំពុះនឹងក្រពះសំរាប់ចំណាយ។

-ដូច្នេះ សម្ភារៈឬដើមទុន សំរាប់ធ្វើរបររកស៊ីមានគ្រប់ៗគ្នាទាំងអស់ តាំងពីមនុស្សរហូតដល់សត្វតិរច្ឆាន ។ បើយើងជាមនុស្សហើយ ត្អូញថាគ្មានរបររកស៊ី គ្មានការធ្វើនោះ វាផ្ទុយខុសពីធម៌ជាតិស្រឡះ អន់ជាងបក្សាបក្សីទៅទៀត ។ ដូចជាសត្វចាប វាចេះធ្វើសំបុកនៅយ៉ាងសមរម្យ ហើយចេះរកស៊ីបានគ្រប់គ្រាន់ ដរាបដល់សល់ពាំយកមកផ្ញើកូនចៅវាទៀត ។ បើប្រៀបធៀបទៅឃើញថា គ្រាន់បើជាងមនុស្សខ្លះ ដែលរកខ្ទមជ្រកគ្មាន រកម្ហូបចំណីបរិភោគមិនបានគ្រប់គ្រាន់ដោយខ្លួនឯង ទាល់តែទៅឱ្យគេប្រើ ឬទៅសុំទានគេ លួចគេ ទើបចិញ្ចឹមជីវិតរស់ ។ នេះមកអំពីមនុស្សគ្មានសុជីវធម៌ មិនស្គាល់ប្រមាណ

ជីវភាពរបស់ខ្លួន គិតតែពីចង់ស្រណុកចង់បានហួស ត្រឡប់ជាអត់ អន់ជាងសត្វ ។

-មនុស្សម្នាក់ៗ មិនត្រូវបំប៉ោងសេចក្ដីប្រាថ្នា ឱ្យធំហួសសមត្ថភាពខ្លួន ដរាបដល់ទន់សរសៃដៃជើង កាន់ជង់ចបមិនកើត នឹងមិនត្រូវបំផតសេចក្ដីប្រាថ្នា ឱ្យអស់រលីងដេកចាំតែធ្វើខ្ញុំគេនោះទេ ត្រូវតែស្ទង់សល់ប្រមាណជីវភាពខ្លួនឱ្យច្បាស់ ទើបមិនខូចកិត្តិយស ។ បើយើងជាកូនអ្នកទ័លក្រ ចំណេះវិជ្ជាក៏ទន់ខ្សោយ មិនអាចឈោងចាប់មុខរបរធំៗ របរស្រណុក ដូចមុខរបរធ្វើរាជការជាដើមបានទេ យើងត្រូវតែធ្វើរបរតាមសមត្ថ-ភាពខ្លួនដែលអាចធ្វើទៅបាន ដូចជាធ្វើស្រែចំការ ធ្វើជាងឈើជាងដែក ជាងស៊ីម៉ង់ត៍ ឬលក់ដូរបន្តិចបន្តួច មានលក់ម្ហូបចំណីជាដើម ដែលជារបរអ្នកជានោះ យើងអាចរស់នៅដោយស្រួលគឺ មានផ្ទះនៅ មានចំណីអាហារគ្រប់គ្រាន់ មានសំ-លៀកបំពាក់សមរម្យ កើតជាមនុស្សថ្លៃថ្នូរ ជាងអ្នកធ្វើរាជការខ្លះ ដែលស៊ីសំណូកនោះទៅទៀត ព្រោះយើងរកបានដោយ

យុត្តិធម៌សុចរិតត្រឹមត្រូវ ។

-ការចេះលៃលក ដឹងប្រមាណ មិនល្មោភហួសសមត្ថភាពខ្លួន នឹងមិនស្ងាប់គំនិតដូច្នេះ ឈ្មោះថាជាមនុស្សមានសុជីវធម៌ចេះស្គាល់ប្រមាណជីវភាពរបស់ខ្លួន ។

-ត្រូវវៀរនូវរបរអកុសលថោកទាបបំផុត ដែលមនុស្សលោកមិនត្រូវធ្វើនោះចេញគឺ របរលួចប្លន់, របរស៊ីសំណូក, របរក្បត់ជាតិលក់ស្រុកទេស, របររត់គយ នឹងរបរក្លែងបន្លំ មានក្លែងក្រដាសប្រាក់ជាដើម ។ ព្រោះរបរទាំងនេះខុសនឹងច្បាប់រដ្ឋ បើយើងបានធ្វើរបរទាំងនេះណាមួយហើយ ទោះបីរាជការចាប់បានក្តី មិនបានក្តី ជីវិតរបស់យើងឈ្មោះថាជាជីវិតមានទោស ឬជីវិតជាប់គុកស្រេចទៅហើយ សូម្បីរកបានដល់កើតជាមហាសេដ្ឋីក៏ដោយ ពិតជាស្ងាប់ទាំងរស់ស្អុយទាំងស្រស់ ។ បើរាជការរកលេសចាប់មិនបាន ក៏មានអ្នកដទៃគេដឹងដែរ ។

-បើជីវិតយើងរស់នៅ ដោយសារមុខរបរពុករលួយក្រខ្វក់

ដូច្នេះ សុជីវធម៌របស់យើង គឺការដឹងប្រមាណជីវភាពនោះក៏គ្មានដែរ ព្រោះយើងជាមនុស្សគំរក់ កំសាកចោលម្សៀត ធ្វើមុខរបរត្រឹមត្រូវថ្លៃថ្នូរសុចរិត នឹងគេមិនកើត ។

-របរកសិកម្ម គឺការធ្វើស្រែចំការ ច្បារដំណាំគ្រប់ប្រភេទ, របរនេះជាមធ្យោបាយស័ក្តិសិទ្ធិមួយ សំរាប់ស្រូបបឺតយកផលិតផលពីព្រះធរណី ជាមុខរបរថ្លៃថ្នូរបរិសុទ្ធ មិនច្របូកច្របល់ដោយអំពើថោកទាបទុច្ចរិត ហើយអាចធ្វើបានដោយងាយទៀត មិនរើសឋានៈមនុស្ស គឺអ្នកក្រក៏ធ្វើបាន អ្នកមានក៏ធ្វើបាន អ្នកចេះឬអ្នកល្ងង់ក៏ធ្វើបានឱ្យតែមានចិត្តចង់ធ្វើ ។

-ដើម្បីធ្វើរបរនេះឱ្យបានផលច្រើនគ្រប់គ្រាន់ ដល់ការចំណាយនោះ ត្រូវយកចិត្តទុកដាក់ឧស្សាហ៍ព្យាយាម ធ្វើឱ្យទាន់ពេលវេលា ហើយចេះថែរក្សាត្រួតពិនិត្យ ដាក់ជីស្រោចទឹក ការពារសត្វល្អិតចង្រៃ បោចស្មៅធ្វើរបង នឹងធ្វើទ្រនប់ទឹកជាដើម ។ ការធ្វើទាំងអស់នេះ ត្រូវធ្វើដោយខ្លួនឯងខ្លះ ពឹងពាក់ឱ្យគេជួយខ្លះ ជួលគេធ្វើឱ្យខ្លះ ធ្វើដោយម៉ាស៊ីនខ្លះ តាមមធ្យោបាយដែល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស សាវី**

ខ្លួនមាន កុំខ្ជិលច្រអូសខ្ជីខ្ជា គិតតែពីដើរលេងស៊ីផឹកត្រែតត្រត ធ្វើឱ្យរួចតែពីដៃ ហើយដេកចាំឱ្យស្រែចំការធ្វើជំនួសខ្លួន បង្វែរផលមកឱ្យខ្លួនវិញនោះ ធ្វើម្ដេចនឹងបានផលគ្រប់មុខចំណាយ ។ ដល់ពេលខ្វះស្រែកថាក្រ ព្រោះរបរស្រែចំការនេះធ្វើឱ្យខ្លួនក្រ នាំឱ្យខូចឃីហោរបរកសិកម្មអស់ ថាជារបរសំរាប់អ្នកក្រទៅវិញ ។

-មានខ្វះទៀតខ្ជិលណាស់ មួយឆ្នាំៗធ្វើរបរតែម្ដង ចំនួន៥ ឬ៦ខែតែប៉ុណ្ណោះ ដល់ពេលច្រូតកាត់ហើយ មិនធ្វើរបរអ្វីទៀតទេ គិតតែពីដេកគ្រោកដើរលេងស៊ីផឹក. ចុះបើធ្វើរបរតែ៥ឬ៦ខែដូច្នេះ ហើយក្រពះវាឃ្លានរាល់ថ្ងៃ ដល់ទៅ១២ខែឯណោះ តើបានអ្វីនឹងបំពេញឱ្យបាត់ឃ្លាន? ប្រាកដជាខ្ចីបុលជឿបណ្ដាក់ ឬលួចប្លន់គេនោះឯង ។ នេះជាលក្ខណៈមនុស្សគ្មានសុជីវធម៌ មិនស្គាល់ប្រមាណជីវភាព មិនចេះលៃលករកចំណូល នឹងចំណាយឱ្យស្មើគ្នា ធ្វេសប្រហែសឱ្យធ្លាក់ខ្លួន ទៅក្នុងឋានៈទ័លក្រថោកទាប ដែលមិនងាយនឹងកែទម្រង់វិញបាន ។

-របរពាណិជ្ជកម្ម ការជំនួញដូញលក់នេះ មិនសំរាប់

តែអ្នកមានទេ អ្នកក្រក៏ធ្វើបានដែរ ។

ដើម្បីធ្វើជំនួញឱ្យបានផលគ្រប់គ្រាន់ ដល់ការចំណាយនោះ ត្រូវលៃធ្វើជំនួញណា ដែលសមនឹងសមត្ថភាពខ្លួន គឺដែលខ្លួនចេះដឹងយល់របៀបផង មានដើមទុនល្មមធ្វើបានផង កុំអាងតែទៅចងការខ្ចីប្រាក់គេ មកធ្វើដើមឱ្យបានធំបានហ៊ឺហា ហើយយកផលចំណេញសងតែការប្រាក់គេនោះ មិនកើតទេ ។

គ្រប់របរជំនួញ តែងតែមានការជឿបណ្តាក់ ទៅវិញទៅមកខ្លះ ត្រង់នេះត្រូវប្រយ័ត្នឱ្យមែនទែន គឺកុំជឿបណ្តាក់យកមកច្រើនពេក ដរាបដល់លក់ចេញមិនអស់ នឹងមិនត្រូវជឿបណ្តាក់ឱ្យទៅគេច្រើនពេក នាំឱ្យខូចខាតដោយទារយកមិនបាន ឬក៏ទារក្រេបាន បណ្តាលឱ្យខ្វះដើមទុនរកតទៅទៀត ។

ត្រូវជាអ្នកពិតត្រង់ហើយដឹងដើមដឹងចុង កាលបើយករបស់អ្វីៗពីអ្នកណាមកលក់ ត្រូវប្រញាប់បង្វិលដើមឱ្យគេវិញគ្រប់ចំនួន ឬក៏ជាងពាក់កណ្តាល កុំទុកចាយផ្តេសផ្តាសឱ្យអស់ប្រាក់ដើមនោះ នាំឱ្យខូចការទាក់ទង មិនហ៊ានទៅយកឥវ៉ាន់

ពីគេមកលក់ទៀត ។

កុំគិតយកចំណេញតែម្នាក់ឯងច្រើនពេក ត្រូវលៃឱ្យល្មមគ្នាយកទៅលក់បានចំណេញផង នឹងកុំឱ្យថ្លៃហួសដល់ទៅអ្នកទិញប្រើប្រាស់ផង គឺកុំលក់យកធ្វើអ្នកមានតែម្តង ដែលនាំឱ្យខូចឈ្មោះ ហោចាប់រលំ ខានរកស៊ីជំនួញនោះតទៅទៀត ។

អ្នកធ្វើជំនួញគ្រប់ប្រភេទទាំងអស់ ត្រូវទាក់ទងរាប់អានអ្នករកស៊ីមុខជំនួញត្រូវគ្នា យកធ្វើជាមិត្រ ដើម្បីបានពិភាក្សាជជែកជំនុំ អំពីហេតុផលខាតចំណេញ នឹងដំណើរប្រព្រឹត្តទៅនៃមុខជំនួញ ឱ្យបានដឹងតម្លៃឡើងចុះភ្លាមៗទាន់កាលសម័យផង ស្រណុកពឹងពាក់ខ្ចីគ្នាទៅវិញទៅមកផង ចំពោះករណីណាដែលយើងខ្វះហើយត្រូវការ ។

ជាសំខាន់បំផុត ត្រូវដឹងឱ្យច្បាស់នូវហេតុដែលនាំឱ្យខាតឬឱ្យចំណេញ ហើយត្រូវសន្សំផលចំណេញ សូម្បីបន្តិចបន្តួចក៏ត្រូវតែសន្សំយក ជាជាងអត់ទទេ កុំចាំតែចំណេញច្រើនទើបចង់បាន ទើបធ្វើជំនួញនោះ គួរយកតម្រាប់តាមសត្វកណ្ដៀរ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ត្រូវមានការគួរមរាក់ទាក់ពេះពាយ ចំពោះភ្ញៀវអ្នកមកទិញឥវ៉ាន់ពីយើង ឬដែលយើងត្រូវទៅលក់ឱ្យគេ កុំប្រើអាការៈធ្មើងធ្មៃ ប្រកាន់ឬកធំតូច ប្រើសំដីធំៗគំរោះគំរើយ ទោះបីអ្នកមកទិញបង្អាប់បន្ទុះថ្លៃ ដោយពាក្យមិនគួរគប្បីយ៉ាងណា ក៏កុំរវល់ស្តាប់ កុំអាក់អន់ចិត្តដោយពាក្យសំដីនោះៗ គប្បីប្រើទឹកមុខនឹងពាក្យសំដីស្រស់ញញឹម ពិរោះទន់ផ្អែម ទាក់ទាញឱ្យទាល់តែបានទិញឥវ៉ាន់យើង ហើយរាប់អានយើងទៀត ។

កាលបើអ្នកធ្វើជំនួញចេះលៃលក យកចិត្តទុកដាក់ប៉ិនប្រសប់ ចេះប៉ាន់ប្រមាណកិច្ចការ ដូចនាំមកជាគោលៗដោយខ្លីនេះហើយ តែងបានចំរើន ជួញអ្វីៗក៏មិនងាយខាតរលំ អាចនាំផលចំណូលឱ្យចូលមក បានគ្រប់គ្រាន់ដល់ការចំណាយ ទើបឈ្មោះថាជាអ្នកមានសុជីវធម៌ ចេះស្គាល់ប្រមាណជីវភាព ។

-របរធ្វើជាង អ្នកដែលចេះវិជ្ជាណាមួយ ដូចចេះធ្វើគ្រឿងអលង្ការ - ចេះធ្វើតុទូតាំង - ចេះឆ្លាក់គូសវាស - ចេះធ្វើគ្រឿងឥដ្ឋស៊ីម៉ង់ត៍ - ចេះធ្វើផ្ទះសំបែង នឹងចេះធ្វើគ្រឿងដែកជាដើម

ហើយយកចំណេះទាំងនោះ មកធ្វើជាមុខរបរចិញ្ចឹមជីវិត អាច ញ៉ាំងជីវភាពឱ្យប្រព្រឹត្តទៅបានស្រួល ហើយថ្ងៃថ្នូរថែមទៀត ។ របរធ្វើជាងនេះ អាចរកផលចំណូលបានដោយស្រួល មិនភ័យ ពីការខ្វះខាតខាងមុខចំណាយ ឱ្យតែចេះរបរនេះប្រាកដ ហើយ យកចិត្តទុកដាក់ធ្វើឱ្យត្រឹមត្រូវល្អ ។ បើធ្វើខ្ជីខ្ជា ធ្វើឱ្យរួចតែពីដៃ ឬធ្វើដោយចិត្តទុច្ចរិត កេងកិបយកចំណេញហួសហេតុ ឬក៏ធ្វើ ឈប់ៗព្រោះខ្ជិល គិតតែពីដេកក្រោកៗដើរលេងស៊ីផឹក ក្នុង មួយឆ្នាំធ្វើបានតែ៥ឬ៦ខែនោះ តើរកចំណូលពីណា ឱ្យបាន គ្រប់គ្រាន់ បើក្រពះវាត្រូវចំណាយរាល់ថ្ងៃ ដល់ពេលខ្វះខាតគ្មាន ចំណីអាហារសំលៀកបំពាក់ ស្រែកថ្ងូរថាក្រ ។ នេះជាលក្ខណៈ មនុស្សគ្មានសុជីវធម៌ មិនស្គាល់ប្រមាណជីវភាពរបស់ខ្លួន ។

ឯមុខរបរដទៃៗទៀត ដូចជារបរធ្វើរាជការ របរស៊ីឈ្នួល នឹងរបរតូរ្យតន្ត្រីច្រៀងរាំជាដើម ក៏ត្រូវតែខំប្រឹងប្រែង ព្យាយាម យកចិត្តទុកដាក់ ធ្វើឱ្យជិតដល់តាមកំរិតការងារនោះ ។ កុំខ្ជិលច្រអូស ឈប់ញយៗត្រូវឧស្សាហ៍ធ្វើឱ្យបានជាប់ជានិច្ចរាល់

ពេលវេលាពល់ថ្ងៃខែឆ្នាំ ទើបបានផលចំណូលបរិបូណ៌គ្រប់គ្រាន់ ធូនល្មមដល់ការចំណាយ ។

## ១-អំពីការបំណាយ

មនុស្សម្នាក់ៗ ដែលខំធ្វើរបរគ្រប់យ៉ាងបានផលចំណូលមកហើយ ត្រូវចេះចំណាយ បរិភោគប្រើប្រាសឱ្យសមប្រមាណ គឺចេះកាញ់គ្នេរលែលកឱ្យបានគ្រប់គ្រាន់ ល្មមរស់នៅសមរម្យនឹងគេ កុំចាយប្រើប្រាសខ្ជះខ្ជាយធំទូលាយពេក កុំកំណាញ់ស្វិតស្វាញត្បិតត្បៀតពេក ដូចខាងក្រោមនេះ៖

-ទ្រព្យដែលរកបានមកទោះតិចក្តីច្រើនក្តី ត្រូវលែលករំលែកជាបួនចំណែក គឺលែយកមួយចំណែកចិញ្ចឹមអ្នកមានគុណមានមាតាបិតាជាដើម ដែលលោកបានចិញ្ចឹមរក្សា ទំនុកបំរុងយើងតាំងពីកើតមក មានជូនបាយទឹកនំចំណីសំពត់អាវ ឬជូនលុយកាក់ សំរាប់ឱ្យលោកចាយធ្វើបុណ្យទាន ។

-រំលែកមួយចំណែកទៀត ទំនុកបំរុងចិញ្ចឹមបុត្រធីតា

ឱ្យមានចំណីអាហារសំលៀកបំពាក់ នឹងប្រដាប់សិក្សារៀនសូត្រ ប្រដាប់ប្រើប្រាស់ឱ្យសមរម្យតាមសមត្ថភាពខ្លួន កុំឱ្យបុត្រធីតាអត់ឃ្លានរហេមរហាម ស្លៀកពាក់រយ៉ីរយ៉ៃ ខ្វះប្រដាប់សិក្សារៀនសូត្រ ចូលចំណោមជំនុំនឹងគេមិនចុះ ជាហេតុឱ្យថោកទាបខូចកិត្តិយសដល់វង្សត្រកូល ។

-រំលែកមួយចំណែកទៀត ទុកសំរាប់ធ្វើបុណ្យទាន ជួយជាតិនឹងសាសនា ដែលអាចផ្តល់ប្រយោជន៍ឱ្យខ្លួន ក្នុងលោកនេះនឹងលោកខាងមុខ គឺបើមានគេធ្វើកុដិវិហារសាលា ឬធ្វើស្ពានផ្លូវថ្នល់មន្ទីរពេទ្យជាដើម ហើយឃោសនាអែងរ៉ាស ត្រូវឱ្យមានលុយកាក់ចូលធ្វើនឹងគេខ្លះ តាមសមត្ថភាពខ្លួន ។

-មួយចំណែកទៀត សំរាប់ចំណាយ ទិញគ្រឿងឧបភោគបរិភោគរាល់ថ្ងៃ គឺបើមិនទាន់មានផ្ទះនៅ ត្រូវសន្សំសំចៃឱ្យមានផ្ទះនៅឡើង បើមានផ្ទះនៅស្រាប់ហើយ ក៏ត្រូវសន្សំទុកសំរាប់ជួសជុល កុំបណ្តោយឱ្យផ្ទះបាក់បែកធ្លុះធ្លាយ ហើយត្រូវឱ្យមានចានឆ្នាំង ប្រដាប់ប្រើប្រាស់គ្រប់គ្រាន់ក្នុងផ្ទះ នឹងទិញ

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាមី**

ចំណីអាហារបរិភោគឱ្យបានគ្រប់គ្រាន់ សមគួរតាមកំឡាំងទ្រព្យដែលរកបាន កុំហ៊ឺហាស៊ីធំចាយធំ ហួសមុខចំណូលដែលរកបាន ដរាបដល់ខ្វះខ្វីគេមកស៊ីចាយថែមទៀតនោះ មិនឈ្មោះថាជាអ្នកស្គាល់ប្រមាណជីវភាព ជាអ្នកមានសុជីវធម៌ទេ ។ ជាពិសេស មិនគួរបរិភោគចំណីអាហារជឿគេទេ ដូចជាមនុស្សខ្វះ ទៅទិញជឿអង្ករត្រីសាច់គេជាដើម យកមកចិញ្ចឹមជីវិតដល់ពេលដាច់ខែ ឬពេលដែលមានទើបសងគេវិញ ។ នេះមិនមែនមកពីក្ររកមិនបានទេ គឺមកពីខ្វះខ្នាយចាយឥតគំនិតគ្មានសុជីវធម៌ ពេលដែលរកបាន ឬពេលដែលបើកប្រាក់ខែមក មិនចេះកាញ់ត្នេរលៃលកទុក សំរាប់បន្តជីវិត គិតតែចាយពង្រួសឱ្យទាល់តែអស់រលីង ដល់ពេលឃ្វានខ្វាចដាច់ជីវិត ទើបទៅជឿជីវិតគេយកមកបន្តជីវិតខ្លួន គឺបណ្ដោយជីវិតខ្លួនធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃគេ ធ្វើដូច្នោះមិនសមរម្យសោះ នាំឱ្យអាប់កិត្តិយសធំណាស់ ។

ឯការទិញជឿនោះទៀត គេតែងយកចំណេញលើសពី

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាធី**

វិញដល់ដៃ គឺគេគិតការប្រាក់ថែមលើថ្លៃលក់នោះទៀត ម្ហោះហើយមុខចំណាយកាន់តែដុនដាប ធ្លាប់ចាយ ១០ រៀលឆ្អែត ត្រូវឡើងដល់១៥ឬ១៦រៀលទើបឆ្អែត, អនុភាពនៃថវិកាគ្រួសារចេះតែចុះទៅៗ ត្រូវក្ររហាមអស់មួយជីវិត ព្រោះតែគ្មានសុជីវធម៌ មិនស្គាល់ប្រមាណជីវភាពនេះឯង ។

## គ-អំពីសណ្ដាប់ធ្នាប់នៃការបរិភោគប្រើប្រាស

ពេលបរិភោគអាហារក្នុងគ្រួសារនីមួយៗ សុទ្ធតែបានកំរិតពេលវេលាតាមទំលាប់គ្រួសារ ដូច្នេះសមាជិកគ្រួសារម្នាក់ៗត្រូវមកបរិភោគរួមគ្នាឱ្យទាន់ពេលវេលា កុំឱ្យគេចាំខ្លួន ឬគេលំបាកបំបែកម្ហូបអាហារទុកឱ្យ ។ អ្នកដែលមានអាយុក្មេងជាងត្រូវទៅជួបជុំគ្នាមុនពួកចាស់ៗ ចាត់ចែងរៀបចំកំរាលកន្ទេល ឬរៀបចំតុកៅអី ចានស្លាបព្រា និងដបកែវទឹកជាដើម កុំឱ្យមនុស្សចាស់ទៅចាំខ្លួន ឬទៅរៀបចំឱ្យខ្លួន ។

-ត្រូវបរិភោគចំណីអាហារ ឱ្យល្មមតែឆ្អែតបាត់ឃ្លាន កុំ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

បរិភោគតាមចំណង់ ដកបដល់តឹងពោះចាក់ច្រាស បណ្ដាលឱ្យមានអាសន្នក្អួតចង្អោរ ឬមានអាការៈហល់ផ្ទៃធំពោះកំប៉ោង ក្រោកមិនចង់រួច ដើរទ្រាលទ្រល បញ្ចេញរូបរាងផ្ទៃកដល់ភ្នែកអ្នកដទៃ ឱ្យគេសំគាល់បានថា ជាមនុស្សល្មោភស៊ីដូចជ្រូក ។

-មុននឹងបរិភោគ ត្រូវរៀបចំផុសលាងឱ្យខ្លួនឱ្យស្អាតបាត បើមានញើសក្អែល ឬប្រឡាក់ដៃជើងដោយអ្វីៗ ត្រូវផ្ងូតទឹកជំរះចេញ កុំឱ្យមានធុំក្លិនអាក្រក់ នាំឱ្យគេខ្ពើមរអើម ។

-មិនគួរបរិភោគអាហារអាក្រាតខ្លួនទទេ មិនបានពាក់អាវ ត្រូវស្លៀកពាក់ឱ្យមានអាវខោឬសារុង, ប៉ុន្ដែមិនត្រូវស្លៀកខោអាវឬសារុងណា ដែលមានក្លិនឆ្អេះឆ្អាបស្មោកគ្រោកក្រខ្វក់ នាំឱ្យគេខ្ពើមរអើមនោះទេ ។

-ពេលជួបជុំគ្នាហើយ មុននឹងបរិភោគ កុំថ្ងៃងអាការៈឃ្លានជ្រុលឆ្ងេឆ្ងា ភ្នែកសំឡឹងម្ហូបអាហារលេបទឹកមាត់ ឬលូកស៊ីនេះស៊ីនោះមុន ដែលជាអាការៈឥតរបប ។

-ត្រូវអង្គុយបរិភោគ តាមទីកន្លែងដែលខ្លួនធ្លាប់អង្គុយ

កុំម្តងអង្គុយត្រង់នេះម្តងត្រង់នោះគ្មានរបៀប ។ ពួកក្មេងត្រូវគោរពចាស់ បើអង្គុយរាបនឹងកន្ទេល ត្រូវបត់ជើងឱ្យសមរម្យ ។ វៀរតែអ្នកចាស់ជាងអនុញ្ញាតឱ្យពែន ឬឱ្យបញ្ឈរជង្គង់ ទើបគួរធ្វើតាម ។ ជាពិសេស ត្រូវលូកម្ហូបអាហារក្រោយមនុស្សចាស់ ។

-បើមនុស្សចាស់ជាងបរិភោគអស់បាយហើយ ត្រូវសុំចានមកដួសជូន ទោះខ្លួនកំពុងជាប់មាត់បរិភោគឆ្ងាញ់យ៉ាងណាក៏ត្រូវឈប់ ដួសជូនមនុស្សចាស់សិន ។ មុនដំបូងគួរដួសឱ្យច្រើនបន្តិច តែកុំឱ្យហៀរចាន ដល់លើកក្រោយដួសល្មម ៗ បានហើយ ។ ឯមនុស្សចាស់ បើខ្លួនត្រូវការឱ្យគេដួសច្រើន ឬតិចត្រូវប្រាប់គេផង កុំសម្ងំស្ងៀមដរាបដល់បរិភោគមិនអស់ ឬមិនឆ្អែត ទើបបន្ទោសក្មេងៗនោះឡើយ ។

-ត្រូវបរិភោគដោយអាការៈសមរម្យ កុំឱ្យឮសូរមាត់ផ្ចប់ៗ ឬសង្កៀតធ្មេញជាដើម ។ បើបរិភោគមានសមស្លាបព្រាកុំឱ្យឮសូរច្រេវច្រាវ គឺកុំឱ្យប៉ះស្លាបព្រានិងចាន ឬនិងធ្មេញ ។

-ពេលហុតសំឡ កុំឱ្យឮសូរគ្រូកៗ ត្រូវហុតឱ្យស្រួល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ឱ្យអស់ពីស្លាបព្រា កុំហុតជាប់ៗគ្នាពីរបីដងទើបឈប់ មុននឹងយកស្លាបព្រាទៅជួតសំឡត្រូវឱ្យស្អាត កុំឱ្យមានជាប់គ្រាប់បាយជិតកាកសម្ល ឬទឹកមាត់ ។

-កុំលូកចានសម្លមួយពីរនាក់ ចាំគេលូករួច សឹមយើងលូកជាក្រោយ ទាំងកុំលូកប្រទាក់ប្រទើសកន្ទងរំលងដៃគ្នា ។

-បើម្ហូបនោះគ្រៀមស្វិត ដូចសាច់ឬត្រីជាដើម ដែលគេបេះក្រុបាន យើងត្រូវយកសមស្លាបព្រាឬចង្កឹះ ជួយទប់ជួយបេះផង ។

-ត្រូវវៀរនូវការលូកញយៗ ចំពោះម្ហូបណាដែលឆ្ងាញ់ជាងគេ នឹងកុំចំកោងទ្រាលទៅលើស្លកឬតុ ទៅចាប់ទៅជួតម្ហូបដែលនៅឆ្ងាយពីខ្លួន ។

-អ្នកបរិភោគរួមជាមួយ បើឃើញថាម្ហូបណានៅឆ្ងាយអ្នកម្ខាងលូកមិនដល់ គប្បីមានការគួរសម ប្តូរដាក់ទៅខាងនេះម្តង ខាងនោះម្តង ឱ្យបានបរិភោគទាំងអស់គ្នា ។ វៀរតែអ្នកម្ខាងថា មិនត្រូវការទេ ។

-តាមទម្លាប់ខ្មែរយើង ត្រូវបរិភោគឱ្យអស់បាយពីចាន កុំឱ្យមានគ្រាប់បាយនៅសល់ ជាទុព្ភួតសញ្ញាបញ្ជាក់ឱ្យអ្នកបរិភោគដឹងថា បាយមួយគ្រាប់ៗនោះ កើតឡើងដោយសេចក្ដីព្យាយាមយ៉ាងនឿយហត់ របស់កសិករជាច្រើនខែ មិនមែនកើតមកដោយងាយៗទេ ។

-កុំបរិភោគបញ្ចេញអាការៈឆ្ងាញ់ឱ្យគេដឹង គឺកុំបញ្ចេញសូរសព្ទធំៗផឺះផឹះ ។ បើបរិភោគម្ទេស កុំបញ្ចេញខ្យល់ហឹរធ្វើស៊ីតស៊ូតឱ្យគេឮ ប្រសិនបើហឹរខ្លាំងដល់ចេញទឹកភ្នែកទឹកសំបោរ ត្រូវសុំទោសគេក្រោកចេញឱ្យឆ្ងាយ ទៅខ្ពុរមាត់ជុសលាងមុខឱ្យស្អាត សឹមមកបរិភោគវិញ ដើម្បីកុំឱ្យគេខ្ពើមខ្ពូន ។

-កំពុងបរិភោគ កុំឆ្លៀតនិយាយ ឬឆ្លើយទាំងអាហារនៅក្នុងមាត់ ត្រូវទំពារលេបឱ្យអស់សឹមនិយាយ ។

-មិនត្រូវបរិភោគខ្ជីខ្ជា ឱ្យជ្រុះគ្រាប់បាយកំពុបទឹកសម្ល ត្រីសាច់បន្ទៃរាត់រាយ ប្រឡាក់ពេញកន្ទេលពេញតុ ត្រូវប្រយ័ត្នឱ្យស្អាតជានិច្ច សូម្បីតែមុខមាត់ ក៏មិនត្រូវឱ្យជាប់គ្រាប់បាយ

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី សស់ សាទី

កាកសម្ដែរ ឧស្សាហ៍សង្កេតពិនិត្យខ្លួនឯង បើសង្ស័យថា គ្រែង មានជិតប្រឡាក់ ជាប់នៅមុខមាត់ហើយ ត្រូវយកកូនកន្សែង ជូតភ្លាម កុំទុកឱ្យជិតប្រឡាក់ឡើយ ។ មានខ្លះទុកពុកមាត់ ពុកចង្កា ដល់បរិភោគទៅ វាជិតជាប់កាកបាយសម្លស្រមាមប៉ាក ដូចជ្រូកស៊ីបាយ គួរឱ្យខ្ពើមក្រៃពេក ។

-កំពុងបរិភោគភោជន កុំនិយាយប៉ប៉ាច់ប៉ប៉ោច សើច ក្អាកក្អាយ ឱ្យខ្ចាយទឹកមាត់ចូលបាយសម្ល ។ បើជួនជាមាន ការត្រូវនិយាយ គួរនិយាយតិចៗល្មមតែឮ ត្រូវចំណុចសើច អត់មិនបាន ត្រូវងាកមុខចេញ ឬយកដៃបិទបាំងមាត់ កុំបើក ចំហឱ្យចំម្លូបអាហារ ។

-កំពុងបរិភោគ បើមាននរណាមួយធ្វើអ្វីខុស ដូចកូន ចៅទារស៊ីផ្ដេសផ្ដាសជាដើម មិនត្រូវជេរវាយទះតប់គំហកកំហែង ទេ ត្រូវឱ្យមានបរិយាកាសល្អជានិច្ច ។

-បើក្អកកណ្ដាសឬត្អើក ក្នុងពេលកំពុងបរិភោគ ឬក៏ ឈ្លក់បាយសម្ល ត្រូវងាកមុខចេញ បើមិនបាត់ទៅភ្លាមទេ ត្រូវ

សុំទោសគេក្រោកទៅឱ្យឆ្ងាយ កុំឱ្យគេខ្ពើមរអើម ដោយសារការក្អកកណ្តាសជាដើមនោះ ដរាបដល់បានស្រួលបួលសឹមមកបរិភោគវិញ ។

-កំពុងបរិភោគ បើចង់កើឬ ផោម ត្រូវតែមានមធ្យោបាយធ្វើជាសុំទោសក្រោកទៅយកនេះនោះ ឱ្យឆ្ងាយកុំឱ្យគេដឹងឮដល់ហើយស្រួលបួល ទើបគួរចូលមកបរិភោគវិញ ។

-កំពុងបរិភោគ កុំនិយាយចាក់ដោត ឱ្យនរណាមួយកើតសេចក្តីអន់អាក់ ថ្នាំងថ្នាក់ចិត្តក្រោធខឹង ទាំងខ្លួនឯង ក៏មិនត្រូវថ្ងៃងអាការៈក្រោតខឹងដែរ ត្រូវខំអត់ទ្រាំចាំបរិភោគហើយ ។

-ត្រូវមានអាការៈរីករាយក្នុងពេលបរិភោគ ដើម្បីឱ្យឆ្ងាញ់បាយ កុំនិយាយរំលឹក ពីគ្រាលំបាកកំសត់កើតទុក្ខ ស្រណោះអាឡោះអាល័យ ចំពោះអ្វីៗឡើយ ។

-មិនត្រូវនិយាយដំណាល ពីរឿងដែលនាំឱ្យកើតការខ្ពើមរអើម មាននិយាយពីខ្មោចស្លាប់ ពីគំរង់សាកសពពីបង្គន់ជាដើម ដែលនាំឱ្យគេខ្ពើមលេបបាយមិនរួច ។

-កំពុងបរិភោគ ជួនជាមានឆ្អឹងនៅក្នុងមាត់ ត្រូវខ្ជាក់ដោយលាក់លៀមកុំឱ្យគេឃើញ បើខ្ជាក់ហើយកុំចោលនៅលើតុ ឬដាក់នៅលើស្លក ឬក៏ដាក់ទៅក្នុងកន្ថោ ដែលនៅជិតល្មមគេមើលឃើញនោះឡើយ ត្រូវចោលទៅទីកំបាំង កុំឱ្យគេខ្ពើមដោយសារខ្លួន ។

-បើមានជាប់ឆ្អឹង ឬសាច់នៅធ្មេញ ត្រូវយកដៃបិទបាំងមាត់សិនសឹមចាក់ ហើយខ្ជាក់ចោលកុំឱ្យគេឃើញ, ឯឈើចាក់ធ្មេញដែលបានប្រើហើយនោះ ត្រូវចោលដែរ កុំយកមកជូត ឬយកទៅហិតរួចដាក់ទៅលើតុលើស្លក ឬសៀតត្រចៀកទុកចាក់ទៀតនោះឡើយ ។

-មិនគួរខ្ទរមាត់ ខាកស្ដោះដាក់កន្ថោ ឬក្នុងទីណាមួយឱ្យអ្នកបរិភោគជាមួយ គេឃើញឬឮសូរ នាំឱ្យខ្ពើមរអើមឡើយ ត្រូវទៅឱ្យឆ្ងាយ កុំឱ្យគេឮសូរខាកស្ដោះជាដើមនោះ ។

-ត្រូវបញ្ចប់ការបរិភោគឱ្យបានដំណាលគ្នា កុំឈប់មុនពេកក្រោយពេក, វៀរតែអ្នកបរិភោគជាមួយនោះ គេមិនសួរ

ឃ្លាន គេមានសុំគ្រោកមុន ។ បើយើងរួចមុនគេ ចង់គ្រោកចេញ ត្រូវមានពាក្យគួរសមថា ‹‹សុំគ្រោកមុនហើយ នៅបរិភោគឱ្យបានស្រួលបរិបូណ៌ចុះ›› ។

-អំពីការប្រើប្រាស់របស់ទ្រព្យវិញ ក៏ត្រូវស្គាល់ប្រមាណខ្លួន នឹងវត្ថុប្រើប្រាស ដូចជាការបរិភោគអាហារភោជនដែរ គួរលៃឱ្យសមល្មមមាឌ កុំហ៊ឺហាហួសកុំត្បិតត្បៀតពេក លៃឱ្យបានសមរម្យទៅតាមសមត្ថភាព នឹងកាលសម័យ ។ បើយើងជាអ្នកទ័លក្រ មិនត្រូវបង្ខំស្លៀកពាក់ហ៊ឺហា ខ្ចីបុលចងការប្រាក់គេទិញម៉ូតូទិញឡានជិះ ឱ្យជំពាក់បំណុលរុំក្បិន ម្ចាស់គេតាមទារមុខក្រោយ នាំឱ្យខូចកិត្តិយសនោះទេ ។ ម្យ៉ាងទៀត ត្រូវស្លៀកពាក់ឱ្យសមប្រមាណកាល ដូចពេលធ្វើការងារ មិនត្រូវយកសំលៀកបំពាក់ល្អសំរាប់ទៅបុណ្យ សំរាប់ដើរលេងមកស្លៀកពាក់ទេ ។ មានអ្នកខ្លះចង់ហ៊ឺហាជ្រុលស្ទូបរិភោគបាយនឹងអំបិល ឬនឹងសៀង ឬក៏សុំទានគេបរិភោគ សន្សំលុយកាក់ទុកទិញសលៀកបំពាក់ ហើយយកក្រដាសកាសែតបត់ញាត់ក្នុង

ហោប៉ៅ ក្រៃងឱ្យគេដឹងថាជាអ្នកមានលុយ ហ៊ឺហាផ្ដេសផ្ដាស ខុសរបៀប ស្លៀកខោឡេវ ពាក់ស្បែកជើងឃ្មុបដើរលុយកក់ ដើរកាត់ស្រែចំការ លើកឫកខ្ពស់ហាក់មិនហ៊ានដើរដី ខ្លាចប្រឡាក់ជើង ។ នេះជាលក្ខណៈមនុស្សគ្មានសុជីវធម៌ មិនស្គាល់ប្រមាណជីវភាពរបស់ខ្លួន ។

-អំពីការប្រើវ៉ែនតា ត្រូវប្រើឱ្យសមតាមលក្ខណៈខ្លួន នឹងកាលសម័យ កុំក្រៃងធ្វើងងឹតពាក់វ៉ែនតាញោបមិនដោះ, ឯអ្នកដែលពាក់វ៉ែនតាពណ៌ បើចូលទៅផ្ទះគេឬប្រាស្រ័យនឹងអ្នកធំជាងឬក៏ស្មើគ្នាត្រូវដោះចេញទើបគួរ ។

-អត្ថបទដូចបរយាយមកជាគោលៗនេះ ជាវត្ថុបទទី ៣នៃសុជីវធម៌ គឺការស្គាល់ប្រមាណជីវភាព ។

-ក្នុងវត្ថុបទនេះ អប់រំមនុស្សឱ្យស្គាល់ប្រមាណខ្លួន នឹងមុខរបរដែលខ្លួនត្រូវធ្វើត្រូវរក កុំឱ្យនៅទំនេរ កុំឱ្យដេកចាំធ្វើ ចាំរកតែមុខរបរដែលស្រួលស្រណុក ដែលធំៗហួសសមត្ថភាពខ្លួន នឹងឱ្យស្គាល់ប្រមាណការស៊ីចាយ ការប្រើប្រាសរបស់ទ្រព្យ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

# វគ្គបទទី៤
# ការស្គាល់កាលសម័យ

-ដើម្បីរស់នៅក្នុងពិភពលោក ឱ្យបានសមរម្យទាន់សម័យនឹងគេ កុំឱ្យប្រជែងប្រដាំងឈ្លើយតែម្នាក់ឯង នឹងធ្វើដំណើរជីវិតឱ្យប្រព្រឹត្តទៅទាន់ព្រឹត្តិការណ៍ ដែលជាហេតុឱ្យបានលាភបានជ័យ សុខចំរើននោះ ត្រូវជាអ្នកស្គាល់កាលសម័យឱ្យច្បាស់ គឺស្គាល់ពេលវេលាដែលត្រូវ ដេក ដើរ ឈរ អង្គុយ និយាយ ស្តាប់ គិតធ្វើការងារថា ‹‹ពេលនេះម៉ោងនេះអញត្រូវដេក, ពេលនោះម៉ោងនោះអញត្រូវភ្ញាក់ ត្រូវក្រោកធ្វើការងាររៀនសូត្រ›› ជាដើម ។

-ម្យ៉ាងទៀតត្រូវបំពេញ ករណីយកិច្ចរបស់ខ្លួនឱ្យទាន់ល្បឿននៃដំណើរជីវិត ព្រោះជីវិតចេះតែប្រព្រឹត្តលឿនទៅមុខគ្រប់នាទីមិនដែលល្បីថាវិលត្រឡប់ថយក្រោយ ឬឈប់បង្អង់ចាំឱ្យយើងបំពេញករណីយកិច្ចសិននោះទេ ។

-ដូច្នេះមនុស្សម្នាក់ៗ មិនត្រូវស្ទាប់ចិត្តគំនិតជាប់ជំពាក់ញៀនញ៉ាម ចំពោះអារម្មណ៍ណាមួយយូរពេកទេ ត្រូវឱ្យមាន

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

ចលនាប្រព្រឹត្តទៅទាន់កាលសម័យ នឹងទាន់ដំណើរជីវិត ។ ដូចជាពេលសិក្សារៀនសូត្រ ត្រូវស្រូតរូតប្រឹងប្រែងឱ្យទាន់ចំណេះដែលត្រូវចេះដឹង តាមទំហំជំនាន់វ័យរបស់ខ្លួន កុំគិតតែពីដេកនឹងសមាជជជែកគ្នាលេង ក្នុងម៉ោងដែលត្រូវសិក្សា ។ បើអស់សមត្ថភាពនឹងសិក្សាតទៅទៀតហើយ មិនត្រូវរើរើសការងារយូរពេកទេ ការអ្វីក៏ធ្វើសិនទៅ គឺដំណើរជីវិតប្រព្រឹត្តទៅ ដល់ត្រឹមណា យើងត្រូវបំពេញករណីយកិច្ចឱ្យទាន់ត្រឹមនោះ កុំឱ្យពេលវេលារត់ចោលយើងឆ្ងាយពេក ។ បើយើងមិនស្រូតតាមឱ្យទាន់កាលទេសៈទេ អនាគតរបស់យើង ត្រូវពេលវេលាទំពាស៊ីអស់, ពេលគេត្រូវមានប្រពន្ធកូនគ្មាន, ពេលគេត្រូវមានចៅខ្លួនទើបនឹងមានប្រពន្ធ ចេះតែខុសដើរមិនទាន់សម័យ មិនទាន់ព្រឹត្តិការណ៍សោះ មកពីគ្មានសុជីវធម៌មិនស្គាល់កាលសម័យ នៅក្រាញផ្សងព្រេងមួយកន្ទែងៗយូរៗពេក, ដូចជាពេលប្រឡងរកការងារធ្វើ បើប្រឡងពីរបីដងមិនបានហើយ កុំក្រាញនៅដាក់ដីម៉ង់ត៍ប្រឡងរាប់ឆ្នាំ ឱ្យទាល់តែគ្រប់ក្រសួងគ្មានសល់នោះឡើយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

-ឯការស្គាល់កាលសម័យនោះ មានច្រើនយ៉ាងដូចខាងក្រោមនេះ ។

## ក-អំពីឥរិយាបថ៤

-ការដេកជាអាហារមួយយ៉ាងសំខាន់ សំរាប់ជីវិតមនុស្ស ប៉ុន្តែបើដេកមិនត្រឹមត្រូវតាមពេលវេលា គឺដេកច្រើនពេក ឬតិចពេកនោះ អាចក្លាយទៅជាថ្នាំពិស ញ៉ាំងមនុស្សឱ្យវិនាសអន្តរាយខូចផលប្រយោជន៍គ្រប់យ៉ាង ។ ដូចជាអ្នកសិក្សារៀនសូត្រ បើខំរៀនពេកមិនបានដេកឱ្យគ្រប់គ្រាន់ ត្រឹមត្រូវតាមពេលវេលាទេ បណ្តាលឱ្យខ្សោយដល់សរសៃវិញ្ញាណ ។ យូរៗទៅជាឆ្កួតវង្វេង នឹងស្គមរីងរៃគ្មានសុខភាពបរិបូណ៌ ។ បើគិតតែពីដេកច្រើនពេកនោះ ក៏នាំឱ្យខ្ជិលច្រអូស រមាយក្នុងការរៀនសូត្រ ចេះតែងងុយដេក ។ ពេលត្រូវទៅរៀនក្រោកទៅមិនទាន់ម៉ោង កើតជាមនុស្សមានដំណើរយឺតយ៉ាវ ទៅណាមិនបានទាន់គេ ធ្លាប់ខូចអស់មួយជីវិត ដល់ឈប់រៀនទៅធ្វើ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេ សាទី**

ការងារ ក៏រវល់តែដេកជ្រុលទៅមិនទាន់ម៉ោង នាំឱ្យខូចកិត្តយស ត្រូវចៅហ្វាយនាយស្តីបន្ទោសរាល់ពេលវេលា ។ បើត្រូវធ្វើដំណើរទៅណាមកណាដោយយានយន្តផ្សេងៗ តែងតែទៅមិនទាន់ នាំឱ្យខកដំណើរខ្លួនឯងនឹងអ្នកដទៃដែលបានសន្យាថាទៅជាមួយគ្នានោះទៀត ។ បើជាអ្នកធ្វើស្រែចំការ ឬធ្វើជំនួញជាដើមវិញ រឹតតែអន្តរាយធំណាស់ទៅទៀត ព្រោះពេលវេលាសុទ្ធតែជាមាសនឹងប្រាក់ រវល់តែដេកផ្តេសផ្តាស មាសប្រាក់រត់ចោលអស់ ។

ដើម្បីបានសំរេចផលប្រយោជន៍សមដូចបំណង ត្រូវដេកឱ្យទៀងទាត់តាមពេលវេលា គឺពេលដេកត្រូវតែដេក ពេលក្រោកត្រូវតែក្រោក បើគ្មានការអ្វីធ្វើទេ ក៏ត្រូវតែក្រោកកុំឱ្យធ្លាប់ខ្លួន ។

-ការដើរជាឥរិយាបថមួយយ៉ាងប្រសើរ ហើយជាថ្នាំកែរោគយ៉ាងសំខាន់ អាចញុំាងធាតុទាំងបួនឱ្យប្រព្រឹត្តទៅស្រួល នាំឱ្យរូបកាយមានសុខភាពល្អ ។ ប៉ុន្តែត្រូវដើរឱ្យមានពេលវេលា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

មានសណ្តាប់ធ្នាប់ល្អ កុំដើរផ្តេសផ្តាសអាក់សែ មិនស្គាល់ពេលម៉ោង គឺមិនត្រូវដើរចច្រប់ ទៅក្នុងទីដែលមិនគួរដើរ ឱ្យហួសពេលវេលា ដូចជាកន្លែងដែលធ្លាប់កើតរឿងហេតុអំពីចោរ និងតៀមស្រា បនស្រីផ្កាមាសជាដើម ព្រោះកន្លែងទាំងអស់នេះជាអព្វមង្គល ទោះខ្លួនជាអ្នកបរិសុទ្ធល្អក៏ដោយ កាលបើមានកើតរឿងហេតុឡើង គេអាចចោទប្រកាន់ រង្កៀសសង្ស័យចំពោះខ្លួនបាន្នាំឱ្យសៅហ្មងខូចកិត្តិយស ។

-ម្យ៉ាងទៀតមិនត្រូវដើរលេង ក្នុងពេលម៉ោងដែលត្រូវរៀនសូត្រ ត្រូវធ្វើការងារ និងត្រូវដេក គឺត្រូវប្រកាន់ពេលម៉ោងឱ្យទៀងទាត់ ដូចជាពេលត្រូវរៀនសូត្រធ្វើការងារ និងពេលដេកនោះ ទោះបីចង់ទៅលេងទីណា ឬមានមិត្រសំឡាញ់មកបបួលទៅលេងកន្លែងណាក៏ដោយ មិនត្រូវទៅទេ ព្រោះមិនមែនជាពេលដើរលេង ។

ក្នុងថ្ងៃឈប់ឬថ្ងៃបុណ្យ បើដើរទៅលេងក្នុងទីណាៗ មិនត្រូវដើរឱ្យហួសពេលដេក ពេលបរិភោគអាហារទេ ត្រូវធាប់

ត្រឡប់វិញឱ្យបានមុនពេលម៉ោងនោះបន្តិច ដើម្បីកុំឱ្យជ្រុលខូចពេលម៉ោងទៅខាងមុខទៀត ។

-ចំពោះស្ត្រីមេផ្ទះ ក៏ត្រូវដើរឱ្យមានពេលម៉ោងទៀតទាត់ដែរ ដូចជាមានការដើរទៅរកអ្វីមួយ ត្រូវធាប់ត្រឡប់វិញកុំឱ្យហួសពេលម៉ោងចំអិនអាហារ ឬពេលបោកគក់សំលៀកបំពាក់ នឹងពេលរៀបចំផ្ទះសំបែងជាដើម ។

-ឯបុរសជាមេគ្រួសារ បើធ្វើដំណើរទៅទីណាៗ មានទៅធ្វើការរកស៊ីជាដើម ក៏ត្រូវប្រញាប់មកវិញឱ្យទាន់ពេលម៉ោង ដែលខ្លួនបានប្រាប់គេដែរ កុំឱ្យគេទន្ទឹងមើលផ្លូវ នាំឱ្យគេកើតសេចក្តីភ័យព្រួយដោយសារខ្លួន គឺមិនត្រូវដើរផ្តេសផ្តាសតាមចិត្តឱ្យខុសពេលវេលានោះឡើយ ។

-ទីកន្លែងណាដែលគេមានហាមឃាត់ មិនឱ្យដើរតាមកាលសម័យ ដូចជាមានធ្វើពិធីធំៗជាផ្លូវរដ្ឋនៅទីណាមួយ ដែលរាជការមានដាក់សញ្ញាហាម មិនឱ្យដើរចូលទៅ មិនឱ្យដើរកាត់ហើយយើងចេះតែចេសដើរឡុលចូលទៅ ដើម្បីមើលអ្វីៗនោះ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

មិនគួរទេ បើយើងធ្វើដូច្នោះ ឈ្មោះថាជាមនុស្សគ្មានសុជីវធម៌ មិនស្គាល់កាលសម័យ ។

-ការឈរជាឥរិយាបថមួយ ដែលត្រូវប្រព្រឹត្តឱ្យត្រឹមត្រូវតាមកាលសម័យដែរ ដូចជាក្នុងថ្នាក់រៀន ក្នុងការិយាល័យរាជ-ការ ឬក្នុងគេហស្ថានរបស់ខ្លួន ឬក៏ក្នុងទីណាមួយ បើមានអ្នកធំជាងយើងគេចូលទៅក្នុងទីនោះ យើងត្រូវក្រោកឈរឡើង ដើម្បីឱ្យមានសេចក្ដីគោរពគួរសម ។ ប៉ុន្តែមិនត្រូវចេះតែឈររហូត ឬឈរតែមួយភ្លែតអង្គុយវិញភ្លាម មិនស្គាល់កាលនោះទេ ។ បើនៅក្នុងថ្នាក់រៀន ឬក្នុងការិយាល័យរាជការ ដែលមានអ្នកធំជាចៅហ្វាយនាយ ឬជាគ្រូចូលទៅនោះ ចាំលោកប្រាប់ថាឱ្យអង្គុយសិនទើបគួរអង្គុយ ។ ក្នុងគេហស្ថានរបស់ខ្លួន បើមានភ្ញៀវជាមនុស្សស្មើគ្នា ឬជាអ្នកធំជាងចូលទៅនោះ កុំនាំគេឈរយូរពេកហួសពេលវេលា ត្រូវឆាប់អញ្ជើញឱ្យគេអង្គុយ ។ បើពេលដែលយើងអញ្ជើញនោះ គេមិនទាន់អង្គុយទេ យើងត្រូវតែឈរកំដរគេសិន កុំអាលអង្គុយមុនគេ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ក្នុងពិធីបូជាសព ឬបញ្ចុះសព បើយើងទៅដល់កន្លែងមុន ហើយគេរៀបឱ្យអង្គុយកៅអី ពេលដែលហែសពទៅដល់ត្រូវក្រោកឈរគោរពសព ដរាបដល់គេដាក់សពលើកន្លែងតម្កល់មានជើងថ្កល់ជាដើមហើយ ទើបគួរអង្គុយ ។ ដល់ពេលព្រះសង្ឃនិមន្តទៅបង្សុកូល ត្រូវក្រោកឈរគោរពទៀត ដរាបដល់សូត្រចប់ទើបគួរអង្គុយ ។ ដល់ពេលធួលភ្លើងបូជា ឬរំកិលសពដាក់ទៅក្នុងរណ្ដៅ ត្រូវក្រោកឈរម្ដងទៀតប្រហែល៥នាទីទើបគួរអង្គុយ ។ ឯអ្នកអង្គុយរាបផ្ទាល់កន្ទេល មិនគួរក្រោកឈរទេ គ្រាន់តែដាក់ដៃឱ្យស្រួលកុំចាប់នេះនោះ ហើយអង្គុយសង្រួមគោរពបានហើយ ។

កំពុងដើរឬអង្គុយនៅទីណាមួយ មានអង្គុយក្នុងរោងកុន-ល្ខោនជាដើម បើដល់ពេលវេលាគោរពទង់ជាតិ ដោយបានឮភ្លេងនគររាជ ឬសញ្ញាណាមួយ ត្រូវក្រោកឈរតម្រឹមជើងសំយ៉ុងដៃ បែរទៅរកសូរសព្ទនឹងសញ្ញានោះ គោរពដល់ចប់ទើបគួរអង្គុយ ឬធ្វើដំណើរតទៅទៀត ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

បើឈរមើលអ្វីៗ មានក្បួនហែសពជាដើម មិនត្រូវឈរមើលក្មេងខ្លួន ឱ្យហួសពេលវេលាដែលត្រូវសិក្សារៀនសូត្រធ្វើការងារ ឬពេលបរិភោគភោជនាហារទេ គប្បីវាសវៃឆាប់ត្រឡប់វិញកុំឱ្យខុសខូចខាតពេលវេលា ដែលត្រូវប្រព្រឹត្តធ្វើ ។

-ការអង្គុយជាឥរិយាបថមួយទៀត ដែលត្រូវប្រព្រឹត្តឱ្យត្រឹមត្រូវតាមពេលវេលាដែរ គឺត្រូវអង្គុយតាមកាលសម័យដែលគួរអង្គុយ ។ ការអង្គុយនេះ មានលក្ខណៈបែបបទទាក់ទងគ្នាដូចជាការឈរដែរ ។

## ១-អំពីករណីយកិច្ច

មនុស្សម្នាក់ៗសុទ្ធតែមានករណីយកិច្ច ត្រូវប្រព្រឹត្តធ្វើគ្រប់ៗគ្នា ។ ដើម្បីប្រព្រឹត្តធ្វើឱ្យបានថ្លៃថ្នូរ មិនទាស់អធ្យាស្រ័យរង្កៀសអាក់អន់រំខានចិត្តដល់អ្នកដទៃនោះ ត្រូវប្រព្រឹត្តធ្វើឱ្យបានស្របតាមពេលវេលាកាលសម័យៈ

-ពេលយប់ឬថ្ងៃ ដែលជាពេលឈប់សំរាកដេក មិន

ត្រូវនិយាយឬសើចខ្លាំងៗឡូឡា ។ ឱ្យភ្ញាក់ផ្អើលរំខានដល់អ្នកដទៃ រកគេសម្ងំដេកពួនមិនបាននោះឡើយ ។ បើយើងមិនទាន់ដេក ត្រូវនិយាយឱ្យតិចៗ គោរពដល់អ្នកដេក ។

-អំពីការបើកបិទទ្វារបង្អួច បើដល់ពេលវេលាដែលត្រូវឈប់សំរាកដេកហើយ ត្រូវបើកបិទតិចៗកុំឱ្យឮក្តុងក្តាំង នាំឱ្យភ្ញាក់ផ្អើលដល់អ្នកដទៃ ។

-អំពីការសិក្សាទន្ទេញរៀនសូត្រ ឬអានសៀវភៅរឿងរ៉ាវសារពត៌មានជាដើម មិនត្រូវស្រែកទន្ទេញ ឬអានខ្លាំងៗក្នុងពេលវេលាដែលគេត្រូវឈប់សំរាកដេកឡើយ ត្រូវទន្ទេញឬអានតិចៗ កុំឱ្យអ្នកដទៃរំខានដោយសារខ្ញុំ ។

-បើមានរឿងហេតុទាស់អធ្យាស្រ័យគ្នា រវាងភរិយាស្វាមីក្នុងពេលដែលគេឈប់សំរាកដេកពួននោះ គប្បីអត់ទ្រាំសិនមិនត្រូវស្រែកជេរបញ្ចោរ វាយតប់កណ្តាលយប់អធ្រាត្រ ឱ្យភ្ញាក់ផ្អើលដល់អ្នកដទៃ ដែលនាំឱ្យជោកទាបខូចកិត្តិយសទេ ។

-អំពីការជេរស្តីបន្ទោស ប្រដៅកូនចៅក៏ដូចគ្នា មិន

ត្រូវជេរស្តីវាយប្រដៅឡូឡា ក្នុងពេលដែលគេត្រូវសំរាកដេកពួន ឱ្យអ្នកជទៃរំខានដោយសារខ្លួនឡើយ ។

-ឯអ្នកមានកូនចៅតូចៗ មិនត្រូវស្រែកច្រៀងបំពេបើកបទឡូៗ កណ្តាលយប់អធ្រាត្រ ដែលជាពេលគេដេកទេ ត្រូវបំពេតិចៗបានហើយ បើខ្លួនជាអ្នកចំណូលខាងការបំពេកូន ។

-អំពីការប្រើវិទ្យុ ទោះក្នុងពេលវេលាណាក៏ដោយ ត្រូវបើកសំឡេងតិចៗ ល្មមតែស្តាប់ឮខ្លួនឯងបានហើយ កុំបើកខ្លាំងនាំឱ្យអ្នកជិតខាង ដែលគេមិនចូលចិត្តស្តាប់ កើតសេចក្តីធុញទ្រាន់រំខានចិត្តដោយសារខ្លួន ។

-ក្នុងពិធីបុណ្យទាននឹងធ្វើមង្គលផ្សេងៗ មានមង្គលការជាដើម បើយើងមានគ្នាតិចល្មមទេ មិនត្រូវប្រើឧគ្ឃោសនស័ព្ទឱ្យឮឡូឡាពេញភូមិស្រុក កណ្តាលយប់អធ្រាត្រ រកគេសម្ងំដេកពួនផងមិនបាន ។ មានអ្នកខ្លះចូលចិត្តប្រើឧគ្ឃោសនស័ព្ទផ្តេសផ្តាសណាស់ សូម្បីស្រែកហៅគ្នាបួនដប់នាក់ ដែលអង្គុយជិតគ្រាន់តែខ្សិបឮនោះ ក៏ប្រើឧគ្ឃោសនស័ព្ទដែរ ។ មានអ្នក

ខ្លះទៀតនិមន្តព្រះសង្ឃមកឆាន់ ឬនិមន្តធម្មថិកសំដែងធម៌ទេសនា ក៏ស្រែកនិមន្តតាមឧគ្ឃោសនស័ព្ទដែរ ខុសរបៀបបែបបទប្រពៃណី គ្មានសេចក្តីគោរពគួរសមសោះ បញ្ចេញអាការៈខ្វះសុជីវធម៌ ឥតសេចក្តីអៀនខ្មាស់ ។ ឯឧគ្ឃោសនស័ព្ទ ដែលអ្នកប្រាជ្ញបង្កើតមកនោះ មិនមែនសំរាប់ស្រែកបង្អួត ឱ្យគេឮថាខ្លួនចេះនិយាយ ឬឱ្យគេដឹងថាខ្លួនមានកូនចៅការនោះទេ គឺសំរាប់ប្រើក្នុងពិធីបុណ្យ ឬក្នុងទីប្រជុំធំៗមានមនុស្សរាប់ពាន់ម៉ឺននាក់ ដែលនិយាយធម្មតាស្តាប់គ្នាមិនឮ ទើបគេប្រើឧគ្ឃោសនស័ព្ទនឹងសំរាប់ប្រកាសផ្សាយដំណឹងជាអាសន្ន ឬឃោសនាដំណឹងផ្នែកពាណិជ្ជកម្ម មានឃោសនាលក់ថ្នាំជាដើម ។ ការប្រើទាំងអស់នេះ ក៏គេប្រើទៅតាមកាលសម័យ ពេលវេលាដែរ មិនចេះតែប្រើផ្តេសផ្តាស មួយយប់ទល់ភ្លឺនោះឡើយ ។

-អំពីការជប់លៀង ស៊ីផឹកកំសាន្តផ្សេងៗក្នុងគ្រួសារដែលមានរាំច្រៀងស្រែកឡូឡា ក៏មិនត្រូវឱ្យប្រព្រឹត្តទៅហួសពេលវេលា ដល់យប់អធ្រាត្ររកគេដេកផងមិនបាននោះឡើយ ។

បើយ៉ាងយូរណាស់ ដល់ម៉ោង១១ ឬ១២ត្រូវតែឈប់ ព្រោះជាពេលវេលាដែលគេត្រូវដេកពួនគ្រប់គ្នា ។

ទោះបីក្នុងពេលវេលាដែលមិនទាន់ហួសម៉ោងនោះ ក៏មិនគួរស៊ីផឹកស្រែកហ៊ោកញៀវឡូឡា ឱ្យឮកង់រំពងដល់ផ្ទះពីរបីដែរ ព្រោះការស្រែកឡូឡាកង់រំពងនោះ មិនមែនជាលក្ខណៈរបស់ជនអ្នកមានសុជីវធម៌ឡើយ ។

ការស្គាល់ពេលវេលា ដូចបរិយាយមកដោយគោលៗនេះ ជាវត្តបទទី២នៃសុជីវធម៌ គឺការស្គាល់កាលសម័យ ។

ក្នុងវត្តបទនេះ អប់រំឱ្យមានគំនិត ប្រព្រឹត្តទៅកាន់ដំណើរជីវិត ទាន់ព្រឹត្តិការណ៍ កុំឱ្យខូចអានាគត នឹងធ្វើខ្លួនឱ្យជាទីស្រឡាញ់រាប់អាន នៃអ្នកនៅផ្ទះជិតខាងភូមិផងរបងជាមួយ ។

# វគ្គបទទី៥

# ការស្គាល់ប្រជុំជន និងទីប្រជុំ

ដើម្បីបានជាមនុស្សចុះជំនុំនិងគេ ត្រូវចេះរបៀបរៀបចំពាក្យសំដី និយាយស្ដី, ដេកដើរឈរអង្គុយស៊ីផឹក, ស្លៀកពាក់, សួរឆ្លើយ, គោរពក្រាបសំពះថ្វាយបង្គំ ចាប់ដៃផ់ក់ក្បាលនឹងអ្នកកណ្ដាលសជាដើម ឱ្យមានបែបបទសណ្ដាប់ធ្នាប់ល្អ ។

បើយើងមិនបានដឹង មិនចេះរៀបចំចរិយាទាំងនេះ ឱ្យបានបែបបទល្អទេ គេថាមនុស្សឈ្លើយ ឥតសណ្ដាប់ធ្នាប់ គ្មានសុជីវធម៌ ឬថាជាមនុស្សមិនចុះជំនុំ, ទៅចូលចំណោមជំនុំនិងគេក្នុងទីណានាំឱ្យអ្នកផងគេធុញទ្រាន់ អាក់អន់រំខានចិត្ត អៀនខ្មាស់ដោយសារខ្លួនក្នុងទីនោះ ។

ដូច្នេះមនុស្សម្នាក់ៗ ត្រូវឱ្យចេះរបៀបរៀបចំកាយវាចា ឱ្យបានសមរម្យដូចតទៅនេះ៖

## ក-គារវកិច្ចចំពោះប្រជុំជន

ប្រជុំជនគឺពួកជនដែលកំពុងប្រជុំគ្នាមានច្រើនយ៉ាងគឺ៖ ប្រជុំ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **ស៊ស សាទី**

ជនស្តាប់សន្និសិទ, ប្រជុំជនស្តាប់សមាជ, ប្រជុំជនធ្វើទាន ប្រជុំជនស្តាប់ធម៌ទេសនា, ប្រជុំជនរៀបមង្គលការ, ប្រជុំជនធ្វើបុណ្យសព, ប្រជុំជនមើលរបាំស្តាប់តូរ្យតន្ត្រី និងប្រជុំក្នុងពេងកុនល្ខោនជាដើម ។

អ្នកទៅប្រជុំទាំងនោះ ត្រូវមានសេចក្តីគួរសម គោរពចំពោះប្រធាននៃប្រជុំជន នឹងគោរពចំពោះមិត្រសំឡាញ់ ឬចៅហ្វាយនាយជាដើម ដែលបានទៅប្រជុំជាមួយគ្នា ដោយអាការៈសមរម្យតាមឋានៈ តាមទំនៀមទំលាប់ដែលរាប់អាននិយមប្រើ ៖

-ការគោរពតាមទំលាប់ខ្មែរសម័យនេះ មានលើកដៃសំពះផងចាប់ដៃងក់ក្បាលផង, ចំពោះស្ត្រីនិងបុរស ឬស្ត្រីនិងស្ត្រីខ្មែរយើង គេគោរពត្រឹមតែសំពះសួរសុខទុក្ខគ្នា នឹងសំពះលាគ្នាប៉ុណ្ណោះ មិនបានងក់ក្បាលចាប់ដៃ ដូចជាបុរសនិងបុរសទេ ។

-ក្មេងត្រូវសំពះចាស់មុន កូនចៅក្មួយនិងប្អូន ត្រូវសំពះមាតាបិតាជីដូនជីតាមាមីងនិងបងមុន, សិស្សនិងពាស្រ្ត ត្រូវសំពះគ្រូនិងមន្ត្រីមុន ។ ឯមាតាបិតាជីដូនជីតា មិនត្រូវសំពះ

ទៅកូនចៅវិញទេ គ្រាន់តែថ្លែងអាការៈទទួលគួរសម ដោយពាក្យសំដីឱ្យពរជ័យបានហើយ ។

-ការគំនាប់ផ្កក់ក្បាលចាប់ដៃនោះ ជាគារវកិច្ចរបស់ពួកអឺរ៉ុប ប៉ុន្តែសព្វថ្ងៃក្លាយជា គារវកិច្ចអន្តរជាតិទៅហើយ គេអាចយកមកប្រើលាយឡំគ្នា ជាមួយនឹងគារវកិច្ចប្រចាំជាតិរៀងៗខ្លួន បានឥតទាស់ខុស ។

ការចាប់ដៃមានលក្ខណៈដូច្នេះ គឺគេចាប់ដៃស្តាំនិងដៃស្តាំ ហើយមើលមុខញញឹមរកគ្នា តែមិនត្រូវចាប់ច្របាច់ខ្លាំងដល់ឈឺ ឬចាប់យូរពេកឱ្យហួសពី២ឬបីនាទីទេ, មិនត្រូវលើកកែងដៃ ឬចុងដៃឱ្យខ្ពស់ ឬហុចដៃទៅបញ្ឆៀងខ្លួន នឹងហុចដៃទៅក្រោយទេ ត្រូវបែរមុខឱ្យចំ សំយុងដៃឱ្យស្រួល ហើយចាប់ឱ្យពេញដៃ ។ ប៉ុន្តែកុំចាប់ចង្កិចចុងដៃ គេទុកជាមានចិត្តរាប់អានដោយស្មោះនឹងគ្នា ។ ចាប់ហើយត្រូវលែងវិញឱ្យស្រួលកុំកញ្ឆក់រលាស់ ។ បើដៃស្តាំយើងឈឺ ឬប្រឡាក់វត្ថុអ្វីៗ ហើយគេហុចដៃមកចាប់យើងនោះ ត្រូវបង្ហាញដៃឈឺឬដៃប្រឡាក់ឱ្យគេដឹង ហើយសុំ

ទោស ដោយពាក្យសំដីគួរសមនឹងគេវិញ ។ ឯរបៀបហុចដៃចាប់មុនក្រោយ នឹងលើកដៃសំពះខ្ពស់ទាបនោះ មាននិយាយក្នុងវគ្គបទទី២ ត្រង់រាជការនឹងប្រជារាស្ត្ររួចហើយ ។

-បើអង្គុយឬឈរឆ្ងាយពីគ្នា គ្មានឱកាសទៅចាប់ដៃបាន ត្រូវងក់ក្បាលគំនាប់រកគ្នា, មានអ្នកខ្លះងក់ក្បាលញញឹមហើយសំ-ពះហើយលើកដៃស្តាំបន្តិចផង ដើម្បីសំដែងសេចក្តីរាប់អាន យ៉ាងស្មោះស្ម័គ្រស្និទ្ធស្នាលនឹងគ្នា ។

-បើក្នុងប្រជុំជននោះមានព្រះសង្ឃផង ហើយគ្មានឱកាសនឹងលុតជង្គង់ថ្វាយបង្គំ ដូចជាលោកគង់កៅអីជាមួយគ្រហស្ថ ឬគង់ក្នុងទីខ្លះដែលចង្អៀតចង្អល់ មានមនុស្សឈរជុំវិញនោះ មិនត្រូវលុតជង្គង់ថ្វាយបង្គំទេ ទោះបីព្រះសង្ឃនោះមានឋានៈធំយ៉ាងណាក៏ដោយ គ្រាន់តែបន្ទន់ខ្លួនឱនក្បាល លើកដៃសំពះដល់ប្រជុំចិញ្ចើមបានហើយ ទុកជាមានគារវកិច្ចចំពោះព្រះសង្ឃពេញបរិបូណ៌ ។ បើទៅប្រជុំក្នុងវត្តអារាម ក្នុងកុដវិហារសាលា ឬក្នុងទីប្រជុំបុណ្យណាដែលមានឱកាសដ៏គួរនោះ ត្រូវតែលុតជង្គង់

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សៅ សាមី**

ថ្វាយបង្គំ, បើគ្រាន់តែគោរពសំពះនោះមិនគួរវិញទេ ។

-ក្នុងប្រជុំជនទាំងឡាយ ដូចជាប្រជុំធ្វើបុណ្យទាន នឹងធ្វើមង្គលការជាដើម បើទៅដល់ហើយ ត្រូវទៅគោរពគួរសមសំពះចាប់ដៃ អ្នកជាប្រធាននៃប្រជុំជន ឬអ្នកម្ចាស់ផ្ដើមបុណ្យនោះសិន សឹមអង្គុយតាមទីកន្លែង ដើម្បីបង្ហាញមុខឱ្យគេដឹងថា បានទៅជួយទៅប្រជុំជាមួយដែរ កុំលាក់មុខទៅពួនសម្ងំអង្គុយកៀនកោះឥតការគួរសមឡើយ ។

បើក្នុងប្រជុំជននោះមានព្រះសង្ឃផង មានព្រះពុទ្ធរូបផង, កាលបើគួរសមនឹងម្ចាស់បុណ្យឬប្រធាននៃប្រជុំជនហើយ ត្រូវថ្វាយបង្គំព្រះពុទ្ធរូបរួច សឹមថ្វាយបង្គំព្រះសង្ឃជាក្រោយ ។

-បើប្រជុំជននោះជាផ្លូវរដ្ឋ មានព្រះមហាក្សត្រឬព្រះប្រមុខរដ្ឋ ស្ដេចយាងទៅជាព្រះធិបបតីក្នុងប្រជុំជននោះ ត្រូវអង្គុយឬឈរឱ្យរៀបរយសមរម្យចាំគោរពទទួល មានទះដៃនឹងស្រែកថ្វាយពរជ័យ ។ ជាទំនៀម, មុននឹងព្រះមហាក្សត្រឬព្រះប្រមុខរដ្ឋស្ដេចយាងទៅដល់ ឥស្សរៈជនទាំងឡាយ តែងតែអញ្ជើញ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **ស៊ សាទី**

ទៅមុនជាលំដាប់លំដោយហូរហែ ។ ដូច្នេះ យើងត្រូវថ្លែងសេចក្ដីគោរពទទះដៃទទួល ឥស្សរៈជនទាំងអស់នោះដែរ ។

-ដល់ពេលចប់ពិធីប្រជុំ ឬពិធីបុណ្យហើយ ត្រូវគោរពសំពះចាប់ដៃលាប្រធានឬម្ចាស់បុណ្យ និងមិត្រសំឡាញ់ជាដើម ដោយអាការៈគួរសមដូចកាលទៅដល់ដែរ កុំក្រោកចេញមកធ្វើព្រងើយ ឥតការគួរសមគោរពលានរណានោះឡើយ ។

-ក្នុងពេលលាគ្នាត្រឡប់វិញនេះ បើមានឥស្សរៈជន ឬគ្រូអាចារ្យចៅហ្វាយនាយយើង បានទៅក្នុងប្រជុំជននោះដែរ ត្រូវចាំធ្វើគារវកិច្ចគោរពជូនលោក ឱ្យធ្វើដំណើរទៅមុនផុតសិន ទើបគួរទៅទីលំនៅខ្លួនជាក្រោយ ។

-បើកំពុងតែប្រជុំ ហើយមានគេប្រាប់ថា មានការអាសន្នណាមួយនៅឯផ្ទះត្រូវទៅឱ្យឆាប់នោះ យើងមិនត្រូវលួចលាក់ទៅមិនឱ្យម្ចាស់បុណ្យគេដឹង ឬមិនឱ្យនរណាគេដឹងនោះទេ ត្រូវតែមានការគោរពគួរសមប្រាប់លាគេតាមដំណើររឿង ដោយស្ងប់ស្ងាត់កុំឱ្យផ្អើលខូចការប្រជុំខូចពិធីបុណ្យ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស សាទី**

ការធ្វើគារវកិច្ចគោរពប្រជុំជននេះមាន លក្ខណៈខុសៗគ្នា តាមទីប្រជុំ ដូចជាប្រជុំធ្វើសន្និសិទ ធ្វើសមាជ និងទីប្រជុំធ្វើបុណ្យ ។ ទានផ្សេងៗក្នុងសាសនាជាដើម សុទ្ធតែមានរបៀបខុសៗគ្នា ។ ដូច្នេះសូមធ្វើគារវកិច្ច លៃតាមទីប្រជុំនោះៗផងចុះ ។

## ១-ការប្រើឥរិយាបថក្នុងទីប្រជុំ

អ្នកទៅកាន់ទីប្រជុំទាំងឡាយ ត្រូវប្រុងប្រយ័ត្នឥរិយាបថ ទាំងបួន កុំឱ្យភ្ញាំងភ្ញាត់ផ្តេសផ្តាស តាមទំលាប់ដែលយើងធ្លាប់ប្រព្រឹត្តនៅផ្ទះរបស់ខ្លួន គឺត្រូវប្រើឱ្យសមទៅតាមទីប្រជុំ៖

ប្រជុំធ្វើបុណ្យក្នុងសាសនា ដូចជាពេលស្តាប់ទេសនា មិនត្រូវបណ្តោយទៅតាមការងោកងុយ ឱ្យដេកលក់កំពុងស្តាប់ធម៌ទេ ។ មានជនខ្លះក្រាបប្រណម្យស្តាប់ធម៌ ស្រាប់តែលក់កណ្តាលទីប្រជុំនោះទៅ ដកពបដល់ស្រមុកផងក៏មាន នាំឱ្យរំខានដល់អ្នកស្តាប់ឯទៀតផង ខ្វះសេចក្តីគោរពចំពោះព្រះធម៌ផង ។ នេះជាអាការៈថោកទាបគ្មានសុជីវធម៌ មិនត្រូវឱ្យមានអាការៈ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

បែបនេះក្នុងទីប្រជុំឡើយ ។

-នៅភូមិស្រុកខ្លះ បើមានប្រជុំធ្វើបុណ្យធំមួយៗ ដូចបុណ្យសពជាដើម ពេលទេសនាឬធ្វើពិធីផ្សេងៗរួចហើយ គេនាំគ្នាទៅដេកធម៌អាថ៌ ក្នុងទីរោងប្រជុំនោះដរាបដល់ភ្លឺ អ្នកណាងុយក៏ដេកទៅ ។ បើយើងដេកមិនទាន់លក់ទេ ហើយមានព្រះសង្ឃ ឬចាស់ទុំណាមួយដើរទៅជិតនោះ ត្រូវក្រោកអង្គុយ ឬអង្គុញជើងគួរសមសិន កុំដេកធ្វើព្រងើយ ។

បើមានចាស់ព្រឹទ្ធាចារ្យ អាស្រ័យដំណេកនៅកន្លែងណាមួយ ក្មេងមិនត្រូវទៅដេកទន្ទឹម ឬដេកលើទីខ្ពស់ជាងចាស់ទេ ទាំងមិនត្រូវធ្វើអ្វីក្នុងក្តាំងឱ្យរំខានឡើយ ។

បើគេអង្គុយប្រជុំជជែកគ្នាក្នុងទីណា មិនត្រូវទៅដេកប្រកៀកជិតទីនោះឡើយ ។ ជាពិសេស បើក្នុងរោងប្រជុំបុណ្យនោះ គេរៀបអាសនៈព្រះពុទ្ធរូបនៅទិសណា មិនត្រូវដេកយកជើងទៅទិសនោះ ទាំងមិនត្រូវដេកយកជើង ទៅចំរង់អ្នកអង្គុយជជែកធម៌អាថ៌ជាដើមនោះឡើយ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាមី**

-ការដើរក្នុងទីប្រជុំ ដូចប្រជុំឬបុណ្យទានជាដើម បើយើងកំពុងអង្គុយក្នុងចំណោមជាមួយគេ ហើយជួនជាមានការចាំបាច់ត្រូវក្រោកដើរទៅយកវត្ថុអ្វីៗជាដើមនោះ ត្រូវដើរឱនដោយអាការៈសមរម្យ កុំប្រញាប់ប្រញាល់ពេក ក្រែងប៉ះទង្គិចអ្នកដទៃ ។ បើគេអង្គុយចង្អៀត ត្រូវមានវាចាគួរសមសុំទោស សុំផ្លូវគេផង ។

-ក្នុងទីប្រជុំស្តាប់សមាជ ឬស្តាប់សន្និសិទជាដើម ដែលមានមនុស្សអង្គុយឬឈរផ្តុំគ្នាដោយក្រុមៗនោះ អ្នកដើរទៅមកត្រូវដើរវាងខាងក្រោយខ្នងគេ កុំដើរជ្រៀតជ្រែកកាត់ហ្វូងគេឱ្យសោះ សូម្បីគេប្រជុំតែពីរបីនាក់ក៏ដោយ ។

-ដើរក្នុងក្បួនហែផ្សេងៗមានហែសពជាដើម ដែលមានមនុស្សទៅជួបជុំគ្នាច្រើន ត្រូវពិនិត្យមើលរបៀបក្បួនគេ តើយើងគួរដើរត្រង់ណា ? ។ បើមានអ្នករៀបក្បួននោះមិនជាការពិបាកអ្វីទេ គេឱ្យដើរត្រង់ណា ដើរឱ្យតែត្រង់ជួរគ្នា ឱ្យមានល្បឿនប្រហែលគ្នាទៅជាការស្រេច ។ ប៉ុន្តែបើក្បួនហែនោះ គ្មានអ្នករៀបចំហ្មត់ចត់ទេ ដូចក្បួនហែសពឯកជនជាដើម

យើងត្រូវដឹងថា តាមទំលាប់អ្នកជូនដំណើរសព ត្រូវដើរក្រោយសព . គឺស្ត្រីដើរមុន បុរសដើរក្រោយ ។ ឯអ្នកដែលជាក្រុមគ្រួសារសពវិញគឺ ភរិយានិងកូនចៅស្រីៗ ដើរពីក្រោយជាប់នឹងរថយន្តសព, កូនចៅប្រុសៗដើរទន្ទឹមសព ឬឈរអមមឈូសសព ។ បើពួកកូនចៅចិនវិញ កូនចៅប្រុសៗដើរនាំមុខសព ស្រីៗដើរជូនពីក្រោយសព ។

ការប្រជុំគ្នាដើរក្នុងក្បួនហែសពនេះ ត្រូវដើរដោយអាការៈស្ងប់ស្ងៀម កុំនិយាយដែកគ្នាសើច ឬនិយាយគ្នាពីរឿងអ្វីៗនឹងមិនត្រូវដើរពាយប៉ាយ ម្តងដើរត្រង់នេះ ម្តងទៅត្រង់នោះគ្មានសណ្តាប់ធ្នាប់ គ្មានជួរគ្មានសង្កាត់ត្រឹមត្រូវឡើយ ។

-ក្នុងទីប្រជុំឬក្រៅទីប្រជុំ បើមានមន្ត្រីតូចធំ ឬចៅហ្វាយនាយ គ្រូអាចារ្យមាតាបិតា ចាស់ព្រឹទ្ធាចារ្យអង្គុយកៅអីក្តី អង្គុយរាបក្តី បើយើងមានការដើរកាត់មុខ ឬដើរទៅជិត គប្បីបន្ទន់ខ្លួនឱនក្បាលបន្តិច ជាគារវកិច្ចចំពោះលោកទាំងនោះ ។

បើលោកទាំងនោះ ហៅយើងទៅសាកសួរកិច្ចការអ្វីមួយ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស សាទី**

ត្រូវប្រើឥរិយាបថតាមការគួរ គឺបើលោកអង្គុយកៅអី យើងត្រូវដើរទៅជិតឈរគោរពសិន បើមានកៅអីទំនេរលោកហៅឱ្យអង្គុយ ទើបគួរអង្គុយ ហើយសឹមនិយាយតប ។ បើលោកអង្គុយរាប យើងត្រូវអង្គុយរាបដែរ សឹមនិយាយតប ។ កាលបើនិយាយហើយលាលោកវិញ ត្រូវក្រោកដើរថយក្រោយបានពីរបីជំហានសិន សឹមបែរមុខទៅរកទីដែលយើងត្រូវទៅ កុំបែរឱ្យខ្នងទៅលោកភ្លាម មិនគួរសមទេ ។

-នៅក្នុងទីប្រជុំ យើងមិនត្រូវទៅឈរជិតកិបនឹងអ្នកអង្គុយកៅអី ឬអ្នកអង្គុយរាបទេ ។ បើជួនជាលើកដៃទៅ ប៉ះទង្គិចអ្នកឈរដូចគ្នា ឬអ្នកដើរជិតយើង ត្រូវសុំទោសដោយវាចាគោរព ហើយត្រូវអត់ទោស ឱ្យគ្នាទៅវិញទៅមកកុំប្រកាន់ ។

-នៅក្នុងទីប្រជុំកុំឈរស្ទឹមចង្កេះ លូកហោប៉ៅ ឈរជ្រែងបោះជើងទៅមុខទៅក្រោយ ដែលជាអាការៈឥតគួរសមផង នាំឱ្យច្រងេងច្រងាងទើសមុខមាត់អ្នកឈរជិតខាងផង គប្បីឈរឱ្យបានសមរម្យល្អ ។

-បើមានការត្រូវឈរប្រជុំគ្នានិយាយអ្វីៗ ហើយក្នុងទីប្រជុំនោះ មានអ្នកធំជាងខ្លួនដូចជាចៅហ្វាយនាយ អ្នកមានយសស័ក្តិ គ្រូអាចារ្យនឹងមាតាបិតាជាដើម មិនត្រូវឈរប្រកិតជិតលោកពេកទេ គួរឈរឱ្យឃ្លាតបន្តិច ដោយអាការៈគោរពសមរម្យ កុំប្រចត់ចង្កេះ លូកហោប៉ៅ ឈរបង់ចំទែងឈរកន្ទែកជើងទទោកជើង នឹងយោលយោគខ្លួនឡើយ ។

-នៅក្នុងទីប្រជុំជន ដូចជាផ្លូវថ្នល់ សួនផ្កា មាត់ច្រកនិងមាត់ទ្វារមាត់ជន្លើរជាដើម មិនត្រូវទៅឈរលេង ឱ្យទើសអ្នកធ្វើដំណើរទៅមកទេ បើចង់ឈរមើលអ្វីៗនៅទីនោះៗ ត្រូវរកទីគួរឈរសឹមឈរ ។

-ឥរិយាបថឈរក្នុងទីប្រជុំនេះ ត្រូវលៃផ្សំទៅតាមកាលផង ទើបមិនទាស់អធ្យាស្រ័យ អាក់អន់ចិត្តចំពោះគ្នានឹងគ្នាទៅវិញទៅមក ដូចជាទីប្រជុំមើលរបាំរាំច្រៀង នឹងមើលបុណ្យអុំទូកជាដើម អ្នកដែលបាននៅមុខគេមិនត្រូវឈរទេ នាំឱ្យអ្នកក្រោយមើលផងមិនឃើញ កើតក្តៅក្រហាយចិត្ត ។ កាលបើ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

អ្នកមុខអង្គុយហើយ អ្នកឈរបន្ទាប់ក៏ត្រូវតែអង្គុយដែរ វៀរតែអ្នកនៅក្រោយគេបង្អស់នោះ ទើបគួរឈរបាន ។ ឯអ្នកឈរក្រោយគេនោះទៀត មិនត្រូវឈរកិប ឬឈរប្រជ្រៀតបៀតទៅរកអ្នកអង្គុយទេ ទើបឈ្មោះថាជាអ្នកមានសុជីវធម៌ក្នុងការឈរ ។

-ការអង្គុយក្នុងទីប្រជុំមានពីរយ៉ាងគឺ អង្គុយរាបនឹងអង្គុយកៅអី ត្រូវអង្គុយឱ្យសមតាមឋានៈខ្លួន ដែលគួរអង្គុយមុខ អង្គុយកណ្តាលឬអង្គុយក្រោយគេ ។ នៅទីប្រជុំខ្លះមានអ្នកចាត់របៀបគេអញ្ជើញឱ្យអង្គុយតាមថ្នាក់ ដែលគេបានគ្រោងទុកនោះ យើងមិនត្រូវប្រកែកចចេសក្រាញអង្គុយតាមចិត្តខ្លួនទេ ត្រូវតែគោរពតាមអ្នកចាត់របៀប ។ នៅក្នុងទីប្រជុំបុណ្យសាសនា មានចាស់ៗខ្លះដាក់ខ្លួនទាបពេក ចេះតែខ្មាចដួរមុខ មិនព្រមទៅអង្គុយសោះ ទោះបីអ្នកម្ចាស់បុណ្យ ឬក្មេងៗអញ្ជើញយ៉ាងណាក៏មិនព្រម ចេះតែក្រាញថយក្រោយ រកកៀនកន្លៀតជញ្ជាំងដើម្បីផ្អែកតម្រង់ខ្នង ឬក៏ខ្មាចគេឃើញថាខ្លួនចាស់ មានសក់ស្កូវធ្មេញបាក់ជាដើមក៏មិនដឹង ។ ការធ្វើដូច្នេះ នាំឱ្យពិបាក

រំខានចិត្តក្មេងៗផង នាំឱ្យខូចរបៀបទីប្រជុំបុណ្យគេផង ។ នេះជាលក្ខណៈមនុស្សគ្មានសុជីវធម៌ ក្នុងទីអង្គុយនៅទីប្រជុំ ។

-ក្នុងទីប្រជុំនិមួយៗ បើមានព្រះសង្ឃផង ព្រះមហាក្សត្រ ឬប្រមុខរដ្ឋផង នាម៉ឺនធំៗផងនោះ; ព្រះសង្ឃតែងគង់អាសនៈពិសេសខ្ពង់ខ្ពស់ សំរាប់ព្រះមហាក្សត្រគោរព, បន្ទាប់មករាជាសនៈព្រះមហាក្សត្រឬប្រមុខរដ្ឋ, បន្ទប់មកទៀតអាសនៈសំរាប់នាម៉ឺនធំៗអង្គុយ ។

បើក្នុងទីប្រជុំដែលមានព្រះសង្ឃ នឹងមន្ត្រីខេត្រ-ស្រុក-ឃុំ ហើយនឹងចាស់ព្រឹទ្ធាចារ្យនោះ; ព្រះសង្ឃតែងគង់លើអាសនៈវិសេស ត្រូវមានកន្ទេលល្អជាងគ្រហស្ថ ឬកន្ទេលពីរជាន់ ឬក៏កន្ទេលមួយជាន់ ព្រំមួយជាន់ទៀត, បន្ទាប់មកកន្ទេលមួយជាន់បានហើយ ។ ឯអស់លោកមន្ត្រីខេត្រមន្ត្រីស្រុកនឹងមន្ត្រីឃុំអង្គុយជួរមុខ ជាមួយលោកអាចារ្យ, ជួរបន្ទាប់មកចាស់ទុំជាលំដាប់ទៅ ។

បើក្នុងទីប្រជុំនោះ មានតែព្រះសង្ឃនឹងចាស់ព្រឹទ្ធាចារ្យ

ត្រូវចាស់ព្រឹទ្ធាចារ្យនោះជាធំ អង្គុយជួរបន្ទាប់ព្រះសង្ឃ ទើបក្មេងៗអង្គុយជាលំដាប់មក ។

-តាមប្រពៃណីខ្មែរពីបុរាណ ក្នុងទីប្រជុំធ្វើបុណ្យ ឬធ្វើមង្គលផ្សេងៗមានមង្គលការជាដើម បុរសនិងស្ត្រីមិនអង្គុយច្របូកច្របល់គ្នាទេ គេបែកគ្នាជាពីរពួក ជួនកាលឱ្យបុរសអង្គុយជួរមុខជិតព្រះសង្ឃ ស្ត្រីអង្គុយក្រោយ, ជួនកាលអង្គុយជួរម្ខាងម្នាក់គឺ បុរសអង្គុយខាងស្តាំស្ត្រីអង្គុយខាងឆ្វេង, ឯបុរសនិងស្ត្រីដែលចាស់ៗអង្គុយជួរមុខ មុនពួកក្មេងៗ ។

ដល់មកសម័យសព្វថ្ងៃនេះ ក្នុងទីប្រជុំធ្វើបុណ្យទានខាងសាសនា នៅកាន់តាមប្រពៃណីបុរាណដដែល ។ ឯក្នុងទីប្រជុំជប់លៀង, ប្រជុំស្តាប់តូរ្យតន្ត្រីមើលរបាំ ឬប្រជុំស្តាប់សន្និ-សិទជាដើមនោះ តែងនាំគ្នាអង្គុយជាគូៗ តាមគូភរិយាស្វាមីរៀងៗខ្លួន ។ បើមានក្រុមគ្រួសារទៅផង ក៏គេនាំគ្នាអង្គុយជាជួរតាមក្រុមគ្រួសារគេទៅ ។ នេះជារបៀបថ្មីមួយ ក្លាយតាមពួកអឺរ៉ុបតែគេទុកជារបៀបអន្តរជាតិទៅហើយ ។

-អង្គុយបរិភោគអាហារ ក្នុងទីប្រជុំជប់លៀងទាំងឡាយ មានជប់លៀងក្នុងពិធីមង្គលការជាដើម ។ បុរសស្ត្រីជាគូស្វាមីភរិយា គេច្រើនដូកន្ទេងគ្នាអង្គុយ គឺភរិយាយើងអង្គុយជិតស្វាមីគេបែរមុខចំមកយើង, ភរិយាគេអង្គុយជិតយើង បែរមុខចំទៅស្វាមីគេ ។ នេះជាការសំដែងសេចក្ដីគួរសមរាប់អានគ្នាមួយ តាមអារ្យធម៌អឺរ៉ុប ដែលក្លាយទៅជារបៀបអន្តរជាតិមួយដែរ ។

-បែបបទអង្គុយកៅអី តាមទំលាប់ខ្មែរ បើអង្គុយគោរពបុគ្គលណាមួយ មិនត្រូវគងជើងឬព័ទ្ធជើងទេ ត្រូវអង្គុយសំយុងជើងឱ្យទឹមគ្នា កុំយះកន្ទែកច្រងេងច្រងាង ឬទោកជើង, ដៃទាំងពីរដាក់ឱ្យស្រួលលើភ្លៅ ខ្លួនត្រូវត្រង់កុំផ្អែកទ្រេត នឹងមិនត្រូវយកដៃពាក់គងលើបង្អែកកៅអី ។ របៀបអឺរ៉ុប ការអង្គុយកៅអីហើយគងក្រពាត់ជើងលើគ្នា គេទុកជាកិច្ចគោរពគួរសមរបស់គេទៅវិញ ។

-ក្នុងទីប្រជុំណាមួយ បើមានយកក្មេងទៅផង ត្រូវប្រយ័ត្ន ឱ្យវាអង្គុយ ស្ងៀមនៅជិតខ្លួនកុំឱ្យវាក្រោកដើរចេញចូល កាត់មុខ គេ ឬជាន់កន្ទងដៃជើងគេឥតកោតញញើត ។ បើទីប្រជុំនោះ គេរៀបកៅអីឱ្យអង្គុយ មិនគួរយកក្មេងទៅផងទេ វៀរតែគេ អញ្ជើញទាំងក្មេងនោះផង ទើបគួរយកទៅ ព្រោះអ្នកចាត់ របៀបកៅអីឱ្យភ្ញៀវអង្គុយ គេគិតគ្រប់តែចំនួនភ្ញៀវ បើយើង សណ្ដោងយកក្មេងទៅផង ត្រូវឱ្យវាអង្គុយកៅអីមួយដែរ នាំ ឱ្យខ្វះភ្ញៀវឯទៀត គេរកកៅអីអង្គុយផងមិនបាន ។ ឯអ្នក ម្ចាស់ទីប្រជុំនោះ ក៏មិនត្រូវបណ្ដោតបណ្ដោយកូនចៅខ្លួន ឱ្យទៅ ដណ្ដើមកន្លែងភ្ញៀវអង្គុយដែរ ។

-ការជប់លៀងក្នុងទីប្រជុំធ្វើមង្គលការ ភ្ញៀវទាំងឡាយ មិនត្រូវយកក្មេងទៅតាមជាដាច់ខាត ព្រោះនាំឱ្យរំខានគេមួយរយ ជំពូក, ត្បិតម្ហូបអាហារ គេរៀបតាមតែចំនួនមនុស្សដែលគេបាន អញ្ជើញ រហូតដល់ចានកែវស្លាបព្រាចង្កឹះ តុកៅអីសំរាប់អង្គុយ សុទ្ធតែរៀបតម្រូវតាមចំនួនមនុស្សទាំងអស់ ចុះបើយើងស្រ- ឡាញ់កូនជាងស្រឡាញ់កិត្តិយស សណ្ដោងយកវាទៅផង ឱ្យ

អ្នកដទៃគេទើសទាល់រំខានចិត្ត គេខ្ពើមកូនយើង ដែលវាស៊ីផ្ដេសផ្ដាស, ជួនកាលវាហៀរសំបោរ វាខ្ទាក់បាយសំឡ ហើយវារលាស់ដៃខ្ទាតប្រឡាក់គេឯងនោះ ។ ដល់ពេលគេត្រឡប់ផ្ទះវិញ មុខជាមើលងាយត្មះតិះដៀល និយាយដើមយើងមិនខាន ។

ការយកក្មេងទៅតាមក្នុងពិធីមង្គលការនេះ នៅស្រុកស្រែចំការចូលចិត្តណាស់, បើផ្ទះនៅជិតគ្នាសុទ្ធតែបិទទ្វារ ជញ្ជូនកូនចៅទៅអស់រលីងពីផ្ទះ ម្ល៉ោះហើយវាឥតរបបគ្រប់បែបយ៉ាង គឺវាជជែកប្រឡែងគ្នា វាទាំនំអន្សមស៊ី ទារបាយសំឡ ទារទឹកផឹក វាផុះវានោម វាដើរជាន់ដើរកន្ទេងមិនស្គាល់ចាស់ទុំធំតូច ឯកន្លែងអង្គុយទោះបីអង្គុយផ្ទាល់នឹងកន្ទេល ក៏នាំឱ្យចង្អៀតចង្អល់ រកភ្ញៀវអង្គុយបរិភោគឱ្យស្រួលបួលផងមិនបាន ។ ដូច្នេះត្រូវតែឱ្យមានសុជីវធម៌ក្នុងរឿងនេះ គឺមិនត្រូវយកកូនចៅទៅ ឱ្យរំខានចង្អៀតចង្អល់ ខូចទីប្រជុំគេនោះទេ ។

-ទីប្រជុំទាំងឡាយ ដែលមានកន្លែងអង្គុយជាសាធារណៈមិនមែនទិញលេខកន្លែងដូចក្នុងរថយន្តឈ្នួល ក្នុងរោងកុនល្ខោន

ជាដើមនោះ បើមានស្រ្តីមកដល់ក្រោយគ្មានកន្ទេងអង្គុយ បុរសដែលក្មេងជាងគេ ត្រូវក្រោកឈរឡើង អញ្ជើញស្ត្រីនោះឱ្យអង្គុយកន្ទេងខ្លួន ។ កិច្ចនេះមិនចំពោះតែស្រ្តីទេ បើមានបុរសដែលចាស់ជាងខ្លួន មកដល់ក្រោយគ្មានកន្ទេងអង្គុយនោះ យើងដែលមានវ័យក្មេង ត្រូវជូនកន្ទេងទៅមនុស្សចាស់អង្គុយ ហើយយើងឈរទៅ ព្រោះនៅក្មេងមានកម្លាំងអាចឈរបាន ។

-បែបបទអង្គុយរាបផ្ទាល់កន្ទេល ខ្មែរយើងនិយមអង្គុយបត់ជើងជាការគួរសម សំរាប់សំដែងសេចក្តីគោរព ចំពោះអ្នកដែលគួរគោរព ។

ការអង្គុយបត់ជើងគោរពនេះ កុំច្រត់ដៃទៅនឹងកន្ទេល ត្រូវដាក់ដៃឱ្យស្រួលលើភ្លៅ ។ បើរួយបង្គុយ ត្រូវប្រែបត់ទៅម្ខាងទៀតឱ្យសមរម្យ កុំលើកជើងច្រងើងច្រងាង គឺត្រូវឱនខ្លួនទៅមុខ ដៃទាំងពីរច្រត់លើភ្លៅ បង្ហើបបង្គុយបន្តិច ប្រែបត់ទៅម្ខាងទៀតបានដោយស្រួលហើយ តែត្រូវប្រយ័ត្ន កំពុងប្រែបង្គុយនោះ កុំបញ្ចេញសូរស័ព្ទខ្យល់ដង្ហើមឱ្យឮឡើយ នាំឱ្យ

អ្នកធំដែលយើងគោរពនោះ សំគាល់បានថាយើងធុញទ្រាន់ ។

ឯការអង្គុយពែន អង្គុយច្រហោង នឹងអង្គុយបញ្ឈរជង្គង់នោះតាមទំលាប់ខ្មែរយើង សំរាប់ប្រើចំពោះអ្នកតូចតាចជាងខ្លួន ឬមនុស្សស្មើគ្នា ។

## គ-ការប្រើវាចាក្នុងទីប្រជុំ

វាចាគឺពាក្យសំដី ជាឃីហោរបស់មនុស្សលោក គេអាចស្គាល់ថាមនុស្សបែបណាៗបាន ដោយសារស្តាប់ពាក្យសំដី; បានផលសុខចំរើនវិនាសអន្តរាយ ក៏ដោយសារពាក្យសំដីនេះដែរ បានជាអ្នកប្រាជ្ញបុរាណ លោកចង់ភាសិតទុកមកថា‹‹សំដីជាឯក..., អណ្តាតជាអាទិកន្ទង់ បានសុខទុក្ខផង ពីព្រោះអណ្តាត..., សំដីសជាតិ មាយាទសពូជ..., មនុស្សយកសំដី ដំរីយកភ្លុក... ›› នឹងមួយបទទៀតថា ‹‹រនាបបាក់យករនាបជួស សំដីហួសគ្មានអ្វីជួសបាន...›› ។

ដូច្នេះមុននឹងនិយាយស្តី ត្រូវរៀបពាក្យសំដីឱ្យមានបែបបទ

ល្អ ដឹងខុសដឹងត្រូវ ប្រកបដោយសេចក្ដីគួរសមសុភាពទន់ផ្អែម ទោះនិយាយក្នុងទីប្រជុំក្ដី ក្រៅទីប្រជុំក្ដី, ត្រូវនិយាយឱ្យមានសណ្ដាប់ធ្នាប់តាមទំលាប់ទំនៀមដូចតទៅនេះ៖

-បើក្នុងទីប្រជុំមានព្រះសង្ឃ, ស្ដេច, មន្ត្រីធំតូចទៅរួមប្រជុំផង ត្រូវនិយាយឱ្យសមតាមកិត្តិយសបុគ្គលនោះៗ កុំឱ្យខ្ពស់ហួសទាបហួសគឺ មនុស្សស្មើគ្នាត្រូវនិយាយទៅរកថា ខ្ញុំ, ឆ្លើយថាបាទ; គេធំជាង ១សក្តិ២សក្តិ ត្រូវនិយាយទៅរកថា ខ្ញុំបាទ, ឆ្លើយថាបាទ; គេធំជាង៣សក្តិ ត្រូវនិយាយទៅរកថា ខ្ញុំប្របាទ, គេធំជាង៤ទៅ៧សក្តិ ត្រូវនិយាយទៅរកថា ខ្ញុំប្របាទម្ចាស់, ឆ្លើយថាប្របាទម្ចាស់ ។ សូមបញ្ជាក់ថា រាស្ត្រសាមញ្ញនិយាយទៅរករដ្ឋមន្ត្រី នឹងចាង-ហ្វាងក្រសួងនានាដែលមានសក្តិធំថា ខ្ញុំប្របាទម្ចាស់, ឆ្លើយថាប្របាទម្ចាស់ ទើបគួរសមតាមទំលាប់ល្អ ។

ឯការនិយាយឆ្លើយចំពោះព្រះសង្ឃ និងព្រះមហាក្សត្រ ធ្លាប់បានចេះដឹងស្រាប់ហើយ ។ បើចង់ចេះដឹងឱ្យវិសេសវិសាល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ថែមទៀត សូមមើលរៀនតាមក្បួនរាជសព្ទ និងសៀវភៅទំលាប់ទំនៀម ឬសៀវភៅប្រជុំលិខិត របស់ឯកឧត្តមមហាមន្ត្រី ញ៉ុក.ធូវ ទៀតចុះ ។

-ការនិយាយក្នុងទីប្រជុំ ដូចជាត្រូវថ្លែងសុន្ទរកថា, ឬបញ្ចេញយោបល់អ្វីមួយ ត្រូវនិយាយឱ្យច្បាស់លាស់មានដើមមានចុង ប្រើពាក្យឱ្យច្បាស់តាមតួអក្សរ អានឱ្យត្រូវតាមលំនាំភាសាជាតិ កុំនិយាយវិលវល់ចាប់ចុងប្រយុងដើម រកគេស្ដាប់មិនបាន នឹងកុំឱ្យវែងពេកឥតប្រយោជន៍ ខ្លីពេកស្ដាប់មិនអស់សេចក្ដី ត្រូវលៃឱ្យល្មមតាមពេលវេលា និងតាមដំណើររឿងដែលត្រូវនិយាយ ។

-ក្នុងទីប្រជុំមួយៗ ដូចក្នុងសមាជជាតិជាដើម ត្រូវឆ្លើយឱ្យត្រូវតាមពាក្យសួរ កុំឆ្លើយឱ្យឃ្លាតឆ្ងាយពីព្រំដែនសំនួរ ដរាបដល់ខុសគ្នាមេឃហើយនឹងដី បើគេសួរពីមនុស្សត្រូវឆ្លើយពីមនុស្សវិញ កុំឆ្លើយពីសត្វឬពីស្រែចំការ តបនឹងសំនួរមនុស្សនោះឡើយ ។ ជាពិសេសចំពោះការឆ្លើយនេះ ត្រូវរើសពាក្យ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេ សាទី**

ឆ្លើយឱ្យចំៗចំណុច ដែលគេសួរតែម្តង កុំអធិប្បាយវាតវង់វាប់ម៉ោង មិនទាន់ដល់ចំណុចដែលគេសួរនោះឡើយ ។

-ក្នុងទីប្រជុំ មិនត្រូវនាំគ្នានិយាយប្រកែកជជែកពីនេះពីនោះផ្តេសផ្តាស ក្នុងពេលដែលគេកំពុងប្រុងស្មារតីស្តាប់សេចក្តីថ្លែងការ ឬកំពុងស្តាប់ធម៌ទេសនា ។ បើមានការចាំបាច់ត្រូវនិយាយខានមិនបាននោះ គួរនិយាយតិចៗ ឬក៏នាំគ្នាចេញឱ្យឆ្ងាយពីអ្នកស្តាប់ហើយសឹមនិយាយ កុំឱ្យគេរំខានចិត្ត រកស្តាប់អ្វីមិនបានដោយសារការឥតរបបរបស់ខ្លួន ។

-អ្នកកាន់ព្រះពុទ្ធសាសនា គួរឱ្យចេះធម៌ត្រៃប្រណាមសង្ខេប និងយំកិញ្ចិជាដើម សំរាប់សូត្រក្នុងទីប្រជុំបុណ្យសាសនា កុំទៅអង្គុយធ្មឹង បើកបិទមាត់ក្រាបងើបមិនត្រូវនឹងគេ ក្នុងពេលដែលគេនាំគ្នាសូត្រធម៌នោះឡើយ ។

-ការពិភាក្សាគ្នាក្នុងទីប្រជុំ មិនត្រូវនិយាយកាត់គ្នា ឬដណ្តើមគ្នានិយាយទេ បើម្នាក់និយាយហើយ អ្នកឯទៀតត្រូវឈប់សិន គោរពស្តាប់អ្នកនិយាយនោះឱ្យចប់ ទើបគួរនិយាយ

បាន ។ បើមានការចង់និយាយកាត់ ត្រូវមានពាក្យគួរសមថា «សុំទោសសុំនិយាយកាត់បន្តិច» ។ ឯអ្នកដែលកំពុងនិយាយនោះ បើមានគេសុំនិយាយកាត់ដូច្នេះហើយត្រូវឈប់ភ្លាម កុំចេះតែនិយាយម្នាក់ឯង ធ្វើជាមិនឮនោះឡើយ ។

-ជនជាធំជាចៅហ្វាយនាយ ឬជាមាតាបិតាគ្រូអាចារ្យ មិនគប្បីស្តីបន្ទោស ជេរបញ្ចោរ និយាយហែកកេរ្តិ៍ខ្មាស់បន្ទុះបង្អាប់អ្នកតូចអ្នកនៅក្រោមបង្គាប់ខ្លួនកណ្តាលទីប្រជុំទេ គួរតែនិយាយរំលឹកទូន្មានប្រៀនប្រដៅស្តីបន្ទោស ក្នុងទីស្ងាត់កំបាំង ។ នេះចំពោះអ្នកដែលមានកំហុស ល្មមស្តីបន្ទោសបាន ។ បើអ្នកដែលធ្វើខុសច្រើនដងឬមានទោសកំហុសធំចំពោះរដ្ឋ ដូចជាក្បត់ជាតិ ស៊ីសំណូកធ្វើឱ្យពុករលួយខូចប្រយោជន៍ជាតិនោះ ត្រូវតែនិយាយប្រាប់កណ្តាលទីប្រជុំ ឱ្យគេបានដឹងឮច្បាស់គ្រប់គ្នាថាឈ្មោះនេះធ្វើការនៅទីនេះស្រុកនេះ ខូចអាក្រក់ក្បត់ជាតិពុករលួយបែបនេះៗ ដើម្បីកុំឱ្យអ្នកដទៃតាន់ច្រឡំ ទៅរាប់អានសេពគប់តទៅទៀត នាំឱ្យខូចប្រយោជន៍សាធារណៈកាន់តែធំ គឺ

មិនត្រូវជួយបិទបាំងលាក់លៀម ឬជួយនិយាយកែសំរួលយោគយល់មុខកណ្តាលទីប្រជុំឡើយ ។

-ការមិនពិត គ្មានភស្តុតាងហេតុផលគ្រប់គ្រាន់ មិនត្រូវយកទៅនិយាយកណ្តាលទីប្រជុំឡើយ ។ ឯពាក្យកុហកភូតភរផ្សេងទៀត ដូចជាខ្លួនប្រព្រឹត្តខុស ឬកាន់ជើងអ្នកណាមួយដែលមានកំហុស មិនត្រូវនិយាយកុហកភូតភរលុបលាង ដើម្បីកែកំហុសនោះឡើយ ត្រូវនិយាយតែការពិតក្នុងទីប្រជុំជាដរាប ។

-កំពុងប្រជុំ ជួនជាមានអ្នកណាមួយមករកយើងនៅក្រៅទីប្រជុំនោះ, យើងត្រូវសុំទោសប្រជុំជន ឬសុំទោសអ្នកអង្គុយជិតប្រាប់គេថា មានការទៅជួបនឹងអ្នកនេះអ្នកនោះឯក្រៅបន្តិចហើយសឹមចេញទៅ កុំក្រោកចេញពីទីប្រជុំ ឥតមានពាក្យសំដីគួរសមឡើយ ។

-កំពុងស្តាប់សេចក្តីថ្លែងការរបស់វាគ្មិនក្នុងទីប្រជុំ បើពាក្យសំដីវាគ្មិននោះ ជាទីពេញចិត្តត្រឹមត្រូវល្អ គប្បីទះដៃថ្លែងអំណរយល់ស្រប តាមពាក្យសំដីនោះឡើង ។ បើយើងមិនពេញ

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ចិត្ត គឺទាស់អធ្យាស្រ័យនឹងពាក្យសំដីណាមួយនោះ មិនត្រូវនាំគ្នានិយាយរអ៊ូរទាំ ឬថ្លៃងអាការៈមិនគួរសមណាមួយ ដល់ទីប្រជុំនោះឡើយ ។ បើប្រសិនជាគេនិយាយប៉ះពាល់ដល់សិទ្ធិខ្លួន, ដល់ពេលគេនិយាយចប់ ត្រូវក្រោកឈរសុំទោសទីប្រជុំជនហើយនិយាយដោះសាកែសម្រួលវិញ ដោយអាការៈសុភាពគួរសមជានិច្ច កុំប្រទ្បោតខឹងតូងតាង និយាយពាក្យសំដីគំរោះគំរើយតបគេវិញឡើយ ។

-មិនត្រូវនិយាយលេងសើចផ្តេសផ្តាសក្នុងទីប្រជុំ មាននិយាយពីស្រីញី ពីក្បាលអ្នកនេះអ្នកនោះទំពែក ពីភ្នែកខ្វាក់ពីជាត់ស្គមជាដើម ដើម្បីកុំឱ្យគេសើចនោះឡើយ ។ ព្រោះក្រែងមានអ្នកខ្លះនៅក្នុងទីប្រជុំមានអាការៈដូច្នោះ នាំឱ្យគ្នាខ្មាស់អៀនអាក់អន់ចិត្ត ។

-មិនគួរប្រើអាការៈរីករាយនិយាយសប្បាយ ក្នុងទីប្រជុំដែលគេកំពុងមានទុក្ខព្រាត់ប្រាស់ ឬអន្តរាយដោយហេតុណាមួយឡើយ ។ ត្រូវសម្រួមកាយវាចាឱ្យស្រគត់ស្រគំ ជួយរំលែក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

សេចក្ដីទុក្ខសោករបស់គេផង ។

-ក្នុងពេលប្រជុំហែសពទៅបូជាឬទៅបញ្ចុះ មិនត្រូវនិយាយពីកិច្ចការអ្វីទេ ត្រូវមានអាការៈស្ងប់ស្ងៀមជានិច្ច ។ បើមានការចាំបាច់ត្រូវនិយាយខ្សិបៗ កុំឱ្យឮសំឡេងខ្លាំងដល់អ្នកដើរជិតខាង ក្រែងនាំឱ្យខូចអារម្មណ៍ ដែលគេកំពុងពិចារណាធម្មសំវេគណាមួយ ។

-ក្នុងទីប្រជុំដែលកំពុងជជែកពីកិច្ចការណាមួយ មិនត្រូវនិយាយខ្សឹបជាមួយអ្នកអង្គុយជិតខាងខ្លួន ឱ្យអ្នកដទៃឬអ្នកដែលកំពុងនិយាយ កើតសេចក្ដីរង្កៀសសង្ស័យ ថាខ្លួននិយាយដើមពីគេទេ ។ ព្រោះជាហេតុឱ្យខូចសេចក្ដីទុកចិត្តគ្នា មានការបែកបាក់សាមគ្គី ។

-កំពុងពិភាក្សាគ្នាក្នុងទីប្រជុំ ដែលមានសុទ្ធតែជនជាតិដូចគ្នា មិនត្រូវបែរទៅនិយាយនឹងអ្នកជិតខាង ជាភាសាបរទេសមានបារាំងជាដើមទេ ព្រោះនាំឱ្យអ្នកដទៃដែលស្ដាប់ភាសានោះមិនបាន កើតសេចក្ដីសង្ស័យរង្កៀសអាក់អន់ចិត្ត ។

បើមានការត្រូវនិយាយអ្វីៗ គប្បីនិយាយតែភាសាជាតិរបស់ខ្លួនជាដរាប ។ វៀរតែក្នុងទីប្រជុំនោះ មានជនបរទេសទៅរួមផង ដូចជានៅពេលលៀងភោជនាហារ ពេលលៀងភេសជ្ជៈ ឬពេលជូនដំណើរជាដើម ឬក៏ជនបរទេសនោះជាអ្នកកាសែត ចង់ដឹងកិច្ចការប្រជុំរបស់យើងហើយសួរយើង នោះអ្នកដែលចេះភាសាបរទេស ត្រូវតែថ្លែងអាការៈគួរសម និយាយបកប្រែជាភាសាបរទេសឱ្យគេស្ដាប់បានដឹងកិច្ចការរបស់យើង ដែលគួរឱ្យដឹងផង ដើម្បីផ្សាយកិត្តិយសរបស់កិច្ចការប្រជុំយើងនោះ ឱ្យគេបានដឹងវែងឆ្ងាយទូទៅក្នុងលោក នឹងកុំឱ្យជនបរទេសនោះ ឆ្ងារឆ្ងៀសចិត្តថាយើងនិយាយដើមពីគេផង ។

## ឃ-ការបរិភោគក្នុងទីប្រជុំ

ការបរិភោគគ្រែបផឹកជាដើមនោះ មាននិយាយសព្វគ្រប់ក្នុងវគ្គបទទី៣ គឺការស្គាល់ប្រមាណជីវភាព ត្រង់សន្ទាប់ផ្ទាប់នៃការបរិភោគប្រើប្រាសនោះរួចហើយ, គ្រាន់តែសូមបន្ថែមខ្វះ

ទៀត ដូចតទៅនេះ៖

-ការបរិភោគក្នុងទីប្រជុំទាំងឡាយ មានទីប្រជុំធ្វើមង្គលការជាដើម, តាមទំលាប់ក្នុងរាជធានី នឹងទីរួមខេត្តស្រុកខ្លះច្រើននិយមជប់លៀងតាមរបៀបអន្តជាតិ មានតុកៅអី មិននិយមអង្គុយរាប ដូចនៅស្រុកភូមិខ្លះនោះទេ ។ ដូច្នេះ ត្រូវឱ្យចេះអង្គុយកៅអីបរិភោគ ដោយអាការៈសមរម្យថ្លៃថ្នូរ។

-តាមទំលាប់ពិធីជប់លៀង ក្នុងមួយតុគេអង្គុយ១០នាក់ឬ៨នាក់ ។ បើបើអ្នកចាត់របៀប គេអញ្ជើញឱ្យអង្គុយតុណា មិនត្រូវប្រកែកថាទេៗឈប់សិន ហើយចេះតែឈរផ្ដេសផ្ដាស ឱ្យចង្អៀតរកគេដើរមិនបាន នឹងនាំឱ្យគេពិបាកប៉ាន់ចំនួនភ្ញៀវ ឱ្យដឹងថាមកបានប៉ុន្មានៗតុហើយនោះទេ គប្បីទៅអង្គុយតាមសេចក្ដីអញ្ជើញ ។ វៀរតែយើងមានស្គាល់គ្នា ហើយចង់ទៅអង្គុយជាមួយគ្នានោះចេញ ។ បើតុដែលគ្នាយើងអង្គុយនោះនៅមានកន្លែង ត្រូវប្រាប់អ្នកអញ្ជើញថា ខ្ញុំសុំទៅអង្គុយជាមួយគ្នាខ្ញុំឯតុនោះវិញ ។ មុននឹងអង្គុយ ត្រូវគួរសមចាប់ដៃ ឬសំពះអ្នក

អង្គុយរួមតុជាមួយនោះសិន សឹមទាញកៅអីឱ្យស្រួល កុំឱ្យឮសូរខ្ទាំងមកអង្គុយដោយសមរម្យ កុំផ្អែកច្រខេងច្រខែង លើកជើងបញ្ឈរលើកៅអី ឬយះកន្ទែកជើងច្រងេងច្រងាង យកដៃគោះតុធ្វើចង្វាក់ភ្លេង នឹងកុំពិតខ្លួនទៅលើតុ ។ ពេលបរិភោគត្រូវគងដៃទៅលើតុឱ្យល្មម ហើយឱ្យចេះប្រើកូនកន្សែង ចេះកាន់សមស្លាបព្រា កាន់កាំបិតឬចង្កឹះ ឱ្យសមរម្យកុំឱ្យធ្គង ។

-បើគេលើកម្ហូបមកដល់ កុំប្រញាប់លូកភ្វាម, អ្នកដែលក្មេងជាងឬដែលមានយសស័ក្តិតូចជាងគេ ចាំស្តាប់ពួកចាស់ៗនឹងអ្នកធំជាង អនុញ្ញាត្តិហៅឱ្យបរិភោគសិន សឹមរៀបចំបរិភោគ ។ ឯអ្នកដែលក្មេងជាងតូចជាងគេនោះ ត្រូវចាប់ម្ហូបដាក់ក្នុងចានជូនអ្នកធំនឹងចាស់ៗបានម្នាក់ពីរសិនជាការគួរសម ទើបគួរចាប់ដាក់ចានខ្លួន បរិភោគជាក្រោយ ។

-អំពីការគ្រេបផឹកវិញក៏ដូច្នោះដែរ កុំអាលប្រញាប់ប្រញាល់ផឹកមុនចាស់មុនអ្នកធំ នឹងកុំផឹកសុរាឱ្យស្រវឹងជ្រុល ។

-បើចាប់ម្ហូប មានត្រីសាច់បន្លែជាដើមជ្រុះនៅលើតុ កុំ

រើសមកបរិភោគវិញ ត្រូវចាប់ចោលទៅកន្លែងដែលគួរចោល ។

-បើរបូតជ្រុះសមស្លាបព្រា ឬចង្កឹះពីដៃទៅក្រោមតុ មិនត្រូវរើសយកមកបរិភោគវិញទេ ត្រូវសុំថ្មីអំពីអ្នកបំរើទៀត ។

-ត្រូវកាន់ឫកពាថ្លៃថ្នូរគឺ បើមានប៉ះទង្គិចរបូតដៃបែកចានកែវ ឬរលំកំពុបទឹកសុរាជាដើម ត្រូវមានអាការៈធម្មតា ហៅអ្នកបំរើមកប្រមូលកើបហើយ ឱ្យយកថ្មីមកឱ្យទៀត កុំភិតភ័យស្លាយមានទឹកមុខប្លែក ឬនិយាយដោះសារកែខ្លួន ថាដូច្នេះដូច្នោះខ្លាចគេឱ្យសងនោះឡើយ ។

-កុំបរិភោគប្រញាប់ប្រញាល់ ចាប់ញាត់ៗពមធំៗយកឆ្អែតតែម្នាក់ឯងនោះឡើយ ត្រូវលៃមើលគេឯងផងគឺ កុំញាប់ជាងគេ កុំរង្វើលជាងគេពេក ត្រូវបរិភោគឱយល្មមដូចគេ ដែលបានបរិភោគរួមជាមួយខ្លួន ។

-កាលបរិភោគរួចហើយ ត្រូវដាក់ចានកែវសមស្លាបព្រាចង្កឹះកូនកន្សែង នៅមុខខ្លួនតាមភាពធម្មតាគឺ កុំបត់កូនកន្សែងកុំផ្កាប់សមស្លាបព្រា ផ្កាប់ចានកែវឱ្យសោះ ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

-ឯអ្នកបំរើភ្ញៀវ ត្រូវមានចរិយាសុភាពគួរសម ទឹកមុខស្រស់បស់ កុំលើកដាក់ចានកែវបំពង់ទឹកកក ច្រងេងច្រងាងកន្ទងរំលេងខ្ជីនប្រាណអ្នកអង្គុយបរិភោគ និងប្រយ័ត្នជាដាច់ខាត កុំឱ្យកំពុបខ្ទាយអ្វីៗក្នុងពេលបំរើនោះ ។

-ទៅលេងក្នុងទីប្រជុំជនសំរាប់កំសាន្តសប្បាយ ដូចជាទីអង្គរវត្ត, កែប, ទឹកឈូរ, នឹងទីសួននានាជាដើម មិនត្រូវបរិភោគចំណីអាហារឱ្យប្រឡាក់ទីកន្លែង មានបោលកាកបាយសំឡ, ឆ្អឹង, កាកអំពៅ, សំបកកំប៉ុង នឹងសំបកផ្លែឈើផ្សេងៗជាដើម ឱ្យប្រឡាក់រាត់រាយក្នុងទីប្រជុំជននោះ ដែលនាំឱ្យរំខានដល់អ្នកថៃរក្សា នឹងអ្នកទៅកំសាន្តក្រោយៗ រកទីកន្លែងអង្គុយផងមិនបាននោះឡើយ ។

បើយើងបរិភោគរួចហើយ ត្រូវបោសកើបប្រមូលឱ្យស្អាតបោលទៅក្នុងទីដែលគួរបោល ។

# ង-ការប្រើសំលៀកបំពាក់ក្នុងទីប្រជុំ

សំលៀកបំពាក់ដែលតែងប្រើក្នុងទីប្រជុំទាំងឡាយ តាមទំលាប់សម័យនេះមាន២បែបគឺ:

-សំលៀកបំពាក់ទៅក្នុងទីប្រជុំបុណ្យសព, តាមរបៀបអន្តរជាតិ បុរសត្រូវប្រើសំលៀកបំពាក់ក្រុងគឺ អាវមានពីជាន់ពណ៌សចងក្រវាត់ខ្មៅ ខោខ្សែរជើងវែងពណ៌ស នឹងស្បែកជើងខ្មៅ ស្រោមជើងខ្មៅ ។ បើគ្មានសំលៀកបំពាក់បែបនេះទេ ស្លៀកពាក់ធម្មតាក៏បាន ប៉ុន្តែតរូវប្រើពណ៌ស បើយ៉ាងហោចណាស់ក៏ឱ្យបានអាវសដែរ ។ ឯបុរសដែលជាសមាជិកគ្រួសាររបស់សពត្រូវស្លៀកពាក់សទាំងអស់ ។

-ចំណែកសំលៀកបំពាក់ស្ត្រី គឺអាវស កន្សែងស សំពត់ខ្មៅឬពណ៌ សំឡុយក៏បានចងក្បិនក៏បាន ។ បើស្ត្រីដែលជាសមាជិកគ្រួសាររបស់សព ត្រូវស្លៀកពាក់សទាំងអស់ គ្រឿងមាសពេជ្រត្រូវដោះចេញ ។ នៅរាជធានីប្រើសំពត់ចងក្បិន អាវម៉ូដស កន្សែង

ជរស ស្បែកជើងស នឹងកាបូបយួរសដែរ ។

២-សំលៀកបំពាក់ទៅក្នុងពិធីមង្គលការ និងទីប្រជុំសន្និសិទធំៗ, បុរសច្រើនប្រើសំលៀកបំពាក់អន្តរជាតិគឺ អាវក្នុងពណ៌សចងក្រវាត់ អាវធំក្រៅអាវធំនឹងខោខ្សែរជើងវែងពណ៌ខ្មៅស្ទើរ ឬខៀវចាស់ដូចគ្នា នឹងប្រើស្រោមជើងស្បែកជើងឃ្មុប ។ បើគ្មានសំលៀកបំពាក់បែបនេះទេ ប្រើអាវសឺមីដៃវែងចងក្រវាត់ ឬអាវដៃខ្លីខោខ្សែរជើងវែង ស្បែកជើងស្រោមជើងក៏បាន ប៉ុន្តែត្រូវឱ្យស្អាតកុំស្មោកគ្រោក ។

-ចំណែកស្ត្រី ត្រូវស្លៀកហូល ផាមួង ឬខៀន អាវផាហ៊ុម ឬកន្សែងជរពណ៌ ស្បែកជើងនឹងគ្រឿងមាសពេជ្រដែលសុទ្ធតែរបស់ល្អថ្មីៗ គឺនៅពេលទៅពិធីមង្គលការនេះហើយដែលស្ត្រីត្រូវតែងខ្លួនឱ្យល្អស្រស់ឆើត ជាងទៅទីណាៗទាំងអស់ ។

៣-ទៅកាន់ទីប្រជុំធម្មតា ដូចជាទៅមើលកុនល្ខោនឈ្នួលសាមញ្ញជាដើម ត្រូវស្លៀកពាក់ធម្មតាដែរ តាមភេទប្រុសស្រី ប៉ុន្តែត្រូវឱ្យស្អាត កុំឱ្យស្មោកគ្រោកមានក្លិនអាក្រក់ ។

៤-ស្មៀកពាក់ទៅកាន់ទីប្រជុំជាផ្លូវរដ្ឋ ដូចជាពិធីអុំទូក តាំងតុជាដើម ។ ចំពោះមន្ត្រីរាជការដែលមានសំបុត្រអញ្ជើញពីនាយកពិធីនោះងាយទេ ព្រោះមានប្រាប់បង្គាប់របៀបស្លៀកពាក់ជាដើម ក្នុងសំបុត្រកម្មវិធីស្រាប់ហើយ ។

ឯរាស្ត្រសាមញ្ញ ដែលទៅមើលពិធីនោះ ស្លៀកពាក់ធម្មតាតាមមានតាមបាន ប៉ុន្តែត្រូវឱ្យស្អាតហើយសមរម្យផង ។ វៀរតែស្លៀកសារុង ស្លៀកខោទ្រនាប់ ស្លៀកក្រមា នឹងមួរដៃអាវចេញ ។

## ប-កាគោរពពេលប្រជុំ

-ការប្រជុំទាំងឡាយ សុទ្ធតែមានកំណត់ពេលម៉ោង នឹងថ្ងៃខែ ។ អ្នកដែលត្រូវទៅចូលប្រជុំ ក៏សុទ្ធតែបានដឹងពេលម៉ោងប្រជុំគ្រប់ៗគ្នាដែរ គឺដឹងដោយសំបុត្រជាលាយលក្ខណ៍អក្សរក៏មាន ដោយស្តាប់តាមវិទ្យុក៏មាន ដោយគេទៅជំរាបអញ្ជើញផ្ទាល់មាត់ក៏មានដែរ ។ ដូចជាគេអញ្ជើញទៅក្នុងពិធីមង្គល

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

ការ, តាមទំលាប់ច្រើនអញ្ជើញដោយសំបុត្រផង ដោយផ្ទាល់មាត់ផង ។ បើយើងមានកិច្ចរវល់មិនបានទៅក្នុងពេលវេលានោះទេ ត្រូវចាប់ជំរាបគេវិញដោយសំបុត្រ ឬផ្ទាល់មាត់ ដើម្បីកុំឱ្យគេទន្ទឹងចាំមើលផ្លូវផង កុំឱ្យគេខាតចំណីអាហារដែលបំរុងទទួលយើងនោះផង ។

-បើជិតដល់ម៉ោងប្រជុំហើយ ត្រូវទៅកាន់ទីប្រជុំឱ្យបានមុនម៉ោងចំនួន១៥នាទី កុំឱ្យគេទន្ទឹងចាំមើលផ្លូវខ្លួន នាំឱ្យខូចកិច្ចការដែលត្រូវធ្វើក្នុងទីប្រជុំផង នាំឱ្យរំខានដល់អ្នកដែលរង់ចាំខ្លួននោះផង ។

-អ្នកមានបណ្តាស័ក្តិតូច និងអ្នកមានអាយុក្មេងជាង ត្រូវទៅកាន់ទីប្រជុំឱ្យបានមុនអ្នកធំ មុនអ្នកដែលចាស់ជាង មិនត្រូវឱ្យអ្នកធំអ្នកចាស់ជាងចាំខ្លួនឡើយ ។ ទោះបីក្រៅទីប្រជុំ ដែលបានសន្យាណាត់គ្នាថា ទៅជួបគ្នានៅទីណា ឬទៅណាជាមួយគ្នាតែពីរនាក់នោះ ក៏ត្រូវអ្នកដែលតូចជាង ដែលក្មេងជាងទៅរង់ចាំមុនដែរ ដើម្បីឱ្យមានសេចក្តីគោរពដល់អ្នកធំដល់អ្នកចាស់

មិនត្រូវឱ្យអ្នកធំឱ្យអ្នកចាស់ ទៅគោរពចាំខ្លួនវិញទេ ។

-ពេលចូលឬចេញពីទីប្រជុំ មិនត្រូវបង្ខំប្រញាប់ប្រញាល់ពេកទេ ត្រូវចំណាយពេលខ្លះ គោរពដល់ការចេញនិងចូលនោះគឺ អ្នកទៅដល់មុនត្រូវចូលមុន អ្នកទៅដល់ក្រោយត្រូវចូលក្រោយ កុំដណ្តើមគ្នាចូលឥតរបប បើទីប្រជុំមានទ្វារច្រកចូលតូច គួរឈរតម្រៀមចាំតាមលំដាប់មុនក្រោយ ហើយដើរចូលបន្តបន្ទាប់គ្នាទៅ ។ ឯការចេញពីទីប្រជុំវិញក៏ដូចគ្នា អ្នកអង្គុយជិតទ្វារត្រូវចេញមុន អ្នកអង្គុយឆ្ងាយ មិនត្រូវដណ្តើមគេចេញមុនឡើយ ។ ចំពោះការចុះឡើងក្នុងយាន-រថយន្ត-នាវាក៏ត្រូវគោរពពេលវេលាមុនក្រោយនេះដែរ ។

-ពេលកំពុងប្រជុំចំនួនជាពីរឬបីម៉ោងជាដើមនោះ បុគ្គលម្នាក់ៗត្រូវនៅឱ្យស្ងៀម មិនត្រូវនិយាយខ្លាំងៗ ឬបញ្ចេញសូរស័ព្ទអ្វី ដែលនាំឱ្យរំខានដល់ពេលប្រជុំ ត្រូវប្តេជ្ញាចិត្តរៀងៗខ្លួនថា អញត្រូវនៅក្នុងពេលប្រជុំ ដរាបដល់ចប់ចុងចប់ដើមដោយចរិយាថ្លៃថ្នូរ, មិនគប្បីធ្វើខ្លួនឱ្យកើតជាសត្រូវ ជាមេរោគ

ដល់ពេលវេលាប្រជុំ, មិនត្រូវប្រព្រឹត្តធ្វើតាមអំពើចិត្តគឺ ចង់នៅក៏នៅ ចង់ទៅក៏ទៅ ចង់ក្រោកក៏ក្រោក ចង់អង្គុយក៏អង្គុយនឹងចង់ស្តាប់ក៏ស្តាប់ មិនចង់ស្តាប់ក៏ដើរចេញ ឬក៏អង្គុយធ្វើព្រងើយមិនអើពើនិងកិច្ចការប្រជុំ បែរជាមើលសៀវភៅឬមើលកាសែតសំដែងអាការៈ ជាអ្នកមិនត្រូវការដឹងឮ អំពីកិច្ចការប្រជុំនោះឡើយ ។

-ការស្គាល់ប្រជុំជននិងទីប្រជុំ ដូចបរិយាយមកជាគោលៗនេះ ជាវត្តបទទី៥នៃសុជីវធម៌ សំរាប់អប់រំមនុស្សឱ្យចេះចូលចំណោមជំនុំនឹងគេចុះ បំបាត់ចោលនូវភាពមនុស្សឈ្លើយ, មនុស្សឆ្វេង, មនុស្សមិនចុះជំនុំ ដែលហៅថាមនុស្សគ្មានសុជីវធម៌នោះ កុំឱ្យមានក្នុងសង្គមគ្រួសារនិងក្នុងសង្គមជាតិ ។

---

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

# វត្ថុបទទី៦

# ការស្គាល់មិត្រសំឡាញ់

បុគ្គលដទៃក្រៅពីមាតាបិតា ស្វាមីភរិយាបុត្រធីតា និង ញាតិសន្តានរបស់ខ្លួនចេញ គ្មានបុគ្គលណាជាទីស្រឡាញ់ស្និទ្ធស្នាលទុកចិត្ត ជួយផ្តល់ប្រយោជន៍ទៅវិញទៅមក ជាងមិត្រសំឡាញ់ខ្លួនទេ មានតែមិត្រនេះហើយ ដែលអាចជួយគាំទ្រដំណើរជីវិត ឱ្យបានប្រព្រឹត្តទៅស្រួល ប្រកបដោយជោគជ័យក្នុងលោកនេះ ។

តាំងពីព្រេងនាយមកទល់សម័យបរមាណូនេះ ជីវិតមនុស្សត្រូវការមិត្រ ជាងជាងវត្ថុធាតុទាំងអស់ ។

មនុស្សគ្មានមិត្រ ទុកដូចជាមនុស្សជរាពិការគ្រប់យ៉ាងគឺមានភ្នែកភ្លឺ មើលអ្វីមិនឃើញ, មានត្រចៀកស្តាប់ឮ គ្មានអ្វីស្តាប់, មានដៃមាំមួន គ្មានការងារធ្វើ នឹងមានជើងល្អជា ធ្វើដំណើរមិនរួច ។ សិរីសួស្តីរត់មកចំខ្លួនហើយ បែរជាត្រឡប់ទៅរកអ្នកដទៃវិញ ។

ចំណុចយ៉ាងសំខាន់នេះហើយ ដែលបណ្តាលឱ្យជីវិតអ្នក

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

ពិភពលោកបរមាណូសព្វថ្ងៃ ស្រេកឃ្លានមិត្រដាច់ចំណីអាហារ ទៅទៀត ស៊ូបន្ថយចំណីអាហារពលរដ្ឋខ្លួន ឱ្យថយតិចត្រឹមតែ ស៊ីរស់ ដើម្បីសន្សំលុយរាប់កោដិដុល្លា យកទៅចងមិត្រនឹង អ្នកប្រទេសនានា ។

ដូច្នេះមនុស្សម្នាក់ៗ ត្រូវតែមានមិត្រជាចាំបាច់ខានមិនបាន ប៉ុន្តែត្រូវស្គាល់មិត្រឱ្យច្បាស់ ដូចតទៅនេះ ។

## ក-មិត្រល្អត្រូវសេពគប់

ដែលថាមិត្រល្អ គឺមិត្រប្រកបដោយសុជីវធម៌ មាន ការគួរសមយោគយល់គ្នា ជួយយកអាសារគ្នា ស្មោះត្រង់មិន ក្បត់គ្នា ប្រព្រឹត្តធ្វើតែអំពើប្រយោជន៍ ដល់គ្នានិងគ្នាគឺៈ

-ជួយការពារកិត្តិយស រក្សាគ្នាឱ្យបានសុខស្រួល ក្នុង ពេលភ្លាំងភ្លាត់ខុស នឹងពេលធ្វេសប្រហែសផ្សេងៗ មានពេល ផឹកសុរាស្រវឹងជ្រុល ឬចាញ់បោកគេជាដើម ។

-ធ្វើឱ្យមិត្រមានសេចក្តីកក់ក្តៅ ក្នុងពេលមានគ្រោះថ្នាក់ភ័យ

អាសន្នណាមួយ ។

-ជួយផ្តល់បំពេញនូវការខ្វះខាតរបស់មិត្រ ឱ្យបានគ្រប់គ្រាន់តាមសមត្ថភាពខ្លួន ។

-មិនត្រេកអររីករាយ ក្នុងពេលមិត្រមានទុក្ខព្រួយព្រោះខូចខាតអន្តរាយទ្រព្យជាដើម ។

-ត្រេកអររីករាយ ក្នុងពេលមិត្របានលាភសុខចំរើន ។

-ចេះហាមឃាត់អ្នកនិយាយមិនល្អពីមិត្រ ហើយនិយាយលុបលាងពាក្យមិនល្អនោះចោលចេញ ។

-ពោលសរសើរលើកទឹកចិត្ត អ្នកនិយាយល្អពីមិត្រ ។

-ប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់មិត្រ ។

-ជួយលាក់អាថ៌កំបាំងរបស់មិត្រ មិនឱ្យអ្នកដទៃដឹង ។

-មិនលះបង់ចោលគ្នាក្នុងគ្រាក្រ នឹងពេលមានទុក្ខភ័យ ។

-ហ៊ានប្តូរជីវិតស្លាប់រស់ជាមួយគ្នា ។

-រំលឹកទូន្មានមិត្រ មិនឱ្យប្រព្រឹត្តអាក្រក់ ។

ដឹកនាំមិត្រឱ្យធ្វើតែអំពើល្អ មានឱ្យខំរៀនចំណេះវិជ្ជា

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សារី**

ឱ្យខំរកទ្រព្យ នឹងឱ្យធ្វើបុណ្យទានជាដើម ។

-ប្រាប់ដំណឹងល្អ ដែលខ្លួនដឹងច្បាស់ដល់មិត្រ ។

-ឱ្យទ្រព្យដែលគួរឱ្យដល់មិត្រ ។

-ធ្វើខ្លួនឱ្យជាប្រយោជន៍ដល់មិត្ត ។

-រាប់អានមិត្រស្មោះស្មើ មិនប្រកាន់ខ្លួន ។

-មិនកុហកបោកបញ្ឆោតគ្នា ។

-ជួយរក្សាការពារទ្រព្យសម្បត្តិ នឹងបុត្រភរិយាញាតិសន្តានរបស់មិត្រ ។

-ស្រឡាញ់រាប់អានគ្រួសារមិត្រ ដូចគ្រួសារខ្លួន ។

-ក្នុងទីប្រជុំ មិនប្រើអាការៈ ឱ្យខូចកិត្តិយសមិត្រ ។

-ធ្វើបដិសណ្ឋារកិច្ចដោយរីករាយ ក្នុងពេលមិត្រទៅលេងជាមួយ មានជប់លៀងចំណីអាហារជាដើម ។

-នាំស្វាមីភរិយាបុត្រធីតា មកជុំរាបសួរគួរសម ចំពោះមិត្រ ។

-ឱ្យអាសនៈដេកអង្គុយស្មើនឹងខ្លួន ឬវិសេសជាងដល់មិត្រ ។

-ជូនបង្ហាញនិយាយប្រាប់នូវវត្ថុផ្សេងៗ ដែលមានក្នុងលំនៅខ្លួន ដល់មិត្រដែលចង់ឃើញចង់ដឹង ឬដែលជារបស់ប្លែកគួរមិត្រដឹងស្គាល់ ។

-និយាយពីសុខទុក្ខខ្លួនពិតប្រាកដ ប្រាប់ដល់មិត្រ ។

-មិនថ្លៃងអាការៈឱ្យមិត្រស្មើសចិត្តថា ខ្លួនចង់ឱ្យគេឆាប់ត្រឡប់វិញ ឬឱ្យដឹងថាខ្លួនធុញទ្រាន់ មិនពេញចិត្តនឹងបដិសណ្ឋារៈរបស់មិត្រ ។

-បើមិត្រជំរាបលា តែងឃាត់ឱ្យនៅបន្តិចទៀតសិន ។

-បើឃើញមិត្ររវល់ ឬមានភ្ញៀវ តែងឆាប់ត្រឡប់វិញ ។

-មិនអង្គុយនិយាយប៉ប៉ាច់ប៉ប៉ោច ឱ្យមិត្រធុញទ្រាន់ ។

-មិននិយាយកាត់មិត្រ ក្នុងពេលកំពុងនិយាយ បើមានការនិយាយតែងសុំទោសសិន ។

-ពេលមិត្រត្រឡប់វិញ តែងជូនដំណើរដល់មាត់ទ្វាររបង ឬដល់ស្ថានយានជំនិះ លៃតាមការគួរ ។

-មិនថ្លៃងអាការៈស្និទស្នាលនឹងគ្នាពេក ក្នុងទីប្រជុំជន ។

-មិនសុំឬខ្ចីអ្វីៗ របស់មិត្រញឹកញយពេក ។

-បើខ្ចីអ្វីៗ តែងឆាប់សងវិញតាមកិច្ចសន្យា ។

-ក្នុងទីចំពោះមុខមិត្រ មិនវាយកូនចៅទាសកម្មករ មិនឈ្លោះប្តីប្រពន្ធ ធ្វើឱ្យមានបរិយាកាសល្អតែម្យ៉ាង ចំពោះមិត្រ ។

បុគ្គលណាដែលប្រកបដោយសុជីវធម៌ សំរាប់មិត្រសំឡាញ់ ដូចនាំមកជាគោលៗខាងលោះនេះ បុគ្គលឈ្មោះថាជាកល្យាណមិត្រ ជាមិត្រល្អគួរតែសេពគប់ គួរប្តូរជីវិតជាមួយគ្នា ។

ប៉ុន្តែកុំប្រទ្បំយកធ្វើជាចៅហ្វាយនាយ ឬជាទាសកម្មកររបស់ខ្លួន ព្រោះបើប្រទ្បំដូច្នោះ នឹងខានបានធ្វើជាមិត្រសំឡាញ់នឹងគ្នាទៅហើយ ។

## ១-មិត្រអាក្រក់មិនត្រូវសេពគប់

ដែលថាមិត្រអាក្រក់ គឺមិត្រដែលគ្មានសុជីវធម៌នៅក្នុងខ្លួន រាប់អានស្គាល់អ្នកណា យកអ្នកណាធ្វើមិត្រ មានគំនិតអាក្រក់ គិតតែបឺតជញ្ជក់ យកប្រយោជន៍ពីអ្នកនោះ នឹងយកអ្នកនោះធ្វើ

ជាខ្ញុំកញ្ឆះខ្លួន មានលក្ខណៈអាក្រក់ដូចខាងក្រោមនេះ៖

-អ្នកដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន មិនគិតប្រយោជន៍មិត្រ ។

-ឱ្យរបស់មិត្របន្តិចបន្តួច ដើម្បីទាក់យកប្រយោជន៍ធំ យកផលច្រើនពីមិត្រវិញ ។

-ពេលខ្លួនមានអាសន្ន ទើបទៅជួយធ្វើជាមិត្រ ។

-និយាយបញ្ជោរ ល្អតែមាត់ក្រៅចំពោះមិត្រ ។

-សេពគប់ ព្រោះតែចង់បានប្រយោជន៍អំពីមិត្រ ។

-ប្រើកលល្បិចដោយវាចាថា ទាល់ណាស់ក្រណាស់ ឥឡូវរករបរមិនបានផល, ការពារទុកជាមុនកុំឱ្យមិត្រពឹងពាក់បាន ឬកុំឱ្យទារលុយកាក់ដែលខ្លួនជំពាក់មិត្រ ។

-មានវត្ថុបន្តិចបន្តួចដែលមិត្រទទួលយកមិនកើត ធ្វើជាហៅមិត្រឱ្យយក ដោយដឹងមុនថាមុខជាមិនយក ។

-ពេលមិត្រពឹងពាក់ឱ្យជួយ បែរជានិយាយបណ្តោះដៃ

ថា ចាំពេលនេះពេលនោះ ។

-និយាយចាក់បណ្ដោយ ឱ្យមិត្រខូចផលប្រយោជន៍ ។

-សរសើរតែក្នុងទីចំពោះមុខ ។

-និយាយដើមក្នុងទីកំបាំងមុខ ។

-ដឹកនាំមិត្រឱ្យធ្វើអំពើទុច្ចរិត ។

-និយាយបន្ទុះបង្អាប់មិត្រក្នុងទីប្រជុំ ។

-បោកកុហកភូតភរ គ្មានការពិតចំពោះមិត្រ ។

-និយាយផ្ដេសផ្ដាសពីគ្រួសារមិត្រ ប្រាប់អ្នកដទៃ ។

-និយាយកាត់ពាក្យសំដីមិត្រ គ្មានកោតញញើត ។

-យកការសម្ងាត់ពីមិត្រ ទៅប្រាប់អ្នកដទៃ ។

-យកចិត្តទុកដាក់ជួយធុរៈមិត្រដែលបានពឹងពាក់ តែក្នុងទីចំពោះមុខ ដល់កំបាំងមុខបំភ្លេចចោលមិនឈឺឆ្អាល ហើយនិយាយកែសំរួលដោយឧបាយផ្សេងៗ ។

-លាក់ការណ៍កំបាំងខ្លួន មិនស្គាល់ពេលវេលាគួរមិនគួរ ។

-លះបង់ចោលមិត្រក្នុងគ្រាក្រនឹងពេលមានអាសន្ន ។

-ទៅរកខ្ចីរកសុំរបស់ទ្រព្យមិត្រ ញឹកៗញយៗ ។

-ខ្ចីបានហើយមិនសងវិញ ប្រើល្បិចស្ងៀតមិនឱ្យមិត្រទារវិញបាន ។

-បើមិត្រទៅលេងជាមួយ ក្លែងធ្វើជាមានដំណើរទៅទីផ្សេងៗ, ចុះចោលមិត្រ ឬក៏វាយកូនចៅកុំឱ្យមិត្រទ្រាំនៅលេងលើផ្ទះបាន ។

-ប្រើអាការៈដោយឥរិយាបថនឹងទឹកមុខ ឱ្យមិត្ររង្កៀសចិត្ត កនុងពេលដែលទារយកប្រយោជន៍មិនបាន ឬក៏បានរួចហើយ អស់សង្ឃឹមថានឹងបានទៀត ។

-ច្រណែននិន្ទាឈ្នានីសមិត្រ ដោយសេចក្តីលោភលន់ហួសប្រមាណ ។

-ប្រើអាការៈកៀរគរបោកបញ្ឆោតមិត្រ ល្អតែខាងក្រៅដូចផ្លែល្វាខាងក្នុងសុទ្ធតែមមង់ ។

-ប្រើកិរិយាមារយាទមិនសមរម្យ ចំពោះមិត្រឱ្យបានប្រាស

ចាកសមភាព ។

-បុគ្គលណាដែលប្រកបដោយលក្ខណៈអាក្រក់ ដូចនាំមកបរិយាយជាគោលៗនេះ បុគ្គលនើឈ្មោះថាមិត្រអាក្រក់ មិត្រគ្មានសុជីវធម៌ មិនត្រូវរាប់រកសេពគប់ឡើយ ។

ប៉ុន្តែកុំយកជាសត្រូវ ព្រោះនាំឱ្យមានឧបសគ្គក្នុងដំណើរជីវិត, គ្រាន់តែស្គាល់ធម្មតា ក្នុងឋានៈជាមនុស្សដូចគ្នាបានហើយ កុំសេពគប់ស្និទស្នាលតទៅទៀត ។

ការស្គាល់មិត្រសំឡាញ់នេះ ជាសុជីវធម៌ទី៦ចុងក្រោយបង្អស់ សំរាប់ដឹកនាំមនុស្ស ឱ្យដើរត្រង់ផ្លូវ ទៅរកចំរើន កុំឱ្យវង្វេងទៅលើផ្លូវខុស មានបាបគ្រោះព្រោះគេដឹកនាំ ។

(ចប់សុជីវធម៌ប្រចាំសង្គមគ្រួសារ)

---

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី សស់ សាទី

# អត្ថបទពិសេស

---

អំពីលក្ខណៈ

## ស្រីគ្រប់លក្ខណ៍ និងប្រុសគ្រប់លក្ខណ៍

(ដកស្រង់គោលៗពីច្បាប់បុរាណមករៀបរៀង)

ស្ត្រីដែលប្រកបដោយលក្ខណៈ៣១យ៉ាង
ហៅថាស្រីគ្រប់លក្ខណ៍(១)គឺៈ

*១- មិនចេះអេចអូចនិយាយដើមគេ,*

*២- ចេះគួរសមគ្រោកទទួលមាតាបិតានឹងស្វាមី,*

*៣- ដឹងគុណតបគុណមាតាបិតាញាតិសន្តានទាំងពីរខាង,*

*៤-មិនចេះដេកថ្ងៃ,*

*៥- មិនភ្លីភ្លើភ្លេចមុខភ្លេចក្រោយ,*

*៦- ចេះថែទាំរបស់ទ្រព្យ,*

*៧- មិនផិតក្បត់ស្វាមី*

---

១-ក្នុងសៀវភៅ "គោលច្បាប់បំផុសយោបល់" លោកគ្រូ ពាង សុទ មានសរសេរ ជាភាសាបាលីផង ។

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

៨- មិនចេះប្រច័ណ្ឌស្វាមី,

៩- គ្មានកលមាយា,

១០- មិនរំសាយសក់ឱ្យគេឃើញ,

១១- មានចិត្តអត់ធន់ធ្ងន់ធ្ងរ,

១២- មានដើងស្រាល,មិនដើរក្តុងក្តាំង,

១៣- មិនឈរឬអង្គុយសំញែងកាយឱ្យគេឃើញ,

១៤- មិនដើរញ៉ិកញ៉ក់កាច់រាង,

១៥- ចេះសង្រួមភ្នែកមិនក្រឡេករឡេមរឡាម,

១៦- មានដំណើរល្អ មិនគ្រលែងកាយចំទយគូថ,

១៧- មិនបង់បោយញាក់ស្មា គ្រលែងដើមដៃ

១៨- មានសំឡេងតិចច្បាស់លាស់ មិននិយាយឡូឡា,

១៩- មិនចេះឡេះឡោះលេងសើច ។

២០- មិនផ្តោះផ្តងចំពោះបុរសនិងស្ត្រី,

២១- មិនទំរន់ ធ្វើទាល់តែហើយការនោះ,

២២- ទៅទីណាឆាប់ត្រឡប់មកវិញ មិនញៀនអង្គុយផ្ទះគេទេ,

២៣- ចេះទុកដាក់ឥវ៉ាន់ក្នុងពេលគួរទុកដាក់,

២៤- ចេះរៀបចំផ្ទះសំបែង,

២៥- ចេះតុបតែងគ្រឿងឧបភោគបរិភោគ,

២៦- ខ្ជាបចិត្តស្វាមីមាតាបិតា ហើយគោរពតាមឱវាទ;

២៧- បរិភោគចំណីអាហារ ក្រោយស្វាមីនិងមាតាបិតា,

២៨- ឈប់បរិភោគ មុនស្វាមីនិងមាតាបិតា,

២៩- ដេកលក់ក្រោយស្វាមី,

៣០- ភ្ញាក់មុនស្វាមី,

៣១- មានមេត្តាករុណាចេះធ្វើបុណ្យទាន ។

ស្ត្រីប្រកបដោយលក្ខណៈគ្រប់ពេញលេញ ទាំង៣១ នេះ ហៅថាស្រីគ្រប់លក្ខណ៍, បើមិនពេញលេញទេមានខ្វះខាតខ្លះហៅថាស្រីខាតលក្ខណ៍, បើមានតែត្រង់នេះខ្វះត្រង់នោះខ្វះរដាច់រដោចហៅថាស្រីដាច់លក្ខណ៍ឬមីកំដាច់ក្ខណ៍ ។

---

វាយអក្សរកុំព្យូទ័រសាឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សស់ សាទី**

# បុរសដែលប្រកបដោយលក្ខណៈ២៦យ៉ាង

# ហៅថាប្រុសគ្រប់លក្ខណៈគឺៈ

១- ឧស្សាហ៍ខ្នះខ្នែងធ្វើការរៀនសូត្រមិនប្រកាន់ខ្លួន,

២- មិនចេះលួចប្លន់កេងកិបឆបោក,

៣- មិនឈ្លានពានបំពានកូនប្រពន្ធអ្នកដទៃ,

៤- មិនរំភើបញាប់ញ័រ ភ័យអរផ្តេសផ្តាស,

៥- មិននិយាយកុហកករភូត ឱ្យលើសពីការពិត,

៦- មិននិយាយត្រាប់ឱ្យគេអៀនខ្មាស់,

៧- បានឮដំណឹងហើយវិនិច្ឆ័យសិន ទើបជឿជាក្រោយ,

៨- ធ្វើការងារមិនរួសរាន់ពេក មិនយឺតយូរពេក,

៩- មិនចេះនិយាយបំភ្លើសសើចលេង,

១០- ចេះទទួលភ្ញៀវពន្ធីមិនលាក់មុខ,

១១- មានថ្នាំកែរោគបំរុងទុកមិនឱ្យខ្វះ ក្នុងពេលត្រូវការ,

១២- មិនប្រាប់ការសម្ងាត់ដល់អ្នកដទៃ,

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេង សាទី**

១៣- មិនផ្ញើរបស់ទុកនឹងបុគ្គលមិនគួរផ្ញើ,
១៤- មានចិត្តអត់ធន់តស៊ូមិនញញើតញ៉ាក,

១៥- មានស្វាមីភក្តិចំពោះចៅហ្វាយនាយ,

១៦-មិ នចេះឡឹកឡក់ចំពោះស្រីក្រមុំ,

១៧- ស្គាល់ចំណេញស្គាល់ខាត,

១៨- រកប្រដាប់តុបតែងខ្លួនឱ្យភរិយាបុត្រធីតា និងខ្លួនឯង,

១៩- មិនទិញជឿនូវរបស់ប្រើប្រាស់គ្រប់យ៉ាង,
២០- ដឹងគុណ តបគុណ សរសើរគុណ នៃអ្នកមានគុណ,
២១- គោរពតាមឱវាទមាតាបិតាញាតិមិត្រ និងអ្នកប្រាជ្ញ,

២២- ចេះអត់ទ្រាំស្តាប់ នូវពាក្យដែលគេស្តីបន្ទោសប្រដៅ,

២៣- មានកាយវាចាសមរម្យមិនឆ្គង,
២៤-ឱ្យ ដំណឹងមនុស្សក្នុងផ្ទះហើយសឹមចេញទៅ,

២៥- ចេះវាយប្រដៅកូនដោយរំពាត់យ៉ាងតូច,
២៦-ខឹ ងផាប់បាត់មិនខឹងចងកំហឹងទុក ។

បុរសដែលប្រកបដោយលក្ខណៈគ្រប់ពេញលេញទាំង ២៦

នេះហៅថាប្រុសគ្រប់លក្ខណ៍, បើមិនពេញលេញទេ មានខ្វះខាតខ្លះហៅថាប្រុសខាតលក្ខណ៍, បើមានតែត្រង់នេះខ្វះត្រង់នោះខ្វះរដោច់រដោច ហៅថាប្រុសដាច់លក្ខណ៍ ឬអាកំបាក់ទន្សា ។

លក្ខណៈបុរសស្ត្រីគ្រប់លក្ខណ៍ដូចខាងលើនេះ, មានលក្ខណៈខ្វះហួសសម័យទៅហើយ ដែលមនុស្សលោកសម័យនេះធ្វើត្រាប់តាមមិនកើត ។

ឯសម័យបរមាណូនេះ បើបុរសស្ត្រីណាជាអ្នកប្រកបដោយសុជីវធម៌ ដូចបាននាំមកបរិយាយជាគោលៗក្នុងសៀវភៅនេះ, បុរសស្ត្រីនោះឈ្មោះថាជាមនុស្សគ្រប់លក្ខណ៍បានដោយបរិបូណ៌ ។ នេះជាសេចក្ដីសន្និដ្ឋានរបស់អ្នកនិពន្ធខ្ញុំ ។

សុង-ស៊ីវ

---

វាយអក្សរកុំព្យូទ័រសារឡើងវិញ ដើម្បីផ្សព្វផ្សាយជាធម្មទាន ក្នុងវិបសាយ ដោយអ្នកស្រី **សេ សាទី**